ISSN 1560 9812

# ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា

## ការវាយតំលៃជាមូលដ្ឋាន

ឯកសារពិភាក្សាលេខ ២៣

Bruce McKenney និង ព្រុំ តុលា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឯកសារ
ពិភាក្សា
លេខ ២៣

# ធនធានធម្មជាតិ និងជីវភាពនៅតាម
# ជនបទក្នុងប្រទេសកម្ពុជា

## ការវាយតំលៃជាមូលដ្ឋាន

**ឯកសារពិភាក្សាលេខ ២៣**

Bruce McKenney និង ព្រុំ តុលា

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខែកញ្ញា ឆ្នាំ២០០២**

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISSN 1560 9812

**ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជាៈ ការវាយតំលៃជាមូលដ្ឋាន ~**
**ឯកសារពិភាក្សាលេខ ២៣**
**ខែកញ្ញា ឆ្នាំ២០០២**

*Bruce McKenney និង ព្រុំ តុលា*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែលៈ cdri@camnet.com.kh website: http://www.cdri.org.kh

បកប្រែដោយៈ ព្រុំ តុលា និង ច័ន្ទ សុផល
កែសម្រួល និងរចនាដោយៈ អ៊ុំ-ចាន់ថា អែម-ស្ញូវ៉ានី និង យូ សិទ្ធិរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពពន្លឺពេជ្រ ផ្ទះលេខ៨៧$E_0$ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

# មាតិកា


សម្រង់អត្ថបទ ........ ១
បញ្ជីអក្សរកាត់ ........ ១១
សេចក្តីថ្លែងអំណរគុណ ........ ១៣

**ជំពូក១. សេចក្តីផ្តើម** ........ ១៥

**ជំពូក២. វិស័យកសិកម្ម** ........ ២១

២.១. ដំណាំដាំដុះកសិកម្មសំខាន់ៗ ........ ២១
២.២. "ប្រព័ន្ធបរិស្ថាន" ដំណាំស្រូវ និងវិធីសាស្ត្រដាំដុះ ........ ២២
២.៣. ការស្រោចស្រពលើផ្ទៃដីដាំស្រូវ ........ ២៦
២.៤. ស្ថានភាពទូទៅនៃប្រទេសជិតខាងទាក់ទងនឹងផលិតកម្មស្រូវ ........ ២៨
២.៥. ផលិតកម្មកសិកម្មនៅក្នុងប្រទេសកម្ពុជា ........ ៣០
២.៦. សារៈសំខាន់នៃវិស័យកសិកម្ម ចំពោះជីវភាពរស់នៅតាមជនបទ ........ ៣៥
២.៧. ប្រវត្តិទូទៅនៃវិស័យកសិកម្ម កំលុងឆ្នាំ១៨៦៣-១៩៩៩ ........ ៣៩
២.៨. ស្ថានភាពទូទៅ ស្តីពីតួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម ........ ៤១
២.៩. សម្បទានកសិកម្ម ........ ៤២
២.១០. ការលំបាកផ្នែកខាងរូបសាស្ត្រ នៅក្នុងការបង្កើនផលិតកម្មកសិកម្ម ........ ៤៣
២.១១. សក្តានុពលភាព ដើម្បីកែលំអការអភិវឌ្ឍន៍កសិកម្ម ........ ៤៥
២.១២. សន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ ........ ៥០

**ជំពូក៣. វិស័យជលផល** ........ ៥៧

៣.១. តំបន់នេសាទសំខាន់ៗ ........ ៥៧
៣.២. ស្តុកត្រីក្នុងទឹក និងផលនេសាទប្រចាំឆ្នាំ ........ ៥៩
៣.៣. សារៈសំខាន់នៃការនេសាទចំពោះជីវិតជនបទ ........ ៦២
៣.៤. បញ្ហាជនជាតិ និងដែនឡូ៉ ........ ៦៤
៣.៥. ការគ្រប់គ្រងវិស័យជលផលក្នុងអតីតកាល ........ ៦៥
៣.៦. ការគ្រប់គ្រងវិស័យជលផលក្នុងបច្ចុប្បន្នកាល ........ ៦៥
៣.៧. បញ្ហាគ្រប់គ្រងជលផល ........ ៧១

៣.៨. ផលប៉ះពាល់ពីវិស័យផ្សេងៗលើផលផលទឹកសាប ..... ៧៤
៣.៩. បញ្ហាទីផ្សារ ពាណិជ្ជកម្ម និងការនាំចេញរបស់ត្រី ..... ៧៦
៣.១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ ..... ៧៨

**ជំពូក៤. វិស័យព្រៃឈើ** ..... ៨៩
៤.១. ផ្ទៃព្រៃឈើ ..... ៨៩
៤.២. ការប្រមូលផល ការកែច្នៃ និងពាណិជ្ជកម្មឈើ ..... ៩៣
៤.៣. សារៈសំខាន់នៃព្រៃឈើចំពោះជីវភាពជនបទ ..... ៩៦
៤.៤. ការពិនិត្យមើលប្រវត្តិនៃការគ្រប់គ្រងព្រៃឈើ ..... ៩៨
៤.៥. ប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផល និងអនុផលព្រៃឈើ ..... ៩៩
៤.៦. ការគ្រប់គ្រងព្រៃសម្បទាន ..... ១០០
៤.៧. ការគ្រប់គ្រងព្រៃសហគមន៍ ..... ១០៤
៤.៨. ចំណូលរដ្ឋាភិបាល ..... ១០៩
៤.៩. មូលដ្ឋានច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងព្រៃឈើ ..... ១០៩
៤.១០. ការប្រឹងប្រែងកែទំរង់វិស័យព្រៃឈើ ..... ១១១
៤.១១. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ ..... ១១៥

**ជំពូក៥. សន្និដ្ឋាន និងសេចក្តីសង្ខេបផ្នែកដែលគួរធ្វើការស្រាវជ្រាវ** ..... ១២៣

ឧបសម្ព័ន្ធ - ក ..... ១២៧
ឯកសារពិភាក្សាបោះពុម្ពផ្សាយដោយ វិបសអ ..... ១៣៥

# សេចក្តីសង្ខេប

បច្ចុប្បន្ននេះប្រជាជនកម្ពុជាជាង ១០លាននាក់រស់នៅតាមតំបន់ជនបទ ហើយក្នុងចំណោមនោះជាង ៨,៥លាននាក់ រស់នៅដោយពឹងផ្អែកទៅលើធនធានធម្មជាតិដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន ។ ភាគច្រើន គឺជាអ្នកមានជីវភាពខ្សត់ខ្សោយ ដោយ ពឹងផ្អែកទៅលើឯកវប្បកម្មដំណាំស្រូវក្នុងមួយឆ្នាំៗ ត្រី និងធនធានក្នុងទឹក ព្រមទាំងភោគផលព្រៃឈើ ។ ទោះជាស្រូវ គឺជាដំ ណាំសំខាន់សំរាប់ប្រជាជននៅតាមតំបន់ជនបទក៏ដោយ ក៏ប៉ុន្តែធនធានជលផល និងព្រៃឈើ ក៏បានរួមចំណែកដោយមិនអាចខ្វះ បាន ដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេផងដែរ ។ ព្រៃឈើ និងជលផល គឺជាធនធានរួម (ធនធានសាធារណៈដែលជនគ្រប់រូបមាន សិទ្ធិធ្វើអាជីវកម្ម) ដែលបានផ្តល់ដល់គ្រួសារទាំងឡាយសំរាប់ចិញ្ចឹមជីវិតបន្ថែម និងបង្កើតប្រាក់ចំណូលក្នុងគ្រួសារដោយប្រើ ប្រាស់ធនធាន កំលាំងពលកម្មរបស់ពួកគេឱ្យអស់លទ្ធភាពនៅក្នុងរដូវកាលខុសៗគ្នា ព្រមទាំងជាមធ្យោបាយសំរាប់ "ទប់ទល់" នៅពេលដែលកសិផលមានការខូចខាត ។ លើសពីនេះទៀត ចំពោះប្រជាជនដែលគ្មានដីធ្លី មានប្រាក់កាសតិចតួចសំរាប់ធ្វើការ វិនិយោគ និងឱកាសតិចតួចក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ពួកគេអាចទាញយកផលពីនេសាទ ឬផលពីព្រៃទាំងនេះដែរ ដើម្បី ទ្រទ្រង់ជីវភាពរបស់ខ្លួន ។ នៅក្នុងបែបផែននេះ ធនធានធម្មជាតិ កម្ពុជាមិនត្រឹមតែបានផ្តល់សន្តិសុខស្បៀង ប្រាក់ចំណូល និង ឱកាសការងារសំរាប់ប្រជាជនភាគច្រើននោះទេ ក៏ប៉ុន្តែវាបានរួមចំណែកយ៉ាងសំខាន់នៅក្នុង "*ប្រព័ន្ធសុវត្ថិភាព*" សំរាប់ប្រជាជន ក្រីក្រនៅតាមជនបទ ។

នៅក្នុងទសវត្សរ៍កន្លងមកនេះ ជីវភាពរស់នៅតាមជនបទបានជួបប្រទះនូវផលវិបាកកាន់តែខ្លាំងឡើងៗ ដោយសារ ធនធានមានការថយចុះយ៉ាងឆាប់រហ័ស ។ ការប្រមូលផលឈើ ការនេសាទដោយខុសច្បាប់ និងគ្មាននិរន្តរភាពដោយក្រុមហ៊ុន ឯកជន យោធា អាជ្ញាធរមូលដ្ឋាន ព្រមទាំងអត្រាកំណើនប្រជាជននៅតាមជនបទ ជាមូលហេតុធ្វើឱ្យបាត់បង់ និងថយចុះធនធាន ព្រៃឈើមានអត្រាខ្ពស់ និងផលិតភាពត្រីដែលមានតំលៃ ក៏មានការថយចុះដែរ ។ ម៉្យាងវិញទៀត ការប្រកួតប្រជែងដីធ្លីកាន់តែ រីករាលដាលឡើង នាំឱ្យប្រជាជនគ្មានដីធ្លីកាន់តែកើនឡើងជាលំដាប់ ។ បញ្ហាទាំងនេះមានសភាពកាន់តែធ្ងន់ធ្ងរឡើងដោយសារ ការរារាំងប្រជាជននៅតាមជនបទមិនឱ្យមានសិទ្ធិធ្វើអាជីវកម្មលើធនធានធម្មជាតិ ។ នាទសវត្សរ៍កន្លងមកនេះ រដ្ឋាភិបាលបាន ជួលធនធានធម្មជាតិដែលមានផលិតភាពខ្ពស់ឱ្យក្រុមហ៊ុនឯកជន ដូចជា ព្រៃឈើ ជលផល និងដី ក្រោមរូបភាពសម្បទាន ។ នៅ ក្នុងផ្ទៃដីកម្ពុជាដែលមានសរុបប្រមាណ ១៨,១លានហិកតា ក្នុងនោះមាន ៥,៥លានហិកតា ត្រូវបានគ្រប់គ្រងតាមបែបសម្បទាន ដែលមានព្រៃឈើ (៤,២៤លានហិកតា) ដី (0,៨១លានហិកតា) និងជលផល (0,៤២លានហិកតា) ។ ចំនួននេះមានការថយ ចុះ បើធៀបនឹងកំលុងទសវត្សរ៍ទី៩0 គឺមានរហូតដល់ជិត ៨លានហិកតាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមបែបសម្បទាន ។

ការដាក់សំពាធកាន់តែខ្លាំងទៅលើដីធ្លី ជលផល និងព្រៃឈើ នោះវានឹងធ្វើឱ្យប្រជាជនក្រីក្រនៅតាមជនបទ មានការ លំបាកកាន់តែធ្ងន់ធ្ងរនៅទសវត្សរ៍ខាងមុខ ។ ស្ថិតិជំរឿនបានបញ្ជាក់ឱ្យឃើញថា ប្រមាណជា ៥៥% នៃប្រជាជនកម្ពុជា រស់នៅ តាមជនបទនឹងមានអាយុក្រោម ឬស្មើ ១៩ឆ្នាំនៅក្នុងឆ្នាំ១៩៩៨ ពេលនោះប្រជាជននឹងមានសំពាធទៅលើធនធានធម្មជាតិ កាន់

តែខ្លាំងឡើងៗនាពេលអនាគតយ៉ាងឆាប់ខាងមុខនេះ ។ នៅក្នុងសំពាធនៃកំនើននេះ ព្រមទាំងសារៈសំខាន់នៃធនធានធម្មជាតិចំពោះប្រជាជនតាមជនបទ នោះសមាសភាពសំខាន់នៃការខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រនាពេលអនាគត គឺធានាឱ្យបាននូវការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព ។

**តារាងសង្ខេប ES1. ការសង្ខេបអំពីពត៌មានជាមូលដ្ឋានស្តីពីធនធានធម្មជាតិ និងជីវភាពនៅតាមជនបទ**

| | **កសិកម្ម** | **ជលផល** | **ព្រៃឈើ** |
|---|---|---|---|
| **ផលិតផលសំខាន់សំរាប់ប្រជាជននៅតាមជនបទ** | ស្រូវ ដំណាំស្បៀងផ្សេងៗ និងការចិញ្ចឹមសត្វ | ត្រីស្រស់ និងត្រីកែច្នៃ ព្រមទាំងធនធានក្នុងទឹក (ក្តាម កំពិស កង្កែប) | ឈើសំរាប់ធ្វើអុស ឈើជំរទឹក វិរ ឬស្សី ផ្តៅ បន្លែ ផ្លែឈើព្រៃ និងឱសថ |
| **ការបរិភោគជាមធ្យម (មនុស្សម្នាក់/ឆ្នាំ)**[១] | - អង្ករ ១៥០គ.ក<br>- បន្លែ ៣០-៣៥គ.ក<br>- សាច់ជ្រូក ៨គ.ក<br>- បសុបក្សី ៦,៥គ.ក<br>- សាច់គោ ៣គ.ក | ត្រី ២៧-៣៨គ.ក | គ្មានតួលេខស្តីពីការប៉ាន់ស្មានថ្នាក់ជាតិទៅលើការប្រើប្រាស់ និងបរិភោគផលិតផលព្រៃឈើឡើយ ។ |
| **ផលិតកម្មសរុប** | - ស្រូវ ៤លានតោន (២000-0១)<br>- ដំណាំស្បៀង (ទិន្នន័យមិនច្បាស់លាស់)<br>- គោក្របី ៣,៧លានក្បាល<br>- ជ្រូក ១,៩លានក្បាល<br>- មាន់ទា១៥,២លានក្បាល (២000) | ការនេសាទត្រីទឹកសាបប្រចាំឆ្នាំ ២៩0.000-៤៣0.000តោន (ឆ្នាំ១៩៩៤-៩៧) | ទិន្នន័យស្តីពីការប្រមូលផលពុំច្បាស់លាស់ ដោយសារការកាប់ឈើខុសច្បាប់ |
| **ការគ្រប់គ្រង** | - ផ្ទៃដីដាំដុះស្រូវ ២,៣លានហិកតាស្ថិតនៅក្រោមកម្មសិទ្ធិឯកជន (២000-0១)<br>- ដី 0,៨លានហិកតាស្ថិតនៅក្រោមសម្បទានកសិកម្ម | - ឡូត៍នេសាទ 0,៤លានហ.ត<br>- សហគមន៍នេសាទយ៉ាងហោចមាន២៣0.000ha<br>- ដែនសាធារណៈ<br>- តំបន់ការពារ | - ព្រៃសម្បទាន ៤,២លានហិកតា<br>- ព្រៃសហគមន៍ យ៉ាងហោចមាន ៧0.000ហិកតា<br>- តំបន់ការពារ ឬព្រៃការពារ<br>- តំបន់ព្រៃផ្សេងៗ (មិនទាន់បានធ្វើការកំណត់) |
| **គន្លឹះនៃការគ្រប់គ្រង និងបញ្ហាលំបាកក្នុងការអភិវឌ្ឍន៍** | - ដីខ្សោះជីជាតិ ហើយសក្តានុពលភាពបង្កើតទិន្នផលមានតែ ៥0% នៃផ្ទៃដីដាំដុះសរុប<br>- កត្តារារាំង និងប្រសិទ្ធិភាពសេដ្ឋកិច្ចនៃឱកាសពង្រីកការស្រោចស្រព<br>- ការបាត់បង់ក្រោយពីប្រមូលផល និងថ្លៃម៉ាឃីទីង | - នេសាទដោយបំផ្លិចបំផ្លាញ និងខុសច្បាប់ ការបង្កើនសំពាធលើការនេសាទ និងបំផ្លាញជំរកត្រី<br>- ជម្លោះរវាងម្ចាស់ឡូត៍ និងអ្នកនេសាទ<br>- ប៉ះពាល់កសិកម្ម ការកាប់ឈើ និងហេដ្ឋារចនាសម្ព័ន្ធ<br>- បញ្ហាលំបាកខាងម៉ាឃីទីង | - ការកាប់ឈើដោយខុសច្បាប់ បំផ្លិចបំផ្លាញ និងគ្មាននិរន្តរភាព<br>- ជម្លោះកើតមានឡើងរវាងអ្នកកាប់ឈើសំរាប់ពាណិជ្ជកម្ម ឬអ្នកជួលកិច្ចសន្យាបន្ត ជាមួយនឹងអ្នកប្រើប្រាស់ព្រៃឈើនៅតាមមូលដ្ឋាន ។<br>- ខ្វះការគាំទ្រទៅដល់អនុផលព្រៃឈើ |

ក្នុងគោលគំនិតនេះ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងនូវកម្មវិធីធនធានធម្មជាតិ និងបរិស្ថានរបស់ខ្លួននាចុងឆ្នាំ២00១ ។ កម្មវិធីនេះ មានគោលបំណងគាំទ្រដល់គោលនយោបាយស្តីពីបញ្ហានានាទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ។ ឯកសារពិភាក្សាដំបូង

[១] ការប៉ាន់ស្មានបញ្ជាក់ពីការបរិភោគជាមធ្យម ។ កំរិតបរិភោគជាក់ស្តែងមានការប្រែប្រួលពីតំបន់មួយទៅតំបន់មួយនៅទូទាំងប្រទេស ។

នេះបានផ្តល់នូវការប៉ាន់ស្មានស្តីពីស្ថានភាពបច្ចុប្បន្នលើបញ្ហានានាជុំវិញធនធានធម្មជាតិ និងជីវភាពប្រជាជនតាមជនបទ ដោយផ្តោតជាសំខាន់លើវិស័យជាគន្លឹះបី គឺកសិកម្ម (ជំពូកទី២) ជលផល (ជំពូកទី៣) និងព្រៃឈើ (ជំពូកទី៤) ។ ដោយផ្អែកលើមូលដ្ឋាននេះ បញ្ហាខ្វះចន្លោះនានា និងតំរូវការសំរាប់ធ្វើការស្រាវជ្រាវទាក់ទងនឹងសេដ្ឋកិច្ចសង្គម ត្រូវបានធ្វើការកំណត់ឡើង ។ ឯកសារពិភាក្សានេះធ្វើឡើងដោយផ្អែកលើការដកស្រង់ចេញមកពីឯកសារ ការសិក្សាស្រាវជ្រាវនានា និងការធ្វើសំភាសន៍ជាមួយអ្នកជំនាញការ ព្រមទាំងអ្នកអនុវត្តន៍ការងារផ្ទាល់ទាក់ទងនឹងធនធានធម្មជាតិ និងបញ្ហាជីវភាពប្រជាជននៅតាមជនបទ ។ សេចក្តីសង្ខេបអំពីពត៌មានសំខាន់ស្តីពីធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ ត្រូវបានអធិប្បាយក្នុងតារាងសង្ខេប ES1 និងបន្ទាប់មកទៀត គឺជាការពិភាក្សាលទ្ធផលពិស្តារ ។

## កសិកម្ម

ប្រជាជនកម្ពុជាជាង ៨,៥លាននាក់ពឹងផ្អែកទៅលើរបបកសិកម្ម ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ ។ ទោះជាទំហំដីដាំដុះប្រែប្រួលទៅតាមតំបន់នានាក្នុងប្រទេសក្តី ក៏ប៉ុន្តែទំហំដីដាំស្រូវជាមធ្យមក្នុងមួយគ្រួសារ គឺមានផ្ទៃដី ១,៤ហិកតានាឆ្នាំ២០០០-០១ ។ ទិន្នផលស្រូវជាមធ្យម គឺ ២,១តោន/ហិកតា ដូចនេះ សក្តានុពលភាពផលិតកម្មដំណាំស្រូវក្នុងមួយគ្រួសារមានប្រមាណជា ៣តោន (១,៤ហិកតា x ២,១តោន/ហិកតា) ។ ប៉ុន្តែ នាឆ្នាំ២០០០-០១ ផលិតផលស្រូវពិតប្រាកដធ្វើបានក្នុងមួយគ្រួសារមានតែ ២,៤តោនប៉ុណ្ណោះដោយសារបញ្ហាទឹកជំនន់ ។ ជាទូទៅដោយផ្អែកលើតំលៃស្រូវ ក៏រតផលិតផលស្រូវពុំអាចធានាបានចំណូលច្រើនឡើយ ដូចនេះសន្តិសុខស្បៀងនៅតែជាហេតុផលលំបាកសំរាប់ធ្វើការដាំដុះដំណាំស្រូវ ។

នាឆ្នាំ២០០០-០១ ផ្ទៃដីជាង ២,៨លានហិកតាត្រូវបានគេធ្វើកសិកម្ម ដែលក្នុងនោះផ្ទៃដីដាំដុះដំណាំស្រូវមានជាង ២,៣២លានហិកតា ឯដំណាំស្បៀង និងដំណាំឧស្សាហកម្ម ដាំដុះនៅលើផ្ទៃដីប្រមាណជា ០,៤៤លានហិកតា ។ ផលិតផលស្រូវនៅឆ្នាំ២០០០-០១ មានរហូតដល់ ៤លានតោន ។ នៅក្នុងកំលុងទសវត្សរ៍កន្លងមកនេះ ផលិតផលស្រូវមានការកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំប្រមាណជា ២ ទៅ ៣% ស្របនឹងអត្រាកំនើនប្រជាជន ។ និន្នាការផលិតផលស្បៀងផ្សេងទៀត និងការចិញ្ចឹមសត្វ គឺពុំសូវច្បាស់ ដោយសារទិន្នន័យពុំអាចជឿទុកចិត្តបាន ប៉ុន្តែស្ថិតិរដ្ឋាភិបាលបានប៉ាន់ស្មានថា ផលិតផលដំណាំស្បៀងផ្សេងៗ ពុំមានអត្រាកើនឡើងឡើយ ចំណែកឯផលិតកម្មចិញ្ចឹមសត្វមានកំណើនដូចគ្នាទៅនឹងកំណើនប្រជាជនដែរ ។

### *ការសម្លឹងមើលទៅអនាគត*

ការអភិវឌ្ឍន៍កសិកម្ម នឹងមានសារៈសំខាន់ដល់ការបង្កើនជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅតាមជនបទនាពេលអនាគតដ៏ខ្លី ។ អនុសាសន៍សំរាប់អភិវឌ្ឍន៍កសិកម្មក្នុងឯកសារបច្ចុប្បន្ន ផ្តោតសំខាន់លើការពង្រីក និងលំអតំបន់ស្រោចស្រពវិធីសាស្ត្រប្រព័ន្ធកសិកម្មចំរុះ បង្កើនការកែច្នៃផលិតផលកសិកម្ម កែលំអការរើសពូជស្រូវ និងពូជដំណាំផ្សេងៗ កែលំអការប្រើប្រាស់ជី និងថ្នាំពុល គឺមិនឱ្យមានប្រសិទ្ធិភាព កាត់បន្ថយការបាត់បង់កសិផលក្រោយប្រមូលផល និងថ្លៃម៉ាឃីទីង ព្រមទាំងបង្កើនការគាំទ្រដល់សេវាបំរើផ្នែកកសិកម្ម ។

ទោះបីជា និន្នាការផលិតផលកសិកម្មកើនឡើងទាំងទិន្នផល និងផលិតកម្ម តាមរយៈការកែលំអផ្នែកទាំងអស់ខាងលើនេះក៏ដោយ ប៉ុន្តែ នៅមានការលំបាកមួយចំនួនផ្សេងៗទៀត ដែលត្រូវជំនះ ដូចជា បញ្ហារូបសាស្ត្រ បច្ចេកទេស និងសេដ្ឋកិច្ចសង្គម ។ បញ្ហាទាក់ទងជាពិសេស គឺទៅលើដីខ្សោះជីជាតិដែលមានប្រមាណ ៥០% នៃផ្ទៃដីដាំដុះ ហើយកត្តានេះបង្កឱ្យមានសក្តានុពលភាពទាបក្នុងការបង្កើនទិន្នផល ។ បញ្ហាប្រឈមនានារួមជាមួយនឹងដីខ្សោះជីជាតិ ព្រមទាំងលទ្ធភាពក្នុងការគ្រប់គ្រងទឹកបានបញ្ជាក់ឱ្យឃើញថា ការពង្រីកប្រព័ន្ធស្រោចស្រពនៅក្នុងតំបន់ផ្ទៃដីដាំដុះជាច្រើនរបស់កម្ពុជា ពុំអាចមានប្រសិទ្ធិភាពសេដ្ឋកិច្ចឡើយ ។

ការបង្កើនផលិតផលស្រូវនៅតែជាបញ្ហាយកចិត្តទុកដាក់យ៉ាងសំខាន់ ចំពោះគោលនយោបាយកសិកម្មកម្ពុជា ។ គោលបំណងដែលគេលើកឡើងជាញឹកញាប់ គឺបង្កើនទិន្នផលជាមធ្យមរបស់ដំណាំស្រូវកម្ពុជា (២,១តោន/ហិកតា) ឱ្យទាន់ប្រទេសជិតខាងរបស់ខ្លួន ដូចជា ប្រទេសថៃ (២,៣តោន/ហិកតា) និងវៀតណាម (៤,៣តោន/ហិកតា) ។ ការបង្កើនផលិតកម្មតែឯកឯង អាចមានសារៈសំខាន់ដល់ការលើកកំពស់សន្តិសុខស្បៀង ប៉ុន្តែប្រាក់ចំណេញដែលទាញយកមកពីកំនើនផលិតកម្មនេះក៏គួរតែត្រូវលើកយកមកពិចារណានៅក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រផងដែរ ។ នៅក្នុងប្រទេសកម្ពុជា ភាពខុសគ្នារវាងវិធីសាស្រ្តដាំស្រូវដែលអនុវត្តដោយប្រទេសវៀតណាម និងថៃ អាចជាមេរៀនសំរាប់ធ្វើការសិក្សា ។ ជាទូទៅ ទិន្នផលស្រូវនៅថៃ ទាបជាងនៅវៀតណាម ពីព្រោះផលិតផលស្រូវថៃ ផ្តោតទៅលើការប្រើប្រាស់ពូជក្នុងស្រុកដែលមានតំលៃខ្ពស់ ហើយកសិករទទួលបានប្រាក់ចំណេញខ្ពស់ជាងវៀតណាម ។ ផ្ទុយមកវិញ ផលិតកម្មដំណាំស្រូវនៅប្រទេសវៀតណាម ផ្តោតទៅលើការបង្កើនផលិតផលតាមរយៈការពង្រីកប្រព័ន្ធស្រោចស្រព ការប្រើប្រាស់ពូជទំនើប ការប្រើប្រាស់ធនធានផលិតកម្មច្រើន និងអនុវត្តន៏វិធីសាស្រ្តការដាំដុះទ្វេដង ឬបីដងក្នុងមួយឆ្នាំ នៅលើផ្ទៃដីដដែល ។ ទោះជាទិន្នផលស្រូវខ្ពស់នៅប្រទេសវៀតណាមដែលជួយលើកកំពស់ដល់សន្តិសុខស្បៀង ប៉ុន្តែប្រាក់ចំណេញ គឺមានកំរិតទាប ដោយសារការប្រើប្រាស់ធនធានផលិតកម្មខ្ពស់ និងគុណភាពស្រូវទាប ។ ការធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងរវាងផលិតកម្ម ប្រាក់ចំណូល និងសន្តិសុខស្បៀងនៅក្នុងប្រទេសជិតខាងនោះគោលនយោបាយអភិវឌ្ឍន៏កសិកម្មនៅក្នុងប្រទេសកម្ពុជា គួរតែធ្វើការដេញដោលពិភាក្សាឱ្យកាន់តែលំអិតថែមទៀត ។

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវវិស័យកសិកម្មភាគច្រើន ផ្តោតតែទៅលើបញ្ហាផលិតកម្មដំណាំស្រូវប៉ុណ្ណោះ ។ ថ្វីបើមានការអំពាវនាវឱ្យធ្វើកសិកម្មចំរុះ ការកែច្នៃកសិផល និងការធ្វើពាណិជ្ជកម្មកាន់តែកើនឡើងយ៉ាងណាក៏ដោយ ប៉ុន្តែនៅតែខ្វះពត៌មាននៃការស្រាវជ្រាវដំបូងស្តីពីការអនុវត្តន៏បច្ចុប្បន្ន បញ្ហាលំបាក និងឱកាស ។ ដូចគ្នានេះដែរ ការជំរុញឱ្យមានកសិកម្មសម្បទានខ្នាតធំធ្វើឡើងដោយរដ្ឋាភិបាល គួរតែធ្វើការពិនិត្យពិច័យឱ្យកាន់តែច្បាស់លាស់ ដើម្បីធ្វើការកំណត់សក្តានុពលភាពនៃផលប្រយោជន៏ និងតំលៃខាតបង់ចំពោះជីវភាពរស់នៅរបស់ប្រជាជនតាមជនបទ ជាពិសេសពត៌មានខ្លះៗបានបញ្ជាក់ថា ៦៤% (១៦ ក្នុងចំណោម ២៥ក្រុមហ៊ុនដីសម្បទាន) នៃក្រុមហ៊ុនដីសម្បទានដែលបានចុះកិច្ចសន្យា នាពេលបច្ចុប្បន្ននេះកំពុងតែមានបញ្ហាស្តីពីការតវ៉ាពីប្រជាជន ឬមួយការរំលោភយកដីពីប្រជាជន ។

## ជលផល

ប្រជាជនកម្ពុជាជាង ១លាននាក់ បានពឹងផ្អែកទៅលើផលនេសាទទឹកសាប ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ ។ ពួកគេភាគច្រើនបំផុត គឺជាអ្នកនេសាទជាលក្ខណៈគ្រួសារដែលមានទ្រង់ទ្រាយតូច (ដោយធ្វើការកំណត់តាមរយៈការប្រើប្រាស់ឧបករណ៏ នេសាទ) ហើយពួកគេរស់នៅជិតតំបន់ទឹកសាប ។ ទោះជាការនេសាទរបស់គ្រួសារខ្លះ ប្រព្រឹត្តទៅពេញមួយឆ្នាំក៏ដោយ ប៉ុន្តែរយៈពេលដែលសកម្មភាពធ្វើនេសាទត្រីច្រើនបំផុត គឺចាប់ផ្តើមនៅរដូវប្រាំង (ចាប់ពីខែវិច្ឆិកា ដល់ខែកុម្ភៈ) គឺនៅពេលទឹកជំនន់ស្រក កំរិតទឹកធ្លាក់ចុះទាប ហើយត្រីចាប់ផ្តើមផ្លាស់ប្តូរជំរក ។ គ្រួសារប្រជាជននៅតាមជនបទ ក៏បានទទួលផលប្រយោជន៏ពីត្រី និងធនធានក្នុងទឹកផងដែរ (ក្តាម កំពិស និងកង្កែប) ដោយចាប់មកពីវាលស្រែ ។ ការប្រមូលផលភាគច្រើនបំផុតកើតមានឡើងនៅដើមរដូវប្រាំង នៅពេលដែលត្រី និងសត្វក្នុងទឹកដទៃទៀតព្យាយាមផ្លាស់ទីជំរកពីវាលស្រែ ទៅកាន់ទីកន្លែងណាដែលមានទឹកជ្រៅ ។

ស្រូវ និងត្រី គឺជាម្ហូបប្រពៃណីដ៏សំខាន់ចំពោះប្រជាជនកម្ពុជា ។ ត្រីត្រូវបានបរិភោគទាំងនៅស្រស់ និងកែច្នៃនៅទូទាំងប្រទេស ហើយការបរិភោគជាមធ្យមក្នុងមនុស្សម្នាក់ គឺមានប្រមាណ ២៧-៣៨គ.កក្នុងមួយឆ្នាំ ប៉ុន្តែវាមានការប្រែប្រួលតួលេខពី ១៣គ.ក ដល់ ៧០គ.កក្នុងមួយឆ្នាំទៅតាមតំបន់ខ្លះ ។ ត្រីស្រស់ និងត្រីកែច្នៃ មានសមាមាត្រខ្ពស់នៅក្នុងបរិមាណប្រូតេអ៊ីនសាច់សត្វសរុបដែលប្រជាជនកម្ពុជាបរិភោគ ហើយការប៉ាន់ស្មានឃើញថា វាមានពី ៤០ ទៅ ៩០% (នៅតាមភូមិនេសាទ) ។

កំលុងឆ្នាំ១៩៩៤-៩៧ គេប៉ាន់ស្មានឃើញថា ផលត្រីទឹកសាបដែលប្រមូលបានក្នុងមួយឆ្នាំមានពី ២៩០.០០០ ទៅ ៤៣០.០០០តោន ដែលនាំឱ្យត្រីទឹកសាបនៅកម្ពុជាមានទិន្នផលជាប់ចំណាត់ថ្នាក់ទី៤ លើសកលលោក ។ តាមស្ថិតិរដ្ឋាភិបាល បឹងទន្លេសាប និងបឹងធំ ជាតំបន់ដែលសំបូរត្រីបំផុតនៅកម្ពុជា ដោយត្រីប្រមូលផលសំរាប់ពាណិជ្ជកម្មក្នុងអត្រាពី ៥០ ទៅ ៦០% នៃផលត្រីទឹកសាបសរុបនៅក្នុងប្រទេស ។ ដោយខ្វះទិន្នន័យ និងទិន្នន័យមានកំណត់ ដូចនេះតួលេខខាងលើគ្រាន់តែជាការប៉ាន់ស្មានមួយ ប៉ុន្តែមិនជាក់លាក់ទេ ។

*ការសម្លឹងមើលទៅអនាគត*

ទោះជាការប៉ាន់ស្មាននូវការប្រមូលផលត្រីទឹកសាបសរុបមានអត្រាកំនើនខ្ពស់ជាងពីអតីតកាលក៏ដោយ ប៉ុន្តែនេះអាចបណ្តាលមកពីការបង្កើនឧបករណ៍នេសាទ និងកំលាំងពលកម្ម ព្រមទាំងកែលំអវិធីសាស្ត្រប្រមូលទិន្នន័យប្រសើរជាងមុន ពុំមែនបានសេចក្តីថា ត្រីស្តុកក្នុងទឹកមានការកើនឡើងទេ ។ ការពិត ការស្រាវជ្រាវជាច្រើនបានសន្និដ្ឋានថា ផលិតភាពត្រីទឹកសាបនៅក្នុងប្រទេសកម្ពុជានាពេលអនាគតស្ថិតនៅក្រោមការគំរាមកំហែង ដោយសារការបង្កើនសំពាធទៅលើការនេសាទ ការរីករាលដាលនៃការនេសាទខុសច្បាប់ និងការបំផ្លិចបំផ្លាញទីជំរកត្រី ។ ទោះជាការស្រាវជ្រាវនាពេលថ្មីៗនេះ ទៅលើសុខភាពរបស់ត្រីមានកំរិតមួយកំណត់ក៏ដោយ ប៉ុន្តែ ពតិមានពិស្តារខ្លះបានសន្និដ្ឋានថា ការនេសាទប្រភេទត្រីធំដែលធ្វើចរាចរ បន្តពូជយឺតយ៉ាវ ហើយមានការថយចុះ ចំណែកឯប្រភេទត្រីល្អិតៗដែលបន្តពូជឆាប់រហ័សហាក់ដូចជាមានការកើនឡើង ។

ផ្អែកទៅលើលទ្ធផល និងនិន្នាការដែលឆ្ពោះទៅរកកំនើនសំពាធទៅលើការនេសាទ និងជំរកត្រីដែលត្រូវបំផ្លិចបំផ្លាញ នោះអ្នកជំនាញការខាងជលផល បានព្រមានប្រទេសកម្ពុជាទាក់ទងនឹងសក្តានុពលត្រី ដែលអាចមានផលវិបាកស្រដៀងគ្នានឹង "ប្រទេសបង់ក្លាដេស" គឺការថយចុះគួរឱ្យកត់សំគាល់នូវស្តុកត្រី និងជីវចំរុះដល់កំរិតមួយដែលផលិតផលទទួលបានពីការនេសាទមានតែពូជត្រីតូចដែលមានតំលៃទាប និងមានចំនួនតិចតួច ។ នៅក្នុងករណីនេះ គឺពូជត្រីធំ ដែលមានតំលៃខ្ពស់កាន់តែបាត់បង់ចំនួននៅក្នុងការប្រមូលផលត្រីទឹកសាបសរុប ។ ហេតុការណ៍នេះកើតមានឡើងដោយសារប្រភេទពូជត្រីធំៗទាំងនេះពេលដែលបន្តពូជម្តងៗត្រូវការពេលវេលាច្រើនជាងមួយឆ្នាំ ដូចនេះធ្វើឱ្យពួកវាកាន់តែងាយហិនហោចដោយសារសំពាធនៃការនេសាទ ។ ផ្ទុយទៅវិញ ពូជត្រីតូចៗដែលមានតំលៃទាប អាចធ្វើការបន្តពូជនៅកំលុងរយៈពេលតែមួយឆ្នាំ ដូចនេះវាងាយក្នុងការកើនចំនួនឡើងវិញ ទោះជាមានសំពាធពីការនេសាទ ប៉ុន្តែវាអាចកើនចំនួនសមាមាត្រច្រើននៅក្នុងការប្រមូលផលត្រីសរុប ។ បំលាស់ប្តូរសមាសភាពពូជត្រីទាំងនេះ ធ្វើឱ្យមានការថយចុះតំលៃត្រីនីមួយៗនៅពេលនេសាទម្តងៗ ។

ឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងការនេសាទ និងជម្លោះរវាងម្ចាស់ឡូត៍ជាមួយនឹងអ្នកនេសាទជាលក្ខណៈគ្រួសារ ជំនាញការខាងជលផលជាញឹកញាប់បានផ្តល់អនុសាសន៍ឱ្យមានការបង្កើតការគ្រប់គ្រងសហគមន៍នេសាទ ។ ដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែប្រសើរឡើងអំពីមាត្រដ្ឋាន និងទំហំនៃសកម្មភាពសហគមន៍នេសាទ វិទ្យាស្ថាន CDRI បានបង្កើតជាសារពើភ័ណ្ឌ ដោយកំណត់ឃើញថា នៅក្នុងប្រទេសកម្ពុជាមាន ១៦២ដែននេសាទសហគមន៍ (រហូតមកដល់ខែមីនា ឆ្នាំ២០០២) ដែលគ្រប់គ្រងនៅលើផ្ទៃដីប្រមាណ ២៣០.០០០ហិកតា ។ កិច្ចខំប្រឹងប្រែងនៅក្នុងការគ្រប់គ្រងសហគមន៍នេសាទ គឺអនុវត្តយ៉ាងទូលំទូលាយពីអង្គការក្រៅរដ្ឋាភិបាល ក៏ប៉ុន្តែរដ្ឋាភិបាលមានតួនាទីជាអ្នកគាំទ្រ ។ ជំហ៊ានដែលសំខាន់នោះ គឺរួមមានការកាត់ផ្ទៃដីឡូត៍នេសាទជាង ៥០០.០០០ហិកតានៅឆ្នាំ២០០១ ព្រមជាមួយនោះ នាយកដ្ឋានជលផលបានបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងអនុក្រឹត្យស្តីពីសហគមន៍នេសាទកំពុងតែស្ថិតនៅក្នុងដំណើរការរៀបចំ ។

ឱកាសសំរាប់កែលំអម៉ាឃីទីង និងពាណិជ្ជកម្មត្រីឱ្យកាន់តែប្រសើរឡើង អាចជួយបង្កើនប្រាក់ចំណូលដល់អ្នកនេសាទជាលក្ខណៈគ្រួសារ ។ នាពេលថ្មីៗនេះ អន្តរាគមន៍របស់រដ្ឋាភិបាល និងការអនុវត្តន៍ដោយគ្មានការប្រកួតប្រជែងនៅលើទីផ្សារហាក់ដូចជារារាំងដល់សកម្មភាពជំនួញ និងការនាំត្រីចេញទៅលក់ឯបរទេស ដូចជា អាជ្ញាប័ណ្ណ ពន្ធផ្លូវការ និងក្រៅផ្លូវការដែលជា

រវាំងនៅក្នុងមុខជំនួញពាណិជ្ជកម្ម និងនាំចេញ ។ ការបង្កើនការប្រកួតប្រជែងដោយសេរីនៅក្នុងជំនួញ និងនាំចេញ រួមជាមួយនឹងការយល់ដឹងកាន់តែ ប្រសើរឡើងអំពីតំលៃត្រី អាចនឹងជួយជ្រោមជ្រែងដល់អ្នកនេសាទនៅក្នុងការកំណត់តំលៃផលនេសាទ ហើយដែលអាចធ្វើឱ្យពួកគេរកចំណូលពីការនេសាទត្រីបានច្រើនជាងមុន ។ បន្ថែមពីលើនេះ ការប្រកួតប្រជែងនៅក្នុងវិស័យជលផល អាចផ្តល់ឱកាសកាន់តែប្រសើរឡើងដល់សហគ្រិន ការវិនិយោគ និងតំលៃបន្ថែមដល់សហគ្រាសនៅក្នុងស្រុក ។

## ព្រៃឈើ

ទោះជាទិន្នន័យថ្នាក់ជាតិមិនគ្រប់គ្រាន់ក្នុងការប៉ាន់ស្មានយ៉ាងណាក៏ដោយ ប៉ុន្តែករណីសិក្សាបានសន្និដ្ឋានថា ការប្រើប្រាស់ព្រៃឈើមានភាពទូលំទូលាយ និងសំខាន់ចំពោះជីវភាពរស់នៅតាមជនបទរបស់ប្រជាជនកម្ពុជា ។ ព្រៃឈើបានផ្តល់ជា អុស ឈើសំណង់ សំភារៈសំរាប់ផលិតជាឧបករណ៍ប្រើប្រាស់នៅក្នុងគ្រួសារ ជ័រទឹក និងវល្លិ៍ បន្លែ ផ្លែឈើព្រៃ និងថ្នាំព្យាបាលរោគ ។ ប្រជាជននៅជនបទ ក៏អាចទាញ ប្រយោជន៍ពីតំលៃព្រៃឈើដែលមិនធ្វើឱ្យខូចប្រយោជន៍ធំ ដូចជា តំលៃខាងវប្បធម៌និងជំនឿ ពពួករុក្ខជាតិនិងសត្វផ្សេងៗ និងសារៈសំខាន់ចំពោះសេវាបរិស្ថាន ។ សេវាបរិស្ថានរួមមាន រក្សាលំនឹងទីជំរាលជួយទប់ទឹកជំនន់ និងកំរិតហូរច្រោះនៃដីល្បាប់ ។

នៅក្នុងកំលុងទសវត្សរ៍ទី៩០ វិស័យព្រៃឈើនៅក្នុងប្រទេសកម្ពុជាជួបវិបត្តិ ដោយសារការរីករាលដាលនៃការកាប់ឈើដោយខុសច្បាប់ ពុករលួយ ច្បាប់ព្រៃឈើ និងកិច្ចព្រមព្រៀងព្រៃសម្បទានចែងពុំច្បាស់លាស់ ព្រមទាំងការគ្រប់គ្រង និងការអនុវត្តន៍ច្បាប់នៅមានកំរិតខ្សោយ ។ ទិន្នន័យព្រៃឈើបានសន្និដ្ឋានថា កំរិតកាប់បំផ្លាញព្រៃឈើមានការកើនឡើងយ៉ាងខ្លាំងរវាងឆ្នាំ១៩៩៣ និង ១៩៩៧ (ឆ្នាំដែលទិន្នន័យមាន) ។ នាឆ្នាំ១៩៩៧ ស្ថិតិរដ្ឋាភិបាលបានប៉ាន់ស្មានថា ព្រៃឈើប្រទេសកម្ពុជានៅសល់ ១០,៦លានហិកតា ប៉ុន្តែការប៉ាន់ស្មាននេះធ្វើឡើងដោយយោងទៅលើការបកស្រាយចេញមកពីរូបភាពផ្កាយរណបដោយគ្មានការធ្វើសារពើភ័ណ្ឌស្តីពីធនធានព្រៃឈើជាក់ស្តែង "below-the-canopy" inventories ដែលកត្តានេះអាចលាតត្រដាងឱ្យដឹងច្បាស់លាស់អំពីការរិចរិល និងគុណភាពព្រៃឈើដែលនៅសល់ ។ ខាងក្រោមនេះ គឺជាសេចក្តីសន្និដ្ឋានដ៏សំខាន់ពីរចំនុចដែលដកស្រង់ចេញមកពីទិន្នន័យព្រៃឈើដែលគ្របដណ្តប់ក្នុងឆ្នាំ១៩៩៧:

- **ព្រៃឈើភាគច្រើននៅក្នុងប្រទេសកម្ពុជាពុំមានតំលៃខាងពាណិជ្ជកម្មឡើយ** នៅឆ្នាំ១៩៩៧ ព្រៃឈើនៅក្នុងប្រទេសកម្ពុជាមានតែ ៦% ប៉ុណ្ណោះ ប្រហែល ៦៣០.០០០ហិកតា ដែលមានប្រយោជន៍សំរាប់ធ្វើពាណិជ្ជកម្ម គឺស្ថិតនៅក្រុម "ព្រៃស្រោងស្លុក" ។ ចំណែកឯ ៣០% ផ្សេងទៀត (ប្រហែល ៣.២០០.០០០ហិកតា) គឺចាត់ចំណាត់ថ្នាក់ជា "ព្រៃរបោះ" ដែលបញ្ជាក់ថា ឈើហ៊ុបអាចមានពីតិចតួច ឬគ្មានតែម្តង ។ ចំណែកឯតំបន់ព្រៃឈើដទៃទៀតហាក់ដូចជាគ្មានផលប្រយោជន៍ដល់ផលិតកម្មឈើហ៊ុបឡើយ ។
- **ព្រៃលិចទឹកភាគច្រើនត្រូវបានគេកាប់ឆ្ការសំរាប់ដំណាំកសិកម្ម** នៅក្នុងឆ្នាំ១៩៧៣ ព្រៃលិចទឹកមានជាង ១លានហិកតា ប៉ុន្តែនាឆ្នាំ១៩៩៧ ចំនួននេះបានថយចុះរហូតដល់ ៤៥០.០០០ហិកតា ហើយដែលក្នុងនោះ ប្រមាណជា ៣០% គឺជាព្រៃរិចរិល និងព្រៃដុះឡើងវិញជាថ្មី ។ ព្រៃលិចទឹកបានផ្តល់សារៈសំខាន់ជាជំរកត្រី កន្លែងបន្តពូជ និងបង្កាត់ពូជ ។ ដូចនេះការបាត់បង់ព្រៃលិចទឹក ពិតជាមានផលវិបាកជាអវិជ្ជមានដល់ផលិតផលត្រី ។

ករណីសិក្សា និងភស្តុតាងខ្លះៗបានបញ្ជាក់ថា តំបន់ព្រៃដែលនៅសេសសល់ជាច្រើន គឺជាព្រៃរិចរិល ដូចនេះ ប្រវត្តិនៃ "ប្រព័ន្ធសុវត្ថិភាព" ដែលធនធានព្រៃឈើផ្តល់ដល់ប្រជាជនរស់នៅតាមជនបទ កាន់តែមានការយ៉ាប់យឺនគួរឱ្យកត់សំគាល់ ។ ការសិក្សានេះបានកត់សំគាល់ឃើញថា ការរិចរិលធនធានព្រៃឈើដែលនៅជិតភូមិអ្នកស្រុក បានបង្ខំឱ្យពួកគាត់ធ្វើដំនើរកាន់តែឆ្ងាយពីភូមិ ដើម្បីប្រមូលភោគផលព្រៃឈើ ។ មូលហេតុនៃការថយចុះធនធានទាំងនេះ តាមរបាយការណ៍បានបញ្ជាក់ថា បណ្តាលមកពីការកាប់ឈើខុសច្បាប់ និងគ្មាននិរន្តរភាព ព្រមទាំងការរារាំងសិទ្ធិក្នុងការចូលទៅតំបន់ព្រៃសម្បទាន ។ ខណៈដែលមានភាព

ហិរញ្ញវត្ថុ បានបង្កើននូវថ្លៃខាតបង់នៃការទទួលបាននូវធនធានព្រៃឈើ (ពេលវេលា កំលាំងពលកម្ម ថវិកា និងភាពប្រថុយប្រថាន) គ្រួសារនៅតាមជនបទជាអ្នកត្រូវតែចេញការខាតបង់តំលៃនេះ ដោយសារផលិតផលព្រៃឈើមិនងាយនឹងជំនួសបានឡើយ ។ ករណីសិក្សាក៏បានកត់សំគាល់ឃើញថា មានកំនើនសំពាធទៅលើធនធានព្រៃឈើ ។ ជម្លោះជាទូទៅកើតមានឡើងដោយសារការរារាំងមិនឱ្យចូលទៅក្នុងព្រៃប្រមូលផល ការបាត់បង់ធនធានព្រៃឈើដោយសារការកាប់ឈើ បរិយាកាសបំភិតបំភ័យ រួមជាមួយនឹងប្រតិបត្តិការសន្តិសុខនៅក្នុងព្រៃសម្បទាន ។

### *ការសម្លឹងមើលទៅអនាគត*

គោលនយោបាយដឹកនាំដែលប្រុងប្រយ័ត្នសំរាប់វិស័យព្រៃឈើ ត្រូវការចាំបាច់ឱ្យមានពត៌មានថ្មីៗទាក់ទងនឹងព្រៃឈើដែលគ្របដណ្តប់ព្រៃដែលស្តុក និងព្រៃធ្វើការប្រមូលផល ។ ការកាប់ឈើប្រាំរដូវបានកន្លងផុតទៅ ចាប់តាំងពីមានទិន្នន័យថ្មីចុងក្រោយស្តីពីព្រៃឈើគ្របដណ្តប់ ។ ទិន្នន័យព្រៃឈើដែលគ្របដណ្តប់ថ្មីនេះ គឺបំពេញបន្ថែមជាមួយនឹងសំណាក "ការងារអនុវត្តន៍ផ្ទាល់" នៃការសិក្សាសារពើភ័ណ្ឌ ដែលការងារនេះបានផ្តល់ជាសន្ទស្សន៍សំរាប់វាយតំលៃការជឿនលឿនស្តីពីការគ្រប់គ្រងព្រៃឈើតាំងពីឆ្នាំ១៩៩៧ ។ បន្ថែមពីលើនេះការសិក្សាស្រាវជ្រាវបែបនេះ អាចជួយធ្វើការកំណត់តំបន់នានានៅក្នុងប្រទេសកម្ពុជាដែលការកាប់បំផ្លាញព្រៃឈើមានកើតឡើងបន្ទាន់បំផុត ដោយបានអនុញ្ញាតឱ្យមានការវាយតំលៃកាន់តែឆាប់រហ័សអំពីមូលហេតុនៃការបំផ្លាញព្រៃឈើ និងរកផ្លូវដោះស្រាយគ្រប់គ្រងប្រកបដោយសក្តានុពលភាព ។

កិច្ចខិតខំប្រឹងប្រែងនៃកំណែទំរង់ព្រៃឈើបច្ចុប្បន្ននេះ បានផ្តល់ឱកាសក្នុងការកាត់បន្ថយអត្រាបំផ្លិចបំផ្លាញព្រៃឈើ និងបានបង្កើតនូវប្រព័ន្ធគ្រប់គ្រងដែលផ្តល់ផលប្រយោជន៍កាន់តែច្រើនឡើងដល់គ្រួសារក្រីក្រនៅតាមជនបទ ។ កិច្ចខិតខំប្រឹងប្រែងនេះរួមមាន ការព្យួរឈើសម្បទានទុកនាពេលថ្មីៗនេះ ពង្រាងច្បាប់ព្រៃឈើថ្មី និងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ព្រមទាំងការបង្កើន និងពង្រីកការគ្រប់គ្រងព្រៃសហគមន៍ ។ ក្នុងដំណើរឆ្ពោះទៅមុខបញ្ហាដ៏សំខាន់បំផុតនៅក្នុងការគ្រប់គ្រងព្រៃឈើ គឺថាតើគួរត្រូវរក្សាទុកប្រព័ន្ធសម្បទានដែរឬទេ ។ បញ្ហាបង្កើតប្រាក់ចំណូលរបស់រដ្ឋាភិបាល ប្រាក់ចំណេញមកពីសម្បទាន ការវិចរិល និងបាត់បង់ព្រៃឈើ និងផលប៉ះពាល់ដល់សង្គម និងបរិស្ថាន បានបញ្ជាក់ដល់ប្រព័ន្ធសម្បទានថា បានដើរឃ្លាតឆ្ងាយពីការគ្រប់គ្រងព្រៃឈើ និងទិសដៅអភិវឌ្ឍន៍ ។

លើសពីនេះទៀត ការវិភាគសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើការគ្រប់គ្រងព្រៃសម្បទានប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជាបានបញ្ជាក់ឱ្យឃើញថា ហាក់ដូចជាមិនអាចដំណើរការទៅបាន ។ ទីមួយ ដោយសារការដាក់ឱ្យប្រតិបត្តិតាមការប្រមូលផលនិរន្តរភាព គឺក្នុងមួយហិកតាកាប់ឈើពី ១ ទៅ ៣ដើម វានឹងបង្កការលំបាកក្រៃលែង ពីព្រោះប្រតិបត្តិការសម្បទាននេះនឹងមិនអាចមានផលចំណេញខាងសេដ្ឋកិច្ចឡើយ នៅពេលដែលគេធ្វើអាជីវកម្មក្នុងកំរិតទាបបែបនេះ ។ ទីពីរ បើទោះជាសម្បទានិកអាចរកផលចំណេញសមស្របតាមរបបនៃការប្រមូលផលនិរន្តរភាពយ៉ាងណាក៏ដោយ ប៉ុន្តែគេនៅតែបន្តប្រមូលផលក្នុងកំរិតដង់ស៊ីតេខ្ពស់ដោយសារចំណូលផ្នែកហិរញ្ញវត្ថុដ៏ធំសំបើម ។ ការអនុវត្តន៍បែបនេះ ជួយបង្វិលទុនច្រើន និងកាត់បន្ថយហានិភ័យ ដូចជាការកាប់ឈើខុសច្បាប់ដោយអង្គភាពដទៃទៀត និយ័តកម្ម និងច្បាប់ព្រៃឈើដែលដាក់កំហិតខ្លាំងឡើងៗ ការបញ្ឈប់កិច្ចសន្យា បរិយាកាសនយោបាយមានភាពពុំនឹងនរ និងឈើមានជំងឺ ។ល។ ការគ្រប់គ្រងព្រៃសម្បទានប្រកបដោយនិរន្តរភាព ត្រូវការចាំបាច់ឱ្យមានសម្បទានដែលអាចធ្វើទៅបាន សម្បទានិកដែលមានវិជ្ជាជីវៈខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការដាក់ឱ្យការអនុវត្តន៍ច្បាប់ ដែលលក្ខណៈអស់ទាំងនេះ កំពុងតែខ្វះខាតនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ។

ការជជែកវែកញែកស្តីពីការគ្រប់គ្រងព្រៃសម្បទាន ត្រូវតែរួមបញ្ចូលទៅលើការពិចារណាថា តើមានការគ្រប់គ្រងព្រៃឈើតាមវិធីសាស្ត្រណាផ្សេងទៀត ដែលអាចជំនួសសម្បទានបានដែរឬទេ? កម្ពុជាត្រូវការចាំបាច់ឱ្យមានការរៀនសូត្រអំពីសក្តានុពលភាពតួនាទីនៃការលូតលាស់យ៉ាងឆាប់រហ័សក្នុងការបង្កើតការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ដើម្បីផ្តល់នូវការយល់

ដឹងឱ្យកាន់តែប្រសើរឡើងអំពីទំហំ និងវិសាលភាពរបស់សកម្មភាពព្រៃសហគមន៍ វិទ្យាស្ថាន CDRI បានធ្វើជាសារពើភ័ណ្ឌព្រៃសហគមន៍ ដោយកំណត់ឃើញថាមាន ២៣៧ព្រៃសហគមន៍ (មកដល់ខែមីនា ឆ្នាំ២០០២) នៅក្នុងប្រទេសកម្ពុជា ដែលគ្របដណ្តប់ទៅលើផ្ទៃដី ប្រមាណ ៧០.០០០ហិកតា ។ ព្រៃសហគមន៍ទាំងនេះមានការខុសប្លែកគ្នាទាក់ទងនឹងទំហំ ការរៀបចំគោលបំណងគ្រប់គ្រង និងវិធីសាស្ត្រ បញ្ហាដែលលើកឡើង ការជឿនលឿនឆ្ពោះទៅរកការបង្កើតសហគមន៍ និងកំរិតនៃការគាំទ្រ ។

បន្ថែមពីលើការគ្រប់គ្រងព្រៃឈើដែលបានកែលំអ ប្រជាជនរស់នៅតាមជនបទអាចទាញយកផលប្រយោជន៍កាន់តែច្រើនថែមទៀតពីការគាំទ្រដល់ម៉ាឃីទីង និងតំលៃបន្ថែមនៃការកែច្នៃអនុផលព្រៃឈើ ។ ករណីសិក្សាបានរកឃើញថា អនុផលព្រៃឈើ ជាចំណែកមួយនៃចំណូលរបស់ប្រជាជនរស់នៅតាមតំបន់ព្រៃភ្នំ ។ ការគាំទ្រដល់ផ្នែកម៉ាឃីទីង ការលុបបំបាត់ចោលនូវអាជ្ញាប័ណ្ណដែលមិនចាំបាច់របស់រដ្ឋាភិបាល ផលលំបាកនៃលិខិតអនុញ្ញាតមួយចំនួន និងបង្កើតនូវការកែច្នៃថ្នាក់មូលដ្ឋានដែលជាតំលៃបន្ថែម កត្តាទាំងនេះនឹងចូលរួមចំណែកនៅក្នុងការជួយបង្កើនប្រាក់ចំណូលរបស់ប្រជាជនដែលប្រមូលអនុផលព្រៃឈើ ។

## តំរូវការស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គម

នៅក្នុងការរៀបចំការវាយតំលៃជំហ៊ានដំបូងនេះ គេបានកំណត់វិស័យជាសក្តានុពលនានា ដើម្បីស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គមមួយចំនួន ។ វិស័យដែលធ្វើការស្រាវជ្រាវទាំងនេះ ត្រូវបានសង្ខេបដូចខាងក្រោម ហើយការពិភាក្សាពិស្តារត្រូវបានអធិប្បាយនៅចុងជំពូកទី២ ទី៣ និងទី៤ ។

*សក្តានុពលភាពស្រាវជ្រាវទៅលើបញ្ហាកសិកម្ម*

១. តើអ្វីទៅជាមូលហេតុចំបងដែលធ្វើឱ្យបន្លែ និងដំណាំផ្សេងទៀតរបស់កម្ពុជា មិនអាចប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូលពីប្រទេសជិតខាង?

២. តើអ្វីទៅជាសក្តានុពលរយៈពេលខ្លី និងរយៈពេលវែង សំរាប់កែលំអ សមត្ថភាពកែច្នៃបង្កើតតំលៃបន្ថែម និងកែលំអម៉ាឃីទីង? តើការកែលំអទាំងនេះ នឹងមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះជីវភាពជនបទ?

៣. តើអ្វីខ្លះជាតួនាទីសមស្របសំរាប់សម្បទាននៅក្នុងការអភិវឌ្ឍន៍កសិកម្មជារួមនៅកម្ពុជា? តើសម្បទានដីកសិកម្មមានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការលើកកំពស់ជីវភាពជនបទ?

៤. តើទំនាស់លើដីសម្បទានកសិកម្ម ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន? តើគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់? តើគេអាចចាត់វិធានការណ៍អ្វីខ្លះដើម្បីកាត់បន្ថយលទ្ធភាពមានទំនាស់?

*សក្តានុពលភាពស្រាវជ្រាវទៅលើបញ្ហាជលផល*

១. តើប្រព័ន្ធគ្រប់គ្រងឡូត៍នេសាទ មានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

២. តើមានបន្ទុកចំណាយ និងអត្ថប្រយោជន៍អ្វីខ្លះ ក្នុងការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ?

៣. តើមានបំរែបំរួលអ្វីខ្លះនៅក្នុងតំបន់ជាអតីតឡូត៍នេសាទ និងតើវាមានផលប៉ះពាល់អ្វីខ្លះទៅលើជីវភាពជនបទ? តើសហគមន៍ឡូត៍នេសាទមានប្រសិទ្ធិភាពប៉ុណ្ណានៅក្នុងការគ្រប់គ្រងតំបន់ជាអតីតឡូត៍នេសាទ?

៤. តើការនេសាទតាមវាលស្រែមានសារៈសំខាន់ប៉ុណ្ណាចំពោះជីវភាពជនបទ ហើយតើវាមានផលប៉ះពាល់អ្វីខ្លះចំពោះការអភិវឌ្ឍន៍នូវកសិកម្ម និងនេសាទ?

៥. តើទំនាស់អំពីតំបន់នេសាទ ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន ហើយតើគេអាចធ្វើអ្វីខ្លះ ដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

៦. តើការកែច្នៃត្រី សកម្មភាពពាណិជ្ជកម្ម និងការនាំចេញត្រី មានស្ថានភាពយ៉ាងណានាបច្ចុប្បន្ន? តើគេអាចលើកកំពស់ជីវភាពជនបទយ៉ាងណាបានតាមរយៈការកែប្រែវិធីសាស្រ្តបច្ចុប្បន្នក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ?

*សក្តានុពលភាពស្រាវជ្រាវទៅលើបញ្ហាព្រៃឈើ*

១. តើប្រព័ន្ធសម្បទានព្រៃឈើមានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

២. តើមានបន្ទុកចំណាយ និងអត្ថប្រយោជន៍អ្វីខ្លះ ក្នុងការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍?

៣. តើទំនាស់អំពីធនធានព្រៃឈើ ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន ហើយតើគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

៤. តើការកែច្នៃ ពាណិជ្ជកម្ម និងការនាំចេញផលិតផលព្រៃក្រៅពីឈើ (NTFP) មានស្ថានភាពយ៉ាងណានាបច្ចុប្បន្ន? តើគេអាចលើកកំពស់ជីវភាពជនបទយ៉ាងណាបានតាមរយៈការកែប្រែវិធីសាស្រ្តបច្ចុប្បន្នក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ?

# បញ្ជីអក្សរកាត់

| | |
|---|---|
| AACK | អង្គការអភិវឌ្ឍន៍ជនក្រីក្រ (Angka Aphivat Chun Kreykra) |
| AEC | សកម្មភាពដើម្បីសហគមន៍ និងបរិស្ថាន (Action for Environment and Community) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (Cambodian for Human Rights and Development Association) |
| AFSC | គណៈកម្មាធិការបំរើក្វេគ័រអាមេរិកកាំង (American Friends Service Committee) |
| AIT | វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (Asian Institute of Technology) |
| APDO | អង្គការចូលរួមអភិវឌ្ឍន៍អង្គរ (Angkor Participatory Development Organization) |
| ARD | សមាគមអភិវឌ្ឍន៍ជនបទ (Associates in Rural Development, Inc.) |
| AS | អភិវឌ្ឍន៍ស្ត្រី (Aphiwat Strey) |
| BDASE | សមាគមអភិវឌ្ឍន៍ពុទ្ធសាសនា និង ទ្រទ្រង់បរិស្ថាន (Buddhism Development Association and Supporting Environment) |
| BFD | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (Buddhism for Development) |
| BFDK | អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ (Buddhism for Development Kompong Thom) |
| BPS | ព្រះពុទ្ធសាសនាដើម្បីសង្គម (Buddhism for Progressive Society) |
| CAA | សហគមន៍ជំនួយបរទេស អុកស្វាម-អូស្ត្រាលី (Community Aid Abroad, Oxfam Australia) |
| CARDI | វិទ្យាស្ថានអភិវឌ្ឍន៍ និង ស្រាវជ្រាវកសិកម្មកម្ពុជា (Cambodian Agricultural Research and Development Institute) |
| CARERE | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/គំរោងស្តារ និងបង្កើតតំបន់ឡើងវិញ (Cambodia Area Rehabilitation and Regeneration) |
| CCD | អភិវឌ្ឍន៍សហគមន៍កម្ពុជា (Cambodia Community Development) |
| CCK | ចំរើនជាតិខ្មែរ (Chamroen Chiet Khmer) |
| CDRI | វិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CED | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (Community Economic Development) |

| | |
|---|---|
| CEDAC | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (Centre D'etude et de Developpement Agricole Cambodgien) |
| CEPA | សមាគមអភិរក្សបរិស្ថានវប្បធម៌ (Cultural Environmental Preservation Association) |
| CFDS | អង្គការបំរើគ្រួសារអភិវឌ្ឍន៍កម្ពុជា (Cambodia Family Development Services) |
| CFRP | គំរោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃសហគមន៍នៅ (Community Forestry Research Project) |
| CHRD | អង្គការអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជា (Cambodian Human Resource Development) |
| CIAP | គំរោងអូស្រ្តាលីនៃវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ-កម្ពុជា (Cambodia-IRRI-Australia Project) |
| CIDSE | កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងសាមគ្គីភាព (Cooperation International pour le Development et la Solidarite) |
| COCMA | ក្រុមហ៊ុនសំភារៈកសិកម្ម (Compagnie Centrale des Materials Agricoles) |
| CoM | គណៈរដ្ឋមន្ត្រី (Council of Ministers) |
| Concern | ខុនសឺនវើលវ៉ាយដ៍ (Concern Worldwide) |
| CREDO | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា (Cambodian Rural Economic Development Organization) |
| CRS | កាតូលិក រីលីហ្វ សឺវិស៊ីស (Catholic Relief Services) |
| CTIA | សមាគមឧស្សាហកម្មឈើហ៊ុបកម្ពុជា (Cambodian Timber Industry Association) |
| CWS | គ្រីស្តសាសនាបំរើពិភពលោក (Church World Service) |
| DAI | ផ្ទៃព្រៃឈើដែលគេសំរុកកាប់ (Development Alternatives, Incorporated) |
| DFW | នាយកដ្ឋានរុក្ខាប្រមាញ់ (Department of Forestry and Wildlife) |
| DoF | នាយកដ្ឋានជលផល (Department of Fisheries) |
| EDCO | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (Economic Development Community Organization) |
| EEZ | តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone) |
| EPDO | អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (Environmental Protection and Development Organization) |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (Food and Agriculture Organization of the United Nations) |
| GDP | ផលិតផលក្នុងស្រុកសរុប (Gross domestic product) |
| GTZ | កម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាលកម្ពុជា-អាល្លឺម៉ង់ (Deutsche Greesellschaft Fuer Techische Zusammenarbeit) |
| HYV | ពូជស្រូវទំនើប (high-yielding variety) |
| ICC | អង្គការសហការ (International Cooperation for Cambodia) |
| IDRC | មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (International Development Research Center) |

| | |
|---|---|
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IRRI | វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (International Rice Research Institute) |
| KAMFIMEX | ក្រុមហ៊ុននីហ៉ារណៈ-អាហ៉ារណៈត្រីនៅកម្ពុជា (Kampuchea Fish Import and Export Company) |
| KAWP | ក្រុមអភិវឌ្ឍន៍ភូមិ (Krom Aphi Wat Phum) |
| KHRDO | អង្គការខ្មែរអភិវឌ្ឍន៍ធនធានមនុស្ស (Khmer Human Resource for Development Organization) |
| KNCED | សហគមន៍ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ (Khmer National Community Economic Development) |
| KVOD | អង្គការអ្នកស្ម័គ្រចិត្តខ្មែរដើម្បី អភិវឌ្ឍន៍ (Khmer Volunteer Organization for Development) |
| LWS | សាសនាលូថេរ៉ានបំរើពិភពលោក (Lutheran World Service) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MCC | គណៈកម្មការមីណូណៃ (Mennonite Central Committee) |
| MoC | ក្រសួងពាណិជ្ជកម្ម (Ministry of Commerce) |
| MoE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MoP | ក្រសួងផែនការ (Ministry of Planning) |
| MRC | គណៈកម្មាធិការទន្លេមេគង្គ (Mekong River Commission) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Governmental Organisation) |
| NIS | វិជ្ជាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| NRA | គណនេយ្យធនធានធម្មជាតិ (Natural resource accounting) |
| NTFP | អនុផលព្រៃឈើ (Non-Timber Forest Products) |
| PADEK | សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (Partnership for Development in Kampuchea) |
| PMMR | គំរោងការចូលរួមគ្រប់គ្រងព្រៃកោងកាង (Participatory Management of Mangrove Resources) |
| RLR | ស្រូវទំនាបពឹងលើទឹកភ្លៀង (Rainfed Lowland Rice) |
| RPFD | អង្គការអភិវឌ្ឍន៍គ្រួសារក្រីក្រនៅតាមជនបទ (Rural Poor Family Development) |
| SADP | កម្មវិធីអភិវឌ្ឍន៍អាស៊ីអគ្នេយ៍ (Southeast Asia Development Program) |
| SMRP | គំរោងគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពក្នុងអាងទន្លេមេគង្គខាងក្រោម (Sustainable Management of Resources Project) |
| SSP | ស្ត្រីសន្តិភាពដើម្បីបរិស្ថាន (Strey Santepheap daoembei Parethan) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme) |
| VSG | ក្រុមទ្រទ្រង់ភូមិ (Village Support Group) |

| | |
|---|---|
| WI | អង្គការដីសើមអន្តរជាតិ (Wetlands International) |
| WKK | វត្តឃ្លាំងខ្មូត (Wat Khleang Khmot) |
| WSC | អង្គការសមាគមអភិរក្សសត្វព្រៃ (Wildlife Conservation Society) |
| WTPS | វត្តទួលព្រះស្រី (Wat Toul Preah Srey) |

# សេចក្តីថ្លែងអំណរគុណ

ឯកសារពិភាក្សានេះ ផ្អែកលើការសំភាសន៍ជាមួយអ្នកជំនាញការឯកទេស អ្នកធ្វើការដែលអនុវត្តផ្ទាល់លើបញ្ហាធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ និងបានមកពីការសំយោគចេញពីឯកសារ និងការស្រាវជ្រាវថ្មីៗដែលមានស្រាប់ ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អ្នកសំភាសន៍ទាំងនោះ សំរាប់ការពិភាក្សាប្រកបដោយចំណេះដឹងរបស់ពួកគេ និងបណ្ណារក្ស ព្រមទាំងអ្នកដទៃទៀតដែលបានជួយដល់យើងខ្ញុំក្នុងការកំណត់រក និងទីតាំងឯកសារសំខាន់សំរាប់ធ្វើការស្រាវជ្រាវ ។ បន្ថែមពីលើនេះទៀត ពតិមានយ៉ាងសំបូរបែបស្តីពីការគ្រប់គ្រងសហគមន៏ ដែលបានឃើញនៅក្នុងការស្រាវជ្រាវនេះ ត្រូវបានបង្កើតឡើងដោយមានការជួយជ្រោមជ្រែងពីបណ្តាញនានានៃសហគមន៏ព្រៃឈើ និងសហគមន៏នេសាទ ព្រមទាំងការសំភាសន៏តាមទូរស័ព្ទជាមួយនឹងប្រធានគ្រប់គ្រងគំរោងនៅក្នុងប្រទេស ។ សូមថ្លែងអំណរគុណយ៉ាងពន្លឹក ចំពោះអ្នកទាំងអស់គ្នាដែលបានចែករំលែកនូវទំនាក់ទំនងនានាពតិមានគំរោង និងបទពិសោធន៏ ។

អ្នកនិពន្ធក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក យ៉ង់ សាំងកុមារ នៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៏កសិកម្មកម្ពុជា (CEDAC) និងលោក Peter Degen នៃវិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាប ព្រមទាំងលោក Andrew Cock នៃវេទិកាអង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកជំនាញការឯកទេសនៅក្នុងវិស័យកសិកម្ម ជលផល និងព្រៃឈើ ដែលពួកគេបានលះបង់ពេលវេលាផ្ទាល់ខ្លួន ដើម្បីត្រួតពិនិត្យមើលពង្រាងនៃឯកសារពិភាក្សានេះ ព្រមទាំងបានផ្តល់យោបល់ដែលមានប្រយោជន៏ និងគំនិតយោបល់ដ៏មានតំលៃ ។ អ្នកនិពន្ធ សូមអរគុណចំពោះលោក Sarthi Acharya ជានាយកផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI និងលោកស្រី អេវ៉ា មីស្លីវិក នាយិកាវិទ្យាស្ថាន CDRI ដែលបានជួយតំរង់ទិសដៅ និងគំនិតនៅក្នុង ការរៀបចំឯកសារនេះ ។

*ភ្នំពេញ ខែមិថុនា ឆ្នាំ២០០២*

*Bruce Mckenney និង ព្រុំ តុលា*

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា*

# ជំពូកទី ១

# សេចក្តីផ្តើម

នាពេលបច្ចុប្បន្ននេះ មានប្រជាជនកម្ពុជាជាង ១០លាននាក់រស់នៅតាមទីជនបទ[២] ។ ការសិក្សាស្តីអំពីការចូលរួមការងារ និងពលកម្ម បានធ្វើសេចក្តីសន្និដ្ឋានថា ប្រជាជនរស់នៅតាមតំបន់ជនបទប្រមាណជា ៨៥% (ដែលមានចំនួនច្រើនជាង ៨,៥លាននាក់) បានពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្ម នេសាទ និងព្រៃឈើ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ (NIS 2000, Ramamurthy *et at.* 2001) ។ នៅក្នុងចំណោមប្រជាជនទាំងនេះ មានប្រមាណជា ៨០% (ច្រើនជាង ៧លាននាក់) គឺរស់ត្រឹមតែមួយគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតប៉ុណ្ណោះ ។ ពួកគេភាគច្រើន ពឹងផ្អែកជាសំខាន់ទៅលើការដាំដំណាំស្រូវម្តងម្កាលក្នុងមួយឆ្នាំ ត្រី ធនធានក្នុងទឹក និងផលព្រៃឈើ ដូចជា អុស ឈើ ជ័រទឹក វ័រ បន្លែនិងផ្លែឈើព្រៃ និងរុក្ខជាតិឱសថ ។ នៅក្នុងបរិបទនេះ ធនធានធម្មជាតិនៅកម្ពុជា បានផ្តល់ជាប្រយោជន៍សំខាន់សំរាប់សន្តិសុខស្បៀង ប្រាក់ចំណូល និងការងារដល់ប្រជាជនភាគច្រើនបំផុត ។

នាទសវត្សរ៍កន្លងមកនេះ ជីវភាពរស់នៅតាមជនបទមានការលំបាកកាន់តែខ្លាំងឡើងៗ ដោយហេតុថា ធនធានព្រៃឈើ និងជលផលមានការថយចុះជាលំដាប់ ។ ការប្រមូលផលដោយខុសច្បាប់ និងគ្មាននិរន្តរភាពនៃត្រី និងឈើ ដែលធ្វើឡើងដោយក្រុមហ៊ុនពាណិជកម្ម ឃោធា អាជ្ញាធរដែនដី និងកំណើនប្រជាជននៅតាមជនបទ គឺជាមូលហេតុនៃការថយចុះ និងការបាត់បង់ព្រៃឈើនៅក្នុងកំរិតមួយខ្ពស់ ព្រមទាំងចុះថយនូវចំនួនត្រីដែលមានតំលៃ ។ ម្យ៉ាងវិញទៀត ការប្រកួតប្រជែងផ្អែកដីធ្លីកាន់តែមានកំរិតធំធ្ងន់ធ្ងរជាលំដាប់ នាំឱ្យប្រជាជនដែលគ្មានដីធ្លី កាន់តែមានចំនួនច្រើនឡើងគួរឱ្យកត់សំគាល់ ។ ស្ថិតិជំរឿនបានប៉ាន់ស្មាន ឃើញថា ប្រជាជនរស់នៅតាមតំបន់ជនបទប្រមាណជា ៥៥% មានអាយុក្រោម ឬស្មើនឹង ១៩ឆ្នាំកាលពីឆ្នាំ១៩៩៨ ។ ដូចនេះ សំពាធសង្កត់ទៅលើធនធានធម្មជាតិហាក់ដូចជាមានការកើនឡើងនាពេលអនាគតដ៏ខ្លីខាងមុខនេះ នៅពេលដែលយុវជនទាំង នេះចូលរួមនៅក្នុងកំលាំងពលកម្ម ។

សំរាប់ប្រជាជននៅតាមជនបទ បញ្ហានានាដែលទាក់ទងនឹងការបាត់បង់ និងការថយចុះធនធាន ត្រូវគេធ្វើឱ្យកាន់តែយ៉ាប់យ៉ឺនខ្លាំងឡើងៗ ដោយសារតែមានការហាមឃាត់មិនឱ្យប្រើប្រាស់ធនធានទាំងអស់នោះ ។ នៅក្រោមប្រព័ន្ធសម្បទានព្រៃឈើ ជលផល និងដីធ្លី រដ្ឋាភិបាលបានជួលធនធាននៅក្នុងប្រទេសដែលមានផលិតភាពខ្ពស់ភាគច្រើនទាំងនោះ ទៅឱ្យក្រុមហ៊ុនឯកជន ។ កិច្ចសន្យាសម្បទាន បានផ្តល់សិទ្ធិឱ្យក្រុមហ៊ុនឯកជនធ្វើអាជីវកម្មលើធនធានដែលមានក្នុងសម្បទាននោះ នៅក្នុងរយៈពេលកំណត់មួយ ។ ដូចនេះជាហេតុផលមួយដែលទាក់ទងនឹងផលប្រយោជន៍ហិរញ្ញវត្ថុ ក្រុមហ៊ុនឯកជនត្រូវបានដាក់កំរិតមួយយ៉ាងតឹងតឹង និងរារាំងប្រជាជនក្នុងការប្រើប្រាស់ធនធានដែលមាននៅក្នុងកំលុងនៃរយៈពេលកិច្ចសន្យារបស់ខ្លួន ។ ផ្ទៃដីសរុប ១៨,១លានហិកតា ដែលក្នុងនោះមាន ៥,៥លានហិកតា គ្រប់គ្រងដោយសម្បទាន (ព្រៃឈើ ៤,២លានហិកតា ដី

[២] ការប៉ាន់ស្មាននេះ ផ្អែកលើជំរឿនឆ្នាំ១៩៩៨ មានប្រជាជនរស់នៅតំបន់ជនបទ ៩.៦៤២.០៨១នាក់ និងអត្រាកំណើនប្រជាជន ២,៤៩% ។

០,៨លានហិកតា និងជលផល ០,៤លានហិកតា) ។ កាលពីទសវត្សរ៍ទី៩០ ការគ្រប់គ្រងតាមបែបសម្បទាន មានរហូតជិតដល់ ៨លានហិកតា[៣] ។

គោលនយោបាយ និងឯកសារថ្មីៗជាច្រើនរបស់រដ្ឋាភិបាល បានចេញសេចក្តីប្រកាសប្តេជ្ញាយ៉ាងមុតមាំ ក្នុងការកាត់បន្ថយភាពក្រីក្រ[៤] ។ ដូចនេះ ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពនៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ត្រូវតែលើកយកមកពិចារណាអំពីទំនាក់ទំនងជិតស្និទ្ធរវាងជីវភាពប្រជាជនតាមជនបទ និងធនធានធម្មជាតិ ។ គោលនយោបាយនានាដែលរួមចំណែកដល់ការធ្វើឱ្យចុះថយ និងបាត់បង់ធនធានធម្មជាតិ ជាទូទៅត្រូវចាត់ទុកថាជាមូលហេតុនៃការធ្វើឱ្យភាពក្រីក្រនៅតាមជនបទមានការកើនឡើង ។ ដូចគ្នានេះដែរ រាល់គោលនយោបាយនានាដែលសមស្រប ឬអនុវត្ត ទៅលើសម្បត្តិធនធានធម្មជាតិរួម (ព្រៃឈើ និងការនេសាទ) ហើយជួលធនធានដែលសំបូរបែបទាំងនេះ ឱ្យទៅសម្បទានឯកជន ដោយដកហូតធនធានទាំងនេះពីប្រជាជនដែលរស់នៅតាមតំបន់ជនបទ វាអាចនឹងបង្កើតទៅជាជម្លោះ ។

## ១.១. ទិសដៅ និងវិធីសាស្ត្រ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្កើតកម្មវិធីធនធានធម្មជាតិ និងបរិស្ថានឡើងនៅចុងឆ្នាំ២០០១ ។ នៅក្នុងកិច្ចការដំបូងនៃកម្មវិធី ឯកសារនេះ មានបំណងផ្តល់ជាមូលដ្ឋានសំរាប់ (១) បង្កើនការយល់ដឹងអំពីទំនាក់ទំនងរវាងជីវភាពជនបទ ធនធានធម្មជាតិ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និង (២) ធ្វើការកំណត់ចន្លោះ ឬសេចក្តីត្រូវការចាំបាច់សំរាប់ការស្រាវជ្រាវសេដ្ឋកិច្ចសង្គមដែលទាក់ទងដល់ជីវភាពជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ ។ ឯកសារនេះសំរេចបាន គឺផ្អែកទៅលើការសំយោគពីឯកសារនានា និងការសិក្សាថ្មី ព្រមទាំងតាមរយៈការសំភាសន៍ជ្រើសរើសជាមួយអ្នកជំនាញការ និងអ្នកធ្វើការអនុវត្តន៍ផ្ទាល់លើបញ្ហាធនធានធម្មជាតិ និងជីវភាពប្រជាជនជនបទ ។

## ១.២. ធនធានធម្មជាតិ និងយុទ្ធសាស្ត្រជីវិតប្រជាជននៅតាមជនបទ

លក្ខណៈភូមិសាស្ត្រសំខាន់របស់ប្រទេសកម្ពុជារួមមាន ទន្លេមេគង្គ បឹងទន្លេសាប (គឺសំដៅទៅលើបឹងធំ) ទំនាបលិចទឹកដ៏ធំល្វឹងល្វើយ និងតំបន់ទំនាបនានា ។ ចំណែកឯទិសឦសាន និងពាយព្យ គឺតំបន់ខ្ពង់រាប ។ ប្រជាជនកម្ពុជាភាគច្រើនរស់នៅតាមតំបន់ទំនាប ហើយជីវភាពរបស់ពួកគេបានស៊ាំនឹងរដូវប្រាំង និងរដូវវស្សា ។ ទឹកភ្លៀងដែលធ្លាក់នៅក្នុងរដូវវស្សា (ចាប់ពីខែឧសភា ដល់តុលា) រួមទាំងជំនន់តាមបណ្តោយទន្លេ ដៃទន្លេ បឹង និងតំបន់ដីសើម បាននាំយកទឹក និងជីជាតិដីល្បាប់ទៅចាក់គរនៅតំបន់ទំនាបនានា ។ តំបន់ទំនាបទាំងនេះ បានទ្រទ្រង់ដល់ការដាំដុះដំណាំស្រូវជាង ៩០% នៅកម្ពុជា និងបានផ្តល់ជាជំរកដល់វារីជីវិតដ៏សំបូរបែប ។ ជាក់ស្តែងការនេសាទទឹកសាបនៅក្នុងប្រទេសកម្ពុជា មានទិន្នខ្ពស់បំផុត ដោយជាប់លំដាប់ថ្នាក់ទី៤ នៅលើសកលលោក ។ ព្រៃឈើដែលតាមរបាយការណ៍បានបញ្ជាក់ថា គ្របដណ្តប់ជាងពាក់កណ្តាលនៃផ្ទៃប្រទេស បានដើរតួនាទីយ៉ាងសំខាន់នៅរដូវវស្សា ដោយវាបានបង្កើតជាតុល្យភាពតំបន់ជំរាល និងជួយទប់ទឹកជំនន់ ព្រមទាំងការហូរច្រោះនៃដីល្បាប់ ។

នៅក្នុងប្រទេសកម្ពុជា ជីវភាពប្រជាជនជនបទ គឺមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅទៅនឹងបំលាស់ប្តូររដូវកាល និងធនធានធម្មជាតិដែលមាន ។ ថ្វីបើនៅដើម និងចុងរដូវ ក៏អាចមានភាពខុសគ្នាខ្លះៗពីមួយឆ្នាំទៅមួយឆ្នាំ និងពីកន្លែងមួយទៅកន្លែងមួយដែរ តារាងទី១ បានផ្តល់ការអធិប្បាយអំពីបញ្ហាជារួមទាក់ទងនឹងសកម្មភាពសំខាន់នៃប្រជាជនរស់នៅតាមជនបទ ។

---

[៣] តំបន់ព្រៃសម្បទានជាង ២លានហិកតា បានត្រូវលុបចោលនៅក្នុងឆ្នាំ១៩៩៩ ។ ឡូត៍នេសាទជាង ០,៥លានហិកតា ត្រូវបានកាត់ចេញក្នុងឆ្នាំ២០០១ ។ ការកាត់បន្ថយតំបន់សម្បទានដែលធ្វើពាណិជ្ជកម្ម កើតមានឡើងដោយសារលទ្ធផលនៃការខិតខំធ្វើកែទំរង់របស់រដ្ឋាភិបាល និងដោយសារធនធានវិចវិល - តំបន់សម្បទានលែងមានផលិតភាពខ្ពស់ដោយសារលទ្ធផលនៃសកម្មភាពប្រមូលផលគ្មាននិរន្តរភាព ។

[៤] ឧទាហរណ៍ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល ៥ឆ្នាំលើកទីពីរ ២០០១-២០០៥ ឯកសារយុទ្ធសាស្ត្រស្តីពីការកាត់បន្ថយភាពក្រីក្រ និងសកម្មភាពផែនការអភិបាលកិច្ច ។

ទោះជាសកម្មភាពកសិកម្មភាគច្រើននៅក្នុងប្រតិទិនប្រចាំឆ្នាំក៏ដោយ ក៏ជីវភាពប្រជាជនជនបទផ្អែកយ៉ាងសំខាន់ផងដែរទៅលើ "ធនធានរួម" រដ្ឋជាអ្នកគ្រប់គ្រងដូចជា ព្រៃឈើ និងជលផល ហើយប្រជាពលរដ្ឋទាំងអស់មានសិទ្ធិធ្វើអាជីវកម្ម ។ ការមានសិទ្ធិទៅលើធនធានទាំងនេះ បានផ្តល់ឱកាសដល់គ្រួសារនានាមានមុខរបរច្រើន ដើម្បីធ្វើឱ្យមាន"ភាពកក់ក្តៅ" ដើម្បីទប់ទល់នឹងការប្រថុយប្រថាននៃបរាជ័យក្នុងការដាំដុះតែមួយមុខ និងធ្វើឱ្យធនធានពលកម្មរបស់គេប្រើអស់លទ្ធភាព ។

សកម្មភាពកសិកម្មដែលគ្របដណ្តប់យ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា គឺការដាំដុះដំណាំស្រូវវស្សានៅតាមតំបន់ទំនាបដែលចាប់ផ្តើមពីខែឧសភា និងប្រមូលផលនៅខែមករា ( ស្រូវស្រាល និងស្រូវកណ្តាល អាចប្រមូលផលលឿនជាងនេះ) ។ នៅតំបន់ទំនាបកណ្តាលខ្លះ ជាពិសេសតំបន់ដីសណ្តរទន្លេមេគង្គ និងទន្លេបាសាក់ ស្រូវប្រាំង ត្រូវបានគេដាំ ចាប់ពីខែវិច្ឆិកា ដល់ខែកុម្ភៈតាមរយៈការគ្រប់គ្រងទឹកជំនន់ដែលស្រកចុះ ។ ដូចគ្នានេះដែរ បន្លែ និងដំណាំដទៃទៀត ត្រូវបានគេដាំនៅរដូវប្រាំងនៅតាមបណ្តោយមាត់ទន្លេ និងតំបន់សំបូរជីជាតិដែលមានទឹកគ្រប់គ្រាន់ ។ ដីដាំទឹក បានបង្កការលំបាកដល់ការដាំដុះដំណាំផ្សេងៗជាជាងស្រូវទៅទៀត ។ នៅតំបន់ខ្ពង់រាប ស្រូវ និងបន្លែ ត្រូវគេដាំដុះនៅលើស្រែតែមួយក្នុងកំលុងរដូវវស្សា ។

គ្រួសារជនបទដែលរស់នៅជាប់នឹងផ្លូវទឹកសំខាន់ៗជាច្រើន អាចនេសាទត្រីបានពេញមួយឆ្នាំ ចំណែកគ្រួសារខ្លះទៀតអាចនេសាទត្រីបានតាមរដូវ ឬក៏មិនបានធ្វើការនេសាទសោះ ។ ពេលវេលានេសាទត្រីបានផលខ្ពស់បំផុតសំរាប់ "គ្រួសារ" ដែលប្រកបរបរនេសាទខ្នាតតូច ចាប់ផ្តើមឡើងនៅដើមរដូវប្រាំងពីខែវិច្ឆិកា ដល់ខែកុម្ភៈ នៅពេលដែលទឹកជំនន់ចាប់ផ្តើមស្រក ហើយត្រីចាប់ផ្តើមផ្លាស់ប្តូរជំរក ។ ប្រជាជនតាមជនបទក៏អាចទាញផលប្រយោជន៍បានមកពីធនធានក្នុងទឹកផងដែរ ដូចជាត្រីក្តាម កំពិស និងកង្កែប ដោយចាប់នៅតាមវាលស្រែរបស់ពួកគេ ។ ការប្រមូលផលភាគច្រើនកើតឡើងនាដើមរដូវប្រាំងនៅពេលទឹកស្រក និងនៅពេលដែលត្រី ព្រមទាំងសត្វមានជីវិតក្នុងទឹក ភៀសខ្លួនពីក្នុងស្រែទៅកាន់ទីកន្លែងដែលមានទឹកជ្រៅ ។

**តារាងទី១. ប្រតិទិនរដូវកាលទូទៅស្តីពីសកម្មភាពនានារបស់ជីវភាពប្រជាជនរស់នៅតាមជនបទកម្ពុជា - រយៈពេលដែលសកម្មភាពសំខាន់ៗត្រូវដំណើរការ[១]**

| សកម្មភាពរស់នៅរបស់ | រដូវវស្សា | | | | | | រដូវប្រាំង | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រជាជននៅតាមជនបទ | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា |
| ស្រូវវស្សា ( តំបន់ទំនាប ) | | | | | | | | | | | | |
| ស្រូវប្រាំង ( តំបន់ទំនាប ) | --- | | | | | | | | | | --- | --- |
| ស្រូវ/ចំការ[២] ( ខ្ពង់រាប ) | | | | | | | | | | | | |
| បន្លែ ( តំបន់ទំនាប ) | | | | | | | | | | | --- | --- |
| នេសាទជាលក្ខណៈគ្រួសារ | --- | --- | --- | --- | --- | --- | | | | | --- | --- |
| ការនេសាទត្រីស្រែ | --- | --- | --- | --- | --- | --- | | | | | | |
| ការប្រមូលផលព្រៃឈើ | --- | --- | --- | --- | --- | --- | --- | | | | | |

*[១] ជីវភាពតាមជនបទអាចមានការខុសប្លែកពីគ្នាគួរឱ្យកត់សំគាល់ពីកន្លែងមួយទៅកន្លែងទៀត ។ គោលបំណងនៅទីនេះ គឺចង់ផ្តល់នូវស្ថានភាពទូទៅនៃពេលវេលាសំខាន់ដែលប្រជាជនកម្ពុជា មានសកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិត ។ ផ្ទៃខ្មៅគូសបញ្ជាក់ពីពេលវេលានៃសកម្មភាពមមាញឹក ចំណែកឯសញ្ញា ( ---) គឺបញ្ជាក់អំពីសកម្មភាពដែលមិនសូវមមាញឹក ។*

*[២] ចំណែកឯនិយមន័យ "ចំការ" អាចមានការប្រែប្រួល ។ នៅទីនេះពាក្យថា "ចំការ" សំដៅទៅលើបច្ចេកទេសជាប្រពៃណីនៅក្នុងតំបន់ខ្ពង់រាបដែលគេដាំដំណាំស្រូវចំរុះ លាយជាមួយនឹងដំណាំបន្លែនៅលើផ្ទៃដីកសិដ្ឋានតែមួយ ។*

ប្រជាជននៅតាមជនបទដែលរស់នៅក្នុង ឬនៅជិតតំបន់ព្រៃ បានទទួលផលប្រយោជន៍ពីធនធានព្រៃឈើពេញមួយឆ្នាំ ។ ឧទាហរណ៍ ការរកជ័រទឹក និងរកអុស គឺអាចប្រកបរបរនេះបានពេញមួយឆ្នាំ ។ ទោះបីយ៉ាងណាក៏ដោយ ក៏ការប្រមូលផលព្រៃឈើមានការកើនឡើងនៅក្នុងរដូវប្រាំង គឺជាពេលដែលគ្រួសារភាគច្រើននៅតាមជនបទ ពុំសូវជាប់រវល់នឹងការធ្វើស្រែ ហើយងាយស្រួលក្នុងការធ្វើដំណើរ ។

## ១.៣. ផលវិបាកនៃម៉ាក្រូសេដ្ឋកិច្ច និងសន្ទស្សន៍ការងារ

វិស័យកសិកម្ម ព្រៃឈើ និងនេសាទមានប្រមាណជា ៣០% នៃផលិតផលក្នុងស្រុកសរុប (ផសស) និងឱ្យការងារដល់ប្រជាពលរដ្ឋ ៧៧% នៅក្នុងឆ្នាំ២000 (CDRI 2002) ។ ក្នុងចំណោមវិស័យទាំងនេះ កសិកម្មរួមចំណែកច្រើនជាងគេនៅក្នុង ផសស និងការងារធ្វើដោយកសិកម្មគ្របដណ្តប់ ២៣% នៃផលិតផលទុនក្នុងស្រុកសរុប និងផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណជា ៧៤% បើធៀបនឹងវិស័យព្រៃឈើ (ផលិតផលទុនក្នុងស្រុកសរុប ៤% និងផ្តល់ការងារដល់ប្រជាពលរដ្ឋតិចជាង ១%) និងវិស័យជលផល (ផលិតផលទុនក្នុងស្រុកសរុប ៣% និងផ្តល់ការងារតិចជាង ២%) ។ ការសិក្សាដទៃទៀត ក៏បានរកឃើញស្រដៀងគ្នានេះដែរ គឺអត្រាផ្តល់ការងារក្នុងវិស័យព្រៃឈើ និងជលផល មានកំរិតទាប ។ ឧទាហរណ៍ ការធ្វើជំរឿនប្រជាជនជាទូទៅនៅក្នុងប្រទេសកម្ពុជា បានប្រមាណឃើញនាឆ្នាំ១៩៩៨ ថា វិស័យជលផលស្រូបកំលាំងពលកម្មប្រជាជនបានត្រឹមតែ ១,៥% ប៉ុណ្ណោះ ឯក្នុងវិស័យព្រៃឈើ ស្រូបកំលាំងពលកម្មបានតែ 0,១៣% "ការកាប់ឈើ និងសេវាកម្ម សកម្មភាពនានាដែលទាក់ទងនឹងព្រៃឈើ" ។ ដូចគ្នានេះដែរ ការធ្វើអង្កេតស្តីពី សេដ្ឋកិច្ចសង្គមនៅកម្ពុជានាឆ្នាំ១៩៩៩ បានរកឃើញថាមានតែកំលាំងពលកម្មប្រមាណជា ២% ប៉ុណ្ណោះដែល "វិស័យជលផល" ស្រូបយក ។ ប៉ុន្តែរបាយការណ៍នេះពុំបានរួមបញ្ចូលការងារនៅក្នុងវិស័យព្រៃឈើ មកពីសកម្មភាពកសិកម្ម និងប្រម៉ាញ់ទេ ។

ស្ថិតិជាតិបានផ្តល់ជាមូលដ្ឋានគ្រឹះដល់ការទ្រទ្រង់គោលនយោបាយ ដូចនេះវាមានសារៈសំខាន់បំផុត ដែលស្ថិតិទាំងនេះឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងយ៉ាងត្រឹមត្រូវ ។ តំបន់ជាច្រើន និងករណីសិក្សានានាបានរកឃើញថា ធនធានជលផល និងព្រៃឈើមានតួនាទីកាន់តែសំខាន់ឡើងនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនតាមជនបទ ជាងអ្វីដែលបានកំណត់នៅក្នុង ផសស និងស្ថិតិការងារជាតិ (ការពិភាក្សាលំអិតសូមអានចំណុច ៣.៣ និង ៤.៣) ។ នៅក្នុងស្ថិតិជាតិ ការប៉ាន់ស្មានអំពីសេដ្ឋកិច្ច និងការងាររបស់វិស័យជលផល និងព្រៃឈើមិនសូវសុក្រឹត ដោយហេតុថា មានការលំបាកទាក់ទងនឹងការធ្វើអង្កេតប្រជាជនដែលពឹងផ្អែកលើមុខរបរច្រើនសំរាប់ចិញ្ចឹមជីវិត ។ ទីមួយ គឺមានការលំបាកក្នុងការបែងចែកច្បាស់លាស់រវាងប្រជាជនកម្ពុជារស់នៅតាមជនបទជាមួយនឹងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដូចជា តើពួកគេជាកសិករ អ្នកនេសាទ ឬអ្នករស់នៅដោយប្រកបរបរប្រមូលផលពីព្រៃឈើ ។ មុខរបរចិញ្ចឹមជីវិតមានការប្រែប្រួលផ្អែកទៅតាមធនធានធម្មជាតិ រដូវកាល សិទ្ធិក្នុងការរុករកទីផ្សារ និងកត្តាដទៃផ្សេងៗទៀត ។ ទីពីរ ប្រជាជនកម្ពុជាភាគច្រើនតែងតែយល់ឃើញថា មុខរបរសំខាន់ទីមួយរបស់ពួកគេគឺធ្វើស្រែ ប៉ុន្តែថាតើមុខរបរនេះផ្តល់ប្រាក់ចំណូលបានច្រើនឬទេសំរាប់ផ្គត់ផ្គង់ជីវភាពរបស់ខ្លួន ។ ការនេសាទ និងប្រមូលផលព្រៃឈើ អាចត្រូវបានគិតបញ្ចូលថា ជាមុខរបរសំខាន់បន្ទាប់បន្សំទីពីរ ឬទីបី ។ ចាប់តាំងពីមានការធ្វើអង្កេតថ្នាក់ជាតិ ហើយស្ថិតិផ្តោតសំខាន់តែទៅលើមុខរបរសំខាន់ទីមួយ ដូចនេះ វាពុំគ្រប់គ្រាន់ល្មមដើម្បីយល់ដឹងពីសារៈសំខាន់នៃធនធានជលផល និងព្រៃឈើ ដើម្បីចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមតំបន់ជនបទបានទេ ។

ផលិតផលទុនក្នុងស្រុកសរុបទទួលរងបញ្ហាស្មុគស្មាញបន្ថែមទៀត គឺជាសន្ទស្សន៍មិនល្អ សំរាប់ធ្វើការវាស់វែងស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។ ការវាស់វែងផលិតផលទុនក្នុងស្រុកសរុប និងប្រាក់ចំណូលជាតិមិនបានរួមបញ្ចូលទ្រព្យធនធានធម្មជាតិដែលអាចខ្សត់ខ្សោយ ដូចជាឈើនៅក្នុងព្រៃ និងត្រីដែលស្តុកនៅក្នុងទឹក ។ មិនដូចបច្ច័យគណនេយ្យដែលមានទ្រព្យសម្បត្តិ ដូចជា អគារ គ្រឿងម៉ាស៊ីនឡើយ គឺថាទ្រព្យធនធានធម្មជាតិមិនមែនចាត់ទុកថា ជាទុនដែលអាចធ្វើការរំលោះបានទេ ។ ដូចនេះ ភាពខ្សត់ខ្សោយធនធានធម្មជាតិមិនអាចកត់បញ្ចូលទៅក្នុងគណនេយ្យជាតិបានឡើយ ។ ជាក់ស្តែងការធ្វើអាជីវកម្មលើធនធានធម្មជាតិមានឥទ្ធិពលយ៉ាងធំធេងទៅលើសន្ទស្សន៍សេដ្ឋកិច្ច ដូចជា ផលិតផលទុនក្នុងស្រុកសរុប ។ ប្រសិនបើសកម្មភាពសេដ្ឋកិច្ចទាក់ទងនឹងការធ្វើអាជីវកម្មទៅលើធនធានធម្មជាតិកើនឡើង នោះវាក៏បានធ្វើឱ្យផលិតផលទុនក្នុងស្រុកសរុបកើនឡើងដូចគ្នាដែរ ទោះបីជាការធ្វើអាជីវកម្មនេះនាំឱ្យធនធានធម្មជាតិក្លាយជាខ្សត់ខ្សោយ និងមិនមាននិរន្តរភាពយ៉ាងណាក៏ដោយ ។ ឧទាហរណ៍ ប្រទេសមួយអាចមើលឃើញថា ផលិតផលទុនក្នុងស្រុកសរុបកើនឡើង កាលណាគេធ្វើការកាប់

ព្រៃឈើទាំងអស់ ចាប់ត្រីទាំងអស់ ជីកធនធានរ៉ែឱ្យអស់ ច្រោះដី បំពុលធនធានទឹក ។ ប៉ុន្តែការបាត់បង់ខាងលើក្នុងរយៈពេលវែង និងផលប៉ះពាល់ជាអវិជ្ជមានទាំងនេះ ពុំបានឆ្លុះបញ្ចាំងនៅក្នុងគណនេយ្យចំណូលជាតិឡើយ ។

ជាប្រការគួរឱ្យស្តាយ ប្រទេសដែលមានប្រាក់ចំណូលទាបដូចកម្ពុជានេះ ជាប្រទេសផ្អែកជាសំខាន់លើធនធានធម្មជាតិដើម្បីរកចំណូល និងការផ្លាស់ប្តូររូបិយប័ណ្ណអន្តរជាតិ ហើយក៏ជាប្រទេសដែលអង្គការអន្តរជាតិនានា បានណែនាំឱ្យប្រើប្រាស់ប្រព័ន្ធសំរាប់គណនេយ្យជាតិ និងការវិភាគម៉ាក្រូសេដ្ឋកិច្ចដែលភាគច្រើនបំផុតមិនបានគិតគូរអំពីគោលការណ៍អត្ថប្រយោជន៍របស់ខ្លួនឡើយ ។ ដោយទទួលស្គាល់បញ្ហាទាំងនេះ និងដោយសារផ្តោតជាសំខាន់លើការអភិវឌ្ឍន៍ដោយនិរន្តរភាព កិច្ចប្រឹងប្រែង ជាច្រើនបាននិងកំពុងធ្វើឡើងនៅលើពិភពលោក តាំងពីដើមទសវត្សរ៍ទី៨0 ក្នុងគោលបំណងរួមបញ្ចូលគណនេយ្យធនធាន ធម្មជាតិទៅក្នុងគណនេយ្យជាតិ ។ ទោះជាការជជែកដេញដោលនៅមានបន្តអំពីវិធីសាស្ត្រនៃគណនេយ្យធនធានធម្មជាតិយ៉ាង មានប្រសិទ្ធិភាពបំផុតក៏ដោយ ក៏ប្រទេសជាច្រើននៅលើសកលលោកបានបង្កើត និងបញ្ចូលវិធីសាស្ត្រគណនេយ្យធនធានធម្មជាតិក្នុងប្រព័ន្ធគណនេយ្យជាតិរបស់ខ្លួនរួចហើយ ។

ទំនាក់ទំនងរវាងអត្រាលូតលាស់ផលិតផលទុនក្នុងស្រុកសរុបកម្ពុជា និងកំនើននៃការធ្វើអាជីវកម្មលើធនធានធម្មជាតិនាពេលថ្មីៗនេះ គួរតែធ្វើការត្រួតពិនិត្យពិច័យឱ្យកាន់តែហ្មត់ចត់ថែមទៀត ។ កំនើនផលិតផលទុនក្នុងស្រុកសរុបនាអតីតកាល អាចមិនមែនជាសន្ទស្សន៍ល្អសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាពឡើយ ។ ប៉ុន្តែប្រការកាន់តែសំខាន់នោះគឺ គួរតែធ្វើការកែតំរូវទៅក្នុងប្រព័ន្ធគណនេយ្យជាតិ ។ ដូចនេះ វាអាចឆ្លុះបញ្ចាំងកាន់តែប្រសើរពីភាពជាក់ស្តែងនៃការធ្វើអាជីវកម្មលើធនធានធម្មជាតិ ព្រមទាំងអត្ថប្រយោជន៍នៃការធ្វើអាជីវកម្មនេះនៅពេលអនាគត ។ ការកែសំរួលនេះអាចនឹងកែលំអសន្ទស្សន៍សំខាន់នៃសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើង ដែលជាមូលដ្ឋានក្នុងការពង្រឹងដល់គោលនយោបាយដឹកនាំប្រទេសស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

## ១.៤. រចនាសម្ព័ន្ធនៃឯកសារពិភាក្សា

ផ្នែកដែលនៅសេសសល់នៃឯកសារពិភាក្សានេះ គឺផ្តោតជាសំខាន់ ទៅលើសេវាធនធានធម្មជាតិដែលមានសារៈសំខាន់បំផុត ចំពោះជីវភាពប្រជាជនតាមជនបទគឺ កសិកម្ម (ជំពូកទី២) ជលផល (ជំពូកទី៣) និងព្រៃឈើ (ជំពូកទី៤) ។ ជំពូកនីមួយៗ បានវាយតំលៃទៅលើស្ថានភាពបច្ចុប្បន្ននៃធនធានធម្មជាតិ ការប្រមូលផលប្រចាំឆ្នាំនិងផលិតកម្ម អ្វីៗដែលទាក់ទងដល់ជីវភាពរបស់ប្រជាជនរស់នៅតាមជនបទ ប្រវត្តិនៃការគ្រប់គ្រង វិធីសាស្ត្រគ្រប់គ្រងនាពេលបច្ចុប្បន្ន និងការប្រឈមនានា ។ ផ្អែកទៅតាមការវាយតំលៃនេះ វិស័យសក្តានុពលភាពជាច្រើនដែលអាចធ្វើការស្រាវជ្រាវនាពេលអនាគត តាមបែបសេដ្ឋកិច្ចសង្គម ត្រូវបានលើកឡើងនៅចុងបញ្ចប់នៃជំពូកនៃនីមួយៗ ។ ជំពូកទី៥ ធ្វើការសន្និដ្ឋាន និងសង្ខេបអនុសាសន៍ទៅលើវិស័យដែលត្រូវធ្វើការស្រាវជ្រាវ ។

## ឯកសារយោង


Cambodia Development Resource Institute (2002), *"Main Economic Indicators,"* (Phnom Penh: CDRI, raw data provided by the Ministry of Economy and Finance)

National Institute of Statistics (2000), *Report on the Cambodia Socio-Economic Survey 1999,* (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *General Population Census of Cambodia,* (Phnom Penh: Ministry of Planning)

Ramamurthy, B., B. Sik, P. Ronnas, and H. Sok (2001), *Cambodia 1999-2000: Land, Labour and Rural Livelihood in Focus* (Phnom Penh: CDRI Working Paper No. 21)

# ជំពូកទី ២

# វិស័យកសិកម្ម

កសិកម្មដើរតួនាទីយ៉ាងសំខាន់ដល់ជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ ដោយបានចូលរួមចំណែកយ៉ាងធំធេងក្នុងការទ្រទ្រង់ជីវភាព និងបង្កើតជាប្រាក់ចំណូល ។ ផ្ទៃដីកសិកម្មភាគច្រើនបំផុតប្រមាណជា ៨៥% នៃផ្ទៃដីដាំដុះសរុបនៅក្នុងប្រទេសកម្ពុជា បាននិងកំពុងប្រើប្រាស់សំរាប់ការដាំដុះដំណាំស្រូវ ។ សកម្មភាពកសិកម្មខ្នាតតូចផ្សេងទៀត ក៏មានសារៈសំខាន់ចំពោះជីវភាពប្រជាជននៅតាមជនបទដែរ ដូចជាការចិញ្ចឹមសត្វ ដំណាំរួមផ្សំនានា និងឈើហូបផ្លែ ។

ជំពូកនេះ នឹងវាយតំលៃស្ថានភាពបច្ចុប្បន្ននៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា ដោយផ្តោតជាសំខាន់លើផលិតកម្មដំណាំស្រូវ ពីព្រោះវាបានដើរតួនាទីជាចំបងនៅក្នុងជីវភាពរបស់ប្រជាជននៅតាមជនបទ (និងដោយសារសំបូរទិន្នន័យដែលអាចរកបាន) និងធ្វើការពិភាក្សាយ៉ាងសង្ខេបអំពីសកម្មភាពកសិកម្មផ្សេងៗទៀត ។ ពត៌មាននៅក្នុងជំពូកនេះ គឺបានអធិប្បាយអំពីតំបន់កសិកម្មសំខាន់ៗ វិធីសាស្ត្រសំខាន់ក្នុងការដាំដំណាំស្រូវ ផលិតកម្មប្រចាំឆ្នាំ ការប្រៀបធៀបនឹងតំបន់ជិតខាង សម្បទានកសិកម្ម ព្រមទាំងឱកាស និងការប្រឈមនានាដែលទាក់ទងនឹងការបង្កើនផលិតផលកសិកម្ម ។ ចំនុចសក្តានុពលសំរាប់ធ្វើការស្រាវជ្រាវនាពេលអនាគតត្រូវបានលើកឡើងដោយផ្អែកតាមការវាយតំលៃនៃកង្វះខាត និងតំរូវការនៃការសិក្សាស្រាវជ្រាវ ។

## ២.១. តំបន់ដាំដុះកសិកម្មសំខាន់ៗ

ផ្អែកលើការអង្កេតតាមរយៈរូបថតពីលើអាកាសទាក់ទងនឹងប្រើប្រាស់ដីនាឆ្នាំ១៩៩៦-៩៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការប៉ាន់ស្មានឃើញថា ផ្ទៃដីប្រហែល ៦,៤លានហិកតានៅក្នុងប្រទេសកម្ពុជា គឺសមស្របសំរាប់វិស័យកសិកម្ម (ក្រសួងផែនការឆ្នាំ២០០១) ។ នៅក្នុងចំនោមផ្ទៃដីកសិកម្មសរុបទាំងអស់ គឺមានប្រមាណជា ២,៨លានហិកតា ត្រូវបានដាំដុះក្នុងឆ្នាំ២០០០-០១ ។ ស្រូវត្រូវបានដាំដុះនៅលើផ្ទៃដី ប្រមាណជា ២,៣លានហិកតា ចំណែកឯដំណាំស្បៀងផ្សេងៗ ដំណាំឈើហូបផ្លែ និងដំណាំឧស្សាហកម្មត្រូវបានដាំដុះនៅលើផ្ទៃដីប្រមាណជា ៤៣៨.០០០ហិកតា (តារាង ២.១) ។

ស្រូវវស្សាគ្របដណ្តប់ភាគច្រើនទៅលើផ្ទៃដីកសិកម្មប្រទេសកម្ពុជា ហើយនាឆ្នាំ២០០០-០១ តំបន់ដាំដុះរបស់វាមានរហូតដល់ ២,០៦លានហិកតា បើធៀបនឹងស្រូវប្រាំងមានប្រមាណតែ ០,២៦លានហិកតាប៉ុណ្ណោះ ។ ស្រូវវស្សាត្រូវបានដាំដុះនៅគ្រប់ខេត្តទាំងអស់ ប៉ុន្តែភាគច្រើនបំផុតគឺ ត្រូវបានគេដាំនាតំបន់ជុំវិញបឹងទន្លេសាប និងបឹងធំ ទន្លេមេគង្គ និងទន្លេបាសាក់ (ផែនទី២.១) ។ ស្រូវប្រាំងត្រូវបានគេដាំនៅតំបន់ទំនាបលិចទឹកនៃទន្លេមេគង្គដែលនៅទីនោះ កសិករអាចគ្រប់គ្រងដោយទាញយកទឹកជំនន់ដែលកំពុងស្រកយកមកស្រោចស្រព ។ នៅក្នុងឆ្នាំ២០០០-០១ មានខេត្តចំនួនបួន ដូចជាខេត្តព្រៃវែង កណ្តាល តាកែវ និងកំពង់ចាម បានដាំដុះស្រូវប្រាំង គឺជិត ៨០% នៃផ្ទៃដីដាំដុះស្រូវប្រាំងសរុបក្នុងប្រទេសកម្ពុជា ។

**តារាង ២.១. តំបន់កសិកម្មនាឆ្នាំ១៩៨០-២០០១**

| ឆ្នាំ[១] | ដំណាំស្រូវ (ពាន់ហិកតា) | ដំណាំស្បៀងផ្សេងៗ[២] (ពាន់ហិកតា) | ដំណាំឧស្សាហកម្ម[៣] (ពាន់ហិកតា) | ដំណាំឈើហូបផ្លែ និង អចិន្ត្រៃយ៍ (ពាន់ហិកតា) | សរុប (ពាន់ហិកតា) |
|---|---|---|---|---|---|
| 1980-81 | 1,441 | 178 | 32 | N/A[5] | 1,651 |
| 1990-91 | 1,890 | 152 | 108 | N/A | 2,150 |
| 1995-96 | 2,086 | 143 | 102 | N/A | 2,331 |
| 1996-97 | 2,153 | 148 | 120 | N/A | 2,422 |
| 1997-98 | 2,076 | 133 | 128 | N/A | 2,337 |
| 1998-99 | 2,095 | 126 | 118 | N/A | 2,339 |
| 1999-00 | 2,158 | 142 | 116 | N/A | 2,415 |
| 2000-01 | 2,318 | 154 | 120 | 164 | 2,757 |

*[១] ដំណាំក្នុងមួយឆ្នាំ ត្រូវបានកំណត់ចាប់ពីថ្ងៃទីមួយ ខែមីនា រហូតដល់ចុងខែកុម្ភៈ ។*
*[២] ដំណាំស្បៀងផ្សេងៗនៅក្នុងឆ្នាំ២០០០-០១ រួមមាន ពោត បន្លែ សណ្តែកបាយ ដំឡូងមី និងដំឡូងជ្វា ។*
*[៣] ដំណាំឧស្សាហកម្មឆ្នាំ២០០០-០១ រួមមាន សណ្តែកសៀង ល្ង សណ្តែកដី អំពៅ ថ្នាំជក់ ក្រចៅ និងកៅស៊ូ ។*
*[៤] ដំណាំហូបផ្លែនៅឆ្នាំ២០០០-០១ មាន ចេក ស្វាយចន្ទី ដូង មៀន ស្វាយ ទឹកដោះគោ ល្មុត ធូរេន ខ្នុរ ទៀប ក្រូច កាហ្វេ សាវម៉ាវ ត្របែក ម្នាស់ និងម្រេច ។*
*ប្រភព: វិទ្យាស្ថានស្ថិតិជាតិ (២០០១) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០០១)*

ដំណាំស្បៀងរួមផ្សំនានា និងដំណាំឈើហូបផ្លែដូចជា ពោត បន្លែ ចេក ខ្នុរ និងស្វាយ គឺត្រូវបានដាំក្នុងទ្រង់ទ្រាយតូច នៅតាមតំបន់ដែលដីមានជីជាតិ ដងទន្លេដែលអាចយកទឹកមកស្រោចស្រពបានព្រមទាំងនៅជិតទីផ្សារ ។ ឧទាហរណ៍ ប្រមាណ ៧០% នៃផ្ទៃដីដំណាំពោត គឺស្ថិតនៅក្នុងខេត្តដែលមានដង់ស៊ីតេប្រជាជនខ្ពស់ ដូចជា ខេត្តកណ្តាល បាត់ដំបង និងកំពង់ចាម ។ ដូចគ្នានេះដែរ នៅក្នុងខេត្តកណ្តាលផ្ទៃដីកសិកម្មច្រើនជាង ៦០% ត្រូវបានគេដាំដំណាំឈើហូបផ្លែ ។ បន្ថែមពីលើការដាំដុះដំណាំសំរាប់ធ្វើពាណិជ្ជកម្ម គឺដំណាំស្បៀង និងឈើហូបផ្លែត្រូវបានគេដាំនៅតាមសួនជុំវិញផ្ទះ និងតំបន់ទីខ្ពស់ដែលអាចគេចផុតពីការជាំទឹក ព្រមទាំងដាំជាដំណាំចំរុះ (ដំណាំ ចំការ) នៅតាមតំបន់ខ្ពង់រាប (Shams 1997) ។

នាពីរទសវត្សរ៍កន្លងមកនេះ ស្ថិតិរដ្ឋាភិបាលបានបញ្ជាក់ថា តំបន់ផលិតកម្មដំណាំស្រូវបានកើនឡើងជាង ៦០% ចំណែកឯតំបន់ដាំដុះដំណាំដទៃទៀតពុំមានការកើនឡើង គឺនៅដដែល ។ ក្នុងរយៈពេលនេះ តំបន់ដាំដុះដំណាំស្រូវជាមធ្យមកើនឡើងប្រមាណជា ៤៤.០០០ហិកតាក្នុងមួយឆ្នាំ គឺស្មើនឹងកំណើនអត្រាប្រជាជនប្រមាណជា ២-៣% ក្នុងមួយឆ្នាំ ។ ទោះជាអត្រាផ្ទៃដីដាំដុះដំណាំស្រូវ (២,៣លានហិកតា) មានការកើនឡើងយ៉ាងណាក៏ដោយ ប៉ុន្តែនៅតែតិចជាងផ្ទៃដីដែលបានធ្វើការដាំដុះដំណាំស្រូវនៅក្នុងកំលុងឆ្នាំ១៩៦៦-៦៧ (២,៩លានហិកតា) ដែលជាពេលមុនកើតមានសង្គ្រាមស៊ីវិល (Javier 1997, NIS 2001) ។

## ២.២. "ប្រព័ន្ធបរិស្ថាន" ដំណាំស្រូវ និងវិធីសាស្ត្រដាំដុះ

វិធីសាស្ត្រដាំដុះដំណាំស្រូវនៅកម្ពុជាមានការវិវត្តន៍ពឹងផ្អែកលើរបាយទឹកភ្លៀង ទឹកជំនន់ ទឹកសំរក ឋានលេខា និងកំពស់ស្រែ ព្រមទាំងជីជាតិដី ។ ភាពខុសប្លែកគ្នានៃកត្តាបរិស្ថានទាំងនេះមានឥទ្ធិពលទៅលើការជ្រើសរើសនៃពូជស្រូវ និងវិធីសាស្ត្រដាំដុះដែលភាគច្រើនបំផុតនាំទៅរកផលិតភាពខ្ពស់ និងធានាបាននូវទិន្នផល ។ វិធីសាស្ត្រដាំដុះដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា (និងប្រទេសនានានៅក្នុងតំបន់ត្រូពិច) ត្រូវបានបែងចែកទៅតាមរដូវប្រាំង និងរដូវវស្សា ។ ស្រូវរដូវវស្សារួមមាន ស្រូវទំនាប ស្រូវឡើងទឹក និងស្រូវភ្នំ (ស្រូវចំការ) ដោយពឹងផ្អែកទៅលើរបបទឹកភ្លៀង ចាប់ពីខែឧសភា ដល់ខែវិច្ឆិកា ។ បន្ថែមពីលើរបបទឹកភ្លៀង តំបន់ដាំដុះស្រូវទំនាប និងស្រូវឡើងទឹកខ្លះទៀត បានទទួលផលប្រយោជន៍ពីទឹកជំនន់រដូវវស្សាដែលហូរនាំយកមកជាមួយនូវដីល្បាប់សំបូរជីជាតិ មកចាក់គរលើវាលស្រែ ។ ស្រូវប្រាំងពឹងផ្អែកយ៉ាងសំខាន់ទៅលើការគ្រប់គ្រងទឹកជំនន់ដែលស្រកចុះ គឺចាប់ពីខែវិច្ឆិកា (នៅពេលដែលរដូវភ្លៀងបានបញ្ចប់) ដល់ខែកុម្ភៈ ។ តារាង២.២ បានធ្វើការសង្ខេបទិន្នន័យទាក់ទងនឹងការដាំដុះស្រូវប្រាំង និងស្រូវវស្សាក្នុងកំលុង ឆ្នាំ១៩៦៦ ដល់ឆ្នាំ២០០១ ។

## ផែនទី២.១. ការគ្រប់គ្រងដីរបស់ប្រទេសកម្ពុជាពីឆ្នាំ១៩៩៧_៩៨

**តារាង២.២. តំបន់ដាំដុះសំខាន់នៃប្រព័ន្ធកសិកម្មដំណាំស្រូវពីឆ្នាំ១៩៦៦ -២០០១**

| ឆ្នាំ[១] | ស្រូវវស្សា | | | | ស្រូវប្រាំង | សរុប |
|---|---|---|---|---|---|---|
| | ស្រូវទំនាប (ពាន់ហិកតា) | ស្រូវឡើងទឹក (ពាន់ហិកតា) | ស្រូវភ្នំ ឬស្រូវចំការ (ពាន់ហិកតា) | *សរុបរង (ពាន់ហិកតា)* | (ពាន់ហិកតា) | (ពាន់ហិកតា) |
| 1966-67 | 1,951 | 400 | គ្មានតួរលេខ | 2,351 | 181 | 2,532 |
| 1980-81 | 1,249 | 97 | គ្មានតួរលេខ | 1,346 | 95 | 1,441 |
| 1994-95 | 1,747 | 84 | 38 | 1,869 | 169 | 2,038 |
| 2000-01 | 1,927 | 80 | 52 | 2,058 | 260 | 2,318 |

[១] *ដំណាំក្នុងមួយឆ្នាំ ត្រូវបានកំណត់ចាប់ពីថ្ងៃទីមួយ ខែមីនា រហូតដល់ចុងខែកុម្ភៈ ។*

*ប្រភព: Javier 1997 និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០០១)*

## *២.២.១.ស្រូវទំនាបពឹងលើទឹកភ្លៀង (ស្រូវវស្សា)*

ស្រូវទំនាបពឹងលើទឹកភ្លៀងគ្របដណ្តប់ប្រហែល ៨៣% នៃផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសនៅក្នុងឆ្នាំ២០០០-០១ ។ "ពឹងលើទឹកភ្លៀង" បានន័យថា ការពឹងផ្អែករបស់ដំណាំស្រូវទៅលើរបបទឹកភ្លៀងដែលជាប្រភពទឹកសំខាន់ជាជាងការពឹងផ្អែកលើប្រព័ន្ធស្រោចស្រព ។ ប៉ុន្តែស្រូវទំនាបពឹងលើទឹកភ្លៀងមួយចំនួនតូច ក៏ពឹងផ្អែកទៅលើការស្រោចស្រពបន្ថែមតាមរយៈហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងនៃទឹកជំនន់តាមរដូវកាល (សូមអានផ្នែក២.៣ អំពីការស្រោចស្រពនៃតំបន់ដាំដុះស្រូវ) ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី២.២ ខាងលើឃើញថា នាឆ្នាំ១៩៦៦-៦៧ ផ្ទៃដីប្រហែល ១,៩លានហិកតា ត្រូវបានដាំដុះស្រូវទំនាបពឹងលើទឹកភ្លៀង ប៉ុន្តែនៅកំលុងទសវត្សរ៍ទី៧០ ជាពិសេសនាឆ្នាំ១៩៨០-៨១ ផ្ទៃដីដាំស្រូវមានតែ ១,២៥លានហិកតាប៉ុណ្ណោះ ។ តំបន់ដាំដុះមានការកើនឡើងគួរឱ្យចាប់អារម្មណ៍ ពិសេសនៅឆ្នាំ២០០០-០១ ដែលផ្ទៃដីសរុបមានរហូតដល់ ១,៩លានហិកតា ។

ជាទូទៅ ពូជសំរាប់ដាំដុះស្រូវទំនាបពឹងលើទឹកភ្លៀងត្រូវបានបែងចែកជា ៣ពូជ: ពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ ។ កសិករធ្វើការជ្រើសរើសពូជស្រូវសំរាប់ដាំដុះនៅលើស្រែរបស់គាត់ គឺផ្អែកសំខាន់លក្ខណៈឋានលេខា និងកំរិតកំពស់ដីស្រែរបស់គាត់ ប្រភេទដី និងកំរិតទឹកដែលដក់ក្នុងស្រែ ។ តារាងទី២.៣ ខាងក្រោមនេះបានបង្ហាញអំពីលក្ខណៈដែលកសិករបានបែងចែកដីស្រែរបស់គាត់ចេញជា ៣ចំណែក គឺស្រែលើ ស្រែកណ្តាល និងស្រែក្រោម ។ ស្រែលើ គឺមានលក្ខណៈជាប្រភេទដីខ្សាច់ដែលមានល្បាប់តិចតួច និងមិនសូវដក់ទឹក ។ ដូចនេះកសិករបានជ្រើសរើសពូជស្រូវស្រាល ដែលស៊ាំនឹងភាពរាំងស្ងួតយកមកធ្វើការដាំដុះ ហើយគោលបំណងដាំដុះនេះ គឺភាគច្រើនសំរាប់ទុកបរិភោគ ។ ស្រែកណ្តាលមានទឹកដក់ និងដីល្បាប់ជាមធ្យមដែលបង្ក ការទ្រទ្រង់ដល់ការដាំដុះប្រភេទពូជស្រូវដែលមានគុណភាពល្អវិសេសសំរាប់បរិភោគ និងសំរាប់លក់ដូរ ។ ចំណែកឯស្រែក្រោម កសិករដាំពូជស្រូវធ្ងន់ដែលជាពូជស៊ាំនឹងជំរៅទឹកជ្រៅព្រមទាំងគ្រាប់ស្រូវធ្ងន់ល្អ និងមានគុណភាពប្រសើរសំរាប់ការបរិភោគ ។

**តារាង ២.៣. ទំនាក់ទំនងរវាង ឋានលេខា កំរិតទឹក និងការជ្រើសរើសពូជស្រូវវស្សា នៅតំបន់ទំនាប**

| ឋានលេខា | កំរិតកំពស់ទឹក | ពូជស្រូវ |
|---|---|---|
| ស្រែលើ | ទាប (<20 cm) | ស្រាល (ប្រមូលផលចុងខែវិច្ឆិការ ដល់ដើមខែធ្នូ) |
| ស្រែកណ្តាល | មធ្យម (10 ទៅ 40 cm) | កណ្តាល (ប្រមូលផលពាក់កណ្តាលទៅចុងខែធ្នូ) |
| ស្រែក្រោម | ខ្ពស់ (30 ទៅ >50 cm) | ធ្ងន់ (ប្រមូលផលចុងខែធ្នូ ដល់ពាក់កណ្តាលខែមករា) |

*ប្រភព: Fujisaka 1988, Lando និង Mak 1994a, Nesbitt និង Chan 1997*

ដោយបែងចែកដីស្រែចេញជាប្រភេទផ្សេងៗគ្នា ហើយដាំដុះស្រូវដែលទុំនៅពេលខុសគ្នា ដូចនេះ កសិករអាចកាត់បន្ថយបាននូវភាពប្រថុយប្រថានរបស់ខ្លួន ទាក់ទងនឹងការខូចខាតផលទាំងស្រុងដោយសារទឹកជំនន់ និងភាពរាំងស្ងួត និងប្រើប្រាស់ធនធានកំលាំងពលកម្មបានប្រសើរបំផុត ព្រមទាំងចូលរួមបង្កើនសន្តិសុខស្បៀងឱ្យមានភាពប្រសើរឡើង ។ ការពិត រយៈពេល

ដាំដុះកាន់តែខ្លី ភាពប្រថុយប្រថានកាន់តែមានកំរិតទាប ដែលទាក់ទងនឹងបរាជ័យក្នុងការប្រមូលផលស្រូវ ។ ជាមួយនឹងគំនិតនេះ កសិករបច្ចុប្បន្នដាំពូជស្រូវណាដែលមានរយៈពេលខ្លីក្នុងការប្រមូលផលនៅក្នុងតំបន់ដែលពីមុនកន្លងមកធ្លាប់តែដាំពូជស្រូវធ្ងន់ ។ ក្នុងការដាំដុះស្រូវទំនាបពឹងលើទឹកភ្លៀងនាឆ្នាំ១៩៦៦-៦៧ ក្នុងនោះពូជស្រូវស្រាល និងស្រូវធ្ងន់គ្របដណ្តប់ប្រមាណជា ២០% (ឬប្រមាណជា ០,៥លានហិកតា) បើធៀបនឹងឆ្នាំ២០០០-០១ ប្រភេទពូជទាំងពីរនេះត្រូវបានគេធ្វើការដាំដុះរហូតដល់ ៦៦% (ឬប្រមាណ ជា ១,៣លានហិកតា) ។

### *២.២.២. ស្រូវឡើងទឹក*

នាឆ្នាំ២០០០-០១ ស្រូវឡើងទឹកត្រូវបានគេធ្វើការដាំដុះនៅលើផ្ទៃដីតែជាង ៣% ប៉ុណ្ណោះ ។ វាគឺជាប្រភេទពូជស្រូវដែលដើមវាធុននឹងទឹកបានរយៈពេលយ៉ាងហោចណាស់ ១ខែ ហើយជំរៅទឹកនេះជ្រៅជាង ៥០ស.ម ឬពេលខ្លះរហូតដល់ ៣ម៉ែត្រ (Javier 1997, Pillot *et al.* 2000) ។ ស្រូវឡើងទឹកត្រូវបានគេដាំនៅតំបន់ដែលទាប និងហាប់ដែលមានទឹកជំនន់គ្របដណ្តប់ជាប្រចាំ ជាពិសេសតំបន់នៅជុំវិញបឹងទន្លេសាប តំបន់ដីសណ្តទន្លេមេគង្គ និងទន្លេបាសាក់ ។ ដោយហេតុថាជំរៅទឹកជ្រៅ នោះការប្រើប្រាស់ធនធានផលិតកម្ម ដូចជាជីគីមី និងថ្នាំពុលគីមី មិនសូវជានិយមឡើយ (Lando and Mak 1994b) ។

ដូចនេះ នាកំលុងឆ្នាំ១៩៦៦-៦៧ ស្រូវឡើងទឹកគ្របដណ្តប់តែនៅលើផ្ទៃដីដាំដុះប្រមាណ ៤០០.០០០ហិកតា ហើយមកដល់ឆ្នាំ២០០០-០១ មានតែ ៨០.០០០ហិកតាប៉ុណ្ណោះ ។ និន្នាការនៃការធ្លាក់ចុះនូវផ្ទៃដីដាំដុះសំរាប់ស្រូវឡើងទឹក គឺត្រូវមើលត្រលប់មកគោលនយោបាយខ្មែរក្រហម និងសង្គ្រាមស៊ីវិលនាកំលុងទសវត្សរ៍ទី៧០ ។ នៅក្នុងកំលុងសង្គ្រាមស៊ីវិល កសិករបញ្ឈប់ការដាំដុះដំណាំស្រូវដែលនៅឆ្ងាយពីផ្ទះរបស់ពួកគេ ជាពិសេសគឺស្រូវឡើងទឹក ។ បន្ថែមពីលើនេះ គោលនយោបាយខ្មែរក្រហមមានបំណងបង្កើនទិន្នផលស្រូវតាមរយៈធ្វើប្រព័ន្ធស្រោចស្រព ហើយមិនបានលើកទឹកចិត្តក្នុងការដាំដុះស្រូវឡើងទឹកឡើយ ដោយសារវាមានទិន្នផលទាប ។ ដោយគ្មានការសំរបសំរួលក្នុងរយៈពេលយូរអង្វែង ជាពិសេសការស្តុក និងថែរក្សាពូជស្រូវឡើងទឹក នោះពូជនានាដែលមានភាពស៊ាំល្អ ត្រូវបានបាត់បង់ពីព្រោះគ្មានការដាំដុះប្រចាំឆ្នាំ (Javier 1997) ។ ជាងនេះទៀតអាចមកពីកសិករបោះបង់ការដាំដុះស្រូវឡើងទឹក ដោយសារវាមានភាពប្រថុយប្រថានខ្ពស់ពេក ជាពិសេសទិន្នផលអាចមានការខូចខាតទាំងស្រុង ដោយសារសក្តានុភាពភាពនៃបញ្ហាគ្រប់គ្រងទឹកដោយរួមបញ្ចូលកំរិតទឹកដែលឡើង ជំរៅអតិបរមារបស់ទឹករយៈពេលនៃជំរៅទឹកអតិបរិមា រយៈពេលទឹកស្រក និងកំរិតទឹកដែលស្រកចុះ ។

### *២.២.៣. ស្រូវភ្នំ ឬស្រូវចំការ*

ស្រូវភ្នំនាឆ្នាំ២០០០-០១ គ្របដណ្តប់លើផ្ទៃដីប្រហែលជា ២% នៃដីសំរាប់ដំណាំស្រូវសរុប ។ ស្រូវភ្នំ ត្រូវបានគេដាំដុះតាមចង្កេះភ្នំ និងតំបន់ភ្នំនាប្រទេសកម្ពុជា ដែលមានកំរិតកំពស់ចាប់ពី ២០០ ទៅ ១.០០០ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ ។ ដោយសារវាពឹង ផ្អែកទៅលើទឹកភ្លៀង នោះស្រូវភ្នំត្រូវបានគេដាំដុះក្នុងកំលុងរដូវវស្សា ហើយជាពិសេសការប្រមូលផលត្រូវបានធ្វើឡើងនៅពេលចប់រដូវភ្លៀង សូម្បីតែមានការខុសគ្នាទាក់ទងនឹងពូជ និងលក្ខខ័ណ្ឌផ្សេងៗក៏ដោយ ។ ដីស្រែសំរាប់ស្រូវភ្នំត្រូវបានគេដាំលាយចំរុះជាមួយនឹងដំណាំដទៃទៀត (ដំណាំចំការ) ដូចជា ពោត ដំឡូងជ្វា ដំឡូងឈើ ត្រឡាច ននោង និងបន្លែផ្សេងៗ ។ ដំណាំចំរុះជាទូទៅត្រូវបានគេអនុវត្តដាំដុះនៅតំបន់ខ្ពស់ៗ និងតំបន់ព្រៃឈើក្នុងខេត្តមណ្ឌលគិរី និងរតនគិរី ដែលនៅទីនោះ វាបានបញ្ជាក់ពីវិស័យកសិកម្មជាការងារចំបងរបស់ជនជាតិភាគតិចនានា ។

ប្រព័ន្ធបរិស្ថានស្រូវភ្នំ និងបច្ចេកទេសដាំដុះរបស់វា មានលក្ខណៈប្រែប្រួលគួរឱ្យកត់សំគាល់ ដោយផ្អែកទៅលើកត្តាបរិស្ថានដូចជាៈ កំរិតកំពស់ដី ទឹកភ្លៀង ប្រភេទដី និងការអនុវត្តន៍ដាំដុះ ។ ទោះជាលក្ខណៈចំរុះនេះ ពុំមានរូបភាពច្បាស់លាស់យ៉ាងណាក៏ដោយ ប៉ុន្តែជាទូទៅស្រូវភ្នំត្រូវបានគេបែងចែកជាពីរក្រុមខុសគ្នាៈ ការដាំដុះអចិន្ត្រៃយ៍ និងការដាំដុះបែបពនេចរ ។ ការដាំដុះបែបពនេចរត្រូវបានគេសង្កេតឃើញថា មានការនិយមអនុវត្តច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ដែលរួមមានការកាប់

ឆ្ការ និងដុតព្រៃ សំរាប់ដាំដុះស្រូវ និងដំណាំផ្សេងៗទៀត ហើយការអនុវត្តន៍ដាំដុះនេះ ធ្វើឡើងនៅលើដីដែលកាប់ឆ្ការតែក្នុងរយៈពេល ២ ទៅ ៥ឆ្នាំប៉ុណ្ណោះ មុននឹងគេធ្វើការផ្លាស់ប្តូរទៅកន្លែងផ្សេងទៀត (Javier 1997) ។ ក្នុងករណីភាគច្រើនកសិករធ្វើការកាប់ឆ្ការដីដែលគេបានដាំដុះពីមុន ប៉ុន្តែ ដីនេះត្រូវបានទុកចោលទំនេរជាច្រើនឆ្នាំកន្លងមកហើយ ។ ដូច្នេះ ព្រៃដែលកាប់ឆ្ការសំរាប់កសិកម្មពនេចរ ជាធម្មតា គឺជាព្រៃបន្ទាប់បន្សំដែលដុះឡើងវិញម្តងទៀត ប៉ុន្តែមិនមែនជាព្រៃសំខាន់ឡើយ ។ ការដាំដំណាំស្រូវភ្នំជាអចិន្ត្រៃយ៍ គឺជាការដាំស្រូវនៅទីកន្លែងដដែលជាច្រើនឆ្នាំ ពិសេសគឺដីស្រែដែលមានទំហំតូចៗនៅជិតផ្ទះកសិករ ។ វិធីសាស្ត្រដាំដុះនេះ ច្រើនតែអនុវត្តដោយជនជាតិខ្មែរជាជាងជនជាតិភាគតិច ។

### *២.២.៤. ស្រូវប្រាំង*

នាឆ្នាំ២000-0១ ការដាំដុះស្រូវប្រាំងគ្របដណ្តប់ប្រហែល ១១% នៃផ្ទៃដីដំណាំស្រូវសរុប ។ ដូចដែលបានអធិប្បាយពីខាងលើរួចមកហើយ គឺថាស្រូវប្រាំងត្រូវបានគេដាំនៅតាមតំបន់ទំនាបលិចទឹកទន្លេមេគង្គ ដែលនៅទីនោះកសិករអាចគ្រប់គ្រងទឹកជំនន់ដែលស្រក និងធ្វើការស្រោចស្រពបន្ថែមខ្លះៗដល់ដំណាំរបស់គេនៅពេលណាមានការចាំបាច់ ។ តំបន់សំរកទឹកជំនន់ស្ថិតនៅជុំវិញបឹងទន្លេ ឬនៅពីខាងក្រោមទំនប់ទឹក ជាទូទៅមិនមែនជាតំបន់សមស្របសំរាប់ធ្វើស្រូវវស្សាឡើយ ដោយសារនៅទីនោះទឹកជ្រៅពេក ។ ទឹកជំនន់ ភាគច្រើនចាប់ស្រកនៅចន្លោះចុងខែតុលា និងចុងខែធ្នូ ដែលបន្ទាប់ពីពេលនោះមក ទឹកចាប់ផ្តើមមានជំរៅរាក់ ហើយស្រកយ៉ាងយឺត ។ ទាក់ទងនឹងរយៈពេលខ្លីនៃពេលទឹកសំរកនេះកសិករភាគច្រើនដែលដាំដុះស្រូវប្រាំង គឺពួកគេជ្រើសយកពូជស្រូវស្រាលដែលអាចធ្វើការប្រមូលផលនៅក្នុងខែមករា ឬខែកុម្ភៈ (Pillot *et al.* 2000) ។

ស្រូវប្រាំងមានទិន្នផលខ្ពស់ជាងស្រូវរដូវវស្សា ដោយសារគេអាចធ្វើការគ្រប់គ្រងទឹកបានប្រសើរជាង ពន្លឺថ្ងៃបានទទួលច្រើនជាងនាពេលដំណាក់កាលដំណាំលូតលាស់ និងពូជស្រូវទំនើបឆ្លើយតបទៅនឹងការប្រើប្រាស់ជី ។ បន្ថែមពីលើនេះ ការគ្រប់គ្រងទឹកកាន់តែល្អធ្វើឱ្យមានការកាត់បន្ថយការខូចខាតផលិតកម្មស្រូវ ដូចនេះ វាបានជួយលើកទឹកចិត្តដល់កសិករនៅក្នុងការវិនិយោគរបស់ខ្លួន ជាពិសេសការប្រើប្រាស់ជី (Javier 1997) ។ ទិន្នផលខ្ពស់នៃស្រូវប្រាំងបានជួយជំរុញទៅដល់ការពង្រីកតំបន់ផ្ទៃដីដាំដុះ គឺចាប់ពី ៩៥.000ហិកតា នៅឆ្នាំ១៩៨0-៨១ ឡើងរហូតដល់ ២៦0.000ហិកតានៅក្នុងឆ្នាំ២000-0១ ។

## ២.៣. ការស្រោចស្រពលើផ្ទៃដីដាំស្រូវ

នាឆ្នាំ១៩៩៧-១៩៩៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានប៉ាន់ប្រមាណឃើញថា ផ្ទៃដីប្រហែល ៤៧៣.000ហិកតា (២៣%) នៃផ្ទៃដីដាំដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា ត្រូវបានដាំស្រូវដោយការស្រោចស្រពដែលក្នុងនោះ ផ្ទៃដី ២២៤.000ហិកតា (១១%) គឺស្រូវដែលទទួលការស្រោចស្រពពីរដូវវស្សា និង ២២៤.000ហិកតា (១១%) គឺស្រូវប្រាំងដែលទទួលការស្រោចស្រពបន្ថែម ចំណែកឯផ្ទៃដីត្រឹមតែ ២៥.000ហិកតា (១%) ប៉ុណ្ណោះដែលទទួលការស្រោចស្រពទាំងស្រុង (ក្រសួងផែនការឆ្នាំ២00១) (តារាងទី២.៤)[៥] ។ បើប្រៀបធៀបនឹងតំបន់ដាំដុះស្រូវដោយការស្រោចស្រពលើផ្ទៃដី

---

[៥] ប្រការសំខាន់គួរកត់សំគាល់ថា ឯកសារដទៃទៀតជាច្រើនបានវាយតំលៃថា ផ្ទៃដីដាំដុះនៅក្នុងប្រទេសកម្ពុជា មានតែ ១0-១៥% ប៉ុណ្ណោះ (ឬ ២៥0.000ហិកតា) ដែលធ្វើការស្រោចស្រព (ក្រសួងពាណិជ្ជកម្មឆ្នាំ២00១ Urwin និង Wrigley ២00១) ។ មូលហេតុដែលមានភាពខុសគ្នា រវាងការប៉ាន់ស្មានថ្មីៗនេះរបស់ MAFF ជាមួយនឹងការប៉ាន់ស្មានមកពីឯកសារដទៃទៀត គឺពុំច្បាស់លាស់តេ ។ គេអាចនិយាយបានដែរថា ស្ថិតិរបស់ MAFF បានឆ្លុះបញ្ចាំងពីការដាំដុះដំណាំទ្វេដង មានអត្រាខ្ពស់នៅតំបន់ដែលមានការស្រោចស្រពបន្ថែមនៅរដូវវស្សា និងការស្រោចស្រពស្រូវប្រដេញទឹក (ការប៉ាន់ស្មានទាំងពីរនេះមាន ២២៤.000ហិកតា) ។ ប៉ុន្តែ វាហាក់ដូចជាពុំមានលទ្ធភាពដាំដុះដំណាំនៅក្នុងតំបន់ដាំដុះស្រូវប្រដេញទឹកក្នុងកំលុងរដូវវស្សាឡើយ ដោយសារកំពស់កំរិតទឹកខ្ពស់ ។ ប្រសិនបើមានការដាំដុះទ្វេដងកើតមានឡើងមែន នោះ MAFF អាចគណនាត្រឹមត្រូវនៅក្នុងតំបន់ទាំងពីរនេះបាន ។ ការប៉ាន់ស្មានរបស់ MAFF គឺពុំមានលទ្ធផលបញ្ជាក់ច្បាស់លាស់ស្តីពីភាពខុសគ្នានៃការប៉ាន់ស្មានពីប្រភពផ្សេងគ្នាទាំងនេះ ។ ការស្រាវជ្រាវនេះ អធិប្បាយអំពីតំបន់ស្រោចស្រពដោយអនុលោមតាមស្ថិតិថ្មីបំផុតរបស់ MAFF ។

ប្រមាណជា ២៧៦.០០០ហិកតានៅឆ្នាំ១៩៩៣-៩៤ វាបង្ហាញកំណើនប្រហែល ២០០.០០០ហិកតា ។ ការស្រោចស្រពនៅរដូវប្រាំងតាមរយៈការបង្ហៀរ ហាក់ដូចជាមានការកើនឡើងច្រើន ចំណែកឯការស្រោចស្រពបន្ថែមនៅរដូវវស្សាវិញ គឺមានកំណើនយ៉ាងយឺតយ៉ាវ ។ ចំពោះដំណាំស្រូវនាឆ្នាំ១៩៩៣-៩៤ ការដាំដុះបានទ្វេដង (បានសេចក្តីថាក្នុងមួយឆ្នាំដាំស្រូវបានពីរដងលើផ្ទៃដីដដែល) គ្របដណ្តប់ទៅលើផ្ទៃដីតែ ២០.០០០ហិកតាប៉ុណ្ណោះ ហើយទិន្នន័យនាពេលបច្ចុប្បន្នស្តីពីការដាំដុះទ្វេដងនេះ ពុំមានឃើញកត់ត្រាឡើយ ។

នៅកំលុងរដូវវស្សា ការស្រោចស្រពបន្ថែមអាចជួយបង្កើនទិន្នផលស្រូវ ហើយការងារនេះធ្វើឱ្យកសិករមានការពឹងផ្អែកតិចតួចទៅលើសក្តានុពលភាពនៃភាពមិនទៀងទាត់របស់ទឹកភ្លៀង ។ នៅក្នុងកំលុងរដូវប្រាំង ការស្រោចស្រពបំពេញបន្ថែមបានផ្តល់សារៈប្រយោជន៍ដល់កសិករ ហើយបានអនុញ្ញាតឱ្យពួកគាត់បង្កើនទិន្នផលបានតាមរយៈការគ្រប់គ្រងបាននូវកំរិតទឹក ។ តំបន់ដាំដុះស្រូវដែលធ្វើការស្រោចស្រពទាំងស្រុង គឺមានដោយកំរនៅក្នុងប្រទេសកម្ពុជា ហើយធនាគារអភិវឌ្ឍន៍អាស៊ីបានឱ្យយោបល់ថា សក្តានុពលភាពសំរាប់បង្កើនតំបន់ស្រោចស្រពទាំងស្រុង ដោយប្រើប្រាស់ម៉ាស៊ីនបូម ឬប្រព័ន្ធបង្ហៀរ គឺមានកំរិតកំណត់នៅឡើយ (Nesbitt 1997) ។

**តារាង២.៤. ការដាំដុះដំណាំស្រូវពឹងផ្អែកទៅលើការស្រោចស្រព ឆ្នាំ១៩៩៣-៩៤ និងឆ្នាំ១៩៩៧-៩៨**

| ការស្រោចស្រពដំណាំស្រូវ | តំបន់ស្រោចស្រពដំណាំស្រូវ (ហិកតា) ឆ្នាំ១៩៩៣-៩៤[១] | តំបន់ស្រោចស្រពដំណាំស្រូវ (ហិកតា) ឆ្នាំ១៩៩៧-៩៨[២] | ប្រភេទនៃការស្រោចស្រព/វិធីសាស្ត្រ ឆ្នាំ១៩៩៧-៩៨ |
|---|---|---|---|
| ការស្រោចស្រពបន្ថែមទៅលើស្រូវវស្សា | 172,727 | 224,200 | ការបង្ហៀរ (~90 %)<br>ការបូម (~10%) |
| ការស្រោចស្រពទាំងស្រុង ឬបន្ថែមទៅលើស្រូវប្រាំង | 103,656 | 248.700 (223.700 មិនពេញលេញ និង 25.000 ការស្រោចស្រពទាំងស្រុង) | ការបង្ហៀរ (~90 %)<br>ការបូម (~10%) |
| ផ្ទៃដីស្រោចស្រពសរុប | 276,393 | 472,900 | ការបង្ហៀរ (~90 %)<br>ការបូម (~10%) |
| % នៃការប្រមូលផលស្រូវ | 15% | 23% | |

*[១] ការដាំទ្វេដងមាន ២០.០០០ហ.តនៅឆ្នាំ១៩៩៣-៩៤ ។ ដូច្នេះ ផ្ទៃដីស្រោចស្រពសរុបប្រហែល ២៥៦.០០០ហ.តនៅឆ្នាំ១៩៩៣-៩៤ ។*
*[២] សកម្មភាពការប៉ាន់ស្មាននៃការដាំដំណាំទ្វេដង គឺគ្មានតួរលេខបញ្ជាក់ឡើយ ។*
*ប្រភព:* Halcrow 1994 *និងក្រសួងផែនការឆ្នាំ២០០១ ។*

ជាប្រការសំខាន់គួរកត់សំគាល់ដែរថា ការជឿជាក់លើប្រតិបត្តិការប្រព័ន្ធស្រោចស្រពនាពេលបច្ចុប្បន្ននៅកម្ពុជា គឺស្ថិតនៅក្នុងភាពមិនទាន់ច្បាស់លាស់នៅឡើយ ។ នៅឆ្នាំ១៩៩៣-៩៤ ការស្រាវជ្រាវដ៏ទូលំទូលាយមួយស្តីពីសក្តានុពលភាពសំរាប់ស្តារប្រព័ន្ធស្រោចស្រពឡើងវិញបានកំណត់ឃើញថា នៅទូទាំងប្រទេសកម្ពុជាមាន ៨៤១ប្រព័ន្ធស្រោចស្រពដែលក្នុងនោះមានតែ ១៧៦ (២១%) ប៉ុណ្ណោះត្រូវបានរាយការណ៍មកថា មានដំណើរការ ចំណែកឯ ៥៥០ (៦៥%) មានដំណើរការខ្លះៗ និង ១១៥ទៀត (១៤%) គឺគ្មានដំណើរការតែម្តង (Halcrow 1994)[៦] ។ ការសិក្សានេះបានបែងចែកប្រព័ន្ធ ស្រោចស្រពជា ៤ក្រុមៈ

- អាងស្តុកទឹក ជ្រោះ អូរ ឬទន្លេ (មាន ៤៣% នៃផ្ទៃដីស្រោចស្រព ឬតំណាងឱ្យ ៤៥% នៃប្រព័ន្ធទាំងមូល) ។ ទឹកភាគច្រើនត្រូវបានប្រើប្រាស់បន្ថែមទៅដល់ការស្រោចស្រពនៅរដូវវស្សា ។ ក្នុងករណីខ្លះ តំបន់ដែលមានផ្ទៃដីតូចៗសំរាប់ដាំដំណាំនៅក្នុងរដូវប្រាំង ត្រូវបានគេធ្វើការស្រោចស្រពដែរ ។ ទឹកត្រូវបានទាញយកពីអាងស្តុកដោយ

[៦] ការសិក្សានេះធ្វើឡើងក្នុង ១៤ខេត្ត ដោយអនុលោមតាមនាយកដ្ឋានធារាសាស្ត្រ និងឧតុនិយម ហើយរួមបញ្ចូលគ្រប់តំបន់ដាំដុះដែលពឹងផ្អែកទៅលើការស្រោចស្រពនារដូវប្រាំង និង ៩៩% នៃតំបន់ដែលធ្វើការស្រោចស្រពបន្ថែមនារដូវវស្សា ។ ប្រព័ន្ធស្រោចស្រពដែលមានស្រាប់ ហើយមានផ្ទៃដីតិចជាង ១០ហិកតា មិនត្រូវបានគិតបញ្ចូលនៅក្នុងការសិក្សានេះទេ ។

ប្រើប្រាស់ប្រព័ន្ធបង្ហូរ ឬកូនម៉ាស៊ីនបូមទឹកចល័ត ។

- ប្រឡាយដោះទឹកចេញមកពីបឹងធម្មជាតិ ទន្លេ និងជ្រោះអូរ ដោយប្រព័ន្ធបង្ហូរ (មាន ២១% នៃតំបន់ស្រោចស្រព និងតំណាងឱ្យ ១៥% នៃប្រព័ន្ធទាំងមូល) ។ ប្រព័ន្ធនេះគ្មានការស្តុកទឹកឡើយ ហើយត្រូវបានគេប្រើប្រាស់ជាសំខាន់សំរាប់ធ្វើការស្រោចស្រពបន្ថែមនៅរដូវវស្សា ។
- ប្រឡាយដែលប្រើស្ថានីយបូមទឹក (មាន ៧% នៃផ្ទៃដីស្រោចស្រព តំនាងឱ្យ ១៥% នៃប្រព័ន្ធទាំងមូល) ។ ទឹកត្រូវបានបូមចេញពីទន្លេ ដែលអនុញ្ញាតដាំដុះដំណាំបានទ្វេដង គឺដាំដំណាំបានពីរដងក្នុងមួយឆ្នាំនៅលើដីដដែល ។
- អាងស្តុកទុកទឹកជំនន់ដែលត្រូវបានយកទៅប្រើប្រាស់ ដើម្បីទ្រទ្រង់ការដាំស្រូវប្រដេញទឹកនៅរដូវប្រាំងតែប៉ុណ្ណោះ (មាន ២៩% នៃតំបន់ធ្វើការស្រោចស្រព និងតំណាងឱ្យ ៣៥% នៃប្រព័ន្ធទាំងមូល) ។

## ២.៤. ស្ថានភាពទូទៅនៃប្រទេសជិតខាងទាក់ទងនឹងផលិតកម្មស្រូវ

ការបង្កើនផលិតកម្មដំណាំស្រូវ តែងតែត្រូវបានកំណត់ថាមានសារៈសំខាន់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ អ្នកវិភាគខ្លះបានឱ្យយោបល់ថា បង្កើនប្រព័ន្ធស្រោចស្រព និងការប្រើប្រាស់ជីគីមី រួមបញ្ចូលជាមួយនឹងការប្រើពូជទំនើបអាចជួយដល់ការបង្កើនទិន្នផលស្រូវនៅក្នុងប្រទេសកម្ពុជាឱ្យ "ដើរទាន់" ជាមួយនឹងប្រទេសជិតខាងរបស់ខ្លួន ដូចជា ថៃ និងវៀតណាម ។ ប៉ុន្តែវិធីសាស្ត្រដែលអនុវត្តដោយប្រទេសវៀតណាម និងថៃ ចំពោះផលិតកម្មស្រូវ គឺមានលក្ខណៈខុសប្លែកខ្លះៗ ដែលចាំបាច់ត្រូវឱ្យមានការជជែកដេញដោលបន្ថែមទៀត ថាតើវិធីសាស្ត្រសមស្របបំផុតយ៉ាងដូចម្តេចទាក់ទងនឹងការអភិវឌ្ឍន៍ផលិតកម្មស្រូវដែលកម្ពុជាគួរប្រកាន់យក ។ ស្ថិតិអង្គការ FAO ស្តីពីផលិតកម្មដំណាំស្រូវនៅតាមតំបន់អាស៊ីអគ្នេយ៍ បានផ្តល់ជាចំណុចចាប់ផ្តើមមួយសំរាប់ការពិភាក្សា (តារាង២.៥.) ។

**តារាង ២.៥. ការប្រៀបធៀបផលិតកម្មស្រូវនៅប្រទេសអាស៊ីអាគ្នេយ៍ ឆ្នាំ១៩៩0-២000**

| ឈ្មោះប្រទេស | ដំណាំស្រូវ | 1990 | 1995 | 1998 | 1999 | 2000 | បរិស្ថានដំណាំស្រូវ និងតំបន់ធ្វើការស្រោចស្រព |
|---|---|---|---|---|---|---|---|
| កម្ពុជា | ទិន្នផល (តោន/ហិកតា) | 1.4 | 1.8 | 1.8 | 1.9 | 2.1 | 83% ស្រូវទំនាប 3% ស្រូវឡើង ទឹក 2% ស្រូវភ្នំ និង 11% ស្រូវ ប្រាំង (ផ្ទៃដីស្រោចស្រព ២៣%) |
| | ផ្ទៃដីប្រមូលផល (លានហិកតា) | 1.9 | 1.9 | 1.9 | 2.1 | 1.9 | |
| | ផលិតផល (លានតោន) | 2.5 | 3.4 | 3.5 | 4.0 | 4.0 | |
| ឡាវ | ទិន្នផល (តោន/ហិកតា) | 2.3 | 2.5 | 2.7 | 2.9 | 3.1 | 58% ស្រូវទំនាប 41% ស្រូវភ្នំ (ផ្ទៃដីស្រោចស្រព 2%) |
| | ផ្ទៃដីប្រមូលផល (លានហិកតា) | 0.7 | 0.6 | 0.6 | 0.7 | 0.7 | |
| | ផលិតផល (លានតោន) | 1.5 | 1.4 | 1.7 | 2.1 | 2.2 | |
| ថៃ | ទិន្នផល (តោន/ហិកតា) | 2.0 | 2.4 | 2.3 | 2.3 | 2.3 | 86% ស្រូវទំនាប 2% ស្រូវឡើង ទឹក 1% ស្រូវភ្នំ និង 12% ស្រូវ ប្រាំង (ផ្ទៃដីស្រោចស្រព 32%) |
| | ផ្ទៃដីប្រមូលផល (លានហិកតា) | 8.8 | 9.1 | 9.9 | 10.1 | 10.0 | |
| | ផលិតផល (លានតោន) | 17.2 | 22.0 | 22.8 | 23.3 | 23.4 | |
| វៀតណាម | ទិន្នផល (តោន/ហិកតា) | 3.2 | 3.7 | 4.0 | 4.1 | 4.3 | 84% ស្រូវទំនាប8% ស្រូវឡើង ទឹក 8% ស្រូវភ្នំ (ផ្ទៃដី ស្រោចស្រព 60%) |
| | ផ្ទៃដីប្រមូលផល (លានហិកតា) | 6.0 | 6.8 | 7.4 | 7.6 | 7.7 | |
| | ផលិតផល (លានតោន) | 19.2 | 25.0 | 29.1 | 31.4 | 32.6 | |

*ប្រភព: Bui 2000, Kupkanchanakul 2000, FAOSTAT 2001, NIS 2001*

ទិន្នផលស្រូវនៅប្រទេសកម្ពុជា គឺមានកំរិតទាបបំផុតក្នុងចំណោមប្រទេសទាំង ៤ ក្នុងតំបន់អាស៊ីអគ្នេយ៍ ។ ប៉ុន្តែកំណើន ទិន្នផលនាពេលបច្ចុប្បន្ន ជាមធ្យម ២,១តោន/ហិកតា បានបញ្ជាក់ឱ្យឃើញថាក្នុងរយៈពេលដ៏ខ្លីខាងមុខនេះទិន្នផលស្រូវប្រទេស កម្ពុជាអាចតាមទាន់ប្រទេសថៃ ដែលមានទិន្នផលស្រូវថេរយូរអង្វែងគឺជាមធ្យម ២,៣តោន/ហិកតា ។ នាឆ្នាំ២000 ប្រទេស វៀតណាមមានទិន្នផលស្រូវជាមធ្យម ៤,៣តោន/ហិកតា

បានសេចក្តីថា មានអត្រាខ្ពស់ជាងប្រទេសកម្ពុជាដល់ទៅ ២ដង ។ បន្ថែមពីលើនេះ កសិករវៀតណាមមានលទ្ធភាពដាំដំណាំស្រូវទៅដល់ទ្វេដង ឬ ៣ដងក្នុងមួយឆ្នាំនៅលើដីដែលរបស់ខ្លួនដោយបង្កើននូវផលិតភាពរបស់ដី ។ ការដាំដំណាំទ្វេដងនៅក្នុងនិទាឃរដូវ និងរដូវក្តៅ គឺជាការនិយមបំផុតចំពោះប្រទេសវៀតណាមក្នុងពេលជាមួយគ្នានេះដែរ ការដាំដំណាំបាន ៣ដង (និទាឃរដូវ រដូវក្តៅ និងសិសិររដូវ) គឺច្រើនតែធ្វើនៅតាមតំបន់ដីសណ្តរទន្លេមេគង្គ (Bui 2000) ។

គំលាតខុសគ្នានៃទិន្នផលស្រូវជាមធ្យមរវាងប្រទេសថៃ និងប្រទេសវៀតណាម បានឆ្លុះបញ្ចាំងអំពីភាពខុសគ្នានៃវិធីសាស្ត្រអនុវត្តន៍ទៅលើផលិតកម្មដំណាំស្រូវ ។ ជាទូទៅ កសិករថៃ និយមដាំពូជស្រូវប្រពៃណី និង "ពូជជ្រើសរើស" នៅក្នុងស្រុកដែលមានគុណភាពខ្ពស់ និងគ្រាប់ស្រូវវែង ។ ប្រភេទពូជទាំងនេះ មានតំលៃនាំឱ្យកសិករថៃ ទទួលបានចំណូលខ្ពស់ពីកសិដ្ឋានរបស់គាត់[៧] ។ ចំណូលខ្ពស់ ជាហេតុផលសំខាន់ដែលកសិករយកមកអនុវត្ត ហេតុដូចនេះហើយទើបកសិករថៃ ពុំសូវនិយមដាំពូជស្រូវទំនើបឡើយ បើប្រៀបធៀបនឹងកសិករវៀតណាម ។ ទិន្នផលទាបនៅថៃ មិនអាចឆ្លុះបញ្ចាំងអំពីភាពទន់ខ្សោយនៃប្រព័ន្ធគ្រប់គ្រងទឹក ការប្រើប្រាស់ធនធាន ផលិតកម្មទាប ឬមួយក៏ជួបបញ្ហាប្រឈមនានាឡើយ (Kupkanchanakul 2000) ។ កសិករថៃភាគច្រើន បន្តដាំដុះស្រូវ ដោយគ្មានប្រព័ន្ធស្រោចស្រព ហើយនាឆ្នាំ១៩៩៧-៩៨ ផ្ទៃដីដាំដុះស្រូវដែលធ្វើការស្រោចស្រពមានប្រមាណតែ ៣២% ប៉ុណ្ណោះនៅក្នុងប្រទេសថៃ ដែលក្នុងនោះការស្រោចស្រពបន្ថែមនៅរដូវវស្សាមាន ២០% និងការស្រោចស្រពនៅរដូវប្រាំងមាន ១២% ។ ភាគច្រើនការស្រោចស្រពនៅរដូវប្រាំង គឺកសិករប្រើប្រាស់ពូជទំនើប (Kupkanchanakul 2000) ។

ផ្ទុយមកវិញ ចំណែកឯប្រទេសវៀតណាមបានយកចិត្តទុកដាក់សំខាន់ទៅលើការប្រើប្រាស់ពូជស្រូវទំនើប និងពង្រីកបន្ថែមនូវប្រព័ន្ធស្រោចស្រព ។ ប្រហែល ៦០% នៃផ្ទៃដីដាំដុះស្រូវសរុបពឹងផ្អែកទៅលើការស្រោចស្រព ហើយការអនុវត្តន៍នេះអនុញ្ញាតឱ្យមានប្រពលវប្បកម្មដំណាំស្រូវកើតឡើង ដោយក្នុងមួយឆ្នាំអាចដាំដុះបានពី ២ ទៅ ៣ដង ព្រមទាំងមានទិន្នផលរហូតដល់ ៤តោន/ហិកតា ។ ឆ្លងតាមរយៈវិធីសាស្ត្រប្រពលវប្បកម្មដំណាំស្រូវ ប្រទេសវៀតណាមបានក្លាយទៅជាអ្នកនាំស្រូវលក់ចេញទៅបរទេសដោយឈរលំដាប់ទី៣ នៅលើសកលលោក បន្ទាប់ពីសហរដ្ឋអាមេរិក (លេខ១) និងថៃ (លេខ២) (FAOSTAT 2001) ។ ទោះបីជាប្រទេសវៀតណាម ទទួលបានលទ្ធផលជោគជ័យគួរឱ្យកត់សំគាល់ក្នុងការបង្កើនផលិតកម្មស្រូវនៅក្នុងទសវត្សរ៏កន្លងទៅនេះយ៉ាងណាក៏ដោយ ប៉ុន្តែចំណូលបានមកពីផលិតកម្មស្រូវនៅមានកំរិតទាបនៅឡើយ ។ ចំណូលទាបបានមកពីដំណាំស្រូវ រួមជាមួយនឹងដីកសិដ្ឋានកាន់តែរួញតូចទៅៗ ព្រមទាំងប្រពលវប្បកម្មកសិកម្ម (ឧទាហរណ៏ ដីមានជាតិអំបិល និងសត្វល្អិតធន់ទ្រាំនឹងថ្នាំពុលគីមី) កត្តាទាំងនេះបានជះឥទ្ធិពលមិនល្អ ទៅដល់និរន្តរភាពនៃកំរិតផលិតកម្មដំណាំស្រូវនៅវៀតណាម (FAOSTAT 2001) ។

មិនដូចជាប្រទេសថៃ វៀតណាម និងកម្ពុជាទេ ប្រទេសឡាវភាគច្រើននៃផលិតកម្មដំណាំស្រូវរបស់ខ្លួន បន្តអនុវត្តដាំដុះនៅតាមតំបន់ខ្ពង់រាបដែលនៅទីនោះកសិករប្រហែល ៦០% ត្រូវបានគេធ្វើការប៉ាន់ស្មានឃើញថា មានបទពិសោធន៏ទៅនឹងការខ្វះខាតស្រូវសំរាប់បរិភោគជាប្រចាំក្នុងមួយឆ្នាំៗ ។ ទោះជាមានភាពខ្វះខាតក៏ដោយ ប៉ុន្តែទិន្នផលស្រូវជាមធ្យមនៅប្រទេសឡាវក្នុងទសវត្សរ៏កន្លងមកនេះ មានការកើនឡើងសន្សឹមៗរហូតដល់ ៣,១តោន/ហិកតានាឆ្នាំ២០០០ ។ កត្តានេះកើតមានឡើងដោយសារប្រព័ន្ធស្រោចស្រព (ត្រឹមតែ ២% នៃផ្ទៃដីដាំដុះសរុប) ការប្រើជីគីមី ឬការទទួលយកបច្ចេកវិទ្យា ដូចជាពូជស្រូវ

---

[៧] "ពូជជ្រើសរើសក្នុងស្រុក" សំដៅលើពូជដែលមានស្រាប់ (ជាទូទៅមិនមានការផ្លាស់ប្តូរ) ដែលត្រូវបានគេកំណត់ឡើងតាមរយៈការស្រាវជ្រាវថាជាពូជដែលប្រសើរបំផុតសំរាប់ធ្វើការដាំដុះនៅក្នុងប្រព័ន្ធបរិដ្ឋានដំណាំស្រូវខុសៗគ្នា ដោយផ្អែកទៅលើគុណភាពគ្រាប់ស្រូវ សក្តានុពលទិន្នផល និងកត្តាដទៃផ្សេងទៀត ។

ទំនើប គឺមានកំរិតតិចតួចបំផុត ។ ច្រើនជាង ៨៥% នៃផលិតកម្មស្រូវនៅប្រទេសឡាវ គឺប្រើប្រាស់ពូជស្រូវប្រពៃណី ឬពូជ "ស្រូវដំណើប") ។

នាបច្ចុប្បន្ននេះ ផលិតកម្មស្រូវនៅប្រទេសកម្ពុជា គឺមានវិធីសាស្ត្រប្រហាក់ប្រហែលទៅនឹងប្រទេសថៃ ដូចជា លក្ខណៈបរិស្ថានដំណាំស្រូវ ទិន្នផលជាមធ្យម ការប្រើប្រាស់ពូជក្នុងស្រុក និងផ្ទៃដីស្រោចស្រព ។ ក៏ប៉ុន្តែ យុទ្ធសាស្ត្រកសិកម្មរបស់កម្ពុជាហាក់ដូចជាមាននិន្នាការផ្តោតទៅលើបង្កើនផលិតកម្មដំណាំស្រូវ ដោយអនុវត្តវិធីសាស្ត្រស្រដៀងគ្នានឹងប្រទេសវៀតណាមដូចជា បង្កើនប្រព័ន្ធស្រោចស្រព ប្រើប្រាស់ពូជស្រូវទំនើប ពង្រីកការដាំដុះបន្ថែម និងដាំដំណាំស្រូវទ្វេដងនៅទីណាដែលអាចមានលទ្ធភាពធ្វើទៅបាន ។ ឯកសារពិភាក្សានេះ មិនមានបំណងជូនយោបល់ថាតើវិធីសាស្ត្រផលិតកម្មដំណាំស្រូវដែលអនុវត្តដោយប្រទេសវៀតណាម ឬថៃ សមស្របបំផុត សំរាប់ការអនុវត្តន៍ចំពោះប្រទេសកម្ពុជាឡើយ ក៏ប៉ុន្តែបទពិសោធន៍អនុវត្តន៍របស់ប្រទេសជិតខាងទាំងនេះ សមតែលើកយកមកពិនិត្យ ពិច័យចំពោះការដឹកនាំនយោបាយដែលទាក់ទងនឹងវិស័យកសិកម្មនៅកម្ពុជា ។ ជាពិសេសទៅទៀតនៅក្នុងខណៈពេលដែលធ្វើការបង្កើនផលិតកម្ម និងទិន្នផលទូទាំងប្រទេស កត្តាដែលសំខាន់នោះគួរតែធ្វើការផ្តោតយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងក្លាឡើងទៅជីវភាពរស់នៅរបស់កសិករ និងយុទ្ធសាស្ត្រ ផលិតកម្មដែលអាចកែលំអឱ្យកាន់តែប្រសើរបំផុតដល់សន្តិសុខស្បៀង និងប្រាក់ចំណូលរបស់ពួកគេ ។

## ២.៥. ផលិតកម្មកសិកម្មក្នុងប្រទេសកម្ពុជា

ស្ថិតិរបស់រដ្ឋាភិបាលបានបង្ហាញឱ្យឃើញថា នៅក្នុងប្រទេសកម្ពុជាដំណាំស្រូវ និងផលិតកម្មចិញ្ចឹមសត្វមានការកើនឡើងគួរឱ្យកត់សំគាល់នាទសវត្សរ៍កន្លងមក ក៏ប៉ុន្តែផលិតកម្មដំណាំស្បៀង និងដំណាំឧស្សាហកម្មដទៃទៀត គឺមិនដើរទៅមុខ ។ ចាប់ពីឆ្នាំ១៩៩០-៩១ មកដល់ឆ្នាំ២០០០-០១ ផលិតកម្មដំណាំស្រូវបានកើនឡើងពី ២,៥លានតោន ដល់ ៤លានតោន គឺមានកំណើនប្រហែល ៦០% ។ ផលិតកម្មស្រូវបានកើនលើសពីតំរូវការក្នុងស្រុក ដែលជាកត្តាផ្តល់ឱ្យប្រទេសកម្ពុជា មានផលស្រូវលើសនៅក្នុងឆ្នាំថ្មីៗកន្លងមកនេះ ។ ប៉ុន្តែ ផលិតផលលើសនេះ នៅតែមានភាពមិនស្មើគ្នា ។ តំបន់ជាច្រើននៅកម្ពុជានៅតែបន្តជួបប្រទះកង្វះខាតស្រូវ ដោយមានកត្តាលំបាកដូចជា: កត្តារូបសាស្ត្រដែលមានផលប៉ះពាល់ទៅលើតំបន់ផលិតកម្ម (ឧទាហរណ៍ គុណភាពទឹកដី) ហេដ្ឋារចនាសម្ព័ន្ធនៅខ្សោយ ព្រមទាំងនៅខ្សោយក្នុងផ្នែកលំហូរពាណិជ្ជកម្ម និងពត៌មានម៉ាឃីទីង ។

ការចិញ្ចឹមសត្វ ជាផ្នែកមួយនៃប្រព័ន្ធកសិកម្មកម្ពុជាមានការកើនឡើងយឺតយ៉ាវ បើធៀបនឹងផលិតកម្មស្រូវ ។ ចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០ គោមានការកើនឡើង ៣៧% ជ្រូកកើនឡើង ២៨% និងបសុបក្សីកើនឡើង ៨៧% ។ ប៉ុន្តែផលិតកម្មក្របីមានចំនួនថយចុះរហូតដល់ ៦% នៅក្នុងកំលុងពេលខាងលើនេះ ។ ផលិតកម្មដំណាំស្បៀងផ្សេងៗមានការប្រែប្រួលឡើងចុះគួរឱ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ មានតែដំណាំពោត និងដំឡូងមីទេ ដែលបានបង្ហាញពីសញ្ញាណនៃការកើនឡើង ។ ខាងក្រោមនេះ គឺជាការពិភាក្សាលំអិតស្តីពីផលិតកម្មស្រូវ ដំណាំស្បៀង និងការចិញ្ចឹមសត្វ ។

### *២.៥.១. ផលិតកម្មដំណាំស្រូវ*

ទោះជាផលិតកម្មដំណាំស្រូវបានកើនឡើងគួរឱ្យកត់សំគាល់នៅកំលុងទសវត្សរ៍កន្លងមកនេះ ប៉ុន្តែការលូតលាស់នេះមានសភាពពុំស្មើគ្នាឡើយ ។ យោងតាមស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញឱ្យឃើញថា កំណើននៃផលិតកម្មស្រូវស្ទើរតែទាំងអស់ កើតមានឡើងក្នុងកំលុងរយៈពេលពីរខុសគ្នា-នៅក្នុងរយៈពេលឆ្នាំចាប់ពី ១៩៩៤-៩៥ ដល់ ១៩៩៥-៩៦ ដែលមានកំណើនច្រើនជាង ១,២លានតោន និងរយៈពេលពីរឆ្នាំចាប់ពី១៩៩៨-៩៩ ដល់ ១៩៩៩-២០០០ គឺកំលុងពេលនេះ ផលិតកម្មស្រូវមានកំណើនដល់ ០,៥លានតោន (ក្រាហ្វិកទី២.១) ។ កំនើនផលិតកម្មយ៉ាងគំហុកនេះ (៥៥% និង ១៥% រៀងៗគ្នា) បានឆ្លុះបញ្ចាំងពីឆ្នាំដែលទិន្នផល និងផ្ទៃដីប្រមូលផលមានការកើនឡើងគួរឱ្យកត់សំគាល់ (ក្រាហ្វិក២.២) ។ នៅឆ្នាំបន្ទាប់មកផលិតកម្មមានលក្ខណៈស្មើ ។

ការបង្កើនទិន្នផល ជាយន្តកម្មសំខាន់នៃផលិតកម្មដំណាំស្រូវនាទសវត្សរ៍កន្លងមកនេះ មិនមែនជាការពង្រីកផ្ទៃដីដាំដុះឡើយ ។ ទិន្នផលស្រូវជាមធ្យមមានការកើនឡើងពី ១,៣៥តោន/ហិកតា ទៅដល់ ២,១២តោន/ហិកតាក្នុងកំលុងឆ្នាំ១៩៩០-៩១ ដល់ ២០០០-០១ គឺអត្រាកំនើននេះជិតដល់ ៦០% ។ ថ្វីបើក្នុងកំលុងពេលនេះផ្ទៃដីដាំដុះដំណាំស្រូវមានការកើនឡើងពី ១,៨៩លានហិកតារហូតដល់ ២,៣២លានហិកតា ប៉ុន្តែ ផ្ទៃដីប្រមូលផលជាក់ស្តែងមិនមានការកើនឡើងឡើយ ។ នៅក្នុងរយៈពេល ៣ឆ្នាំបន្តបន្ទាប់គ្នាកន្លងមក (១៩៩៨-៩៩ ដល់ ២០០០-០១) មានផ្ទៃដីតែ ១,៩៧លានហិកតាដែលបានធ្វើការប្រមូលផល ជាមធ្យម បើធៀបនឹង ១,៨៦លាន ហិកតានៅក្នុងឆ្នាំ១៩៩០-៩១ ។

ដោយសារតែផលិតកម្មពឹងផ្អែកទៅលើផ្ទៃដីប្រមូលផល ដែលអាចឡើងចុះរៀងរាល់ឆ្នាំ ដោយសារអាកាសធាតុ (ការខូចខាតដោយទឹកជំនន់ និងភាពរាំងស្ងួត) ដូចនេះ ទិន្នផលក្នុងមួយហិកតា គឺជាកត្តាប្រសើរ ដែលតំណាងឱ្យសន្ទស្សន៍រយៈពេលវែងនៃការវិវត្តន៍របស់កំណើនផលិតកម្មដំណាំស្រូវ ។ ក្រាហ្វិក២.៣ បានគូសបញ្ជាក់ពីនិន្នាការទិន្នផលស្រូវប្រាំង និងស្រូវវស្សាក្នុងទសវត្សរ៍កន្លងមកនេះ ។ ទិន្នផលស្រូវវស្សាមានការកើនឡើងក្នុងកំលុងរយៈពេលពីរឆ្នាំបន្តបន្ទាប់ គឺពីឆ្នាំ១៩៩៣-៩៤ ដល់ ១៩៩៥-៩៦ (២,២តោន/ហិកតា ដល់ ១,៦៤តោន/ហិកតា) និងពីឆ្នាំ១៩៩៨-៩៩ ដល់ ២០០០-០១ (១,៦០តោន/ហិកតា ដល់ ១,៩៥តោន/ហិកតា) ទិន្នផលស្រូវវស្សាមានអត្រាស្មើថេរនៅឆ្នាំដទៃទៀត ។ ដូចនេះដែរ ទិន្នផលស្រូវប្រាំងកើនឡើងក្នុងរយៈពេលមួយឆ្នាំពី១៩៩៣-៩៤ ដល់ ១៩៩៤-៩៥ (២,៥០តោន/ហិកតា ដល់ ៣តោន/ហិកតា) និងកំនើនទិន្នផលមានការកើនឡើងម្តងទៀតពីឆ្នាំ១៩៩៨-៩៩ ដល់ឆ្នាំ២០០០-០១ (២,៩៣តោន/ហិកតា ដល់ ៣,១៩តោន/ហិកតា ។ ទិន្នផលស្រូវរដូវប្រាំងមានអត្រាស្មើថេរនៅឆ្នាំដទៃទៀត ។

នៅក្នុងការវិភាគអំពីទិន្នន័យលើដំណាំស្រូវ គេគួរឱ្យកត់សំគាល់ផងដែរថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាពេលថ្មីៗនេះ បានកែលំអវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យរបស់ខ្លួនលើដំណាំស្រូវ ។ ដោយចាប់ផ្តើមអនុវត្តនាឆ្នាំ១៩៩៨ MAFF បានអនុវត្តវិធីសាស្ត្រយកសំណាកទូទាំងប្រទេស ដើម្បីគាំទ្រដល់ទិន្នន័យ ដំណាំស្រូវរបស់ខ្លួនឱ្យកាន់តែមានភាពសុក្រឹតឡើង ។ មុនឆ្នាំ១៩៩៨ ការប៉ាន់ស្មានត្រូវបានបង្កើតឡើងតាមរបៀបអង្កេតដែលធ្វើដោយអាជ្ញាធរមូលដ្ឋាន (ដោយមន្ត្រីថ្នាក់ភូមិ ឬថ្នាក់ឃុំ) ។ នៅក្នុងករណីភាគច្រើន ការធ្វើអង្កេតអំពីផ្ទៃដីដាំដុះផ្ទៃដី ការប្រមូលផល និងផលិតកម្ម អាចមានភាពត្រឹមត្រូវ ចំណែកឯវិធីសាស្ត្រយកសំណាក គឺបានកែលំអនូវសុក្រឹតភាពឱ្យកាន់តែច្បាស់លាស់ទៀត ។

**ក្រាហ្វិក២.១. ផលិតផលស្រូវពីឆ្នាំ១៩៩០-២០០១**




[១] *Crop year defined as from 1st of March to end of February. ប្រភព: NIS 2001, MAFF 2001*

ការកំណត់ថាតើកត្តាណាខ្លះដែលរួមចំណែកខ្លាំងទៅដល់កំនើនទិន្នផលនៅទសវត្សរ៍កន្លងមកនេះ គឺមានសារៈសំខាន់ណាស់ ពីព្រោះការយល់ដឹងនេះ អាចជួយផ្តល់ជាមូលដ្ឋានគ្រឹះ សំរាប់គោលដៅបំលាស់ប្តូរនយោបាយកសិកម្មដែលគាំទ្រទៅដល់ការកែលំអ ទិន្នផលនាពេលអនាគតឱ្យកាន់តែប្រសើរឡើង ។ ទោះជាយ៉ាងណាក៏ដោយ កំណើនទិន្នផល និងផលិតកម្មស្រូវដែលកើនឡើងខ្លាំងពីរដងនាទសវត្សរ៍កន្លងមកនេះ មានការលំបាកក្នុងការពន្យល់ហេតុផល ។ បើផ្អែកទៅលើរយៈពេលកំណើនលើកទី១ (១៩៩៣ ដល់ ១៩៩៥) ហាក់ដូចជាដោយសារមូលហេតុនៃការកើនឡើងនូវការប្រើប្រាស់ជីគីមី និងការទទួលយកនូវពូជទំនើប ។ ការបើកចំហទីផ្សារសេរីនៅដើមទសវត្សរ៍ទី១៩៩០ បានផ្តល់នូវការសំរបសំរួលសេវាកម្មប្រកួតប្រជែងដោយនាំចូលជីគីមីដោយអ្នកជំនួញឯកជន ។ ការនាំចូលនូវជីគីមីមានការកើនឡើងពីចំនួន ១០.០០០-២០.០០០តោន/ឆ្នាំនៅកំលុងឆ្នាំ១៩៩០-៩២ ហើយចំនួននេះកើនរហូតដល់ចំនួន ៨០.០០០-៩០.០០០តោន/ ឆ្នាំនៅក្នុងកំលុងឆ្នាំ១៩៩៣-១៩៩៥ (Cameron 1995, Center for National Polily 1996) ។

## ក្រាហ្វិក២.២. ទិន្នផលស្រូវ និងផ្ទៃដីប្រមូលផលពីឆ្នាំ១៩៩០-២០០១




*ប្រភព: NIS 2001, MAFF 2001*

## ក្រាហ្វិក២.៣. ទិន្នផលស្រូវប្រាំង និងស្រូវវស្សាពីឆ្នាំ១៩៩០-២០០១



*ប្រភព:* NIS 2001, MAFF 2001

មុនពេលបើកទីផ្សារសេរីសំរាប់ជីគីមី គឺការលក់ និងចែកចាយជីគីមី ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនរដ្ឋមានឈ្មោះថា ក្រុមហ៊ុន សំភារៈកសិកម្មមជ្ឈិម (COCMA) ដែលចំណុះឱ្យក្រសួងកសិកម្ម ។ កសិករត្រូវបានគេដកស្រង់សំដីថា មានបញ្ហាច្រើន ជាមួយនឹងក្រុមហ៊ុនរដ្ឋនេះ ដោយសារគ្មានលទ្ធភាពឆ្លើយតបភ្លាមៗទៅនឹងបំរែបំរួលតំរូវការ ការផ្គត់ផ្គង់គ្មានរបៀបរៀបរយ មិនអាចធានាបាននូវគុណភាពជី និងកង្វះខាតសេវាកម្ម ។ ដោយបញ្ហាទាំងនេះហើយ ទើបបានជាអ្នកជំនួញឯកជនជីគីមី បានមកចូលរួមចែករំលែកទីផ្សារភ្លាមៗជាមួយនឹង COCMA នៅពេលដែលទីផ្សារចាប់ផ្តើមបើកចំហ ។ ហេតុការណ៍បានកើតមានឡើង ថ្វីបើក្រុមហ៊ុនរដ្ឋមានជីគីមីស្តុកដែលផ្តល់ដោយជំនួយបរទេសយ៉ាងណាក៏ដោយ (ច្រើនជាង ១០០.០០០តោននៅកំលុងឆ្នាំ ១៩៩៣-១៩៩៥) ហើយកត្តានេះបានផ្តល់ឱ្យ COCMA នូវតំលៃមានប្រៀបជាងជំនួញឯកជន ។ នៅឆ្នាំ១៩៩៥ សេវាឯកជនបានដណ្តើមយកទីផ្សារប្រហែល ៧៥% បើធៀបនឹង COCMA គឺមានតែ ២៥% ប៉ុណ្ណោះ (Center for National Policy 1996) ។

ការផ្តើម និងការទទួលយកពូជស្រូវទំនើបមកដាំដុះ ការកែលំអប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកកាន់តែប្រសើរឡើង ក៏បានរួមចំណែកនៅក្នុងការបង្កើនផលិតកម្ម និងទិន្នផលស្រូវដែរ ។ គំរោងកម្មវិធី Cambodia-IRRI-Australia Project (CIAP)[៨] បានផ្តល់នូវបច្ចេកវិទ្យាទាក់ទងនឹងការកែលំអដែលរួមមាន ពង្រីកការប្រើ ប្រាស់ពូជទំនើប IR66 ដែលគ្រប ដណ្តប់ជាង ៩0% នៃផ្ទៃដីដាំដុះស្រូវប្រាំង (Young *et al.* 2001) ។ ការទទួលយកមកប្រើប្រាស់នូវពូជ IR66 ត្រូវបាននិងកំពុង ជំរុញដោយ CIAP ព្រមទាំងភ្នាក់ងារអភិវឌ្ឍន៍នានា ដោយបានជួយសំរបសំរួលនៅក្នុងការពង្រីកផ្ទៃដីដាំដុះស្រូវប្រាំងដែលមានការស្រោចស្រព (Young *et al.* 2001) ។ ដូចដែលបានធ្វើការកំណត់សំគាល់ខាងលើ គឺតំបន់ស្រោចស្រពដំណាំស្រូវមានការកើនឡើងប្រមាណជា ២០០.០០០ហិកតាក្នុងកំលុងទសវត្សរ៍ទី៩០ ដែលក្នុងនោះ ៧៥% ជាការស្រោចស្រពនៅក្នុងរដូវប្រាំង ។

### *២.៥.២. ដំណាំស្បៀងផ្សេងៗ*

ក្រៅពីដំណាំស្រូវ នៅមានដំណាំពោត និងបន្លែដែលមានសារៈសំខាន់ចំពោះជីវភាពរស់នៅរបស់ប្រជាជនតាមជនបទ ។ កសិករតែងតែដាំបន្លែ និងដំណាំពោត ជាផ្នែកមួយនៃដំណាំចំការ ឬសួនបន្លែ សំរាប់បំរើដល់ការបរិភោគ ។ ពោតត្រូវបានគេដាំសំរាប់ធ្វើជាចំណីសត្វ និងមនុស្ស ។ ដំណាំស្បៀងផ្សេងៗ ដូចជា ដំឡូងជ្វា ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀង ត្រូវបានដាំដុះដោយកសិករផងដែរ ប៉ុន្តែផលិតកម្មនៅមិនទាន់រីករាលដាលដូចជា បន្លែ និងដំណាំពោតឡើយ ។

**ក្រាហ្វិក២.៤. ផលិតផលដំណាំស្បៀងផ្សេងៗពីឆ្នាំ១៩៩០-២០០១**

[៨] CIAP គឺជាគំរោងរួមគ្នារវាងអង្គការ IRRI និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលចាប់ផ្តើមនៅឆ្នាំ១៩៨៧ ។AUSAID បានផ្តល់ថវិកាដល់អង្គការ IRRI ដែលជាផ្នែកមួយនៃគំរោងនេះ ។




*Source: NIS 2001, MAFF 2001*

ទិន្នន័យរដ្ឋាភិបាលស្ដីពីផលិតកម្មដំណាំស្បៀងនាទសវត្សរ៍កន្លងមកនេះ អាចនៅមិនទាន់មានភាពសុក្រឹតនៅឡើយទេ ដោយសារការប៉ាន់ស្មានស្ថិតិដែលធ្វើឡើងដោយមន្ត្រីថ្នាក់មូលដ្ឋាន គឺពឹងផ្អែកទៅលើការពិនិត្យសង្កេត ជាជាងទៅលើវិធីសាស្ត្រធ្វើសំនាក ។ បន្ថែមពីលើនេះ ការប៉ាន់ស្មានអាចយកជាប្រភពផ្លូវការបាន ចំពោះផលិតកម្ម ដូចជា ដំណាំចំការ និងការដាំដុះធំៗ ។ ប៉ុន្តែប្រភពដែលមិនបានគិតបញ្ចូលនៅក្នុងស្ថិតិ ដូចជា សួនបន្លែគ្រួសារ ។ ទោះបីជាផលិតកម្មដែលបានមកពីសួនបន្លែគ្រួសារមានទ្រង់ទ្រាយតូច ប៉ុន្តែមានគ្រួសារចំនួនយ៉ាងច្រើននៅតាមជនបទបានដាំសួនបន្លែ ដូចនេះវាមានសារៈសំខាន់ដែលអាចជាវិភាគទានដល់ផលិតកម្មដំណាំស្បៀងសំរាប់ជាតិទាំងមូលផងដែរ ។

យោងតាមទិន្នន័យរដ្ឋាភិបាលផលិតកម្មដំណាំស្បៀង គឺមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែជាទូទៅ និន្នាការនៃកំណើនលូតលាស់មានសភាពស្មើរ គឺមានតែដំណាំពោត និងដំឡូងមីប៉ុណ្ណោះដែលសន្ទស្សន៍បានបង្ហាញថា មានកំណើនមានការលូតលាស់ខ្លះនាពេលថ្មីៗនេះ (ក្រាហ្វិក២.៤) ។ ពីរឆ្នាំកន្លងមកនេះ ផលិតកម្មដំណាំពោត កើនពី ៥០.០០០តោនដល់ជាង ១៥០.០០០តោន ឯចំណែកដំឡូងមី គឺមានកំណើនដូចគ្នានឹងពោតដែរ ។ ផលិតកម្មដំណាំបន្លែមានលំនឹងថេរ ២០០.០០០តោនជាច្រើនឆ្នាំមកហើយ ចំណែកឯផលិតកម្មដំឡូងជ្វា សណ្ដែកបាយ និងសណ្ដែកសៀងវិញ មិនមានអត្រាកើនឡើងទេ ។

## ២.៥.៣. ផលិតកម្មចិញ្ចឹមសត្វ[៩]

ការចិញ្ចឹមសត្វមានតួនាទីសំខាន់នៅក្នុងកសិកម្មចំរុះនៃជនបទកម្ពុជាដែលរួមមាន គោ ក្របី ជ្រូក និងបសុបក្សី (មាន់ និងទា) ។ យោងតាមស្ថិតិរដ្ឋាភិបាល ចំនួនគោ ជ្រូក និងបសុបក្សីនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងគួរឱ្យកត់សំគាល់ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ចំណែកឯចំនួនក្របីវិញមានការថយចុះ (តារាង២.៦) ។ គោ និងក្របីត្រូវបានគេប្រើប្រាស់សំរាប់ដំណើរការក្នុងកសិដ្ឋានដូចជា ភ្ជួររាស់ មធ្យោបាយដឹកជញ្ជូនផលិតផល និងជាប្រភពនៃជីធម្មជាតិ ។ ការលក់គោសំរាប់យកសាច់ គឺជាផលប្រយោជន៍បន្ទាប់បន្សំ ។ ចំណែកឯសាច់ក្របីវិញ ត្រូវបានគេលាយជាមួយសាច់គោ ឬក៏លក់ទៅវៀតណាម ប៉ុន្តែជាទូទៅប្រជាជនកម្ពុជា ពុំសូវចូលចិត្តបរិភោគឡើយ ។ កសិករចិញ្ចឹមជ្រូក និងបសុបក្សី ដើម្បីលក់ជាសាច់ និងស៊ុតសំរាប់ប្រាក់ចំណូល ។ កសិករខ្លួនគាត់ផ្ទាល់ បរិភោគផលិតផលចិញ្ចឹមសត្វនេះ ក្នុងបរិមាណតិចតួចតែប៉ុណ្ណោះ ។

**តារាង២.៦. ផលិតកម្មចិញ្ចឹមសត្វ ឆ្នាំ១៩៩០-២០០០**

| ឆ្នាំ | គោ (ពាន់ក្បាល) | ក្របី (ពាន់ក្បាល) | ជ្រូក (ពាន់ក្បាល) | បសុបក្សី (ពាន់ក្បាល) |
|---|---|---|---|---|

[៩] ផ្នែកនេះពឹងផ្អែកទៅលើឯកសាររបស់ Maclean (1998) ដែលបានផ្ដល់ការវាយតំលៃយ៉ាងទូលំទូលាយមួយស្ដីពីតួនាទីរបស់បសុសត្វនៅក្នុងប្រព័ន្ធកសិកម្មកម្ពុជា ។

| | | | | |
|---|---|---|---|---|
| 1990 | 2,181 | 736 | 1,515 | 8,163 |
| 1991 | 2,257 | 755 | 1,550 | 8,816 |
| 1992 | 2,468 | 804 | 2,043 | 9,901 |
| 1993 | 2,542 | 824 | 2,123 | 10,629 |
| 1994 | 2,621 | 809 | 2,025 | 10,026 |
| 1995 | 2,786 | 765 | 2,044 | 10,066 |
| 1996 | 2,762 | 744 | 2,151 | 11,412 |
| 1997 | 2,821 | 694 | 2,438 | 12,098 |
| 1998 | 2,680 | 694 | 2,339 | 13,117 |
| 1999 | 2,826 | 654 | 2,189 | 13,417 |
| 2000 | 2,993 | 694 | 1,934 | 15,249 |
| *អត្រាលូតលាស់ប្រចាំឆ្នាំមធ្យម* | *3.2%* | *-0.6%* | *2.5%* | *6.4%* |

*ប្រភព: NIS 2001 និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទឆ្នាំ២00១*

- **គោ និងក្របី** គោ និងក្របីត្រូវបានគេប្រទះឃើញនៅទូទាំងតំបន់ដាំដុះដំណាំស្រូវនៃប្រទេសកម្ពុជា ប៉ុន្តែ ក្របីត្រូវបានគេចិញ្ចឹមនៅតំបន់ទំនាបជុំវិញបឹងទន្លេសាប ខេត្តព្រៃវែង និងខេត្តស្វាយរៀង ។ នេះសបញ្ជាក់ឱ្យឃើញថា ក្របីមានលក្ខណៈល្អប្រសើរជាងគោនៅក្នុងតំបន់ទំនាបដែលមានដីល្បាប់ស្អិត ។ ចំបើងស្រូវគឺជាអាហារសំខាន់សំរាប់គោ និងក្របីនៅក្នុងប្រទេសកម្ពុជា ។ វាគឺជាចំណីតែមួយគត់នៅក្នុងកំលុងរដូវដែលមិនអាចរកស្មៅបាន ដូចជា: កំលុងដើមរដូវវស្សានៅពេលដែលសត្វពាហនៈត្រូវបានគេរក្សាទុកនៅក្បែរផ្ទះ ដើម្បីធ្វើការងារ និងក្នុងកំលុងរដូវវស្សានៅពេលដែលគ្រប់វាលស្រែគ្របដណ្តប់ទៅដោយដំណាំស្រូវ ។ ក្នុងកំលុងឆ្នាំ១៩៩0-២000 ចំនួនសត្វគោមានការកើនឡើងគួរឱ្យកត់សំគាល់ គឺពី ២,២លានក្បាល រហូតដល់ ៣លានក្បាល-កំនើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៣,២% ។ ចំណែកឯចំនួនក្របីវិញមានការថយចុះបន្តិច គឺពី ៧៣៦.000ក្បាល ធ្លាក់មកដល់ ៦៩៤.000ក្បាល ។ ការកើនឡើងចំនួនសត្វគោ អាចបណ្តាលមកពីអត្រាបន្តពូជរបស់វាឆាប់រហ័ស កសិករចូលចិត្តចិញ្ចឹមវាច្រើនជាងក្របី និងការរត់ពន្ធនៃសត្វក្របីទៅកាន់ប្រទេសវៀតណាម និងថៃ ។ ដោយរួមបញ្ចូលជាមួយគ្នារវាងសត្វគោ និងក្របី អត្រាកំនើនប្រចាំឆ្នាំនៃចំនួនគោ និងក្របីក្នុងកំលុងទសវត្សរ៍កន្លងមកនេះ គឺមានប្រមាណ ២,៥% ឬអត្រាកំនើននេះស្មើនឹងអត្រាកំនើនប្រជាជន និងការពង្រីកផ្ទៃដីដំណាំស្រូវ ។ ជាការឆ្លើយតប ចំនួនមធ្យមនៃគោ និងក្របីក្នុងមួយគ្រួសារតាមជនបទ ដែលប្រកបមុខរបរកសិកម្ម គឺនៅថេរ ក្នុងអត្រា ២,២ក្បាលក្នុងមួយគ្រួសារ ។ ជាធម្មតា ក្នុងមួយគ្រួសារត្រូវការសត្វពាហនៈ ២ក្បាល សំរាប់ធ្វើការអូសទាញនៅក្នុងកសិដ្ឋាន ។
- **ជ្រូក** សកម្មភាពចិញ្ចឹមជ្រូកកើតមានឡើងនៅទូទាំងប្រទេសកម្ពុជា ក៏ប៉ុន្តែតំបន់ដែលចិញ្ចឹមច្រើនស្ថិតនៅជុំវិញទីក្រុងភ្នំពេញ និងតំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ ។ ខេត្តដែលមានការចិញ្ចឹមជ្រូកច្រើនក្នុងមួយគ្រួសារមានខេត្តស្វាយរៀង កំពត និងតាកែវ ។ ខេត្តទាំងនេះ (ជាពិសេសខេត្តស្វាយរៀង) នៅជិតប្រទេសវៀតណាម ដូច្នេះជ្រូកអាចត្រូវគេនាំចេញទៅទីផ្សារខាងក្រៅដោយឆ្លងកាត់ព្រំដែន ។ នៅកម្ពុជា ចំណីជ្រូកភាគច្រើនបំផុត គឺកន្ទក់ដែលកសិករទិញមកពីរោងម៉ាស៊ីនកិនស្រូវ (ជារឿយៗ កន្ទក់ទាំងនេះបានមកពីស្រូវរបស់កសិករ) ។ បរិមាណគុណភាព និងថ្លៃកន្ទក់អាចរកបានពីរោងម៉ាស៊ីនស្រូវក្នុងមូលដ្ឋាន វាជាកត្តាកំណត់យ៉ាងសំខាន់នៃចំនួន និងប្រាក់ចំណូលដែលបានមកពីការចិញ្ចឹមជ្រូកនៅក្នុងភូមិ ។ ជ្រូកស្ទើរតែទាំងអស់ ត្រូវបានគេចិញ្ចឹមសំរាប់លក់យកប្រាក់ ។ ចាប់ពីឆ្នាំ១៩៩0-២000 ចំនួនជ្រូកមានការប្រែប្រួលប្រហែល ២លានក្បាល ។ ចំនួននេះមានការថយចុះនៅក្នុងកំលុងរយៈពេល ៤ឆ្នាំកន្លងមកនេះ គឺពី ២,៤លានក្បាលនាឆ្នាំ១៩៩៧ ធ្លាក់មកដល់ត្រឹមតែ ១,៩លានក្បាលនៅក្នុងឆ្នាំ២000 ។ មូលហេតុនៃការធ្លាក់ចុះនេះ គឺមានភាពពុំច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយ គេគួរតែកត់សំគាល់ថា ជ្រូកដែលមានពូជខុសគ្នា វាក៏មានអាយុកាល ទំងន់ និងគុណភាពសាច់ខុសគ្នាដែរ ។ ដូច្នេះការថយចុះចំនួនជ្រូកមិនមែនបញ្ជាក់ថា តំលៃសរុបរបស់ជ្រូកដែលលក់ដូរមានការថយចុះឡើយ

ប្រសិនបើកសិករប្តូរការចិញ្ចឹម ពីពូជក្នុងស្រុកទៅជាពូជបង្កាត់ដែលមានទំងន់ធ្ងន់ និងមានគុណភាពសាច់ខ្ពស់ ។

- **បសុបក្សី** កសិករស្ទើរតែទាំងអស់ចិញ្ចឹមមាន់ ចំណែកឯការចិញ្ចឹមទាវិញ គឺច្រើនតែធ្វើឡើងនៅតំបន់ដែលមានទឹកគ្រប់គ្រាន់នារដូវប្រាំង ។ ការចិញ្ចឹមមាន់ក្នុងភូមិ ត្រូវបានគេលែងឱ្យរកស៊ីដោយសេរី និងផ្តល់ជាចំណីអាហារស្រូវបន្ថែមប្រចាំថ្ងៃបន្តិចបន្តួចបាចឱ្យវាស៊ីផ្ទាល់ដី ។ ដូចគ្នានេះដែរ ការចិញ្ចឹមទាត្រូវបានគេលែងឱ្យរកស៊ីនៅតាមវាលស្រែ បឹងបួរ និងស្រះ ។ ប្រពលវប្បកម្មនៃការចិញ្ចឹមមាន់ ទា នៅក្នុងប្រទេសកម្ពុជា ហាក់ដូចជាមានការកើនឡើង ពិសេសនៅតំបន់ជុំវិញទីក្រុងភ្នំពេញ ។ ទោះជាស្ថិតិរដ្ឋាភិបាលបានបញ្ជាក់ឱ្យឃើញថា ចំនួនបសុបក្សីមានការកើនឡើង ស្ទើរតែពីរដងនៅក្នុងកំលុងទសវត្សរ៍កន្លងមកនេះក៏ដោយ ប៉ុន្តែការប៉ាន់នេះគួរតែចាត់ទុកជាលំនាំទូទៅតែប៉ុណ្ណោះ ដោយមានបញ្ហាលំបាកនានា រួមជាមួយនឹងសុក្រឹតភាពនៃការរាប់ចំនួនមាន់ទា ។

## ២.៦. សារៈសំខាន់នៃវិស័យកសិកម្ម ចំពោះជីវភាពរស់នៅតាមជនបទ

ដូចជាបានរៀបរាប់បញ្ជាក់ពីខាងលើស្តីពីដំណាំស្រូវ ដំណាំស្បៀងផ្សេងៗ និងផលិតកម្មចិញ្ចឹមសត្វ កសិកម្ម មានតួនាទីសំខាន់ចំពោះជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាតាមជនបទ ។ ប្រជាជនជាង ១០លាននាក់រស់នៅតំបន់ជនបទ ហើយក្នុងនោះប្រមាណជា ៨,៥លាននាក់ពឹងផ្អែកទៅលើវិស័យកសិកម្មដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន ។ ភាគច្រើនបំផុត កសិដ្ឋានដំណាំស្រូវគឺជាមូលដ្ឋានគ្រឹះសំខាន់ដើម្បីធានានូវសន្តិសុខស្បៀង ប្រភពនៃការផ្តល់ការងារ និងប្រាក់ចំណូល ។ សមាមាត្រនៃប្រជាជនទាំងអស់ដែលធ្វើការនៅក្នុងវិស័យកសិកម្ម គឺមានអត្រាថេរ ប្រមាណជា ៧៥% ក្នុងកំលុងទសវត្សរ៍កន្លងមកនេះ[១០] ។ ជាចំណែកមួយនៃភាគរយផលិតផលទុនក្នុងស្រុកសរុប កសិកម្មមានការថយចុះពី ៤0% នៃផលិតផលទុនក្នុងស្រុកសរុបនាឆ្នាំ១៩៩0 ធ្លាក់មកដល់ ២៣% នៅក្នុងឆ្នាំ២000 (CDRI 2002) ។ មូលហេតុដែលធ្វើឱ្យភាគរយនៃវិស័យកសិកម្ម មានការថយចុះក្នុងផលិតផលទុនក្នុងស្រុកសរុប ដោយសារមូលហេតុវិស័យដទៃទៀត (ជាពិសេសវាយនភ័ណ្ឌ និងរោងចក្រកាត់ដេរ) មានអត្រាលូតលាស់ឆាប់រហ័សជាងវិស័យកសិកម្មនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ ។

ចំពោះគ្រួសារនៅតាមជនបទដែលប្រកបរបរកសិកម្ម ដីសំរាប់ដាំដុះដំណាំស្រូវជាមធ្យមមានប្រហែល ១,៤ហិកតា នៅក្នុងឆ្នាំ២000-0១ (តារាង២.៧) ។ ប្រាកដណាស់ ទំហំដីកសិដ្ឋានមានការប្រែប្រួលនៅកម្ពុជា តំបន់ដែលមានដង់ស៊ីតេខ្ពស់ ដូចជា ខេត្តកណ្តាល និងកំពង់ស្ពឺ មានផ្ទៃដីកសិដ្ឋានតូចជាងគេ (តិចជាង ១ហិកតា) ចំណែកខេត្តស្ថិតនៅតំបន់អគ្នេយ៍មានផ្ទៃដីកសិដ្ឋាន ១-២ហិកតា រីឯតំបន់ដែលមានដង់ស៊ីតេតិច ដូចជាខេត្តនៅតំបន់ពាយព្យមានផ្ទៃដីកសិដ្ឋាន ប្រមាណ ជា ២-៤ហិកតា (Helmers 1997) ។ នាឆ្នាំ២000-0១ ផលិតផលស្រូវជាមធ្យមក្នុងមួយគ្រួសារប្រហែល ២,៤តោន ។ ប៉ុន្តែប្រការគួរឱ្យកត់សំគាល់ផ្ទៃដីប្រមូលផលនៅក្នុងឆ្នាំ២000-0១ មានអត្រាទាបដោយសារទឹកជំនន់បំផ្លិចបំផ្លាញ ។ ប្រសិនបើផ្ទៃដីដាំដុះសរុបត្រូវបានគេប្រមូលផលទាំងអស់ នោះផលិតផលស្រូវជាមធ្យមក្នុងមួយគ្រួសារអាចទទួលបាន ៣តោន ។

**តារាង ២.៧. ការដាំដុះដំណាំស្រូវ និងផលិតកម្មក្នុងមួយគ្រួសារពីឆ្នាំ១៩៩៨-២00១**

| | 1998-99 | 1999-00 | 2000-01 |
|---|---|---|---|
| ចំនួនប្រជាជននៅតាមជនបទសរុប (ពាន់នាក់)[១] | 9,642 | 9,882 | 10,128 |

[១០] វិស័យកសិកម្មដែលកំណត់នៅទីនេះរួមមាន ដំនាំស្រូវ ដំណាំផ្សេងៗ និងផលិតកម្មចិញ្ចឹមសត្វ ។ ព្រៃឈើ កៅស៊ូ និងត្រី មិនត្រូវបានរាប់បញ្ចូលឡើយ ដោយសកម្មភាពទាំងនេះឱ្យការងារធ្វើមានអត្រាតិចជាង ៣% និងរួមចំណែកតិចជាង ៧% នៅក្នុងផលិតផលទុនក្នុងស្រុកសរុបនៅក្នុងឆ្នាំ២000។ សូមអាននៅក្នុងផ្នែក១.៣. បញ្ហាប្រឈមផ្នែកម៉ាក្រូសេដកិច្ច និងសន្ទស្សន៍ការងារ ដែលនៅក្នុងផ្នែកនេះគ្មានការពិភាក្សាទូលំទូលាយស្តីពីបញ្ហាប្រឈមនៅក្នុងការរកការងារធ្វើ និងការប៉ាន់ស្មានផលិតផលទុនក្នុងស្រុកសរុប។

| | | | |
|---|---|---|---|
| ចំនួនគ្រួសារនៅតាមជនបទសរុប (ពាន់គ្រួសារ) | 1,866 | 1,913 | 1,961 |
| គ្រួសារនៅតាមជនបទ ដែលប្រកបមុខរបរកសិកម្ម (ពាន់គ្រួសារ)[២] | 1,573 | 1,613 | 1,653 |
| ផ្ទៃដីដាំដុះដំណាំស្រូវសរុប (ពាន់ហិកតា) | 2,095 | 2,158 | 2,318 |
| ផ្ទៃដីប្រមូលផលស្រូវសរុប (ពាន់ហិកតា) | 1,963 | 2,080 | 1,903 |
| ផ្ទៃដីដាំដុះក្នុងមួយគ្រួសារ (ហិកតា) | 1.33 | 1.34 | 1.40 |
| ផ្ទៃដីប្រមូលផលក្នុងមួយគ្រួសារ (ហិកតា) | 1.25 | 1.29 | 1.15 |
| ទិន្នផលស្រូវជាមធ្យម (តោន/ហិកតា) | 1.79 | 1.94 | 2.12 |
| សក្តានុពលផលិតកម្មស្រូវជាមធ្យមក្នុងមួយគ្រួសារ ផ្អែកលើផ្ទៃដីដាំដុះ (តោន) | 2.38 | 2.60 | 2.97 |
| ផលិតផលស្រូវជាក់ស្តែងមធ្យមក្នុងមួយគ្រួសារផ្អែកលើផ្ទៃដីប្រមូលផល (តោន) | 2.23 | 2.50 | 2.44 |

[១] *ការប៉ាន់ប្រជាជនជនបទផ្អែកលើស្ថិតិជំរឿនឆ្នាំ១៩៩៨ និងផ្អែកលើការប៉ាន់អត្រាលូតលាស់ប្រជាជនកម្ពុជាដែលមានអត្រា ២.៤៩% ។*
[២] *ប្រមាណជា ៨៤.៣% នៃប្រជាជននៅតាមជនបទប្រកបមុខរបរក្នុងវិស័យកសិកម្មនាឆ្នាំ១៩៩៨* (Ramamurthy *et al.* 2001).
*ប្រភព:* NIS 2000, NIS 2001

គ្រួសារនៅតាមជនបទដែលប្រកបមុខរបរកសិកម្ម ពឹងផ្អែកទៅលើសកម្មភាពផ្សេងៗ ដើម្បីធានាសន្តិសុខស្បៀង និងប្រាក់ចំណូល ដូចជា ការដាំដុះដំណាំស្រូវ និងដំណាំផ្សេងៗទៀត សួនបន្លែគ្រួសារ ផលិតកម្មចិញ្ចឹមសត្វ ការនេសាទត្រី (សូមអានជំពូក៣) ការប្រមូលផលព្រៃឈើ (សូមអានជំពូកទី៤) និងលក់កំលាំងពលកម្ម ។ ទោះជាកំរិតនៃសន្តិសុខស្បៀង និងប្រាក់ចំណូលដែលទទួលបានពីសកម្មភាពទាំងនេះ មានការប្រែប្រួលពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេសយ៉ាងណាក៏ដោយ ប៉ុន្តែដំណាំស្រូវនៅតែជាអាហារយ៉ាងសំខាន់ចំពោះគ្រួសារនៅតាមជនបទ និងមិនអាចខ្វះបានសំរាប់ធានានូវសន្តិសុខស្បៀង ។ ប្រសិនបើគិតជាមធ្យមភាគ ស្រូវបានផ្តល់នូវតំរូវការថាមពល/កាល់ឡូរី ប្រមាណ ៦៥-៧៥% សំរាប់ប្រជាជនកម្ពុជា (Murshid 1998) ។ ស្រូវត្រូវបានរួមបញ្ចូលជាមួយនឹងត្រី (ត្រីស្រស់ ឬត្រីប្រហុក) និងបន្លែ គឺជាអាហារសំរាប់ទ្រទ្រង់ជីវភាពប្រជាជននៅតាមជនបទ ។

### *២.៦.១. ការបរិភោគអង្ករ និងប្រាក់ចំណូល*

នៅក្នុងប្រទេសកម្ពុជាការបរិភោគអង្ករក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំមានអត្រា ១៥០គីឡូក្រាម (Helmers1997) ។ ចំនួននេះស្មើនឹងស្រូវ ២៥០គីឡូក្រាម ឬតំរូវការ ១.៣តោនក្នុងមួយគ្រួសារ[១១] ។ តំរូវការស្រូវប្រមាណ ៥០០គីឡូក្រាមបន្ថែមទៀតអាចទុកធ្វើពូជជារៀងរាល់ឆ្នាំ ការបាត់បង់ក្រោយប្រមូលផល បុណ្យទាន និងសកម្មភាពផ្សេងៗ ។ ដូច្នេះគិតជាមធ្យមក្នុងមួយគ្រួសារត្រូវការស្រូវប្រហែល ១.៨តោនសំរាប់ទុកបរិភោគ ។ ប្រសិនបើប្រៀបធៀបផលិតផលជាមធ្យមក្នុងមួយគ្រួសារនាឆ្នាំ២០០០-០១ មាន ២.៤តោន គឺបានសេចក្តីថា កំរិតផលិតកម្មដែលមានផលលើសមានប្រមាណ ០.៦តោន ។ ប៉ុន្តែជាប្រការសំខាន់ គេគួរតែកត់សំគាល់ដែរថា ផលិតកម្មដំណាំស្រូវមានការប្រែប្រួលពីតំបន់មួយទៅតំបន់មួយទៀត ជាពិសេសនៅក្នុងតំបន់ដែលមានផលិតផលស្រូវលើស និងតំបន់ដែលខ្វះខាត ។

តំលៃសរុបនៃផលិតផលស្រូវក្នុងមួយគ្រួសារមាន ២០០-៣០០ដុល្លារ បើសិនជាយើងគិតផ្អែកទៅលើផលិតផលជាមធ្យម ២.៤តោន និងតំលៃស្រូវក្នុងមួយគីឡូក្រាមមាន ៣០០-៥០០រៀល ។ បើសិនជា ស្រូវ ១.៨តោនទុកសំរាប់បរិភោគបានន័យថា មានតែ ០.៦តោនប៉ុណ្ណោះដែលសល់សំរាប់លក់ដូរ ដែលគិតជាទឹកប្រាក់ប្រហែលជា ៥០-៨០ដុល្លារ សំរាប់ធ្វើការទូទាត់ទៅលើថ្លៃជី ថ្នាំពុល និងជួលកំលាំងពលកម្ម ។ ដូចនេះ ផលិតផលស្រូវហាក់ដូចជាមិនអាចរកចំណូលបានច្រើនឡើយ ប៉ុន្តែ

[១១] អង្ករត្រូវបានកិនមកពីម៉ាស៊ីនកិនស្រូវនៅក្នុងភូមិដែលផលិតបានជាមធ្យមប្រមាណ ៥៣% នៃទំងន់ស្រូវ ។ ប៉ុន្តែ ម៉ាស៊ីនកិនស្រូវដែលមានប្រសិទ្ធិភាពខាងពាណិជ្ជកម្ម អត្រាកិនជាអង្ករមានពី ៦០% ឬខ្ពស់ជាងនេះ (Rickman *et al.* 2001) ។ បើម៉ាស៊ីនមានប្រសិទ្ធិភាពនៅកម្ពុជាដែលមានអត្រាកិនអង្ករជាមធ្យមប្រមាណជា ៦០% នោះផលិតផលស្រូវ ២៥០គ.ក អាចផលិតបានអង្ករ ១៥០គ.ក ។ ចំនួនសមាជិកក្នុងមួយគ្រួសារជាមធ្យមនៅកម្ពុជានាឆ្នាំ១៩៩៨ មាន ៥.២នាក់ ដូចនេះ តំរូវការបរិភោគស្រូវក្នុងមួយគ្រួសារមាន ១.៣តោន ។

សន្តិសុខស្បៀងនៅតែជាហេតុផលសំខាន់ចំពោះការដាំដុះដំណាំស្រូវ ។

### ២.៦.២. ការបរិភោគបន្លែ និងប្រាក់ចំណូល

ការដាំបន្លែ និងដំណាំផ្សេងៗទៀតតំណាងឱ្យសក្តានុពលភាពសំខាន់ ដែលជាប្រភពនៃជីវជាតិវីតាមីន ជីវជាតិរ៉ែ និងប្រូតេអ៊ីន ដែលអាចជួយប្រឆាំងនឹងកង្វះជីវជាតិ និងបញ្ហារួមផ្សំផ្សេងទៀត (ឧទាហរណ៍ រោគរាកូរុស បណ្តាលមកពីកង្វះជីវជាតិដែក និងរោគខ្វាក់មាន់ បណ្តាលមកពីកង្វះជីវជាតិអា) ។ អត្រានៃការបរិភោគបន្លែនៅក្នុងប្រទេសកម្ពុជា ហាក់ដូចជានៅក្រោមកំរិតអនុសាសន៍ដែលបានកំណត់ ។ ការបរិភោគបន្លែក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃមានប្រមាណ ១០០ក្រាមនៅក្នុងឆ្នាំ១៩៩៤ និង ៤១ក្រាមក្នុងមួយថ្ងៃនៅក្នុងឆ្នាំ១៩៩៩ (Ungsa and Hean 1994, Zaman 2000) ចំណែកឯអង្គការ FAO បានផ្តល់អនុសាសន៍ក្នុងការបរិភោគបន្លែក្នុងមួយថ្ងៃ ២០០ក្រាម និងអង្គការសុខភាពពិភពលោកដល់អនុសាសន៍ក្នុងការបរិភោគបន្លែក្នុងមួយថ្ងៃប្រមាណជា ៣០០ក្រាមឯណោះ ។ ប៉ុន្តែប្រភពរបាយការណ៍ទាំងពីរខាងលើ ស្តីពីការគណនាអត្រាបរិភោគបន្លែរបស់ប្រជាជនកម្ពុជា ហាក់ដូចជាសាមញ្ញដោយសារពួកគេយកតួលេខប្រចាំឆ្នាំនៃផលិតកម្មដំណាំបន្លែ ចែកជាមួយនឹងចំនួនប្រជាជនកម្ពុជាសរុប ។ វិធីសាស្ត្រនេះពុំបានបូកបញ្ចូលបន្លែដែលបរិភោគពីផលិតកម្មក្រៅផ្លូវការ (ឧទាហរណ៍ សួនបន្លែគ្រួសារ) និងការនាំចូលបន្លែយ៉ាងសន្ធឹកសន្ធាប់ពីប្រទេសវៀតណាម និងថៃ ។ ជាការពិត លទ្ធផលដែលបានមកពីការអង្កេតដែលមានកំរិតកំណត់បានរកឃើញថា បន្លែដែលបានបរិភោគនៅក្នុងប្រទេសកម្ពុជា គឺបានមកពីការនាំចូលដែលមានអត្រា ២៥-៥០%[១២] ។

នៅពេលដែលគេធ្វើការគណនាផលិតផលបន្លែក្រៅផ្លូវការ និងបន្លែនាំចូលរួមបញ្ចូលគ្នានៅក្នុងផលិតកម្មបន្លែសរុប នោះការបរិភោគក្នុងមនុស្សម្នាក់ប្រហែល ៨០-៩០ក្រាមក្នុងមួយថ្ងៃ (ឬ ៣០-៣៥គីឡូក្រាម/ឆ្នាំ)[១៣] ។ ការពិត ការបរិភោគបន្លែជាក់ស្តែង មានការប្រែប្រួលគួរឱ្យកត់សំគាល់ពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេស ជាពិសេសការបរិភោគបន្លែនៅតាមទីប្រជុំជន (នៅទីណាដែលបន្លែភាគច្រើនបំផុតត្រូវបានគេធ្វើការលក់ដូរ) ហាក់ដូចជាមានអត្រាខ្ពស់ជាងនៅតាមតំបន់ជនបទ ។ បន្ថែមពីលើនេះ គ្រួសារប្រជាជននៅតាមជនបទដែលមានសួនបន្លែគ្រួសារ ពួកគេបរិភោគបន្លែច្រើនជាងគ្រួសារដែលគ្មានសួនបន្លែគ្រួសារ ។ ការអង្កេតថ្មីៗនេះទៅលើ ៦៨០គ្រួសារនៃខេត្តចំនួន៥ បានរកឃើញថា ៤៥៩គ្រួសារ (ឬ២ភាគ៣) មានសួនបន្លែគ្រួសារ (Helen Keller International Cambodia 2000) ។

### ២.៦.៣. ការបរិភោគបសុសត្វ និងប្រាក់ចំណូល

ដោយសារវាជាប្រភពផ្តល់ប្រូតេអ៊ីន ផលិតផលបសុសត្វបន្តដើរតួនាទីបន្តិចបន្តួចនៅក្នុងការផ្តល់នៅជីវជាតិជាមធ្យមដល់ប្រជាជនកម្ពុជានៅតាមជនបទ បើគេធៀបនឹងការបរិភោគត្រី ។ Maclean (1998) បានប៉ាន់ថា នាឆ្នាំ១៩៩៧ ការបរិភោគសាច់បសុសត្វប្រចាំឆ្នាំក្នុងមនុស្សម្នាក់ គឺប្រហែល ១៧,៥គីឡូក្រាមដែលក្នុងនោះការ បរិភោគសាច់ជ្រូកមាន ៨គីឡូក្រាម ការបរិភោគសាច់បសុបក្សីមាន ៦,៥គីឡូក្រាម ការបរិភោគសាច់គោ និងក្របីមាន ៣គីឡូក្រាម ។ បើធៀបជាមួយនឹងការសិក្សាស្តីពីការបរិភោគត្រី បានបញ្ជាក់ថា ការបរិភោគត្រីជាមធ្យមក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំមានប្រមាណ ២៧-៣៨គីឡូក្រាម ។

---

[១២] Cameron and Twyford-Jones (1995) បានប៉ាន់ស្មានឃើញថា យ៉ាងហោចណាស់បន្លែដែលបរិភោគនៅក្នុងប្រទេសកម្ពុជាប្រមាណ ៥០% គឺនាំចូលពីប្រទេសជិតខាង តួលេខនេះផ្អែកទៅលើការអង្កេត ដែលមានកំរិតកំណត់មួយ ។ Ungsa and Hean (1994) បានកំណត់ឃើញថា បន្លែដែលលក់នៅលើទីផ្សារនាទីក្រុងភ្នំពេញប្រមាណ ២៦% គឺជាបន្លែនាំចូល ។

[១៣] ផលិតកម្មបន្លែសរុបនៅក្នុងឆ្នាំ១៩៩៩ មានចំនួនពី ៣៥០.០០០ ដល់ ៤០០.០០០តោន ។ តួលេខនេះបានមកពីស្ថិតិរដ្ឋាភិបាលដែលក្នុងរបាយការណ៍មាន១៨០.០០០តោនបូកជាមួយនឹង ១២០.០០០តោនផ្សេងទៀត ដែលបានមកពីផលិតផលសួនបន្លែគ្រួសារ (ផ្អែកទៅលើការអង្កេតរបស់អង្គការ Hellen Keller International Cambodia 2000) រួមទាំងបន្លែនាំចូលដែលមានពី ៥០.០០០-១០០.០០០តោន ។ គ្មានតួលេខដែលប៉ាន់ស្មានពីការបេះបោចបន្លែមកពីក្នុងព្រៃទេ ។ ដោយសន្មតថា គ្មានការនាំចេញ និងគ្មានការខូចខាតនៅពេលដែលផលិតកម្មសរុបចែកជាមួយនឹងចំនួនប្រជាជនសរុប នោះគេទទួលបានអត្រានៃការបរិភោគបន្លែក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃមានពីរ ៨០ ទៅ ៩០ក្រាម ។

នេះបញ្ជាក់ឱ្យឃើញថា ការបរិភោគខុសគ្នាយ៉ាងច្រើនរវាងត្រី និងសាច់បសុសត្វ ហើយម្យ៉ាងវិញទៀត ការបរិភោគត្រីមានអត្រាខ្ពស់នៅតំបន់នេសាទតាមជនបទ (សូមអានជំពូកទី៣) ។ ការប៉ាន់ស្មានថ្នាក់ជាតិបានបញ្ជាក់ថា ផលិតផលបសុសត្វមានប្រមាណ ១/៣នៃសាច់ដែលបានបរិភោគ ដែលអត្រានេះហាក់ដូចជាមានកំរិតទាបយ៉ាងខ្លាំងនៅតាមតំបន់ជនបទ ។ គ្រួសារកសិករភាគច្រើនបរិភោគត្រឹមតែស៊ុត និងបសុបក្សីខ្លះៗតែប៉ុណ្ណោះ ចំណែកឯជ្រូក ត្រូវបានគេយកទៅលក់នៅឯទីសត្តឃាត (គោ និងក្របីត្រូវបានគេយកទៅលក់នៅពេលដែលវាគ្មានសមត្ថភាពបំរើការនៅក្នុងកសិដ្ឋាន) ដែលបំរើឱ្យអ្នកបរិភោគនៅតាមទីប្រជុំជន ។ ទោះជាគ្រួសារនៅតាមជនបទកំរនឹងទិញ សាច់ពីទីសត្តឃាតដើម្បីបរិភោគយ៉ាងណាក៏ដោយ ប៉ុន្តែគេក៏អាចបរិភោគសាច់ជ្រូក និងសាច់គោ នៅពេលដែលមានប្រារព្ធពិធីបុណ្យទាន និងក្នុងករណីខ្លះទៀត គេអាចបរិភោគសាច់បសុសត្វដែលងាប់ដោយសារគ្រោះថ្នាក់ចរាចរ ឬដោយសារជំងឺ (Maclean 1998) ។

គោ ក្របី និងជ្រូក គឺជាប្រភពចំណូលយ៉ាងសំខាន់សំរាប់គ្រួសារកសិករ ។ ជ្រូកត្រូវបានគេចិញ្ចឹមដោយផ្ទាល់សំរាប់លក់យកប្រាក់កាស ចំណែកឯគោ និងក្របី ត្រូវបានគេចិញ្ចឹមសំរាប់ធ្វើជាកំលាំងអូសទាញយ៉ាងសំខាន់ ។ ការបង្កាត់ពូជសត្វពាហនៈអាចជួយរកប្រាក់ចំណូលតាមរយៈការលក់កូនគោ និងសត្វពាហនៈ អូសទាញដែលអាចត្រូវបានគេជួលសំរាប់ការរៀបចំដី ។ បន្ថែមពីលើប្រាក់ចំណូល គោ និងក្របីតំណាងឱ្យមធ្យោបាយប្រសិទ្ធិភាពនៃការ "រក្សា" ទ្រព្យធន នៅពេលដែលវាមានអាយុកាលវែងនៅក្នុងផលិតភាព (គោមានអាយុ ៨-១០ឆ្នាំ ចំណែកឯក្របីមានអាយុកាលវែងជាងនេះ) និងនៅក្នុងករណីខ្លះទៀត គោត្រូវបានគេលក់ភ្លាមៗទៅឱ្យឈ្មួញសត្តឃាត ។

### *២.៦.៤. តួនាទីរបស់ជែនឌ័រ និងជនជាតិភាគតិចនៅក្នុងវិស័យកសិកម្ម*

នៅក្នុងការវាយតំលៃអំពីសារៈសំខាន់ នៃវិស័យកសិកម្មចំពោះជីវភាពរស់នៅតាមជនបទ ជាប្រការសំខាន់ផងដែរ ដែលគេត្រូវតែវាយតំលៃថា តើជែនឌ័រ និងជនជាតិភាគតិចអាចមានប្រសិទ្ធិភាពយ៉ាងដូចម្តេចទៅលើផលិតកម្ម សន្តិសុខស្បៀង និងប្រាក់ចំណូល ។ ទោះជាមានការសិក្សានានាស្តីពីជែនឌ័រ និងជនជាតិភាគតិចទាក់ទងនឹងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ ត្រូវបានគេធ្វើឡើងនៅក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ប៉ុន្តែលទ្ធផលនៃការសិក្សានេះ ជារឿយៗតែងតែមានភាពផ្ទុយគ្នា ដោយធ្វើឱ្យមានការលំបាកក្នុងការធ្វើការសន្និដ្ឋានបញ្ចប់ (Catalla et al. 2001) ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានសេចក្តីសន្និដ្ឋានទូទៅខ្លះៗត្រូវបានគេធ្វើការកំណត់ឡើង ។ ជាទូទៅជនជាតិខ្មែរ និងជនជាតិភាគតិចដែលរស់នៅតំបន់ខ្ពង់រាបតែងតែប្រកាន់យករបរកសិកម្មជាមូលដ្ឋានសំខាន់សំរាប់ធ្វើជាសកម្មភាពជីវភាពរស់នៅរបស់ពួកគេ ចំណែកឯជនជាតិចាម និងវៀតណាមជីវភាពរស់នៅរបស់ពួកគេពឹងផ្អែកយ៉ាងសំខាន់ទៅលើការនេសាទ (សូមអានជំពូកទី៣) ។ តួនាទីជាប្រពៃណីរបស់ជែនឌ័រ គឺមានស្រាប់នៅក្នុងវិស័យកសិកម្ម ប៉ុន្តែតួនាទីទាំងនេះនៅរឹងឆ្អឹង ឬមិនអាចបត់បែនបាន ។ ចំពោះកសិកម្មដំណាំស្រូវ និងដំណាំបន្លែ ស្ត្រីចូលរួមច្រើននៅក្នុងការដាំដុះ ស្ទូង ការជំរះស្មៅ ការដាក់ជី ការប្រមូលផល និងសកម្មភាពម៉ាយីទីង និងជំនួញ ។ ចំពោះ បុរសវិញមានតួនាទីសំខាន់នៅក្នុងការរៀបចំដី ការថែរក្សាភ្លឺ និងការដឹកជញ្ជូន (Ahlers *et al.* 1995, Yang Saing 1998, Pillot *et al.* 2000, Catalla *et al.* Norris 2001) ។

## ២.៧. ប្រវត្តិទូទៅនៃវិស័យកសិកម្ម កំលុងឆ្នាំ១៨៦៣-១៩៩៩ [១៤]

កសិករកម្ពុជាមានទំលាប់ដាំដុះដំណាំស្រូវយ៉ាងហោចណាស់២០០០ឆ្នាំមុនមកម្លោះ ដូចនេះ ស្រូវនៅតែជាអាហារយ៉ាងសំខាន់របស់ជាតិរហូតមកទល់សព្វថ្ងៃនេះ ។ កសិកម្មដែលពឹងផ្អែកលើដំណាំស្រូវ មានតួនាទីចំបងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាជាមួយនឹងរយៈពេល (ដែលកាលនោះ) មានផលិតភាពខ្ពស់ ដូចជានៅសម័យអង្គរ (សតវត្សរ៍ទី៩-១៤) និងមានដំណើរការថយក្រោយជារឿយៗដោយសារសង្គ្រាម និងសេចក្តីវេទនាដោយការតស៊ូ ។ ទោះបីជាហេតុការណ៍នេះ មិនបានបកស្រាយនៅ

[១៤] ផ្អែកនេះផ្អែកទៅលើឯកសាររបស់ Helmers (1997) ។

ក្នុងឯកសារពិភាក្សានេះ ដើម្បីរីកញែកឱ្យបានពិស្តារអំពីតួនាទីយ៉ាងសំខាន់របស់កសិកម្មនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ប៉ុន្តែ ការសង្ខេបទូទៅមួយស្តីពីផលិតកម្មកសិកម្មនៅក្នុងរយៈពេលថ្មីៗនេះ ត្រូវបានបកស្រាយដូចខាងក្រោម ដោយចាប់ផ្តើមពីរយៈពេលកំលុងអាណានិគមបារាំងនាឆ្នាំ១៨៦៣ រហូតដល់រយៈពេលបើកចំហសេដ្ឋកិច្ចទីផ្សារនៅឆ្នាំ១៩៨៩ ។

### ២.៧.១. កំលុងពេលអាណានិគមនិយមបារាំង (១៨៦៣-១៩៥៣)

នៅក្នុងកំលុងពេលដែលបារាំងដាក់អាណានិគមនៅក្នុងប្រទេសកម្ពុជា ផ្ទៃដីដាំដុះដំណាំស្រូវមានពី ០,៥លានហិកតាទៅដល់ ១,៧លានហិកតា ជាមួយនឹងទិន្នផលមធ្យមប្រមាណ ១តោន/ហិកតា (Tichit 1981/Helmers 1997) ។ សេដ្ឋកិច្ចអាណានិគមផ្តោតទៅលើការនាំចេញនៅផលិតផលកសិកម្ម-ស្រូវ និងការចិញ្ចឹមសត្វ បញ្ជូនទៅទីកន្លែងកែច្នៃកសិផលរបស់បារាំងដែលស្ថិតនៅទីក្រុង Saigon ។ បារាំងបាននាំចេញស្រូវតាមរយៈការអភិវឌ្ឍន៍ចំការធំៗ និងតាមរយៈការហូតយកពន្ធពីកសិករតូចតាច ។ ចំការធំៗសំរាប់ដាំដុះដំណាំស្រូវមានជាង ១៦.០០០ហិកតា ដែលត្រូវបានបង្កើតឡើងនៅក្នុងខេត្តបាត់ដំបង និងតំបន់ជុំវិញ ។ ចំការធំៗទាំងនេះផ្តោតទៅលើផលិតកម្មដំណាំស្រូវដែលមានគុណភាពខ្ពស់ ដោយប្រើប្រាស់វិធីសាស្ត្រកសិកម្មទំនើប ។ ចំការទាំងនេះត្រូវបានគាំទ្រដោយប្រព័ន្ធប្រលាយស្រោចស្រពប្រពលវប្បកម្ម ការបង្កាត់ពូជដំណាំ និងស្ថានីយពិសោធន៍ដី ។ ដោយហេតុថា ស្រូវមានសារៈសំខាន់ក្នុងការនាំចេញពីខេត្តបាត់ដំបង នោះគេបានស្ថាបនាផ្លូវដែកដែលភ្ជាប់ពីខេត្តនេះទៅទីក្រុងភ្នំពេញ ។ ធ្វើដូចនេះស្រូវអាចត្រូវបាននាំចេញតាមរយៈការដឹកជញ្ជូនផ្លូវទឹកទៅកាន់ទីក្រុង Saigon ។

កសិករកម្ពុជាដែលមានដីកសិដ្ឋានតូច បានបង់ពន្ធក្នុងកំរិតយ៉ាងខ្ពស់បំផុត ទៅឱ្យរដ្ឋាភិបាលអាណានិគមក្នុងចំណោមកសិករក្នុងតណ្ឌចិនដែលគ្រប់គ្រងដោយបារាំង (ជាស្រូវ ជាកំលាំងពលកម្ម និងជាសាច់ប្រាក់) ។ ជាការឆ្លើយតបមកវិញ រដ្ឋាភិបាលអាណានិគមស្ទើរតែពុំមានផ្តល់ការគាំទ្រជាសេវា ដល់កសិករដែលមានផ្ទៃដីកសិដ្ឋានតូចសោះឡើយ ។ ថ្វីបើមានបញ្ហាលំបាកទាំងនេះក៏ដោយ ប៉ុន្តែកម្ពុជាបានក្លាយទៅជាប្រទេស ដែលនាំស្រូវចេញធំបំផុតទីបីនៅក្នុងពិភពលោកនៅក្នុងឆ្នាំ១៩៤០ ដោយសារការពង្រីកផ្ទៃដីដាំដុះនៃកសិករតូចតាច ។ ស្រូវនាំចេញសំរេច បានរហូតដល់ ២០០.០០០តោន ដែលក្នុងនោះ ៣០.០០០តោន បានមកពីចំការស្រូវធំៗនៃខេត្តបាត់ដំបង និងក្រៅពីនោះបានមកពីកសិករដែលមានផ្ទៃដីកសិដ្ឋានតូច ។

### ២.៧.២. កំលុងពេលទទួលបានឯករាជ្យ (១៩៥៣-១៩៧៥)

ពីឆ្នាំ១៩៥៣ ទៅដល់ឆ្នាំ១៩៦៣ ផ្ទៃដីដាំដុះដំណាំស្រូវបានពង្រីកពី ៥០០.០០០ហិកតារហូតដល់ ២,២លានហិកតា និងមានទិន្នផលកើនឡើងតិចតួចប្រមាណ ១,១តោន/ហិកតា ។ ផលិតផលស្រូវសរុបមាន ២,៣លានតោន ហើយអង្ករដែលនាំចេញសំរេចបានក្នុងកំរិត ២៥០.០០០-៤០០.០០០តោន/ឆ្នាំ ។ នៅក្នុងឆ្នាំ១៩៦៤ រដ្ឋាភិបាលកម្ពុជាបានដាក់ពាណិជ្ជកម្មក្រៅប្រទេស (ដោយរួមបញ្ចូលការនាំចេញផលិតផលស្រូវ) ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដែលជាការគ្រប់គ្រងតាមបែបផ្តាច់មុខ ។ ជាដំបូងការនាំចេញជាផ្លូវការកើនឡើង ដោយសារការកែលំអសាជីវកម្មរបស់រដ្ឋមានការប្រសើរឡើងនៅក្នុងការប្រមូលស្រូវពីកសិករ ។ ប៉ុន្តែ ដោយហេតុថាតំលៃស្រូវដែលរដ្ឋាភិបាលទិញពីកសិករមានអត្រាថេរ និងទាបជាងតំលៃទីផ្សារ ហេតុដូចនេះ វាបានលើកទឹកចិត្តឱ្យមានការរត់ពន្ធស្រូវសំរាប់នាំចេញជាជាងលក់ទៅឱ្យរដ្ឋ ។ ការប៉ាន់ស្មានមួយបានបញ្ជាក់ឱ្យឃើញថា ស្រូវនាំចេញប្រមាណ ១/៣ នៅក្នុងឆ្នាំ១៩៦៦ ត្រូវបានគេលក់តាមរយៈ "ទីផ្សារងងឹត" ដែលនៅទីនោះតំលៃស្រូវដែលទទួលបានថ្លៃលើសបីដងនៃតំលៃស្រូវដែលកំណត់ដោយរដ្ឋ ។ នៅពេលដែលចំណូលរបស់រដ្ឋមានការធ្លាក់ចុះយ៉ាងខ្លាំង នោះរដ្ឋបានធ្វើការឆ្លើយតបដោយបង្ខំប្រមូលទិញស្រូវនៅក្នុងតំលៃជាផ្លូវការមួយ ។ កត្តានេះបានឈានទៅរកការតស៊ូដោយប្រដាប់អាវុធ ដែលធ្វើឡើងដោយកសិករនៅក្នុងខេត្តបាត់ដំបង និងខេត្តដទៃផ្សេងទៀតនៅក្នុងកំលុងឆ្នាំ១៩៦៧-៦៨ ។

កម្ពុជាបានផលិតដំណាំស្រូវបានខ្ពស់បំផុតរហូតដល់ ៣,៨លានតោននៅក្នុងឆ្នាំ១៩៦៩-៧០ ដោយសារអាកាសធាតុអំណោយផល ។ ប៉ុន្តែរយៈពេលខ្លីបន្ទាប់ពីការប្រមូលផលនេះមក របបលន់ ណុល បានកាន់អំណាច ហើយប្រទេសកម្ពុជាបាន

ធ្លាក់ទាំងស្រុងចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនជាលើកទីពីរ ។ ការវាយប្រហារគ្នានេះ បានធ្វើឱ្យខ្ទេចខ្ទាំដល់ផលិតកម្មដំណាំស្រូវ ការចិញ្ចឹមសត្វ និងហេដ្ឋារចនាសម្ព័ន្ធជនបទ ។ ស្ថិតិជាផ្លូវការបានបញ្ជាក់ឱ្យឃើញថា ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៤ ផ្ទៃដីដាំដុះដំណាំស្រូវធ្លាក់ចុះរហូតដល់ ៧៧% និងផលិតផលស្រូវធ្លាក់ចុះ ៨៤% ។

### *២.៧.៣. កម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩*

នៅក្នុងការអភិវឌ្ឍន៍កសិកម្មរបបខ្មែរក្រហម (របបកម្ពុជាប្រជាធិបតេយ្យ) មានបំណងបង្កើនផលិតផលស្រូវឱ្យបានបីដង ដោយអនុវត្តការដាំដុះដំណាំទ្វេ ឬបីដងក្នុងមួយឆ្នាំឱ្យបាន ។ ដើម្បីធ្វើឱ្យផែនការសំរេចទៅបាននោះ ពួកគេបានយកពូជស្រូវទំនើបដែលមានទិន្នផលខ្ពស់ មកជំនួសឱ្យពូជស្រូវប្រពៃណីដែលមានទិន្នផលទាប សាងសង់និងពង្រីកប្រព័ន្ធស្រោចស្រព និងបង្កើនផ្ទៃដីដាំដុះដោយកាប់ឆ្ការដីព្រៃបន្ថែម ។ នៅក្នុងឯកសារមួយដែលបានកត់ត្រាយ៉ាងត្រឹមត្រូវ កិច្ចខិតខំប្រឹងប្រែងនេះទទួលបាននូវបរាជ័យទាំងស្រុង (Shawcross 1979, Chandler 1993) ។ ចំពោះវិស័យកសិកម្ម របបខ្មែរក្រហមបានរួមបញ្ចូលចំនួនប្រព័ន្ធស្រោចស្រពដែលមិនអាចប្រើប្រាស់បានយ៉ាងច្រើនសន្ធឹកសន្ធាប់ (ប្រហែលពី ៧០% ទៅ ៨០% នៃប្រព័ន្ធស្រោចស្រពដែលបានស្ថាបនារួច) និងការបំផ្លាញចោលនូវអ្នកធ្វើផែនការកសិកម្ម អ្នកបច្ចេកទេសកសិកម្ម និងអ្នកនយោបាយកសិកម្ម ដែលមានចំនួនពី ១.៦០០ ទុកត្រឹមតែ ២០០នាក់ ដែលក្នុងនោះមានត្រឹមតែ ១០នាក់ប៉ុណ្ណោះដែលបានទទួលការអប់រំមកពីសាកលវិទ្យាល័យ ។ ស្ថានីយពិសោធន៍កសិកម្ម ក៏ត្រូវបានបំផ្លិចបំផ្លាញ សម្ភារកម្មពូជ និងទិន្នន័យបច្ចេកទេស ក៏ត្រូវបានបាត់បង់ (Mysliwiec 1988) ។

### *២.៧.៤. សេដ្ឋកិច្ចផែនការ ១៩៧៩-១៩៨៩*

ឆ្លើយតបទៅនឹងការគំរាមកំហែងដោយគ្រោះទុរភិក្សដែលរីករាលដាល និងកង្វះខាតកំលាំងពលកម្ម សត្វពាហនៈអូសទាញ និងឧបករណ៍បំរើផលិតកម្មនៅក្នុងឆ្នាំ១៩៧៩ ពេលនោះកសិកម្មត្រូវបានគេរៀបចំឱ្យមានឡើង ដោយផ្អែកទៅលើការប្រមូលផ្តុំគ្នាជាក្រុមដោយក្នុងមួយក្រុមមានសមាជិក ២០-២៥គ្រួសារ (ក្រុមសាមគ្គី) ហើយមានគោលបំណងចែករំលែកគ្នាទៅវិញទៅមកនូវធនធានដែលខ្សត់ខ្សោយ និងសំរេចឱ្យបាននូវសេចក្តីត្រូវការស្បៀងជាបន្ទាន់មួយ ។ ដីធ្លីទាំងអស់បានក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែក្រុមសាមគ្គីត្រូវបានគេអនុញ្ញាតឱ្យគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មផងដែរ ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ក្រុមសាមគ្គីមិនបានដើរតាមគោលការណ៍សហករឡើយ ក្នុងករណីភាគច្រើនពួកគេចូលចិត្តធ្វើការដាំដុះជាលក្ខណៈគ្រួសារឯកជននៅលើដីរួម ប៉ុន្តែគេអាចប្រវាស់កំលាំងពលកម្ម ឧបករណ៍ និងកំលាំងអូសទាញជាមួយគ្នា ។ ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៩ ផ្ទៃដីដាំដុះដំណាំស្រូវកើនពី ១,៤លានហិកតារហូតដល់ ១,៩លានហិកតា ព្រមជាមួយគ្នានោះ ទិន្នផលមានការកើនឡើងបន្តិចបន្តួចពី ១,២តោន/ហិកតា ដល់ ១,៤តោន/ហិកតា ។ ទោះជាផលិតកម្មដំណាំស្រូវមានការឡើងចុះខ្លាំងក្នុងកំលុងរយៈពេលនេះក៏ដោយ ដូចជាឆ្នាំដែលខ្សត់ខ្សោយ គឺឆ្នាំ១៩៨១ (១,៩លានតោន) និងឆ្នាំ១៩៨៤ (១,៣លានតោន) ប៉ុន្តែទិន្នផលសំរេចបាននៅក្នុងឆ្នាំ១៩៨៩ មានរហូតដល់ ២,៦លានតោន ។

នៅក្នុងឆ្នាំ១៩៨៩ បានបង្ហាញយ៉ាងច្បាស់ថា ក្រុមសហករមិនអាចទទួលយកបានឡើយ ហើយប្រព័ន្ធសេដ្ឋកិច្ចផែនការបានទទួលបរាជ័យ (Frings 1993) ។ បន្ថែមពីលើនេះទៀត ប្រទេសកម្ពុជាបានទទួលផលប៉ះពាល់ពីការកាត់បន្ថយជំនួយពីប្លុកប្រទេសលោកខាងកើត ។ ឆ្លើយតបទៅលើបញ្ហានេះ គោលនយោបាយថ្មីបានផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារ ។ ក្នុងផ្នែកមួយនៃកំណែទំរង់នេះ កម្មសិទ្ធិឯកជនរួមមាន កម្មសិទ្ធិឯកជនទៅលើដីធ្លីត្រូវបានគេបង្កើតឡើង ដោយអនុញ្ញាតឱ្យមានការបែងចែកដីកម្មសិទ្ធិរួមឱ្យទៅជាកម្មសិទ្ធិគ្រួសារ ។

## ២.៨. ស្ថានភាពទូទៅស្តីពីតួនាទីរបស់ស្ថាប័ននានានៅក្នុងវិស័យកសិកម្ម

ចាប់តាំងពីមានកំណែទំរង់នៅក្នុងឆ្នាំ១៩៨៩មក សេដ្ឋកិច្ចកម្ពុជាបានផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារ

សេរី ។ កត្តានេះត្រូវការចាំបាច់ឱ្យមានការផ្លាស់ប្តូរជាដុំកំភួន ដែលក្នុងនោះស្ថាប័នរដ្ឋាភិបាល និងសាធារណៈ គាំទ្រទៅដល់វិស័យកសិកម្ម ។ ឧទាហរណ៍ មុនពេលដែលមានកំណែទំរង់រដ្ឋាភិបាល គឺជាអ្នកនាំចូល និងចែកចាយជីគីមីតែឯងគត់ ។ ដូចដែលបានកត់សំគាល់ពីខាងលើ នៅដើមទសវត្សរ៍ទី៩០ វិស័យឯកជនផ្គត់ផ្គង់ជីគីមី បានឈានជើងចូលមកទីផ្សារកម្ពុជា និងបានចូលរួមនៅក្នុងកំនើននៃចំណែកហ៊ុននៅលើទីផ្សារយ៉ាងឆាប់រហ័ស ។ នៅក្នុងរយៈពេលនោះរដ្ឋាភិបាលបានបញ្ចប់តួនាទីរបស់ខ្លួននៅក្នុងការគាំទ្រជីគីមី ហើយចុងបញ្ចប់ ការផ្តល់ជំនួយជីគីមី និងភ្នាក់ងារម៉ាឃីទីងគ្រប់គ្រងដោយរដ្ឋ ត្រូវបានលុបចោលនៅក្នុងឆ្នាំ១៩៩៩ (ក្រសួងពាណិជ្ជកម្ម ២០០១) ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នដ៏សំខាន់មួយ ដែលទទួលខុសត្រូវទៅលើការអភិវឌ្ឍន៍ ។ បណ្តានាយកដ្ឋានកសិកម្ម និងកម្មវិធីនានាដែលស្ថិតនៅក្រោមក្រសួងនេះ ផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍន៍ដំណាំ (រួមបញ្ចូលទាំងការស្រោចស្រព) អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ជំរុញការកែច្នៃផលិតផលកសិកម្ម ការស្រាវជ្រាវ និងការអប់រំ ការផ្សព្វផ្សាយ និងសេវាបច្ចេកទេស ។ បណ្តាក្រសួង និងភ្នាក់ងារសាធារណៈនានា ក៏មានតួនាទីសំខាន់នៅក្នុងវិស័យកសិកម្មផងដែរ ដែលអាណត្តិរបស់ខ្លួនបំពេញគ្នា (ជួនកាលជាន់គ្នា) ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ ស្ថាប័នសំខាន់ៗ និងការទទួលខុសត្រូវរបស់គេ ដែលទាក់ទងនឹងវិស័យកសិកម្មរួមមានៈ

- ក្រសួងអភិវឌ្ឍន៍ជនបទ - ការអភិវឌ្ឍន៍ដំណាំ ការស្តារផ្លូវលំឡើងវិញ ការគ្រប់គ្រងធនធានទឹក ការស្រាវជ្រាវនិងការផ្សព្វផ្សាយ ។
- ក្រសួងធនធានទឹក និងឧតុនិយម - គ្រប់គ្រងធនធានទឹកដោយរួមបញ្ចូលទាំងប្រព័ន្ធស្រោចស្រព ។
- ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្ម និងសំណង់- គ្រប់គ្រងដីធ្លី ។
- ក្រសួងបរិស្ថាន-ការពារ និងគ្រប់គ្រងតំបន់បរិស្ថាន វាយតំលៃ និងការបន្ធូរបន្ថយនៃសក្តានុពលភាពនៃផលប៉ះពាល់ដល់បរិស្ថាន ។
- ក្រសួងពាណិជ្ជកម្ម- ជំរុញ និងគាំទ្រដល់ម៉ាឃីទីង ជំនួញ និងការនាំចេញ ។
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន- ជំរុញទៅដល់ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ ។
- វិទ្យាស្ថានកម្ពុជាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម - អភិវឌ្ឍន៍ពូជស្រូវថ្មីៗ និងពង្រីកពូជស្រូវ ។

## ២.៩. សម្បទានកសិកម្ម

បន្ថែមពីលើសកម្មភាពដែលបានអធិប្បាយ MAFF ទទួលខុសត្រូវក្នុងកិច្ចត្រួតពិនិត្យមើលការជួលសម្បទានកសិកម្ម ។ គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ផ្ទៃដីសម្បទានកសិកម្មសរុបនៅក្នុងប្រទេសកម្ពុជា មានទំហំ ៨០៩.២៩៦ហិកតា ត្រូវបានជួលទៅឱ្យក្រុមហ៊ុនឯកជនចំនួន ៤០ (តារាងទី២.៨) ។ ក្រុមហ៊ុនសម្បទានទាំង ៤០ នេះ បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី (CoM) ប៉ុន្តែមានតែ ២៥ក្រុមហ៊ុនប៉ុណ្ណោះ ដែលបានធ្វើកិច្ចព្រមព្រៀងជាមួយ MAFF (សេចក្តីអធិប្បាយកាន់តែពិស្តារបន្ថែមទៀតស្តីពីដំណើរការនៃការផ្តល់សម្បទានកសិកម្ម សូមអាន Chan *et al.* 2001) ក្នុងកំលុងរយៈពេល ២-៣ឆ្នាំកន្លងមក មានក្រុមហ៊ុនសម្បទានដីកសិកម្មចំនួន ១៦ ត្រូវបានលុបចោល ឬដកខ្លួនចេញ ។

**តារាងទី២.៨. សម្បទានកសិកម្មនៅក្នុងប្រទេសកម្ពុជា (គិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១)**[១]

| ស្ថានភាពសម្បទាន | ចំនួនសម្បទាន | ផ្ទៃដីសម្បទានសរុប (ហិកតា) | ចំនួនសម្បទានដែលមានផ្ទៃដីលើសពី ១០.០០០ហិកតា |
|---|---|---|---|
| សម្បទានដែលទទួលបានការយល់ព្រមពី CoM | 25 | 723,606 | 11 out of 25 |

| | | | |
|---|---|---|---|
| និងចុះកិច្ចសន្យាជាមួយ MAFF<br>សម្បទានដែលទទួលបានការយល់ព្រមពី CoM និងពុំទាន់ចុះកិច្ចសន្យាជាមួយ MAFF ឡើយ | 15 | 85,690 | 3 out of 15 |
| **សរុប** | **40** | **809,296** | **14 out of 40** |
| ការលុបចោលសម្បទាន | 16 | 123,680 | 5 out of 16 |

*[១] សូមអាននៅក្នុងឧបសម្ព័ន្ធ-ក ចំពោះពត៌មានពិស្តារស្តីពីសម្បទានកសិកម្មនៅក្នុងប្រទេសកម្ពុជា ។ ប្រភព: MAFF 2001.*

ក្រុមហ៊ុនសម្បទានទាំង ៤០កំពុងតែធ្វើកិច្ចសន្យា ឬព្យាយាមធ្វើកិច្ចសន្យា មានមូលដ្ឋានសំខាន់ស្ថិតនៅក្នុងតំបន់ព្រៃឈើ ។ សម្បទានិក គឺផ្តោតសំខាន់ទៅលើការដាំដុះដំណាំដូងប្រេង (៩សម្បទាន) ដំណាំដំឡូងមី (៩សម្បទាន) ដំណាំកៅស៊ូ (៨សម្បទាន) និងដំណាំស្វាយចន្ទី (៧សម្បទាន)[១៥] ។ ផ្ទៃដីសម្បទានដែលមានទំហំធំជាងគេបង្អស់ ត្រូវបានជួលទៅឱ្យក្រុមហ៊ុនភាពីម៉ិច (មាន ៣១៥.០២៨ហិកតាស្ថិតនៅក្នុងខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំ ដោយដាំចំការឈើដែលគាំទ្រទៅដល់រោងចក្រក្រដាស) និងក្រុមហ៊ុន Green Sea Industry ១០០.៨៥២ហិកតា ស្ថិតនៅខេត្តស្ទឹងត្រែងដែលដើមម៉ៃសាក់) ។ ក្នុងចំណោមដីសម្បទានទាំង ៤០ក្រុមហ៊ុនក្នុងនោះមាន ១៤ក្រុមហ៊ុន ដែលមានផ្ទៃដីលើសពី ១០.០០០ហិកតាដែលជាទំហំអតិបរមាដែលបានអនុញ្ញាតនៅក្រោមច្បាប់ថ្មី គឺច្បាប់កម្មសិទ្ធិអចលទ្រព្យ (ត្រូវបានគេស្គាល់ថា ជា "ច្បាប់ដីធ្លី") ពត៌មានលំអិតស្តីពីដីសម្បទាននៅក្នុងប្រទេសកម្ពុជា ដែលដកស្រង់ចេញពីរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានអធិប្បាយនៅក្នុងឧបសម្ព័ន្ធ-ក ។

ទោះជាសក្តានុពលភាពអភិវឌ្ឍន៍សម្បទានកសិកម្មនៅក្នុងប្រទេសកម្ពុជា អាចធ្វើទៅរួចបានដោយកន្លែងក៏ដោយ ក៏ការវិភាគទៅលើ ២៥សម្បទានដែលមានកិច្ចសន្យាបានបញ្ជាក់ឱ្យឃើញអំពីបញ្ហាមួយចំនួនដូចខាងក្រោម:

- **ការប្រមូលចំណូលរបស់រដ្ឋាភិបាលជាផ្លូវការ** - មានតែសម្បទានិកចំនួន ៨ក្នុងចំណោម ២៥ប៉ុណ្ណោះដែលបានបង់ប្រាក់របស់គេដល់រដ្ឋាភិបាល នេះបានន័យថាសម្បទានកសិកម្ម មិនបានរកចំណូលច្រើនដល់រដ្ឋាភិបាលឡើយ ។
- **ការចុះកំណត់ចំនុចគោលដីសម្បទាន** - មានតែសម្បទានិកចំនួន ១០ ប៉ុណ្ណោះ ដែលបានចុះកំណត់ចំនុចគោលដីសម្បទានបានរួចរាល់ ។ សម្បទានិក ៣ទៀត បានចុះកំណត់ច្បាស់លាស់អំពីដីសម្បទានរបស់ខ្លួន ឯ ១០ទៀតមិនទាន់បានបញ្ចប់ការងារនេះនៅឡើយទេ ។ សម្បទានិក ២ទៀតគ្មានពត៌មាន ។
- **ជម្លោះដីធ្លី និងការទន្ទ្រានកាន់កាប់ដី** - ១៦សម្បទានិកក្នុងចំណោម ២៥បានជួបប្រទះបញ្ហាស្តីពីការតវ៉ា ឬការទន្ទ្រានយកដីសម្បទានពីសំណាក់ប្រជាជនមូលដ្ឋាន ។

បញ្ហាដទៃទៀតទាក់ទងនឹងសម្បទានកសិកម្ម ហាក់ដូចជាគ្មានដំណើរការដេញថ្លៃ និងគ្រប់គ្រងច្បាស់លាស់ ដូចព្រៃសម្បទានឡើយ ។ នៅក្រោម*អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន* ការផ្តល់ព្រៃសម្បទានត្រូវតែពាក់ព័ន្ធទៅនឹងដំណើរការដេញថ្លៃជាសាធារណៈ និងដោយការប្រកួតប្រជែង (មាត្រាទី ៤.៤ក-ម) នៅក្នុងច្បាប់សម្បទានកសិកម្មគ្មានដំណើរការប្រព្រឹត្តិទៅដូចនេះឡើយ ។ ដូចនេះនាពេលបច្ចុប្បន្ន ហាក់ដូចជាមានលទ្ធភាពក្នុងការជៀសវាងដំណើរការដេញថ្លៃព្រៃសម្បទាន (និងតំរូវការគ្រប់គ្រងព្រៃសម្បទាននាពេលអនាគត) ដោយគេជ្រកនៅក្រោមផ្លាកដីសម្បទានជំនួសឱ្យព្រៃសម្បទានវិញ ។ ជាការពិតនាពេលថ្មីៗនេះ យ៉ាងហោចណាស់មានករណីពីរយ៉ាង (Tumring ដំណាំកៅស៊ូនៅក្នុងខេត្តកំពង់ធំ និង Green Sea Industry នៅក្នុងខេត្តស្ទឹងត្រែង) ដែលអតីតតំបន់ព្រៃសម្បទានត្រូវបានគេជួលក្រោមរូបភាពកសិកម្មសម្បទានវិញ បន្ទាប់ពីក្រុមហ៊ុនឈើទាំងនេះបានត្រូវគេហៅឱ្យប្រមូលផលឈើហ៊ុប (NGO Forum 2002) ។ គួរឱ្យកត់សំគាល់ដែរថា ការផ្តល់សម្បទានទៅដល់តំបន់ដែលជាអតីតព្រៃសម្បទាន វារំលោភទៅលើមាត្រា៥.៤ នៃ*អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន* ដែលបាន

[១៥] តាមរបាយការណ៍សម្បទានិកជាច្រើន ដាំដំណាំច្រើនជាងមួយមុខ ។

ថែងថា ព្រៃសម្បទានដែលលុបចោលត្រូវការពារជាតំបន់ព្រៃធម្មជាតិ ។

## ២.១០. ការលំបាកផ្នែកខាងរូបសាស្ត្រ នៅក្នុងការបង្កើនផលិតកម្មកសិកម្ម

ទោះបីជាមានការលំបាកនៅក្នុងផលិតកម្មកសិកម្មមានការខុសប្លែកគ្នា ដោយផ្អែកទៅលើប្រភេទនៃសកម្មភាព ដែលមានស្រូវ ដំណាំផ្សេងៗ ផលិតកម្មចិញ្ចឹមសត្វ និងកត្តាដទៃផ្សេងៗទៀតក៏ដោយ ក៏គេមានលទ្ធភាពក្នុងការវិភាគជាទូទៅស្ដីពីបញ្ហាលំបាកបំផុតទៅលើផ្នែករូបសាស្ត្រ ។ បញ្ហានេះរួមមានរបាយទឹកភ្លៀង ទឹកជំនន់ ភាពរាំងស្ងួត ជីជាតិដី កត្តាចង្រៃ និងជំងឺដែលជាកត្តាបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរទៅលើផលិតកម្មកសិកម្មដល់ប្រទេសកម្ពុជា ។ នៅតាមតំបន់ខ្លះ ការកែលំអបញ្ហាលំបាករូបសាស្ត្រ ដើម្បីបង្កើនផលិតកម្មកសិកម្មនាពេលអនាគតនៅតែមានភាពស្រពិចស្រពិល ដោយសារតែដំណោះស្រាយខាងបច្ចេកទេស (ការស្រោចស្រព ការប្រើប្រាស់ជីគីមី និងថ្នាំពុល) មិនបានគ្រប់គ្រាន់ ឬក៏វិធីសាស្ត្រមានតំលៃថ្លៃពេកដែលពុំអាចទទួលយកបាន ។

### *២.១០.១. របាយទឹកភ្លៀង/ទឹកជំនន់ និងភាពរាំងស្ងួត*

ផ្ទៃដីដាំដុះដំណាំស្រូវនៅក្នុងប្រទេសកម្ពុជាប្រមាណ ៧៧% គឺពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀងដែលជាប្រភពទឹកសំរាប់ធ្វើការស្រោចស្រព ។ ឯចំណែកផ្ទៃដីដំដុះ ១១% ផ្សេងទៀតពឹងផ្អែកទៅលើទឹកភ្លៀង និងប្រព័ន្ធស្រោចស្រពបន្ថែម (ភាគច្រើន គឺមិនអាចធ្វើការកំណត់បាន) ។ នៅក្នុងតំបន់ដែលពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ការកើតមានឡើង កំលុងពេល និងបរិមាណ ទឹកភ្លៀងនៅក្នុងរដូវវស្សាអាចជះឥទ្ធិពលទៅដល់ទិន្នផល ។ ឧទាហរណ៍ :

- របាយទឹកភ្លៀងពុំគ្រប់គ្រាន់នៅដើមរដូវវស្សា (ខែឧសភា ដល់មិថុនា) អាចនាំឱ្យមានការរៀបចំដីពុំបានល្អ ពន្យាពេលសំណាបធ្វើឱ្យសំណាបមានសុខភាពខ្សោយ និងបញ្ហាកត្តាសត្វចង្រៃកើតមានច្រើន ។
- របាយទឹកភ្លៀងពុំគ្រប់គ្រាន់នៅក្នុងខែកក្កដា និងសីហា អាចធ្វើឱ្យមានការពន្យាពេលស្ទូង និងជាមូលហេតុធ្វើឱ្យខ្សោយទៅដល់ការលូតលាស់របស់ដំណាំ ។
- ការថយចុះទឹកភ្លៀងនៅក្នុងខែតុលា និងការឈប់ភ្លៀងនៅដើមដំបូងនៅក្នុងខែវិច្ឆិកា អាចជះឥទ្ធិពលមិនល្អដល់វគ្គបន្តពូជរបស់ដំណាំស្រូវ និងកាត់បន្ថយទិន្នផល ។
- កំរិតទឹកទន្លេចុះទាបខុសពីធម្មតាអាចកាត់បន្ថយតំបន់ដាំដុះស្រូវប្រដេញទឹក ។
- ភ្លៀងច្រើនពេកនៅក្នុងរដូវវស្សា អាចធ្វើឱ្យទិន្នផលមានការខូចខាតដោយសារការបំផ្លាញទឹកជំនន់ និងដំណាំឈ្លក់ទឹក (Javier 1997) ។

ចំពោះផលិតកម្មបន្លែវិញ គេកំរដាំដុះនៅរដូវវស្សាណាស់ ដោយសារបញ្ហាដីជាំទឹកដែលកើតឡើងដោយសារភ្លៀងខ្លាំងពេក ។ នៅរដូវប្រាំងការដាំបន្លែ ក៏ជួបប្រទះបញ្ហាដែរ ដោយសារខ្វះទឹកស្រោចស្រព ។ ចំណែកឯការចិញ្ចឹមសត្វជួបប្រទះបញ្ហាដោយសារខ្វះស្មៅនៅរដូវវស្សាក្នុងពេលដែលវាលស្រែទាំងអស់ត្រូវបានគេដាំស្រូវ ហើយនៅរដូវប្រាំងការខ្វះខាតទឹក ក៏ចោទជាបញ្ហាដែរ ។

### *២.១០.២. ដីខ្សត់ជីជាតិ*

ដីខ្សោះជីជាតិ គឺជាចំណោទយ៉ាងលំបាកបំផុតមួយ នៅក្នុងការបង្កើនទិន្នផលដំណាំនៅក្នុងប្រទេសកម្ពុជា ។ ដីភាគច្រើននៅក្នុងប្រទេសកម្ពុជា ជាដីខ្សោះជីជាតិ ដោយសារការដាំដំណាំដដែលៗរាប់សតវត្សរ៍មកហើយ ហើយដោយគ្មានការបំពេញបន្ថែមឱ្យបានគ្រប់គ្រាន់នូវជីជាតិដែលបាត់បង់ (Javier 1997) ។ ដីភាគច្រើនបំផុត ខ្វះជាតិអាសូត (N) និងផូស្វ័រ (P) ហើយនៅកន្លែងខ្លះទៀត ខ្វះជាតិប៉ូតាស្យូម (K) ។ បញ្ហាដទៃទៀត រួមមាន ដីដែលមានទំរង់រូបសាស្ត្រ និងគីមីខ្សោយ ដូចជា

ដីដែលមានជាតិអាស៊ីត សមត្ថភាពបំលាស់ប្តូររបស់វាចុះខ្សោយ បរិមាណសារជាតិសរីរាង្គទាប ពុលជាតិដែក និងដីមានជាតិប្រៃ (White *et al.* 1997a) ។

ដោយសារតែបញ្ហាទាំងអស់នេះហើយ ទើបតំបន់ដាំដុះស្រូវប្រមាណ ៥០% ត្រូវបានគេចាត់ទុកថា មានសក្តានុពលភាពទាបក្នុងការបង្កើនទិន្នផល (តារាង២.៩) ។ តំបន់ដាំដុះប្រមាណជា ២០% ផ្សេងទៀត ជួបប្រទះនូវបញ្ហារូបសាស្ត្រ និងគីមីដែលមានផលប៉ះពាល់ដល់ទិន្នផល ប៉ុន្តែ គេអាចកែលំអវាបានតាមរយៈការគ្រប់គ្រងដី ។ តំបន់ដាំដុះប្រហែលជា ៣០% ត្រូវបានចាត់ទុកថា មានសក្តានុពលភាពខ្ពស់ក្នុងការបង្កើនទិន្នផល ។ នៅតំបន់ដាំដុះស្រូវប្រដេញទឹក នៅរដូវប្រាំងច្រើនតែជាតំបន់ដែលមានដីសំបូរជីជាតិ ជាងនៅតំបន់ទំនាបដែលពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ។ នេះគឺជាផ្នែកមួយដែលទិន្នផលស្រូវប្រាំងមានអត្រាខ្ពស់ជាងស្រូវវស្សា ។

**តារាង២.៩. សក្តានុពលដើម្បីបង្កើនទិន្នផលពេលអនាគតពឹងគុណភាពដី និងប្រព័ន្ធបរិស្ថានដំណាំស្រូវខុសៗគ្នាឆ្នាំ២០០០-០១**[១]

| សក្តានុពលភាពដី | ស្រូវទំនាបពឹងទឹកភ្លៀង (ពាន់ហ.ត) | ស្រូវឡើងទឹក (ពាន់ហ.ត) | ស្រូវភ្នំ ឬស្រូវចំការ (ពាន់ហ.ត) | ស្រូវប្រាំងដែលមានការស្រោចស្រព (ពាន់ហ.ត) | សរុប (ពាន់ហ.ត) | % នៃផ្ទៃដីដាំដុះស្រូវ |
|---|---|---|---|---|---|---|
| ទាប[២] | 1,079 | 14 | 29 | 52 | 1,174 | 50.7% |
| មធ្យម[៣] | 405 | 8 | 18 | 36 | 467 | 20.1% |
| ខ្ពស់[៤] | 443 | 58 | 4 | 172 | 677 | 29.2% |
| សរុប | 1,927 | 80 | 52 | 260 | 2,318 | 100.0% |

[១] *ការវាយតំលៃសក្តានុពលដីចំពោះតំបន់ដាំស្រូវនៅកម្ពុជា ត្រូវបានធ្វើនៅឆ្នាំ១៩៩៧ នាពេលដែលផ្ទៃដីដាំដុះសរុបមាន ២.០៧៦ ហ.ត ។ តារាងនេះដកស្រង់ចេញមកពីការវាយតំលៃនាឆ្នាំ១៩៩៧ ដោយអនុវត្តន៍ទៅលើសក្តានុពលភាពដីសមាមាត្រនឹង ២.៣១៨ហ.តនៃផ្ទៃដីដាំដុះស្រូវនៅឆ្នាំ២០០០-០១ ។*

[២] *ដីមានសក្តានុពលភាពទាបបានន័យថា លក្ខណៈរូប និងលក្ខណៈគីមីរបស់ដីមានកំរិតកំណត់ ដែលលំបាកនៅក្នុងការគ្រប់គ្រងដី ដូចជាសមត្ថភាពបំលាស់ប្តូរចុះខ្សោយ ឬបញ្ហាពុលជាតិដែកដែលជាមូលហេតុរារាំងដល់ការបង្កើនទិន្នផល ។*

[៣] *ដីមានសក្តានុពលភាពមធ្យម បានន័យថាលក្ខណៈរូប និងលក្ខណៈគីមីនៃដីមានបញ្ហា ប៉ុន្តែគេអាចកែលំអវាបានតាមរយៈការគ្រប់គ្រង ។ រចនាសម្ព័ន្ធរបស់ដីខ្សោយ កង្វះជាតិ អាសូត ផូស្វរ និងប៉ូតាស្យូម ។*

[៤] *ដីមានសក្តានុពលខ្ពស់ មានន័យថា វាមានបញ្ហាកំរិតកំណត់ខ្លះៗទៅដល់ទិន្នផលស្រូវ ។*

*ប្រភព:* White et al. 1997a *និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*

## ២.១០.៣. កត្តាចង្រៃ និងជំងឺ

សត្វល្អិត និងជំងឺ អាចបំផ្លិចបំផ្លាញស្រូវទំនាបដែលពឹងលើទឹកភ្លៀង និងស្រូវភ្នំ (ស្រូវចំការ) ប៉ុន្តែជាទូទៅ គេពុំបានចាត់ទុកវាថា ជាបញ្ហាធំដុំឡើយ (Javier 1997) ។ នេះអាចមកពីដង់ស៊ីតេហ្វូងសត្វមានប្រយោជន៍ និងប៉ារ៉ាស៊ីត មានអត្រាខ្ពស់ ការប្រើប្រាស់ថ្នាំពុលពុំញឹកញាប់នៅកំលុងរដូវវស្សា ព្រមទាំងការប្រើប្រាស់ពូជស្រូវផ្សេងៗគ្នានៅលើវាលស្រែ ។ សត្វល្អិតចង្រៃដែលបំផ្លាញដំណាំកសិកម្ម រួមមាន ដង្កូវស៊ីរូងដើម មមាចត្នោត មមាចខៀវ ទ្រីប កន្លប ដង្កូវមូលស្លឹក ស្រឹង ដង្កូវស៊ីស្លឹក និងដង្កូវហ្វូង ។ ជំងឺរួមមាន sheath blight, bacterial blight និង sheath rot (Jahn *et al.* 1996/Javier 1997) ។ ទិន្នផលស្រូវ ក៏អាចត្រូវបានបំផ្លាញដោយក្តាមតាមរយៈការកាត់សំណាប សត្វស្លាបស៊ីពូជស្រូវ ឬស៊ីគ្រាប់ស្រូវពេលវាទុំ សត្វកណ្តុរបំផ្លាញនៅគ្រប់វគ្គលូតលាស់របស់ដំណាំ ។ ស្មៅចង្រៃអាចបង្កជាបញ្ហាដល់ការដាំដុះស្រូវរដូវប្រាំង ប៉ុន្តែវាពុំសូវបង្កជាបញ្ហានៅរដូវវស្សាទេ ប្រសិនបើទឹកនៅក្នុងស្រែត្រូវបានគេរក្សាទុកឱ្យមាន (Javier 1997) ។ ប៉ុន្តែការធ្វើអង្កេតទៅលើកសិករនៅតាមតំបន់ខ្ពង់រាបបានបញ្ជាក់ឱ្យឃើញថា ប្រមាណ ៨៥% នៃកសិករបានចាត់ទុកស្មៅចង្រៃជាបញ្ហាលំបាកធ្ងន់ធ្ងរ ពីព្រោះគ្រាប់ពូជស្មៅអាចដុះមុនគ្រាប់ពូជស្រូវចំការ (Jahn *et al.* 1999) ។

## ២.១១. សក្តានុពលភាព ដើម្បីកែលំអការអភិវឌ្ឍន៍កសិកម្ម

មានវិធានការជាច្រើនដែលចាំបាច់ ដើម្បីកែលំអការអភិវឌ្ឍន៍កសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទឱ្យមានភាពប្រសើរឡើង វិធានការខ្លះអាចអនុវត្តន៏ទៅបាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ចប្រសើរជាងវិធានការដទៃទៀត ។ អនុសាសន៏នានានៅក្នុងឯកសារបានផ្តោតទៅលើការពង្រីក និងកែលំអតំបន់ស្រោចស្រព វិធីសាស្ត្រកសិកម្មចំរុះ និងបង្កើនការកែច្នៃកសិផល ការកែលំអពូជស្រូវ និងបន្លែ ការកែលំអប្រសិទ្ធិភាពនៃការប្រើប្រាស់ជី និងថ្នាំពុល កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល និងថ្លៃម៉ាឃីទីង និងបង្កើនការគាំទ្រទៅដល់សេវាកសិកម្ម ។

### *២.១១.១. ពង្រីក និងកែលំអតំបន់ស្រោចស្រព*

ការខ្វះខាតប្រព័ន្ធស្រោចស្រព គឺជាបញ្ហាលំបាកជាទូទៅមួយ ក្នុងការបង្កើនផលិតកម្មកសិកម្មនៅប្រទេសកម្ពុជា ។ ទឹកភ្លៀងពុំទៀងទាត់នៅរដូវវស្សា និងខ្វះទឹកនៅរដូវប្រាំង បានបង្កើតនូវតំរូវការយ៉ាងខ្លាំងក្នុងការពង្រីកការស្រោចស្រពព្រមទាំងកែលំអការគ្រប់គ្រងទឹក ។ គោលនយោបាយ និងឯកសារផែនការនានាបានឱ្យយោបល់ក្នុងការពង្រីកសក្តានុពលភាពក្នុងការបង្កើនកសិកម្មស្រោចស្រព ។ ឧទាហរណ៏ *ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គម ២០០១-២០០៥* បានជូនយោបល់ថា "ការស្រោចស្រពបានផ្តល់ឱកាសយ៉ាងប្រសើរមួយ ដើម្បីការលូតលាស់វិស័យកសិកម្ម" (ក្រសួងផែនការឆ្នាំ២០០១) ។ គេកត់សំគាល់ឃើញថា តំបន់ដាំដុះយ៉ាងធំទូលាយនៅក្នុងប្រទេសកម្ពុជាមានដង្ហើមទឹករាក់ និងមានទឹកដក់នៅលើដីគ្រប់គ្រាន់ដើម្បីធ្វើការស្រោចស្រពនៅលើផ្ទៃដីយ៉ាងហោចណាស់ ១លានហិកតាដែរ នៅក្នុងកំលុងរដូវប្រាំង ។

ការវាយតំលៃដទៃទៀតទៅលើសក្តានុពលភាពនៃការស្រោចស្រពនៅកម្ពុជា បានកំនត់ឃើញថា ការពង្រីកប្រសិទ្ធិភាពសេដ្ឋកិច្ចនៅក្នុងការស្រោចស្រព អាចកើតមានទៅលើការស្រោចស្រពទ្រង់ទ្រាយតូច និងមានកំរិតកំណត់ ។ ឧទាហរណ៏ការស្រាវជ្រាវដ៏ទូលំទូលាយមួយស្តីពីសក្តានុពលភាពនៃការស្រោចស្រពទឹកក្រោមដីនៅខេត្តព្រៃវែងបានសន្និដ្ឋានថា មានតែផ្ទៃដីតែ 0,៦% ឬ ៣.000ហិកតាប៉ុណ្ណោះ ដែលអាចធ្វើការស្រោចស្រពបាន ហើយការស្រោចស្រពនេះ អាចមានសុវត្ថិភាពដោយមិនចាប់ផ្តើមប្រើប្រាស់ទឹកក្រោមដីនៅក្រោមកំពស់ ៦ម៉ែត្រនារដូវប្រាំង បើទាញយកទឹកមកស្រោចស្រពទាបជាងកំរិតនេះ វានឹងបង្កការលំបាក ដល់ការប្រើប្រាស់ទឹកសំរាប់បរិភោគ ដល់ប្រជាជនជាច្រើន (Roberts 1998) ។ ការសិក្សានេះ បានប៉ាន់ស្មានឃើញថា នៅឆ្នាំ១៩៨៨ តំបន់ស្រោចស្រពដោយប្រើប្រាស់ទឹកក្រោមដី នៅខេត្តព្រៃវែង មាន ១.២00ហិកតា នេះសបញ្ជាក់ឱ្យឃើញនូវសក្តានុពលភាពក្នុងការពង្រីកត្រឹមតែ ១.៨00ហិកតា មុនការស្រោចស្រពចាប់ផ្តើមធ្វើឱ្យខូចខាតស្រទាប់ទឹកក្រោមដីនារដូវប្រាំង ។

Nesbitt (1997) បានជូនយោបល់ថា មានយុទ្ធសាស្ត្រនានា ដែលមានតំលៃថោកប្រើប្រាស់សំរាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃ "កូនរដូវប្រាំង" ចំពោះដំណាំកសិកម្មដែលកើតមានឡើងនៅរដូវវស្សា ។ យុទ្ធសាស្ត្រនេះ រួមមាន ពង្រាបស្រែដើម្បីចែកចាយទឹក លើកភ្លឺឱ្យខ្ពស់ដើម្បីរក្សាទឹក និងជីកស្រះតូចៗនៅពីក្រោយភ្លឺស្រែ ដើម្បីឱ្យមានទឹកបន្ថែម ។ ការពង្រីកប្រសិទ្ធិភាពសេដ្ឋកិច្ចទៅលើការគ្រប់គ្រងទឹក និងយុទ្ធសាស្ត្រស្រោចស្រពបន្ថែម អាចទទួលបានលទ្ធផលគួរឱ្យសង្ឃឹម ។ ប៉ុន្តែដូចដែលបានរៀបរាប់ពីខាងលើ ធនាគារអភិវឌ្ឍន៏អាស៊ី បានចង្អុលបញ្ជាក់ថា សក្តានុពលភាពក្នុងការបង្កើនការស្រោចស្រពទាំងស្រុង គឺមានកំរិតកំណត់ ទោះជាតាមរយៈការបូម ឬប្រព័ន្ធបង្ហៀរក៏ដោយ (Nesbitt 1997) ។

ការវាយតំលៃរបស់ Halcrow (1994) អំពីលទ្ធភាពស្តារការស្រោចស្រពឡើងវិញបានកំណត់ថា ផ្អែកតាមសក្តានុពលភាពសេដ្ឋកិច្ច នោះគំរោងស្រោចស្រព គួរតែស្ថាបនាឡើងនៅកន្លែងណាដែលដីមានជីជាតិល្អ ។ ទោះជាបច្ចេកទេសក្នុងការគ្រប់គ្រងទឹក និងដី អាចអនុញ្ញាតឱ្យទិន្នផលកើនឡើងនៅគ្រប់ទីកន្លែងដែលមានដីខ្សោះជីជាតិ ក៏ប៉ុន្តែការដាំដំណាំស្រូវ និងដំណាំដទៃទៀត ដោយពឹងលើការស្រោចស្រពលើដីដែលមានជីជាតិខ្សោយ នោះវានឹងនាំមកនូវទិន្នផលទាប ឬទាបបំផុត ។ ដូច្នេះការ

ស្រាវជ្រាវនេះបានសន្និដ្ឋានថា តំបន់ដែលដីមានជីជាតិខ្សោយ គេមិនគួរគាំទ្រដល់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពទេ ដោយសារហេតុផលប្រសិទ្ធិភាពសេដ្ឋកិច្ច ។ ការសិក្សាអំពីគុណភាពដីនាពេលថ្មីៗនេះបានបង្ហាញថា ផ្ទៃដីដាំដុះជាង ៥០% នៅកម្ពុជា ជាដីមានគុណភាពអន់ និងមានសក្តានុពលភាពទាបដើម្បីបង្កើនទិន្នផល (White *et al.* 1997a) ។ បានន័យថា ការពង្រីកការស្រោចស្រពលើផ្ទៃដីដាំដុះក្នុងប្រទេសកម្ពុជា យ៉ាងហោចពាក់កណ្តាលនៃផ្ទៃដីទាំងនេះ ពុំបានផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចឡើយ ។

បន្ថែមពីលើការលំបាកផ្នែករូបសាស្ត្រ ចំពោះសក្តានុពលភាព ជាប្រការគួរកត់សំគាល់លើប្រសិទ្ធិភាពគ្រប់គ្រងប្រព័ន្ធស្រោចស្រពទ្រង់ទ្រាយធំក្នុងរយៈពេលវែង ត្រូវការចាំបាច់ឱ្យមានការសហការ និងការចាត់ចែងនៅក្នុងចំណោមកសិករ ។ ដូចជាសមាគមកសិករ ឬក្រុមអ្នកប្រើប្រាស់ទឹកដែលដើរតួនាទីសំខាន់ក្នុងការបង្កើតគោលការណ៍ និងតួនាទីនានា ដើម្បីប្រើប្រាស់គ្រប់គ្រង និងថែរក្សាប្រព័ន្ធស្រោចស្រព ដោយសារពួកគេមិនសូវនិយមប្រើទេនៅកម្ពុជា ។ ដូចនេះ ការស្តាបនាប្រព័ន្ធស្រោចស្រពថ្មី ត្រូវការចាំបាច់ ដើម្បីចាត់តាំងរៀបចំក្រុមកសិករ ។

មកដល់ឆ្នាំ២០០១ មានប្រព័ន្ធស្រោចស្រពចំនួន ៣៥ ត្រូវបានគេកំណត់ និងធ្វើសំណើរឡើងសំរាប់កម្ពុជា ដែលក្នុងនោះភាគច្រើនបំផុត គឺជាប្រព័ន្ធស្រោចស្រពដែលមានខ្នាតតូចទៅមធ្យម ។ ប្រព័ន្ធស្រោចស្រពទាំងនេះ រួមបញ្ចូលទាំងគំរោងថ្មី និងប្រព័ន្ធដែលមានស្រាប់ដើម្បីធ្វើការកែលំអ ។ ប្រសិនបើគំរោងស្រោចស្រពទាំងនេះ ត្រូវបានគេយកទៅអនុវត្ត នោះនៅកម្ពុជាគេអាចដាំដុះដំណាំទ្វេដងដោយធ្វើការស្រោចស្រព និងអាចបង្កើនផ្ទៃដីដាំដុះបាន ៥០០.០០០ហិកតា ឬជិត ២០% (Urwin និង Wrigley 2001) ។

### ២.១១.២. ការបង្កើតកសិកម្មចំរុះ និងការកែច្នៃកសិផល

ការអភិវឌ្ឍន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា បានផ្តោតយកចិត្តទុកដាក់ជាសំខាន់ ទៅលើការបង្កើនផលិតកម្មដំណាំស្រូវដើម្បីធានានូវសន្តិសុខស្បៀង ។ នៅក្នុងខណៈដែលការបង្កើនផលិតកម្មដំណាំស្រូវទទួលបានលទ្ធផលជោគជ័យគួរឱ្យកត់សំគាល់នៅក្នុងទសវត្សរ៍កន្លងមកនេះ នោះស្ថិតិរដ្ឋាភិបាលស្តីពីដំណាំបន្លែ និងដំណាំផ្សេងៗទៀត មានការលូតលាស់បន្តិចបន្តួចប៉ុណ្ណោះ ។ ការបង្កើនផលិតកម្មដំណាំទាំងនេះ អាចធ្វើឱ្យមានភាពប្រសើរឡើងដល់សន្តិសុខស្បៀងសុខភាព និងអាហារូបត្ថម្ភ និងប្រាក់ចំណូលរបស់កសិករ ។ ការអភិវឌ្ឍន៍កសិកម្មចំរុះ អាចពង្រីកផលិតកម្មស្បៀងពេញមួយឆ្នាំ ដូច្នេះវាអាចជួយសំរាលឱ្យ "មានភាពរលូន" នៅក្នុងតំរូវការស្បៀងតាមរដូវដែលមានការប្រែប្រួល (និងតំលៃ) ។ បន្ថែមពីលើនេះផលិតផលទាំងនេះអាចជួយបង្កើនការកែច្នៃកសិផល ដោយបង្កើតឱ្យមានការទាក់ទាញវិនិយោគទុនកាន់តែច្រើនឡើងនៅក្នុងវិស័យនេះ (ក្រសួងផែនការឆ្នាំ២០០១) ការលូតលាស់នៃការកែច្នៃកសិផលធុនតូច និងអាចជួយបង្កើនតំលៃបន្ថែមចំពោះផលិតផល កែលំអគុណភាពផលិតផល និងឱកាសម៉ាឃីទីង ឱ្យកាន់តែប្រសើរឡើង ព្រមទាំងបង្កើតឡើងនូវឱកាសការងារធ្វើ ។

ដូចដែលបានអធិប្បាយពីខាងលើ ផលិតកម្មដំណាំបន្លែ និងដំណាំផ្សេងៗ ជួបប្រទះនូវការលំបាកក្នុងការដាំដុះក្នុងតំបន់ដំណាំស្រូវនាប្រទេសកម្ពុជា ដោយសារបញ្ហាជំទឹកនៅរដូវវស្សា និងកង្វះទឹកនៅរដូវប្រាំង ។ ទោះជាយ៉ាងណាក៏ដោយ តំបន់ទាំងនេះក៏អាចអនុវត្តបានូវប្រព័ន្ធកសិកម្មខ្នាតតូច ដែលអាចជួយកែលំអជីវភាពរស់នៅរបស់កសិករ ។ ឧទាហរណ៍ ការស្រាវជ្រាវតូចមួយដែលធ្វើឡើងនៅក្នុងខេត្តស្វាយរៀង ដោយធ្វើការប្រៀបធៀបកសិករដែលដាំដុះដំណាំស្រូវតែមួយមុខ និងកសិករដែលអនុវត្តវិធីសាស្ត្រប្រព័ន្ធកសិកម្មចំរុះ នោះលទ្ធផលបានបង្ហាញឱ្យឃើញថា កសិដ្ឋានដែលអនុវត្តន៍កសិកម្មចំរុះ បានបង្កើនប្រាក់ចំណូលដល់កសិករច្រើនជាងគេ (Prom 1999) ។

### ២.១១.៣. ការកែលំអពូជស្រូវ និងពូជបន្លែ

នៅក្នុងប្រព័ន្ធបរិស្ថានដំណាំស្រូវកម្ពុជា គេប៉ាន់ស្មានឃើញថា ពូជស្រូវមាន ២.០០០ប្រភេទខុសៗគ្នា ។ ចាប់តាំងពីឆ្នាំ១៩៨៧មក កម្មវិធី Cambodia-IRRI-Australia Projtct (CIAP) បានអភិវឌ្ឍន៍ និងរំដោះពូជស្រូវបាន ៣៤ពូជ ដែលរួមមាន

ពូជជ្រើសរើសក្នុងស្រុក និងពូជស្រូវកណ្តាលទំនើប ធ្វើឡើងតាមរយៈគណៈកម្មាការអនុសាសន៍ពូជនៃកម្ពុជា (VRCC)[១៦] ។ មានតែពូជស្រូវ IR66 ប៉ុណ្ណោះ ដែលកសិករទទួលយកបានដូចដែលបានអធិប្បាយពីខាងលើ គឺពូជស្រូវនេះ បច្ចុប្បន្នត្រូវបានគេដាំប្រហែល ៩0% នៃផ្ទៃដីស្រូវប្រាំងទាំងមូល ។ ទោះជាពូជជ្រើសរើសក្នុងស្រុក និងពូជស្រូវកណ្តាលទំនើប អាចបង្កើនទិន្នផលយ៉ាងណាក៏ដោយ ប៉ុន្តែ កសិករមិនអាចអនុវត្តករណីខ្លះបាន ដោយសារបញ្ហាម៉ាឃីទីង ។ អ្នកបរិភោគស្រូវក្នុងស្រុក ជាទូទៅតែចូលចិត្តរសជាតិ និងទំរង់របស់ពូជស្រូវប្រពៃណី ។ ឧទាហរណ៍ កសិករនៅខេត្តតាកែវ ស្វាយរៀង និងព្រៃវែងភាគច្រើនដាំពូជស្រូវទំនើប ប៉ុន្តែតាមរបាយការណ៍បញ្ជាក់ថា ពួកគេមិនចង់បរិភោគស្រូវពូជ IR ទេ ដោយហេតុថា "វារឹង និងគ្មានរសជាតិ" (Sok *et al.* 2001) ។ ពូជស្រូវទំនើបជាទូទៅត្រូវបានគេដាំដុះ ដើម្បីលក់ដូរ និងនាំចេញ ប៉ុន្តែគ្រួសារនីមួយៗមិនបរិភោគទេ ។ ថ្វីបើមានបញ្ហានេះក៏ដោយ ពូជស្រូវទំនើបនៅតែមានសារៈសំខាន់ក្នុងការបង្កើនទិន្នផលស្រូវ និងផលិតកម្មស្រូវនាពេលអនាគត ។

ពូជបន្លែក្នុងស្រុករបស់កម្ពុជា ជាទូទៅត្រូវបានគេចាត់ទុកថា មានទិន្នផលទាប ។ មួយផ្នែកនៃបញ្ហានេះ គឺដោយសារគុណភាពគ្រាប់ពូជ ។ ទោះជាកសិករជាច្រើននិយមពូជបន្លែនាំចូល (ជាពិសេសពូជទំនើប) ដែលនាំមកពីវៀតណាម និងថៃយ៉ាងណាក៏ដោយ ប៉ុន្តែគុណភាពត្រួតពិនិត្យពូជទាំងនេះ គឺនៅមានកំរិតនៅឡើយ ។ ដូចនេះ កសិករតែងតែផលិតពូជខ្លួនឯង ឬក៏ទិញពូជនាំចូល ទោះជាវាមានចំណោទលើបញ្ហាគុណភាពគ្រាប់ពូជយ៉ាងណាក៏ដោយ ។ កម្ពុជាមានស្ថាប័នរបស់រដ្ឋាភិបាលពីរកន្លែងដែលផ្តោតទៅលើការស្រាវជ្រាវបញ្ហាផលិតកម្មបន្លែ និងគ្រាប់ពូជ (ស្ថានីយក្បាលកោះ និងស្ថានីយប្រសូត្រ) ។ ប៉ុន្តែស្ថានីយទាំងពីរនេះ នៅតែពុំអាចឆ្លើយតបគ្រប់គ្រាន់នឹងតំរូវការរបស់កសិករ ទាក់ទងនឹងពូជបន្លែ និងសេវាកម្ម ។

### *២.១១.៤. ការកែលំអប្រសិទ្ធិភាពនៃការប្រើប្រាស់ជី និងថ្នាំពុល*

នៅក្នុងការខិតខំប្រឹងប្រែងកែលំអជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនទិន្នផលកសិកម្មនោះកសិករកម្ពុជា បានបង្កើនការប្រើប្រាស់ជី និងថ្នាំពុលគីមី ។ ប៉ុន្តែ ការប្រើប្រាស់ធនធានផលិតកម្មទាំងពីរមុខនេះមានអត្រាលើសកំរិតកំណត់ ។ ការប្រើប្រាស់លើសធនធាន ធ្វើឱ្យបង្កើតថ្លៃផលិតកម្ម ជាលទ្ធផលបានធ្វើឱ្យប្រាក់ចំណូលថយចុះ ។ បន្ថែមពីលើនេះ ការប្រើប្រាស់លើសកំរិត និងពុំត្រឹមត្រូវ អាចនាំឱ្យប៉ះពាល់ដល់សុខភាពរបស់កសិករ សំលាប់ត្រី និងបំពុលដល់ការប្រើប្រាស់ទឹកស្អាត ។ ឧទាហរណ៍ ការស្រាវជ្រាវនាពេលថ្មីៗនេះ ដែលធ្វើឡើងនៅក្នុងភូមិពីរនៃខេត្តតាកែវ បានបញ្ជាក់ឱ្យឃើញថា កសិករ ភាគច្រើនបានប្រើប្រាស់ ជីគីមីលើសពីអនុសាសន៍ ដែលផ្តល់ដោយអង្គការ CIAP និងយល់ព្រមពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (តារាង២.១០) ។ កសិករភាគច្រើនបំផុតដែលពុំបានប្រើប្រាស់ជីគីមីសមស្របតាមអនុសាសន៍ ដោយសារខ្វះការបំពាក់ បំប៉នកសិកម្មយល់ដឹងតិចតួចអំពីពតិមានប្រភេទដី និងការប្រើប្រាស់អនុសាសន៍ព្រមទាំងមានលទ្ធភាពយល់ដឹងអំពីផ្លាកសញ្ញា ណែនាំដែលសរសេរជាភាសាបរទេស (Mary *et al.* 2001) ។

**តារាង២.១០. បរិមាណនៃការប្រើជីគីមី ធៀបនឹងកំរិតអនុសាសន៍ នៅភូមិព្រៃស្វា និងភូមិព្រៃតាម៉ៅ ខេត្តតាកែវ ឆ្នាំ១៩៩៩-២000 នារដូវប្រាំង និងរដូវវស្សា**

| | ភាគរយកសិករនៅភូមិព្រៃស្វា | | ភាគរយកសិករនៅភូមិព្រៃតាម៉ៅ | |
|---|---|---|---|---|
| កំរិតប្រើប្រាស់ | *រដូវវស្សា* | *រដូវប្រាំង* | *រដូវវស្សា* | *រដូវប្រាំង* |
| ក្រោមកំរិតអនុសាសន៍ | 9% | 29% | 57% | 43% |
| ស្មើកំរិតអនុសាសន៍ | 38% | 47% | 29% | 21% |
| លើសកំរិតអនុសាសន៍ | 53% | 24% | 14% | 36% |

*ប្រភព: Mary et al . 2001*

---

[១៦] ការទទួលខុសត្រូវរបស់ CIAP បានប្តូរទៅជា Cambodian Agricultural Research and Development Institute (CARDI) នាឆ្នាំ១៩៩៩ ។

អង្គការសុខភាពពិភពលោក (WHO) បានធ្វើចំណាត់ថ្នាក់ថ្នាំពុល ដោយផ្អែកទៅលើកំរិតជាតិពុល និងកំរិតគ្រោះថ្នាក់ ដូចជា ថ្នាក់ ១ ២ និង ៣ ដែលក្នុងនោះ ថ្នាក់ ១ ត្រូវបានគេចាត់ទុកថា មានជាតិពុលច្រើនបំផុត ។ ប្រទេសជាច្រើនរួមទាំងប្រទេសកម្ពុជាផងដែរ បានហាមប្រាមក្នុងការប្រើប្រាស់ថ្នាំពុល ដែលមាននៅក្នុងចំណាត់ថ្នាក់ ១ក និង ១ខ[១៧] ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ថ្នាំពុលដែលហាមឃាត់ទាំងនេះនៅតែនិយមនៅក្នុងប្រទេសកម្ពុជា ។ ការស្រាវជ្រាវនាពេលថ្មីៗនេះ ដែលធ្វើឡើងដោយអង្គការ CEDAC នៅលើ ៦ខេត្តនៅជុំវិញបឹងទន្លេសាបបានបញ្ជាក់ថា ជំនួញក្នុងកំរិតខ្ពស់នៃការប្រើប្រាស់ថ្នាំពុលដែលហាមឃាត់ នៅតែបន្តសកម្មភាពនៅឡើយ (Yang Saing 2001) ។ ដូចគ្នានេះដែរ Mary *et al. 2001* បានប៉ាន់ស្មានឃើញថា ថ្នាំពុលដែលហាមឃាត់ ត្រូវបានគេប្រើប្រាស់ក្នុងអត្រា ១៥-៣០% នៅរដូវវស្សា និង ៣៥-៥០% នៅក្នុងរដូវប្រាំង ចំពោះភូមិទាំងពីរនៅក្នុងខេត្តតាកែវ ។ ដូចគ្នានឹងជីគីមីដែរ មូលហេតុនៃការប្រើប្រាស់ថ្នាំពុលដែលហាមឃាត់ និងវិធីសាស្ត្រពុំត្រឹមត្រូវ ដោយសារខ្វះពត៌មានស្តីពីថ្នាំពុលដែលហាមឃាត់ ខ្វះវគ្គបំពាក់បំប៉ន និងគ្មានលទ្ធភាពក្នុងការអានផ្លាកសញ្ញាដែលបានណែនាំដែលសរសេរជាភាសាបរទេស ។

ក្រៅពីការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនៃថ្នាំពុល និងជីគីមី មានកម្មវិធីខ្លះទៀត បានជំរុញឱ្យមាននូវវិធីសាស្ត្របង្កើនទិន្នផល ដោយប្រើប្រាស់ធនធានផលិតកម្មតិចតួច ឬគ្មានប្រើប្រាស់ទាល់តែសោះ ។ វិធីសាស្ត្រទាំងនេះរួមមាន វិធានការចំរុះដើម្បីថែទាំដំណាំ (IPM) និងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (SRI) ។ IPM គឺជាយុទ្ធសាស្ត្រផ្អែកទៅលើប្រព័ន្ធបរិស្ថាន ដើម្បីការពារ និងកាត់បន្ថយកត្តាសត្វចង្រៃ តាមរយៈបច្ចេកទេសគ្រប់គ្រងដូចជា ការបំផ្លាញជំរកសត្វចង្រៃ និងការប្រើពូជធុន ។ ថ្នាំពុលត្រូវបានគេប្រើប្រាស់បន្ទាប់ពីត្រួតពិនិត្យទៅឃើញថា ចាំបាច់ និងបាញ់ទៅលើតែសត្វចង្រៃប៉ុណ្ណោះ ។ ការត្រួតពិនិត្យកត្តាចង្រៃត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយជាអប្បរមានៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វមានប្រយោជន៍ និងសរីរាង្គផ្សេងៗដែលមិនមែនជាគោលដៅ ព្រមទាំងបរិស្ថាន ។

SRI រួមបញ្ចូលការអនុវត្តន៍នៃការកែលំអដំណាំ ទឹក ដី និងបច្ចេកទេសគ្រប់គ្រងជីជាតិចំណីអាហារ ។ យោងតាមអង្គការ CEDAC មានកសិករ ៥០០នាក់ ទទួលយកបច្ចេកទេស SRI នៅក្នុងប្រទេសកម្ពុជា ។ បច្ចេកទេសនេះ អាចបង្កើតទិន្នផលពី ១-២តោន/ហិកតា ដល់ ៣-៦តោន/ហិកតា ។ SRI ត្រូវបានគេអនុវត្តនៅប្រទេសនានាជុំវិញពិភពលោក ដែលតាមរបាយការណ៍បានបញ្ជាក់ថា ទិន្នផលអាចកើនរហូតដល់ ២ ឬ ៣ដង[១៨] ។ ថ្វីបើវាមានលទ្ធផលគួរឱ្យសង្ឃឹមក៏ដោយ ប៉ុន្តែ កសិករដែលទទួលយកបច្ចេកទេសនេះ នៅមានបញ្ហាចោទ ដោយសារតំរូវការកំលាំងពលកម្មច្រើន (Moser និង Barrett 2002) ។

### ២.១១.៥. ការកាត់បន្ថយនៃការខាតបង់ក្រោយពេលប្រមូលផល និងថ្លៃម៉ាឃីទីង

ការខាតបង់ក្រោយពេលប្រមូលផលគួរឱ្យកត់សំគាល់ ចំពោះដំណាំស្រូវ បន្លែ និងដំណាំដទៃទៀត នៅក្នុងប្រទេសកម្ពុជា ដោយសារបញ្ហាកែច្នៃ ការទុកដាក់ ដឹកជញ្ជូន និងម៉ាឃីទីង ។ ឧទាហរណ៍ ដោយសារភាពគ្មានប្រសិទ្ធិភាព និងបច្ចេកទេសចាស់របស់ម៉ាស៊ីនកិនស្រូវនៅតាមភូមិនានាជាច្រើន នោះធ្វើឱ្យអង្ករដែលកិនរួចមានអត្រាជាមធ្យមតែ ៥៣% នៃទំងន់ស្រូវតែប៉ុណ្ណោះ ។ ចំពោះម៉ាស៊ីនកិនស្រូវទំនើប មានលទ្ធភាពកិនបានអង្ករប្រមាណ ៧០% នៃទំងន់ស្រូវ (Rickman *et al.* 2001) ។ ស្រូវដែលស្តុកក្នុងជង្រុក អាចបាត់បង់ក្នុងអត្រាខ្ពស់ដោយសារគ្មានលទ្ធភាពក្នុងការត្រួតពិនិត្យសំណើម ការខូចខាត បញ្ហាសត្វល្អិត និងការបាត់បង់តាមរយៈការដឹកជញ្ជូន កើតមានឡើងជារឿយៗ ដោយសារការវិចខ្ចប់ និងការប្រើប្រាស់មិនបានល្អ ។ ទោះជាមានពត៌មានមិនគ្រប់គ្រាន់ស្តីពីការខាតបង់ក្រោយពេលប្រមូលផលចំពោះដំណាំបន្លែ និងដំណាំដទៃទៀត ប៉ុន្តែការបាត់បង់នេះ

[១៧] ថ្នាក់ ១ក និង ១ខ គឺជាថ្នាំពុលដែលត្រូវបានហាមប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដែលចែងនៅក្នុងអនុក្រឹត្យស្តីពីខ្នាតគំរូ និងការគ្រប់គ្រងសំភារៈកសិកម្មឆ្នាំ១៩៩៨ ។

[១៨] SRI បាននឹងកំពុងអនុវត្តនៅក្នុងប្រទេស ម៉ាដាហ្គាស្កា កម្ពុជា ហ្វីលីពីន ចិន ឥណ្ឌូនេស៊ី ស្រីលង្កា និងបង់ក្លាដេស ។

ត្រូវបានគេពិនិត្យឃើញគួរឱ្យកត់សំគាល់ ដោយសារគុណភាពបន្លែរោយខូចខាត ក្រោយពេលប្រមូលផលរួច ។ Ungsa និង Hean (1994) បានរកឃើញថា ការខាតបង់ក្រោយពេលប្រមូលផល ចំពោះដំណាំបន្លែនៅក្នុងខេត្តកណ្ដាលមានរហូតដល់ ១៧% ដោយសារការថែរក្សាទុក និងវិធីសាស្ត្រវិចខ្ចប់មិនបានល្អ ។

ការខាតបង់ក្រោយពេលប្រមូលផល មានសភាពកាន់តែធ្ងន់ធ្ងរឡើង ដោយសារខ្សោយហេដ្ឋារចនាសម្ព័ន្ធ ដែលជាកត្តាពុំអនុគ្រោះដល់ការដឹកជញ្ជូនទំនិញកសិកម្មពីអ្នកផលិត ទៅដល់អ្នកបរិភោគ ។ បញ្ហានោះរួមមានការខ្វះខាតម៉ាឃីទីង និងសេវាកម្មឥណទានជនបទ ហេដ្ឋារចនាសម្ព័ន្ធអន់ និងថ្លៃប្រេងខ្ពស់ ព្រមទាំងបង់ថ្លៃក្រៅផ្លូវការតាមចំនុចត្រួតពិនិត្យនានានៅតាមបណ្ដោយផ្លូវ ។ ថ្លៃសាហ៊ុយរួមបញ្ចូលជាមួយនឹងបញ្ហាទាំងនេះ បានបន្ថែមបន្ទុកទៅលើអ្នកប្រើប្រាស់ ដោយកាត់បន្ថយតំលៃដែលត្រូវទទួលបាន ដោយអ្នកផលិត/កសិករ និងកាត់បន្ថយការលើកទឹកចិត្តចំពោះជំនួញ (រួមបញ្ចូលទាំងតំបន់ដែលមានការខ្វះខាត) ។ បន្ថែមពីលើនេះទៀត ថ្លៃម៉ាឃីទីង បានកាត់បន្ថយសក្ដានុពលភាពនាំចេញនូវបរិមាណស្រូវលើស នៅក្នុងប្រទេសកម្ពុជា (Sok *et al.* 2001 និងក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០១) ។

### ២.១១.៦. បង្កើនការគាំទ្រដល់សេវាកម្មកសិកម្ម

ការគាំទ្រកសិកម្ម និងការងារផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា នៅតែមានកំរិតខ្សោយនៅឡើយ ឬពុំទាន់បង្កើតបាន ។ ធនធាន និងសមត្ថភាពនៅមានកំរិតដែលជាបញ្ហាលំបាកចំពោះរដ្ឋាភិបាលក្នុងការពង្រីកកម្មវិធីផ្សព្វផ្សាយដែលទាក់ទងនឹងពត៌មានបច្ចេកទេសឱ្យដល់ទីជនបទ ។ បច្ចុប្បន្ននេះ ពត៌មានកសិកម្មសំខាន់ៗ ដូចជាបច្ចេកទេសកែលំអផលិតកម្ម និងបច្ចេកទេសកែលំអផលិតផលក្រោយពេលប្រមូលផល តំរូវការទីផ្សារ និងតំលៃ តំរូវការ គុណភាព និងពូជថ្មី ត្រូវបានទទួលតាមរយៈបណ្ដាញផ្សព្វផ្សាយក្រៅផ្លូវការ ដូចជាតាមរយៈកសិករជិតខាង អ្នកចែកចាយផលិតផលកសិកម្ម និងអង្គការក្រៅរដ្ឋាភិបាល ។ នៅក្នុងបរិបទនៃធនធានដែលជួបបញ្ហាលំបាកដល់សេវាផ្សព្វផ្សាយកសិកម្ម នោះនៅពេលអនាគត អ្នកផ្សព្វផ្សាយត្រូវខិតខំធ្វើការជាមួយនឹងកសិករ ក្រុម និងសហករណ៍ ដើម្បីពង្រីកលទ្ធភាពនៅក្នុងការបង្កើនប្រសិទ្ធិភាពនៃការផ្សព្វផ្សាយ ។

ការកែលំអហិរញ្ញវត្ថុសាធារណៈទៅដល់សេវាកម្មកសិកម្ម គឺជាតំរូវការចាំបាច់ ប៉ុន្តែកិច្ចប្រឹងប្រែងនេះគួរតែមានការប្រុងប្រយ័ត្ន កុំ "រុញចេញ" ឬកាត់បន្ថយការលើកទឹកចិត្តចំពោះវិស័យឯកជន និងសេវាកម្ម ។ ឧទាហរណ៍ តាមរយៈការបំពាក់បំប៉នកសិករ និងតាមរយៈការលើកទឹកចិត្តដើម្បីកែលំអគុណភាពទៅលើផលិតកម្មដំណាំពោត ដើម្បីយកធ្វើជាចំណីសត្វ អ្នកវិនិយោគឯកជនម្នាក់ មានលទ្ធភាពធ្វើឱ្យអត្រាបដិសេធពោតនៅក្នុងកិច្ចសន្យាធ្លាក់មកនៅកំរិតមួយកាន់តែទាប គឺពី ៨០% រហូតមកដល់ ១០-១៥% ក្នុងរយៈពេល ៤ឆ្នាំ ។ ដូចគ្នានេះដែរ អ្នកវិនិយោគទុនដទៃទៀតកំពុងតែស្វែងរកការផលិតស្រូវដែលមានគុណភាពក្រអូបដើម្បីនាំចេញ ដោយគេវិនិយោគនៅក្នុងបែបផែនធ្វើកិច្ចសន្យាកសិកម្ម ដោយផ្ដល់សេវាកម្មការផ្សព្វផ្សាយ និងការផ្គត់ផ្គង់ធនធានផលិតកម្ម ព្រមទាំងមានម៉ាស៊ីនកិនស្រូវថ្មី ។ អ្នកវិនិយោគនេះបានចុះកិច្ចសន្យាជាមួយកសិករ ៣០.០០០នាក់ ដើម្បីផលិត និងប្រើប្រាស់ពូជស្រូវដែលមានគុណភាពខ្ពស់ (ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០១) ។ សេវាឯកជនបែបនេះ អាចដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការបញ្ជូនបច្ចេកវិទ្យា ជំនាញ និងពត៌មានឱ្យបានដល់កសិករនាពេលអនាគត ។

## ២.១២. សន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ

ការអភិវឌ្ឍន៍កសិកម្ម នឹងបន្តទៅមុខជាការចាំបាច់ ដើម្បីកែលំអជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាតាមជនបទនាពេលអនាគត ។ និន្នាការនៅក្នុងផលិតកម្មកសិកម្ម នាទសវត្សរ៍កន្លងមកនេះ បានយល់ឃើញថា ទិន្នផល និងផលិតកម្ម អាចកែលំអទៅបាន ប៉ុន្តែគេត្រូវជំនះទៅលើបញ្ហាលំបាកនៅក្នុងផ្នែករូបសាស្ត្រ បច្ចេកទេស និងសេដ្ឋកិច្ចសង្គម ។ បញ្ហាទាក់ទងជាពិសេស គឺទៅលើដីខ្សោះជីជាតិដែលមានប្រមាណ ៥០% នៃផ្ទៃដីដាំដុះ ហើយកត្តានេះបង្កឱ្យមានសក្ដានុពលភាពទាបក្នុងការបង្កើនទិន្នផល ។ ការប្រជែងនានារួមជាមួយនឹងដីខ្សោះជីជាតិ ព្រមទាំងលទ្ធភាពនៃការគ្រប់គ្រងទឹកបានបញ្ជាក់ឱ្យឃើញថា

ការពង្រីកប្រព័ន្ធស្រោចស្រពនៅក្នុងតំបន់ផ្ទៃដីដាំដុះជាច្រើនរបស់កម្ពុជា គឺអាចពុំមានប្រសិទ្ធិភាពសេដ្ឋកិច្ចឡើយ ។ ការកែលំអ និងការគ្រប់គ្រងទឹកជាកត្តាសំខាន់ ដើម្បីធ្វើឱ្យផលិតកម្មចំរុះនាពេលអនាគតប្រសើរឡើង ។ កត្តានេះត្រូវការចាំបាច់ក្នុងការកំណត់តំបន់ដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ច ដើម្បីពង្រីក/កែលំអការស្រោចស្រពដែលមិនធ្វើឱ្យប៉ះពាល់ដល់ត្រី និងទឹកសំរាប់បរិភោគ ។

មានការស្រាវជ្រាវជាច្រើននៅក្នុងវិស័យកសិកម្មកម្ពុជា ដែលបានផ្តោតតែទៅលើផលិតកម្មដំណាំស្រូវ ហើយគោលបំណង គឺគាំទ្រដល់ការកែលំអទិន្នផលស្រូវនៅក្នុងប្រទេសកម្ពុជា (២,១តោន/ហិកតា) ឱ្យតាមទាន់កំរិតទិន្នផលប្រទេសជិតខាង ដូចជាប្រទេសថៃ (២,៣តោន/ហិកតា) និងវៀតណាម (៤,៣តោន/ហិកតា) ។ នៅក្នុងខណៈដែលប្រទេសកម្ពុជាស្វែងរកគំរូសមស្របមួយ ដើម្បីអភិវឌ្ឍន៍ផលិតកម្មដំណាំស្រូវ នោះគេអាចរៀនសូត្របានយ៉ាងច្រើន ដោយដកស្រង់បទពិសោធន៍ពីប្រទេសជិតខាងរបស់ខ្លួនអំពីទំនាក់ទំនង និងការផ្តោះប្តូរពាណិជ្ជកម្ម ក្នុងចំណោមផលិតកម្ម ប្រាក់ចំណេញ និងសន្តិសុខស្បៀង ។ បច្ចុប្បន្ននេះ លក្ខណៈផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជា ស្រដៀងគ្នាបំផុតទៅនឹងប្រទេសថៃ ដូចជា បរិស្ថានដំណាំស្រូវ ទិន្នផលមធ្យម ការនិយមប្រើពូជប្រពៃណី និងតំបន់ដែលស្រោចស្រព ។ ក៏ប៉ុន្តែគោលនយោបាយកសិកម្មរបស់រដ្ឋាភិបាលមាននិន្នាការផ្តោតទៅលើការបង្កើនផលិតកម្មដំណាំស្រូវក្នុងរបៀបមួយ ដែលស្រដៀងទៅនឹងវិធីសាស្ត្រ ដែលអនុវត្តនៅប្រទេសវៀតណាម ដូចជា បង្កើនការស្រោចស្រព ការប្រើប្រាស់ពូជទំនើប ពង្រីកការដាំដុះ និងដាំដំណាំទ្វេដងនៅទីកន្លែងណាដែលមានលទ្ធភាពអាចធ្វើទៅបាន ។ ដូចដែលបានអធិប្បាយដូចខាងលើ ឯកសារនេះគ្មានបំណងជូនយោបល់ថា វិធីសាស្ត្រផលិតកម្មដំណាំស្រូវដែលសមស្របបំផុតនៅក្នុងប្រទេសកម្ពុជា គួរតែអនុវត្តតាមគំរូប្រទេសថៃ ឬវៀតណាមឡើយ ប៉ុន្តែគ្រាន់តែលើកយកមកបង្ហាញនូវវិធីសាស្ត្រខុសៗគ្នាស្តីពីផលិតកម្មដំណាំស្រូវ ដែលអាចមានការប្រែប្រួល ហើយប៉ះពាល់ដល់ប្រាក់ចំណេញ និងសន្តិសុខស្បៀងរបស់កសិករ ។ គុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រ ទាំងនេះគួរត្រូវយកមកជជែកវែកញែកឱ្យកាន់ស៊ីជំរៅថែមទៀតនៅក្នុងគោលនយោបាយដឹកនាំវិស័យកសិកម្មរបស់កម្ពុជានាពេលអនាគត ។

ទិន្នន័យកសិកម្មរបស់ផលិតកម្មស្រូវ មានលក្ខណៈទូលំទូលាយសំបូរបែប និងអាចជឿជាក់បានច្រើនជាងទិន្នន័យផលិតកម្មស្បៀងដទៃទៀត ។ ថ្វីបើបច្ចុប្បន្ននេះ មានការអំពាវនាវឱ្យអនុវត្តកសិកម្មចំរុះ បង្កើនការកែច្នៃកសិផល និងជំនួញឱ្យកាន់តែច្រើនឡើងថែមទៀតក៏ដោយ ប៉ុន្តែវិស័យនេះនៅតែគ្មានពតិមានជាមូលដ្ឋានក្នុងការស្រាវជ្រាវស្តីពីការអនុវត្តន៍ជាក់ស្តែងនាពេលបច្ចុប្បន្ន ការលំបាក និងឱកាស ។ ដូចគ្នានេះដែរ ការជំរុញសម្បទានកសិកម្មខ្នាតធំរបស់រដ្ឋាភិបាល គួរតែត្រូវពិនិត្យពិច័យឱ្យកាន់តែច្បាស់លាស់ ដើម្បីកំណត់នូវសក្តានុពលភាពទាក់ទងនឹងផលប្រយោជន៍ និងថ្លៃចំពោះជីវភាពនៅតាមជនបទ ជាពិសេសពតិមានថ្មីៗកន្លងមកនេះបានបញ្ជាក់ថា សម្បទានកសិកម្មប្រមាណ ៦៤% (១៦ក្នុងចំណោម ២៥សម្បទាន) មានបញ្ហាតវ៉ា ឬការទន្ទ្រានកាន់កាប់យកដីពីសំណាក់ប្រជាជនមូលដ្ឋាន ។

ដោយប្រមាណ ៧៥% នៃកំលាំងពលកម្មធ្វើការងារនៅក្នុងវិស័យកសិកម្ម ដូចនេះគួរតែមានមតិរួមមួយក្នុងចំណោមអ្នកដឹកនាំគោលនយោបាយកសិកម្ម ពីព្រោះថា ការកាត់បន្ថយភាពក្រីក្រនាពេលអនាគត គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើជោគជ័យនៃការអភិវឌ្ឍន៍កសិកម្ម ។ ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព ការអភិវឌ្ឍន៍កសិកម្មនេះ នឹងត្រូវការចាំបាច់ឱ្យមានការគាំទ្រពីសំណាក់គោលនយោបាយដឹកនាំ ដោយផ្អែកលើទិន្នន័យដែលអាចជឿជាក់បាន និងការស្រាវជ្រាវដ៏ល្អមួយ ។ បន្ថែមពីលើការស្រាវជ្រាវផ្នែកបច្ចេកទេស ដូចជា ការគ្រប់គ្រងទឹក និងដី សក្តានុពលភាពស្រោចស្រពពូជស្រូវ និងបន្លែ ។ នោះគេត្រូវការចាំបាច់បំផុតឱ្យមានការស្រាវជ្រាវទៅលើផ្នែកសេដ្ឋកិច្ចសង្គម ថាតើទិសដៅនៃសំណើដើម្បីអភិវឌ្ឍន៍កសិកម្ម អាចមានប្រសិទ្ធិភាពទៅលើជីវភាពប្រជាជននៅតាមជនបទដែរឬទេ ។ ជាពិសេសការស្រាវជ្រាវឱ្យកាន់តែទូលំទូលាយត្រូវការចាំបាច់ឱ្យមានទំនាក់ទំនងរវាងការពង្រីក/ផលិតកម្មកសិកម្ម ការដាំដំណាំចំរុះ យុទ្ធសាស្ត្រកែច្នៃ និងគោលបំណងកាន់តែទូលំទូលាយរបស់រដ្ឋាភិបាលទាក់ទងនឹងការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ ទោះបីជាមានការស្រាវជ្រាវច្រើនដែលរាប់បញ្ចូលពុំអស់

ប៉ុន្តែការអធិប្បាយខាងក្រោមនេះ បានលើកយកពីលទ្ធភាពនៃផ្នែកស្រាវជ្រាវមួយចំនួនទាក់ទងនឹងសេដ្ឋកិច្ចសង្គម ។

## ក. មូលហេតុអ្វីបានជាបន្លែ និងដំណាំដទៃទៀតនៅក្នុងប្រទេសកម្ពុជាមិនអាចប្រកួតប្រជែងជាមួយនឹងការនាំចូលពីប្រទេសជិតខាង?

ការស្រាវជ្រាវទ្រង់ទ្រាយតូចមួយ បានបញ្ជាក់ឱ្យឃើញថា បន្លែប្រហែល ២៥-៥០% ឬច្រើនជាងនេះ ដែលបរិភោគនៅក្នុងប្រទេសកម្ពុជា គឺនាំចូលមកពីប្រទេសវៀតណាម និងថៃ ។ នៅក្នុងខណៈដែលកសិករកម្ពុជា បានពង្រីកកសិដ្ឋានរបស់ខ្លួនឱ្យកាន់តែហួសពីភាពគ្រប់គ្រាន់ ដើម្បីចិញ្ចឹមជីវិត (តំរូវការសន្តិសុខស្បៀង) ឱ្យពួកគេចាប់ផ្តើមដាំដុះដំណាំសំរាប់លក់នៅទីផ្សារ នោះពួកគេចាំបាច់ត្រូវតែប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល ។ គោលនយោបាយ បានអំពាវនាវឱ្យមានការអនុវត្តន៍កសិកម្មចំរុះ និងការបង្កើនផលិតកម្មបន្លែ និងដំណាំដទៃទៀតឱ្យកាន់តែច្រើន នេះអាចជាហេតុផលល្អមួយ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែងវិញ បច្ចុប្បន្ននេះ ហេតុអ្វីបានជាកសិករកម្ពុជាមួយចំនួន អាចប្រកួតប្រជែងបានជាមួយនឹងផលិតផលនាំចូល ចំណែកឯកសិករមួយចំនួនទៀតមិនអាចធ្វើទៅរួច ។ ការយកឈ្នះទៅលើបញ្ហាលំបាកផ្នែកបច្ចេកទេសនៃកសិកម្មចំរុះ គឺជាបញ្ហាប្រឈមតែមួយគត់របស់កសិករកម្ពុជា ពួកគេត្រូវតែរកឱ្យបានចំណូលមកពីការដាំដំណាំទាំងនេះ ឬមួយពួកគេនឹងមិនបន្តដាំដុះវាតទៅមុខទៀត ។ ដើម្បីធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង ស្តីពីការប្រកួតប្រជែង បន្លែ និងផលិតកម្មដំណាំដទៃទៀតរបស់កម្ពុជា ជាមួយនឹងប្រទេសជិតខាង នោះសំណួរស្រាវជ្រាវត្រូវបានលើកយកមកអធិប្បាយដូចខាងក្រោមៈ

- តើអ្វីខ្លះជាការលំបាកចំបង ចំពោះការដាំបន្លែ និងដំណាំដទៃទៀត ក្នុងលក្ខណៈទ្រង់ទ្រាយតូច?
- តើមានថ្លៃផលិតកម្មអ្វីខ្លះ នៅក្នុងប្រទេសកម្ពុជា ធៀបនឹងប្រទេសជិតខាង? តើថ្លៃផលិតកម្មមួយណាដែលខ្ពស់ជាងគេនៅក្នុងប្រទេសកម្ពុជា? និងតើធ្វើយ៉ាងដូចម្តេចដើម្បីកាត់បន្ថយថ្លៃផលិតកម្មនេះ?
- តើត្រូវចាប់ផ្តើមគោលនយោបាយអ្វីខ្លះ ដែលអាចកែលំអការប្រកួតប្រជែងនៃបន្លែ និងផលិតកម្មដំណាំផលិតក្នុងស្រុកឱ្យប្រសើរឡើង?

## ខ. តើអ្វីខ្លះ ជាសក្តានុពលក្នុងរយៈពេលខ្លី និងរយៈពេលវែងសំរាប់កែលំអសមត្ថភាពកែច្នៃឱ្យបានតំលៃបន្ថែមនិងម៉ាឃីនីង និងថាតើការផ្លាស់ប្តូរនេះមានប្រសិទ្ធិភាពយ៉ាងដូចម្តេចដល់ជីវភាពជនបទ?

- តើដំណាំស្បៀងនានាចូលរួមចំណែកក្នុងចំណូលរបស់កសិករយ៉ាងដូចម្តេច? តើតំលៃផលិតផលនៅឯកសិដ្ឋានខុសគ្នានឹងតំលៃផលិតផលដែលលក់នៅលើទីផ្សារយ៉ាងដូចម្តេច? តើចំណូលប៉ុន្មានដែលទទួលបានចំពោះម្នាក់ៗដែលចូលរួមនៅក្នុងជំនួញដំណាំស្បៀង (កសិករ អ្នកជំនួញ អ្នកកែច្នៃ អ្នកលក់រាយ អ្នកនាំចេញ ។ល។)?
- តើដំណាំស្បៀងផ្សេងៗនាពេលបច្ចុប្បន្ននេះត្រូវបានគេយកទៅកែច្នៃយ៉ាងដូចម្តេច? តើឱកាសអ្វីខ្លះដែលមានស្រាប់សំរាប់ធ្វើការកែច្នៃផលិតផលក្នុងទ្រង់ទ្រាយតូច ដើម្បីទទួលបានតំលៃបន្ថែមឱ្យកាន់តែប្រសើរឡើង?
- តើដំណាំស្បៀងត្រូវបានគេធ្វើពាណិជ្ជកម្មយ៉ាងដូចម្តេច និងនៅទីណាខ្លះ? តើនរណាខ្លះពាក់ព័ន្ធនឹងពាណិជ្ជកម្មនេះ? តើពាណិជ្ជកម្មនេះ មានលក្ខណៈសេរី និងដោយការប្រកួតប្រជែង ឬមានបញ្ហាលំបាក ដូចជា បណ្តាញពាណិជ្ជកម្មផ្តាច់មុខ ឬត្រូវការអាជ្ញាប័ណ្ណ និងការអនុញ្ញាត?
- តើដំណាំស្បៀងប្រភេទណាខ្លះ ដែលធ្វើការនាំចេញ (ផ្លូវការ និងក្រៅផ្លូវការ)? តើផលិតផលដំណាំស្បៀងនេះ បានទទួលតំលៃបន្ថែមមកពីការកែច្នៃបន្ទាប់ពីនាំចេញដែរឬទេ? តើឱកាសអ្វីខ្លះសំរាប់ចាប់ផ្តើមកែច្នៃ ដើម្បីទទួលបានតំលៃបន្ថែមនៅក្នុងប្រទេសកម្ពុជា?

## គ. តើអ្វីខ្លះដែលជាតួនាទីសមស្របរបស់សម្បទាន នៅក្នុងការអភិវឌ្ឍន៍កសិកម្មកម្ពុជា? តើកសិកម្មសម្បទានមានប្រសិទ្ធិភាពយ៉ាងដូចម្តេច នៅក្នុងការកែលំអជីវភាពជនបទឱ្យប្រសើរឡើង?

ជាច្រើនឆ្នាំកន្លងមកនេះ រដ្ឋាភិបាលបាននិងកំពុងជំរុញការវិនិយោគទៅលើសម្បទានកសិកម្ម ដែលជាគោលបំណងក្នុងការបង្កើនផលិតកម្មកសិកម្ម និងការនាំចេញ ។ បច្ចុប្បន្ននេះ មានសម្បទានកសិកម្មចំនួន ៤០ ដែលគ្រប់គ្រងលើផ្ទៃដីជាង ៨00.000ហិកតា ហើយបានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដែលក្នុងនោះ ២៥សម្បទាន គ្រប់គ្រងផ្ទៃដីប្រមាណ ៧២0.000ហិកតា បានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ថ្វីបើសម្បទានកសិកម្មមានតួនាទីធំធេងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ ប៉ុន្តែវាមានពតិមានតិចតួចស្តីពីប្រសិទ្ធិភាពជាក់ស្តែង នៅក្នុងការកែលំអការអភិវឌ្ឍន៍ជនបទឱ្យប្រសើរឡើង ។ សំណួរស្រាវជ្រាវសំខាន់រួមមានៈ

- តើអ្វីខ្លះជាថ្លៃ ផលប្រយោជន៏ ប្រសិទ្ធិភាព និងផលប៉ះពាល់នៃការបង្កើនមាត្រដ្ឋានអនុវត្តកសិកម្ម ឱ្យក្លាយជាសម្បទានដែលមានទ្រង់ទ្រាយធំ? "ការបង្កើនទ្រង់ទ្រាយធំ" នេះ ធៀបនឹងវិធីសាស្ត្រធ្វើកិច្ចសន្យាកសិកម្មដែលរួមមានកសិករទ្រង់ទ្រាយតូចក្នុងចំនួនជាច្រើន តើវិធីសាស្ត្រមួយណាមានលក្ខណៈប្រសើរជាង?
- តើអ្វីខ្លះជាដំណើរការដើម្បីកំណត់ថាសម្បទានកសិកម្ម និងត្រូវបានគេផ្តល់យ៉ាងដូចម្តេច និងនៅកន្លែងណា? តើដំណើរការនេះមានលក្ខណៈយ៉ាងដូចម្តេច បើធៀបនឹងដំណើរការដែលផ្តល់ព្រៃសម្បទាន ជាពិសេសទាក់ទងនឹងការដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ការវាយតំលៃផលប៉ះពាល់ទៅលើសង្គម និងបរិស្ថាន និងតំរូវការផែនការគ្រប់គ្រង? តើរដ្ឋាភិបាលបានចំណូល (ផ្លូវការ និងក្រៅផ្លូវការ) ប៉ុន្មានពីការជួល និងថ្លៃឈ្នួលសម្បទានកសិកម្មនេះ? តើចំណូលទាំងនេះត្រូវបានយកទៅប្រើប្រាស់យ៉ាងដូចម្តេចនៅក្នុងគោលបំណងអភិវឌ្ឍន៍ជនបទ?
- តើសម្បទានកសិកម្មមានប្រសិទ្ធិភាពយ៉ាងដូចម្តេចខ្លះទៅលើការអភិវឌ្ឍន៍ជនបទ? តើអ្វីខ្លះជាផលប្រយោជន៍ដែលសម្បទានកសិកម្មបានផ្តល់ឱ្យ ដូចជា ការងារធ្វើនៅក្នុងការអនុវត្តន៏ ឬគាំទ្រដល់ការកែច្នៃ និងការសំរបសំរួលម៉ាឃីទីង? តើសម្បទាមកសិកម្មមានផលប៉ះពាល់យ៉ាងដូចម្តេច ចំពោះការប្រើប្រាស់ធនធានធម្មជាតិដែលធ្វើឡើងដោយប្រជាជននៅជនបទដែលរស់នៅជុំវិញតំបន់នោះ?
- នៅក្នុងទិសដៅរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ តើឈរនៅលើមូលដ្ឋានអ្វីខ្លះ ឬផ្អែកទៅលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដែលសម្បទានកសិកម្មគួរត្រូវបានគេផ្តល់រក្សាទុក ឬក៏លុបចោល ដើម្បីជាគុណប្រយោជន៏ដល់ការគ្រប់គ្រងប្រភេទដទៃទៀត?

## ឃ. តើជម្លោះស្តីពីសម្បទានកសិកម្មត្រូវបានដោះស្រាយដូចម្តេចនាពេលបច្ចុប្បន្ននេះ? តើត្រូវធ្វើអ្វីខ្លះដើម្បីកែលំអយន្តកម្មដោះស្រាយទំនាស់? សំខាន់ជាងនេះទៀត តើត្រូវចាត់វិធានការអ្វីខ្លះដើម្បីកាត់បន្ថយសក្តានុពលភាពជម្លោះនៅក្នុងកន្លែងដំបូង?

យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពេលថ្មីៗនេះ មានសម្បទានដែលកំពុងដំណើរការចំនួន ១៦ក្នុងចំណោម ២៥ ជួបប្រទះនូវបញ្ហាតវ៉ា ឬការទន្ទ្រានកាន់កាប់ដីពីសំណាក់ប្រជាជនមូលដ្ឋាន ។ ប្រជាជនមូលដ្ឋានបានប្តឹងតវ៉ាអំពីផលប៉ះពាល់នេះ ចំពោះជីវភាពរស់នៅរបស់គេដោយសារការបាត់បង់ដី និងរារាំងមិនឱ្យមានសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ ។ ដូចគ្នានេះ សម្បទានិកជាច្រើនបានប្តឹងតវ៉ាថា ពួកគេពុំអាចបន្តសកម្មភាពអនុវត្តតាមផែនការវិនិយោគបានឡើយ ហើយពួកគេអាចបោះបង់ការវិនិយោគនេះចោល ។ លើសពីនេះទៅទៀត បរិយាកាសជម្លោះធ្វើឱ្យសក្តានុពលអ្នកវិនិយោគទុននៅក្នុងសម្បទានកសិកម្ម ហាក់ដូចជាធ្លាក់ទឹកចិត្ត ។ ដូចនេះ ចាំបាច់ត្រូវឱ្យមានការយល់ដឹងឱ្យកាន់តែប្រសើរឡើងថែមទៀត

ស្តីអំពីឫសគល់នៃជម្លោះរបស់សម្បទានកសិកម្ម ។ ធ្វើយ៉ាងនេះ វាអាចផ្តល់ជាមូលដ្ឋានសំខាន់សំរាប់កែលំអដំណើរការអនុវត្តន៏ជាក់ស្តែង/ការផ្តល់សម្បទាននៅក្នុងបែបផែនមួយដែលរាប់បញ្ចូលគ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងកាត់បន្ថយសក្តានុពលភាពជម្លោះ ។ បន្ថែមពីលើនេះ ការសិក្សាស្រាវជ្រាវបន្ថែម គឺត្រូវការចាំបាច់ឱ្យមានយន្តកម្មសំរាប់ដោះស្រាយជម្លោះនៅពេលដែលវាកើតមានឡើង ។

- តើអ្វីទៅជាដំណើរការផ្លូវការ ដើម្បីដោះស្រាយជម្លោះសម្បទានកសិកម្ម ដែលអនុលោមទៅតាមច្បាប់ដីធ្លី និងអនុក្រឹត្យ ព្រមទាំងនិយ័តកម្ម? អ្នកណាខ្លះដែលជាអ្នកចូលរួម តើពួកគេមានតួនាទីអ្វីខ្លះ?
- តើជម្លោះនៅលើសម្បទានកសិកម្ម ត្រូវបានដោះស្រាយយ៉ាងដូចម្តេចនៅក្នុងការអនុវត្តន៏ជាក់ស្តែង?
- តើមានមេរៀន និងគំរូអ្វីខ្លះស្តីពីការដោះស្រាយជម្លោះ សម្បទានកសិកម្មដែលដកស្រង់បទពិសោធន៏មកពីប្រទេសដទៃទៀត? តើមានវិធានការអ្វីខ្លះ មុននឹងផ្តល់សម្បទាន ដើម្បីព្យាយាមកាត់បន្ថយសក្តានុពលភាពជម្លោះ?

## ឯកសារយោង


Ahlers, R. and S. Vlaar (1995), *Up to the Sky: A Study on Gender Issues in Irrigation in Cambodia in the Provinces of Takeo and Prey Veng,* (Phnom Penh: SAWA)

Bui, B. B. (2000), "Bridging the Rice Yield Gap in Vietnam", in Papdemetriou, M.K., F. J. Dent, and E. M. Herath (eds.), *Bridging the Rice Yield Gap in the Asia-Pacific Region* (Bangkok: FAO)

Cambodia Development Resource Institute (2002), "Main Economic Indicators," (Phnom Penh: CDRI, raw data provided by the Ministry of Economy and Finance)

Cameron, B. (1995), *Fertilizer Supply and Quality in Cambodia*, (Phnom Penh: MAFF and Australia Agricultural Assistance Project)

Cameron, B, and P. Twyford-Jones (1995), *Development of the vegetables in Cambodia*, (Phnom Penh: MAFF)

Catalla, R.F., N. Shams, and S. Vignola (2001), "Gender, Sustainable Agriculture and Food Security in Cambodia – An Overview of the Literature" in *Cambodian Journal of Agriculture*, Vol. 4 (Phnom Penh: Cambodian Society of Agriculture)

Center for National Policy (1996), *Fertilizer Sector Policy Issues*, (Phnom Penh: MAFF)

Chan S., S. Tep, and S. Acharya (2001), *Land Tenure in Cambodia, a Data Update*, (Phnom Penh: CDRI Working Paper No. 19)

Chandler, D.P. (1993), *A History of Cambodia*, (Colorado: Westview Press, Second Edition)

FAOSTAT (2001), "Rice Production: General Information and Statistics" (4/6/2001), (www.fao.org/ag/AGP/AGPC/doc/riceinfo/Asia.htm)

Frings, V. (1993), *The Failure of Agricultural Collectivisation in the People's Republic of Kampuchea (1979-1989)*, The Center of Southeast Asian Studies, Working Paper 80 (Victoria, Australia: Monash University)

Fujisaka, S. (1988), "Rice Agroecosystems, Farmer Management, and Social Organization in Kampuchea: PrelimInary Assessment and Research Recommendations", *IRRI Research Paper Series*, no. 136, (Manila: International Rice Research Institute)

Halcrow & Partners Limited (1994), *Irrigation Rehabilitation Study in Cambodia: Inventory & Analyses of Existing Systems: Volume 1 – Main Report*, (Phnom Penh: Mekong Secretariat)

Helen Keller International Cambodia, "Round 1: July-September 1999 – Monitoring activities in village model gardens and household gardens," in *Multi-Benefit Food and Health Model Program*, Year 1, Issue 1, March 2000 (Phnom Penh: Helen Keller International Cambodia).

Helmers, K. (1997), "Rice in the Cambodian economy: past and present", in Nesbitt, H.J. (ed.), *Rice Production in Cambodia,* (Phnom Penh: Cambodia-IRRI-Australia Project)

Jahn, G., C. Pol, S. Pheng, B. Khiev, and N. Chhorn (1999), *Pest Management and Rice Production Practices of Farmers in Upland and Deepwater Rice Ecosystems of Cambodia*, (Phnom Penh: Cambodia-IRRI-Australia Project)

Jahh, G., B. Khiev, S. Pheng, and C. Pol (1997), "Pest management in rice", in Nesbitt, H.J. (ed.), *Rice Production in Cambodia,* (Phnom Penh: Cambodia-IRRI-Australia Project)

Jahn, G., S. Pheng, B. Khiev, and C. Pol (1996), *Farmers' Pest Management and Rice Production Practices in Cambodian Lowland Rice*, (Phnom Penh: Cambodia-IRRI-Australia Project)

Javier, E. L. (1997), "Rice ecosystems and varieties", in Nesbitt, H.J. (ed.), *Rice Production in Cambodia,* (Phnom Penh: Cambodia-IRRI-Australia Project)

Kupkanchanakul, T. (2000), "Bridging the Rice Yield Gap in Thailand", in Papdemetriou, M.K., F. J. Dent, and E. M. Herath (eds.), *Bridging the Rice Yield Gap in the Asia-Pacific Region* (Bangkok: FAO)

Lando, R.P. and S. Mak (1994a), "Rainfed Lowland Rice in Cambodia: A Baseline Survey", *IRRI Research Paper Series*, no. 152, (Manila: International Rice Research Institute)

Lando, R.P. and S. Mak (1994b), "Deepwater Rice in Cambodia: A Baseline Survey", *IRRI Research Paper Series*, no. 153, (Manila: International Rice Research Institute)

Mary C., K. Vann, and V. Sun (2001), *A Survey on Environmental and Health Effects of Agrochemical Use in Rice Production in Takeo Province, Cambodia* (Singapore: EEPSEA)

Maclean, M. (1998), *Livestock in Cambodian Rice Farming Systems*, (Phnom Penh: Cambodia-IRRI-Australia Project)

Ministry of Agriculture, Forestry and Fisheries (2001), *Agricultural Statistics 2000-01,* (Statistics Office: MAFF)

Ministry of Agriculture, Forestry and Fisheries (2000), *Agricultural Statistics 1999-00* (Statistics Office: MAFF)

Ministry of Agriculture, Forestry and Fisheries (1999), *Agricultural Statistics 1998-99* (Statistics Office: MAFF)

Ministry of Agriculture, Forestry and Fisheries (1995), *Report on the Pilot Livestock Sample Survey Conducted in Takeo, Kandal and Prey Veng Provinces*, (Phnom Penh: MAFF)

Ministry of Commerce (2001), *Integration and competitiveness study-Part C: Sector studies-rice, diversified agriculture, handicrafts, fisheries, garments, tourism, labour services,* (Phnom Penh: Ministry of Commerce)

Ministry of Commerce (2000), *Cambodia Opportunities for the New Millennium: Business and Investment Handbook 2000*, (Phnom Penh: Ministry of Commerce)

Ministry of Planning (2001), *(Draft) Second Five Year Socioeconomic Development Plan 2001-2005*, (Phnom Penh: Ministry of Planning)

Moser, C. M., and C. B. Barrett (2002), *(Draft) The System of Rice Intensification in Practice: Explaining Low Farmer Adoption and High Disadoption in Madagascar*, (Ithaca, NY: Cornell University)

Murshid, K. A. S. (1998), *Food Security in an Asian Transitional Economy: The Cambodian Experience*, (Phnom Penh: CDRI Working Paper No. 6)

Mysliwiec, E. (1988), *Punishing the Poor: the International Isolation of Kampuchea,* (Oxford: OXFAM)

Mysliwiec, E. (1987), *Kampuchea: The State of Agriculture and Outlook for the Future",* MPS (Agriculture) Thesis, (Ithaca, NY: Cornell University)

National Institute of Statistics (2001), *Cambodia Statistical Yearbook 2000,* (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *General Population Census of Cambodia 1998* (Phnom Penh: Ministry of Planning)

Nesbitt, H.J. (1997), "Constraints to rice production and strategies for improvement", in Nesbitt, H.J. (ed.), *Rice Production in Cambodia,* (Phnom Penh: Cambodia-IRRI-Australia

Project)

Nesbitt, H.J. and P. Chan (1997), "Rice-based Farming systems", in Nesbitt, H.J. (ed.), *Rice Production in Cambodia,* (Phnom Penh: Cambodia-IRRI-Australia Project)

NGO Forum (2002), "Contribution to the NGO submission to the Consultative Group Forestry Sector", (Phnom Penh: NGO Forum)

Norris, C., S. El, and S. Uy (2001), *Gender Analysis of Rice Technologies Developed by the Cambodia-IRRI-Australia Project (CIAP),* (Phnom Penh: CIAP)

Pillot, D., C. Fusillier, A. Pouliquen, N. Morel, and K. Yang Saing (2000), *Scenarios for the Rural Sector of Cambodia and the Agricultural Education system: Part 2- Farming Systems in Cambodia and Their Evolution,* (Phnom Penh: Ministry of Agriculture, Forestry and Fisheries)

Prom, T. (1999), "*Assessment of Diversified Farming in Chrot Motes Commune, Svay Teap District, Svay Rieng Province, Cambodia",* Msc. Thesis (Thailand: Asian Institute of Technology)

Ramamurthy, B., B. Sik, P. Ronnas, and H. Sok (2001), *Cambodia 1999-2000: Land, Labour and Rural Livelihood in Focus* (Phnom Penh: CDRI Working Paper No. 21)

Rickman, J. F., B. Som, S. Poa, and P. Meas (2001), "Rice milling in Cambodia", in Cox, P. and C. Ros (eds.), *The Impact of Agricultural Research for Development in Southeast Asia,* (Phnom Penh: Proceedings of an International Conference at CARDI, 24-26 October 2000)

Roberts, M.S., (1998), *Groundwater Irrigation in the Cambodian Mekong Delta,* Msc. Thesis, (Ithaca, NY: Cornell University)

Royal Government of Cambodia (2000), *Sub-Decree on the Forest Concession Management,* (Phnom Penh: RGC No. 05 ONKR-BK)

Shams, N., H. Try, and D. Gutierrez (2000), "A Review of Vegetable Pest Management in Cambodia", in *Cambodian Journal of Agriculture*, Vol. 3 (Phnom Penh: Cambodian Society of Agriculture)

Shams N., M. Ungsa, P. Yech, S. Sodavy, S. Nuth, and H. Try (1997), *Review of Vegetable Production in Cambodia,* (Phnom Penh: MAFF).

Shawcross, W. (1979), *Sideshow: Kissinger, Nixon, and the Destruction of Cambodia,* (New York: Simon and Schuster)

Sik, B. (2000), *Land Ownership, Sales and Concentration in Cambodia: A PrelimInary Review of Secondary Data and Primary Data from Four Recent Surveys,* (Phnom Penh: CDRI Working Paper No. 16)

So, S., S. Real, U. Uch, R. Sy, B. Ballard, and S. Acharya, (2001), *Social Assessment of Land in Cambodia, a Field Study,* (Phnom Penh: CDRI Working Paper No. 20)

Sok H., H. Chea, B. Sik (2001*), Cambodia's Annual Economic Review 2001,* (Phnom Penh: Cambodia Development Research Institute)

Tichit, L. (1981), *L'agriculture au Cambodge,* (Paris: Agence de Coopération Culturelle et Technique)

Ungsa, M. and V. Hean (1994), *Vegetable Production, Research and Policy: Country Report,* (Phnom Penh: Department of Agronomy)

Urwin, N. and T. Wrigley (2001), *Environmental Impact Assessment of the Cambodia-IRRI-Australia Project (CIAP),* (Phnom Penh: Cambodia-IRRI-Australia Project)

White, P.F., T. Oberthur, and S. Pheav (1997a), "Soils and Rice", in Nesbitt, H.J. (ed.), *Rice Production in Cambodia*, (Phnom Penh: Cambodia-IRRI-Australia Project)

White, P.F., T. Oberthur, and S. Pheav (1997b), *The Soils Used for Rice Production in Cambodia: A Manual for their Identification and Management,* (Philippines: International Rice Research Institute)

Yang Saing, K. (2001), *Pesticide Use in Tonle Sap Region,* (Phnom Penh: CEDAC) (in Khmer)

Yang Saing, K. (1998), Sustainable Agriculture Country Profile: Cambodia, (Phnom Penh: CEDAC, PAN and RUA)

Yang Saing, K. (1996), *Sustainable Agriculture Development Strategies for Cambodia (Draft).* (Phnom Penh: JVC-RUA)

Young, D., R. Raab, R. Martin, S. Sin, B. Leng, B. Abdon, S. Mot, and M. Seng (2001), *Economic Impact Assessment of the Cambodia-IRRI-Australia Project,* (Phnom Penh: Cambodia-IRRI-Australia Project)

Zaman, A. (2000), Hand Book for Home Gardening in Cambodia: The Complete Manual for Vegetable and Fruit Production (Draft), (Phnom Penh: Helen Keller International Cambodia)

# ជំពូកទី ៣

# វិស័យជលផល

ទឹកសាបនៅប្រទេសកម្ពុជា ដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរបស់ប្រជាជនតាមជនបទ ពីព្រោះវាជាប្រភពជលផលទឹកសាបដ៏មានផលិតភាពខ្ពស់នៅលើពិភពលោក ផ្តល់នូវប្រភពទឹកសំរាប់បរិភោគនិងស្រោចស្រព និងជួយទ្រទ្រង់គមនាគមន៍ផ្លូវ ទឹកទៀតផង[១៩] ។ ភាពសំបូរបែបនៃទន្លេបឹងបួរទាំងនេះ ជួយទ្រទ្រង់ជីវិតសត្វក្នុងទឹកជាច្រើន ដែលមានជាង ៥០០ប្រភេទ ។ សត្វក្នុងទឹកស្ទើរតែគ្រប់ប្រភេទទាំងអស់ត្រូវបានគេចាប់យកទៅប្រើប្រាស់ជាចំណីអាហាររបស់មនុស្ស និងសត្វ ឬក៏ប្រើប្រាស់ ក្នុងការចិញ្ចឹមត្រី (Rainboth 1996) ។

ជំពូកនេះ ពិនិត្យទៅលើស្ថានភាពជាក់ស្តែងនៃជលផលទឹកសាប និងទឹកប្រៃ ដោយផ្តោតសំខាន់ទៅលើជលផលទឹកសាប ពីព្រោះ វាដើរតួសំខាន់ខ្លាំងក្នុងការទ្រទ្រង់ជីវភាពជនបទ ។ ឯកសារនេះផ្តល់ពត៌មានអំពីការស្តុកត្រី និងផលនេសាទប្រចាំឆ្នាំ, សារៈសំខាន់នៃវិស័យជលផលទៅលើជីវភាពជនបទ, ស្ថានភាព និងបញ្ហាប្រឈម ក្នុងការគ្រប់គ្រងជលផល, ឥទ្ធិពលនៃវិស័យដែលទាក់ទងនឹងជលផល, បញ្ហាទីផ្សារ និងពាណិជ្ជកម្មត្រី ។ បន្ទាប់មក មានការលើកឡើងអំពីផ្នែកមួយចំនួនដែលមានសក្តានុពលសំរាប់ការស្រាវជ្រាវទៅអនាគត ដោយផ្អែកលើការវាយតំលៃពីការខ្វះចន្លោះ និងតំរូវការក្នុងការស្រាវជ្រាវ ។

## ៣.១. តំបន់នេសាទសំខាន់ៗ

ប្រហែល ៨៥% នៃផ្ទៃប្រទេសកម្ពុជាស្ថិតនៅក្នុងអាងទន្លេមេគង្គ ។ រាល់ឆ្នាំ ពីខែមិថុនា ដល់តុលា ជំនន់ក្នុងទន្លេមេគង្គ និងដៃរបស់វា បានបង្កើតនូវប្រព័ន្ធអេកូឡូស៊ីលិចទឹកមួយដ៏ធំធេង ។ តំបន់ព្រៃលិចទឹកនិងព្រៃគុម្ពោតរាប់ពាន់គីឡូម៉ែត្រក្រឡា ត្រូវលិចទឹកជាបណ្តោះអាសន្ន ហើយក្លាយជាជំរក និងប្រភពចំណីដ៏ប្រសើរសំរាប់ត្រី (ពិសេសនៅជុំវិញបឹងទន្លេសាបដែលផ្ទៃទឹកកើនប្រហែល ៤-៥ដងនៅរដូវវស្សា កើនពី ២.៥០០គ.ម$^{2}$ - ៣.០០០គ.ម$^{2}$ ទៅប្រហែល ១០.០០០ - ១៥.០០០ម$^{2}$ (Csavas 1994, Rainboth 1996, NEDECO 1998) ។ ជំរៅបឹងទន្លេសាបប្រែប្រួលពី ១-២ម នៅរដូវប្រាំងទៅ ៨-១០ម នៅរដូវវស្សា ។

កំណើនផ្ទៃក្រឡា និងជំរៅទឹកនៃបឹងទន្លេសាប គឺបណ្តាលមកពីទឹកទន្លេមេគង្គដែលឡើងលឿននៅរដូវវស្សា ដោយធ្វើឱ្យទន្លេសាបដែលហូរពីបឹងទន្លេសាបមកភ្នំពេញនោះ ត្រូវហូរបញ្ច្រាសទិសវិញ ។ មានការប៉ាន់ស្មានថា ទន្លេមេគង្គ គឺជាប្រភពផ្តល់ប្រហែល ៦២% នៃទឹកបឹងទន្លេសាបនៅរដូវវស្សា រីឯទឹក ៣៨% ផ្សេងទៀតបានមកពីតំបន់នៅជុំវិញបឹងទន្លេសាប (NEDECO 1998) ។

---

[១៩] ទឹកសាបរួមមានទឹកនៅលើ និងក្រោមដី ដែលមិនទាក់ទងនឹងទឹកសមុទ្រ (ដូច្នេះគឺមិនរួមបញ្ចូល ពាម និងដៃសមុទ្រទេ) ។ ធនធានទឹកទាំងនេះ អាចស្ថិតនៅជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន និងរួមមាន ទន្លេ ស្ទឹង បឹងបួរ ត្រពាំង ដីសើម ព្រៃលិចទឹក វាលស្រែលិចទឹក ទំនប់ និងប្រឡាយស្រោចស្រព វាលទំនាបលិចទឹក និងទឹកជ្រោះ ។

## ផែនទី៣.១. ឡូត៍សេសាននៅប្រទេសកម្ពុជា

ដូចមានបង្ហាញនៅក្នុងផែនទី៣.១ ជលផលទឹកសាបនៅកម្ពុជាបែងចែកចេញជា ៣ តំបន់ :

- **តំបន់បឹងទន្លេសាប និងទន្លេសាប** ដែលជាតំបន់នេសាទសំខាន់បំផុត រួមមាន ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងខេត្តកណ្តាល ដែលស្ថិតនៅខាងជើងក្រុងភ្នំពេញ ។
- **តំបន់ទន្លេមេគង្គ និងទន្លេបាសាក់** រួមមានខេត្តកណ្តាលភាគខាងត្បូងក្រុងភ្នំពេញ ខេត្តកំពង់ចាម តាកែវ ព្រៃវែង និងខេត្តស្វាយរៀង ។
- **តំបន់ទន្លេមេគង្គលើ** ដែលមិនសូវលេចធ្លោខាងផ្នែកនេសាទបែបពាណិជ្ជកម្មទេ ប៉ុន្តែមានសារៈសំខាន់ជួយទ្រទ្រង់ដល់ពូជត្រីដែលធ្វើបំលាស់ទី និងចំពោះការនេសាទលក្ខណៈគ្រួសារ ។ តំបន់នេះរួមមាន ខេត្តក្រចេះ និងស្ទឹងត្រែង (Ahmed *et al.* 1998) ។

ក្រៅពីតំបន់នេសាទទឹកសាប កម្ពុជាមានតំបន់ឆ្នេរសមុទ្រប្រវែង ៤៣៥គ.ម ដែលស្ថិតនៅតាមបណ្តោយខេត្ត-ក្រុងមួយចំនួន ដូចជា ខេត្តកោះកុង ខេត្តកំពត ក្រុងព្រះសីហនុ និងក្រុងកែប[២០] ។ តំបន់ឆ្នេរសមុទ្ររួមមាន ឆ្នេរខ្សាច់ ព្រៃកោងកាង ផ្កាថ្ម និងស្មៅ សមុទ្រ ដែលជួយទ្រទ្រង់ជីវិតសត្វសមុទ្រ ។ ផ្ទៃទឹកតំបន់ឆ្នេររបស់ប្រទេសកម្ពុជា មានផ្ទៃសរុប ៥៥.៦០០គ.ម$^{២}$ ដែលគេហៅថា តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone - EEZ) ដែលលាតសន្ធឹងពីឆ្នេរសមុទ្រចំងាយ ២០០ម៉ៃល (ប្រហែល ៣២០គ.ម) ។ ក៏ប៉ុន្តែគំនូសព្រំប្រទល់ EEC នៅជាកម្មវត្ថុនៃការចរចាជម្លោះព្រំដែនជាមួយប្រទេសវៀតណាម និងថៃ នៅឡើយ ។

## ៣.២. ស្ថានភាពត្រីក្នុងទឹក និងផលនេសាទប្រចាំឆ្នាំ

ស្ថិតិនៃផលនេសាទនៅប្រទេសកម្ពុជា មិនដែលបានវាស់វែងត្រឹមត្រូវទេ ។ រហូតដល់ទសវត្សរ៍១៩៨០ គេឃើញមានការពិពណ៌នាតែខ្លះៗប៉ុណ្ណោះអំពីផលនេសាទ គឺគ្មានទិន្នន័យដែលមានប្រយោជន៍ពេញលេញសំរាប់ការវិភាគអំពីការប្រែប្រួលនៃបរិមាណត្រីដែលបានចាប់ក្នុងរយៈពេលកន្លងទៅនោះទេ ។ ចាប់ពីឆ្នាំ១៩៨១-៩៥ នាយកដ្ឋានជលផលបានប៉ាន់ស្មានថា បរិមាណត្រីទឹកសាបចាប់បានមានពី ៥០.០០០ - ៧៥.០០០តោនក្នុងមួយឆ្នាំ ។ ក៏ប៉ុន្តែស្ថិតិទាំងនេះមានបញ្ហាច្រើនណាស់ ដោយសារមូលហេតុមួយចំនួន ។ ទីមួយ ភាគច្រើនបំផុតនៃត្រីដែលអ្នកនេសាទតូចតាចចាប់បាន ពុំបានរាប់បញ្ចូលនៅក្នុងស្ថិតិជាតិទេ ។ ទីពីរ ស្ថិតិនេសាទគ្រាន់តែបង្ហាញពីបរិមាណត្រីចាប់បាននៅក្នុង ១៣ខេត្ត-ក្រុង (រួមទាំងភ្នំពេញ) ដែលនាយកដ្ឋានជលផលបានអនុវត្តប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ និងធ្វើកិច្ចសន្យាជួលប៉ុណ្ណោះ គឺគ្មានការប្រមូលទិន្នន័យពីខេត្ត-ក្រុងចំនួន ១១ ទៀតនោះទេ (Ahmed *et al.* 1998) ។ ទីបី ប្រព័ន្ធប្រមូលទិន្នន័យដែលទន់ខ្សោយ និងមិនសមស្រប បានបណ្តាលឱ្យមានការរាយការណ៍បន្ថយនូវបរិមាណត្រីដែលឈ្មួញនេសាទធំៗចាប់បាន ។ ឧទាហរណ៍ ស្ថិតិដែលរាយការណ៍ ជាធម្មតាច្រើនផ្អែកទៅលើតួលេខផែនការជាជាងការពិនិត្យគំរូតាងមួយចំនួនលើបរិមាណចាប់បានជាក់ស្តែង (Van Zalinge *et al.* 2000) ។

ដើម្បីប៉ាន់ស្មានឱ្យបានប្រាកដនិយមជាងមុន អំពីបរិមាណត្រីទឹកសាបដែលចាប់បានប្រចាំឆ្នាំនៅកម្ពុជា ពីឆ្នាំ១៩៩៤-៩៧ Van Zalinge *et al.* (2000) បានយកមកគួបផ្សំគ្នានូវទិន្នន័យដែលបានពីការសិក្សាមួយចំនួនលើបរិមាណត្រីចាប់បាន និងបរិមាណត្រីបរិភោគអស់នៅក្នុងការនេសាទធុនធំ មធ្យម និងតូច និងក្នុងការនេសាទនៅតាមវាលស្រែ ។ ប្រភពទិន្នន័យទាំងនេះរួមមាន អង្កេតវាយតំលៃពីផលត្រីចាប់បានធ្វើឡើងដោយគំរោងគ្រប់គ្រងនេសាទត្រីទឹកសាបនៃកម្ពុជា (MRC/DoS/Danida), អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ ធ្វើដោយ Ahmed *et al.* (1998), និងការស្រាវជ្រាវពីការនេសាទតាមវាលស្រែធ្វើដោយ Gregory

[២០] ផ្អែកតាមជំរឿនឆ្នាំ១៩៩៨ ប្រទេសកម្ពុជាត្រូវបានចែកជា ២០ខេត្ត រាជធានីមួយ (ភ្នំពេញ) និងក្រុងចំនួនបី (ក្រុងព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិន) ។

(1997) ។ ការគួបផ្សំគ្នានូវការប៉ាន់ស្មានទាំងនេះបានបង្ហាញថា ផលនេសាទទឹកសាបក្នុងមួយឆ្នាំៗមានប្រហែលពី ២៩០.០០០-៤៣០.០០០តោន (តារាង៣.១) ដែលធ្វើឱ្យការនេសាទទឹកសាបនៅកម្ពុជា មានទិន្នផលខ្ពស់បំផុតនៅក្នុងតំបន់ និងមានលំដាប់ទី៤ នៅក្នុងពិភពលោក Van Zalinge *et al.* (2000) ។ យោងតាមទិន្នន័យរបស់រដ្ឋាភិបាល តំបន់បឹងទន្លេសាប និងទន្លេសាបគឺជាកន្លែងសំបូរត្រីបំផុតនៅកម្ពុជា ដោយផ្តល់ប្រហែល ៥០-៦០% នៃផលត្រីទឹកសាបជាលក្ខណៈពាណិជ្ជកម្មសរុប (NEDECO 1998, Ahmed *et al.* 1998) ។ ប៉ុន្តែដោយសារការក្រខ្សត់ទិន្នន័យពីផលនេសាទនៅកម្ពុជា តួលេខប៉ាន់ស្មានពីផលនេសាទដូចរៀបរាប់ខាងលើអាចចាត់ទុកបានជាការចង្អុលបង្ហាញខ្លះៗមិនសូវច្បាស់លាស់ល្អទេ ។

ការនេសាទខ្នាតធំ មធ្យម និងតូច គឺជាប្រភេទដែលកំណត់ដោយច្បាប់ និងត្រូវបានប្រើប្រាស់ដោយនាយកដ្ឋានជលផលក្នុងការគ្រប់គ្រងការនេសាទ ។ ការនេសាទខ្នាតធំ និងភាគច្រើននៃការនេសាទខ្នាតមធ្យម គឺសំរាប់គោលដៅខាងពាណិជ្ជកម្ម រីឯការនេសាទខ្នាតតូចគឺសំរាប់ការបរិភោគខ្លួនឯង ។ ប្រភេទនានានៃការនេសាទទាំងនេះ មានពិពណ៌នាលំអិតខាងក្រោម (សូមអាន "៣.៦. ការគ្រប់គ្រងជលផលបច្ចុប្បន្ន") ។ ប្រភេទនៃការនេសាទតាមវាលស្រែ គឺសំដៅទៅលើការប្រមូលផលត្រី និងធនធានវារីវប្បកម្មផ្សេងទៀត ដូចជា ក្តាម កំពិស និងកង្កែប ដែលស្ថិតនៅក្នុងវាលស្រែ ។ នៅក្នុងរដូវទឹកឡើង គេចាប់ត្រីនៅពេលវាចូលទៅក្នុងតំបន់លិចទឹកដែលមានទាំងវាលស្រែផង ។ នៅរដូវប្រាំងទឹកស្រក គេចាប់ត្រីនៅពេលវាចាកចេញពីវាលស្រែត្រឡប់ទៅរកទឹកជ្រៅវិញ (Gregory 1997) ។

**តារាង ៣.១. ផលចាប់ត្រីទឹកសាបក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៤ ដល់ ១៩៩៧**

| ប្រភេទនៃការនេសាទ | កំរិតនៃការចាប់ប្រចាំឆ្នាំ (គិតជាតោន) |
|---|---|
| ការនេសាទខ្នាតធំ | |
| ឡូតិ៍នេសាទ[១] | 25 000-75 000 |
| ដាយ (bagnets)[២] | 14 000-16 000 |
| ការនេសាទខ្នាតមធ្យម[៣] | 85 000-100 000 |
| ការនេសាទខ្នាតតូច (ជាលក្ខណៈគ្រួសារ)[៣] | 115 000-140 000 |
| ការនេសាទតាមវាលស្រែ[៤] | 50 000-100 000 |
| សរុប | 289 000-431 000 |

*១. កំរិតចន្លោះនេះ ឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់នៃកំរិតចាប់ប្រចាំឆ្នាំ ។*

*២. កំរិតចន្លោះនេះ បង្ហាញអំពីកំរិតអតិបរមា និងអប្បបរមា ក្នុងឆ្នាំ១៩៩៤-១៩៩៨ ។*

*៣. កំរិតប៉ាន់ស្មានអប្បបរមា គឺផ្អែកលើលទ្ធផលរកឃើញអំពី អ្នកនេសាទត្រីខ្នាតមធ្យម និងខ្នាតតូច ដែលតំណាងឱ្យប្រជាជន ២,៤លាននាក់ (Ahmed et al. 1998) ។ កំរិតប៉ាន់ស្មានអតិបរមា ឆ្លុះបញ្ចាំងនូវការគន់គូរសំរាប់ទូទាំងប្រទេស ។*

*៤. ប្រហែល ១,៨លានហិកតានៃដែននេសាទតាមវាលស្រែ ត្រូវបានគុណនឹងកំរិតទិន្នផល 25-62kg/ha ។ ការប៉ាន់ស្មាន 25kg/ha គឺផ្អែកលើតួលេខអប្បបរមាដែលត្រូវបានរាយការណ៍សំរាប់ភាគឦសាននៃប្រទេសថៃ ដោយ Fedoruk and Leelapatra (1992) ។ ការប៉ាន់ស្មាន 62kg/ha គឺផ្អែកលើតួលេខរកឃើញដោយ Gregory (1997) នៅក្នុងខេត្តស្វាយរៀង ។ Nesbitt (1997) បានប៉ាន់ស្មានថា វាលស្រែវស្សាលិចទឹករាក់ និង លិចទឹកជ្រៅ មានប្រហែល ១,៨លានហិកតា ក្នុងឆ្នាំ១៩៩៤-៩៥ ។*

*ប្រភព: Ahmed et al. 1998 និង Deap et al.1998 in Van Zalinge et al. 2000 ។*

ស្ថិតិនៃការនេសាទសមុទ្ររបស់នាយកដ្ឋានជលផលបង្ហាញថា ផលនេសាទក្នុងមួយឆ្នាំមានប្រហែល ៣០.០០០តោន ប៉ុន្តែ តួលេខនេះទំនងជាទាបជាងផលនេសាទជាក់ស្តែងប្រចាំឆ្នាំ ។ តួលេខផលនេសាទរបស់នាយកដ្ឋានជលផល គឺផ្អែកទៅលើផលនេសាទប៉ាន់ស្មានសំរាប់ឧបករណ៍នេសាទនានាដែលជាប់ពន្ធ ។ ដូច្នេះស្ថិតិរបស់នាយកដ្ឋានជលផល វាឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការប្រមូលពន្ធរបស់ស្ថាប័ននេះ ជាជាងនិន្នាការនៃការចាប់ត្រីសមុទ្រ ។ វិធីសាស្ត្រនៃការប៉ាន់ស្មានផលនេសាទសមុទ្របច្ចុប្បន្ននេះ មិនរាប់បញ្ចូលទូកបរទេសដែលយកផលនេសាទទៅលក់នៅក្រៅប្រទេសកម្ពុជាទេ ទូកនេសាទជំនួញខុសច្បាប់ និងអ្នកនេសាទតូចតាច (Smith 2001) ។

### *៣.២.១. និរន្តរភាពនៃផលនេសាទប្រចាំឆ្នាំ*

ដោយសារខ្វះស្ថិតិជលផលស្តីពីស្តុកត្រីក្នុងទឹក និងផលត្រីចាប់បានប្រចាំឆ្នាំ ក្នុងពេលបច្ចុប្បន្នគេមិនអាចប៉ាន់ស្មានពីបរិមាណផលត្រីដែលអាចចាប់ដោយមានចីរភាពសំរាប់ជលផលកម្ពុជាបានទេ ។ ទោះបីចំនួនប៉ាន់ស្មាននៃផលនេសាទទឹកសាបសរុបក្នុងពេលបច្ចុប្បន្ន វាមានកំរិតខ្ពស់ជាងពីអតីតកាលក៏ដោយ ក៏ចំនួននេះគឺជាលទ្ធផលនៃការប្រឹងប្រែងចាប់ត្រីច្រើនជាងមុន និងការប្រមូលទិន្នន័យបានល្អជាងមុន ហើយវាទំនងជាពុំមានចីរភាពឡើយ ។ ពតិមានតាមការសិក្សាតូចៗបង្ហាញថា ការចាប់ត្រីប្រភេទពូជធំៗ ដែលធ្វើបំលាស់ទីឆ្ងាយ ហើយបន្តពូជយឺតៗ បានធ្លាក់ចុះ រីឯការនេសាទត្រីតូចតាចដែលបន្តពូជលឿនហាក់ដូចជានៅខ្ពស់ដដែល (Van Zalinge *et al.* 2000) ។

ដោយសារនិន្នាការកើនឡើងនៃការបំផ្លាញសំបុកត្រី និងការនេសាទច្រើនជាងមុន អ្នកជំនាញជលផលបានព្រមានពីគ្រោះថ្នាក់ ក្នុងពេលអនាគតដូចនៅប្រទេសបង់ក្លាដេស ដែលជាការធ្លាក់ចុះនូវស្តុកត្រីក្នុងទឹក និងជីវចំរុះដល់កំរិតមួយដែលនៅសល់តែត្រីតូចៗមានតំលៃទាបមួយចំនួនប៉ុណ្ណោះ (Degen *et al.* 2000) ។ នៅក្នុងស៊ីណារីយ៉ូនេះ សមាមាត្រត្រីធំៗដែលមានតំលៃខ្ពស់ នឹងកាន់តែថយចុះ បើធៀបនឹងផលនេសាទទឹកសាបសរុប ។ នេះគឺមកពីពូជត្រីធំៗត្រូវការរយៈពេលលើសពីមួយឆ្នាំដើម្បីលូតលាស់ ជំនួសឱ្យត្រីធំជំនាន់មុន ដែលធ្វើឱ្យវាងាយរងគ្រោះដោយសារការនេសាទច្រើនពេក ។ ឯត្រីតូចៗមានតំលៃទាបដែលអាចធំធាត់ក្នុងរយៈពេលមួយឆ្នាំ វាអាចទប់ទល់នឹងសំពាធនៃការនេសាទច្រើនបានប្រសើរជាង ដូច្នេះសមាមាត្ររបស់វាក៏កើនឡើងនៅក្នុងផលនេសាទសរុប ។ ការប្រែប្រួលនៅក្នុងសមាមាត្រពូជត្រី បានកាត់បន្ថយតំលៃនៃផលនេសាទគិតក្នុងមួយឯកត្តានៃការងារប្រឹងប្រែងនេសាទ (Degen *et al.* 2000) ។

### *៣.២.២. តួនាទីនៃវារីវប្បកម្ម*

ភាគច្រើនបំផុតនៃផលនេសាទទឹកសាបនៅកម្ពុជា គឺបានមកពីការចាប់ត្រី (គឺការប្រមូលត្រីពីស្តុកធម្មជាតិ) ។ ក៏ប៉ុន្តែតួនាទីនៃវារីវប្បកម្មនៅក្នុងផលិតកម្មត្រីក៏ទំនងជាកើនឡើងដែរ ពិសេសនៅក្នុងតំបន់បឹងទន្លេសាប (Gum 2000) ។ វារីវប្បកម្មសំដៅដល់ការចិញ្ចឹមត្រី និងសត្វវារីសាស្ត្រផ្សេងៗ ។ ទិន្នន័យផ្លូវការផ្សេងទៀតអំពីវារីវប្បកម្មបង្ហាញថា ផលិតផលត្រីបានកើនឡើងប្រហែលពី ៩.៦០០តោននៅឆ្នាំ១៩៨៦ ដល់ ១៥.០០០តោននៅឆ្នាំ១៩៩៩ ចំណែកក្រពើបានកើនឡើងពី ៤.៣០០ក្បាលក្នុងឆ្នាំ១៩៨៦ ដល់ ២៥.៣៨០ក្បាលក្នុងឆ្នាំ១៩៩៩ (Noa and Ly 1997, NIS 2001) ។ ក្រពើភាគច្រើនគឺកូនក្រពើមានអាយុ ២-៣ខែប៉ុណ្ណោះ ដែលត្រូវបានគេយកទៅលក់នៅប្រទេសថៃ ។

យុទ្ធសាស្ត្រវារីវប្បកម្មទឹកសាបចំបងជាងគេបំផុតនៅក្នុងប្រទេសកម្ពុជារួមមានៈ ក. ការចិញ្ចឹមបំប៉នកូនត្រីសំរាប់លក់ ខ. ការស្តុកត្រីដែលលើសពីតំរូវការដើម្បីរង់ចាំឱ្យបានថ្លៃខ្ពស់ និង គ. ការចិញ្ចឹមត្រីខ្នាតតូចដែលប្រើប្រាស់ទុនតិច សំរាប់បំរើឱ្យសន្តិសុខស្បៀង ។ ដូច្នេះមានតែការចិញ្ចឹមត្រី និងការចិញ្ចឹមក្រពើទេដែលបង្ហាញថា មានកំរិតចំណេញអាចរស់រានបាននៅក្នុងប្រទេសកម្ពុជា ទោះបីសំរាប់រយៈពេលវែងវានៅមិនទាន់ច្បាស់លាស់ក៏ដោយ (Gum 1998) ។ គេឃើញមានការចាប់អារម្មណ៍ខ្លាំងនៅក្នុងការចិញ្ចឹមវារីសត្វផ្សេងទៀត ដូចជា អន្ទង់ កង្កែប បង្គា និងពស់ ប៉ុន្តែការប្រឹងប្រែងធ្វើវារីវប្បកម្មទាំងនេះមិនទាន់បានជោគជ័យគួរឱ្យកត់សំគាល់នៅឡើយ និងបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន (Noa and Ly 1997, Gum 1998) ។

នៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ការចិញ្ចឹមបង្គាបានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍១៩៩០ តាមរយៈការវិនិយោគរបស់អ្នកជំនួញមកពីថៃ ។ មកដល់ឆ្នាំ១៩៩៥ ស្ថិតិរបស់នាយកដ្ឋានជលផលបង្ហាញថា មានកសិដ្ឋានចិញ្ចឹមបង្គាដែលមានអាជ្ញាប័ណ្ណចំនួន ១១៧ ត្រូវបានបង្កើតឡើងនៅក្នុងខេត្តកោះកុង និងកំពត ដោយគ្របដណ្តប់លើផ្ទៃដី ១.២៧២ហិកតាដែលកាលពីមុនជាដីព្រៃកោងកាង (Bann 1997) ។ មួយឆ្នាំក្រោយមក ប្រហែល ៧០% នៃកសិដ្ឋានចិញ្ចឹមបង្គា ត្រូវបានបោះបង់ចោលទៅវិញដោយសារមិនបានចំនេញ ហើយនិន្នាការនេះបានបន្តរហូតដល់ការដួលរលំមុខរបរនេះក្នុងឆ្នាំ១៩៩៩ ទាំងស្រុង ។

កត្តាមួយចំនួនដែលធ្វើឱ្យការចិញ្ចឹមបង្គាបរាជ័យគឺ គុណភាពដីអន់ ជំងឺ បញ្ហាកិរិតជាតិអំបិល ការប្រើជីបានលទ្ធផលអន់ខ្សោយ ការគ្រប់គ្រងស្រះបង្គាអន់ និងការធ្លាក់ចុះថ្លៃបង្គាអន្តរជាតិ (Mastaller 1999) ។

ការធ្វើស្រែអំបិល គឺជាសកម្មភាពមួយទៀតនៅតំបន់ឆ្នេរសមុទ្រ ដែលបានប៉ះពាល់ដល់ជលផលសមុទ្រ ។ ការបង្កើតស្រែអំបិល តំរូវឱ្យមានការកាប់ព្រៃកោងកាងមួយចំនួន ។ Mastaller (1999) បានប៉ាន់ស្មានថា មានព្រៃកោងកាង ៣.០០០-៤.០០០ហិកតា ត្រូវបានកាប់រានដើម្បីធ្វើស្រែអំបិលនៅខេត្តកំពត និងក្រុងកែប ។ ដោយសារព្រៃកោងកាងផ្តល់ជំរកដ៏សំខាន់សំរាប់ការបន្តពូជត្រី និងការចិញ្ចឹមកូនត្រី ការបាត់បង់ឬការរិចរឹលរបស់វា នឹងធ្វើឱ្យផលិតភាពនេសាទធ្លាក់ចុះ ។

## ៣.៣. សារៈសំខាន់នៃការនេសាទចំពោះជីវិតជនបទ

ការនេសាទនៅក្នុងប្រទេសកម្ពុជា គឺជាប្រភពធនធានរួមដ៏សំបូរបែបមួយ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅតាមជនបទក្នុងការៈ

- ធ្វើចំរុះកម្មសកម្មភាពជីវភាពរបស់ពួកគេ ដើម្បី "ធានា" ទប់ទល់នឹងហានិភ័យនៃការខូចខាតផ្នែកកសិកម្ម ។
- ប្រើប្រាស់ធនធានពលកម្មរបស់គ្រួសារឱ្យបានចំណេញខ្ពស់ក្នុងចំនោមសកម្មភាពជីវភាពផ្សេងៗនៅតាមរដូវនានា ។
- ផ្តល់នូវលទ្ធភាពធ្វើសកម្មភាពបង្កើតចំណូល ដោយចំណាយទុនវិនិយោគតិចតួច និងមិនចាំបាច់មានដីធ្លី ។
- រក្សា/លើកកំពស់ កិរិតអាហារូបត្ថម្ភ ពីព្រោះត្រីស្រស់ និងត្រីកែច្នៃគឺជាប្រភពប្រូតេអ៊ីនមួយ ដ៏សំខាន់ ។

ជលផលផ្តល់នូវសន្តិសុខស្បៀង ប្រាក់ចំណូល និងការងារសំរាប់ប្រជាជនជនបទមួយភាគធំ ។ អង្កេតរបស់ Ahmed *et al.* 1998 បានបង្ហាញអំពីសារៈសំខាន់នៃការនេសាទចំពោះគ្រួសារដែលតាំងទីលំនៅជិតទន្លេបឹងបួរ និងនៅតាមតំបន់នានាដែលមានទឹកលិចនៅរដូវវស្សា ។ របកគំហើញនៅក្នុងការសិក្សានេះ អាចតំណាងឱ្យមនុស្សប្រហែល ២,៤លាននាក់ នៅក្នុង ៣២៨ឃុំ កាលពីឆ្នាំ១៩៩៥-៩៦ ក្នុងនេះមានប្រហែលជា ៤០% ឬ ៩០០.០០០នាក់ ដែលមានការពឹងពាក់គួរឱ្យកត់សំគាល់ទៅលើតែការនេសាទ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដូចជាការកែច្នៃ ការលក់ ការចិញ្ចឹមត្រី ឬការផលិតឧបករណ៍នេសាទ[២១] ។ របកគំហើញបានបង្ហាញផងដែរថា អង្កេតថ្នាក់ជាតិដែលគ្របដណ្តប់លើតំបន់នេសាទទឹកសាបមានទិន្នផលខ្ពស់ផ្សេងទៀត និងការនេសាទនៅតាមវាលស្រែ ប្រហែលរកឃើញថាមានប្រជាជនដល់ជាងមួយលាននាក់ដែលពឹងពាក់លើការនេសាទទឹកសាប ដើម្បីដោះស្រាយជីវភាព[២២] ។

### ៣.៣.១. ការបរិភោគត្រី និងសន្តិសុខស្បៀង

បាយ និងត្រី គឺជាអាហារមូលដ្ឋានជាប្រពៃណីរបស់ប្រជាជនកម្ពុជា ។ មានការបរិភោគត្រីស្រស់ និងត្រីកែច្នៃនៅទូទាំងប្រទេស ហើយគេប៉ាន់ស្មានថា បរិមាណត្រីបរិភោគជាមធ្យមក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ ប្រែប្រួលយ៉ាងខ្លាំងពី ១៣,៣គ.ក រហូតដល់ ៧០គ.កនៅតាមតំបន់ខ្លះៗ (តារាង៣.២) ។ ត្រីស្រស់ និងត្រីកែច្នៃ តំណាងឱ្យមួយភាគធំនៃប្រូតេអ៊ីនសរុបបានមកពីសត្វ ដោយមានតួលេខប៉ាន់ស្មានពី ៤០-៦០% (Csavas 1994) ឬច្រើនដល់ ៧៥% (ដូចជាឯកសាររបស់ Nao and Ly 1997;

[២១] ការសិក្សានេះកំណត់ថា គ្រួសារពឹងលើការនេសាទ គឺជាគ្រួសារដែលមានអ្នកដឹកនាំ ឬសមាជិកណាម្នាក់ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនេសាទ (ដូចរៀបរាប់ខាងលើ) មួយយ៉ាងតិចនៅក្នុងមួយភាគធំនៃឆ្នាំនិមួយៗ ។

[២២] គ្មានការប៉ាន់ស្មានច្បាស់លាស់ទេ អំពីចំនួនប្រជាជនរស់នៅតាមឆ្នេរសមុទ្រដែលពឹងពាក់លើការនេសាទសមុទ្រ ។ ប៉ុន្តែ ដោយសារឆ្នេរសមុទ្រកម្ពុជាមានប្រវែងខ្លី និងដង់ស៊ីតេប្រជាជនរស់នៅតាមតំបន់ឆ្នេរសមុទ្រមានកិរិតទាប ( ២ ឬ ៣ដង ទាបជាងដង់ស៊ីតេមធ្យមថ្នាក់ជាតិ) ដូច្នេះប្រជាជនដែលពឹងផ្អែកលើការនេសាទសមុទ្រមានចំនួនតិច ហើយប្រាកដជាតិចខ្លាំងណាស់បើធៀបនឹងប្រជាជនដែលពឹងផ្អែកលើការនេសាទទឹកសាបដែលមានផ្ទៃទឹកធំទូលាយ (Smith 2001) ។

Degen *et al.* 2000) ឬរហូតដល់ ៩០% នៅក្នុងឃុំដែលពឹងពាក់លើការនេសាទ (Ahmed *et al.* 1998)[២៣] ។ ដោយសារត្រីមានសារៈសំខាន់ខ្លាំងនៅក្នុងរបបអាហាររបស់ជនកម្ពុជា ដូច្នេះគេបានលើកឡើងថា ជលផលទឹកសាបនៅកម្ពុជាបានរួមចំណែកដល់សន្តិសុខស្បៀងថ្នាក់ជាតិ ក្នុងកំរិតខ្ពស់ជាងជលផលទឹកសាបនៅឯប្រទេសផ្សេងទៀតក្នុងទូទាំងពិភពលោក (Van Zalinge *et al.* 2000) ។ ពត៌មានស្តីពីការបរិភោគត្រីសមុទ្រមានតិចតួចខ្លាំងណាស់ ។ របាយការណ៍ខ្លះបានលើកថា មានមិនដល់ ២០% នៃផលនេសាទសមុទ្រសរុបទេដែលត្រូវបានបរិភោគនៅក្នុងស្រុក (Azimi *et al.* 2001) ។

## *៣.៣.២. ការបង្កើតចំណូល និងការងារ*

Van Zalinge *et al.* (2000) ធ្វើការប៉ាន់ស្មានថា តំលៃជារូបិយវត្ថុនៃផលនេសាទទឹកសាបសរុបនៅកម្ពុជា គឺ ១០០-២០០លានដុល្លារ ដោយមិនរាប់ចូលនូវផលនេសាទជីវព្រឹត្តិ (សំរាប់បរិភោគខ្លួនឯង) ទេ ។ ការប៉ាន់ស្មានមួយក្នុងពេលថ្មីៗអំពីផលត្រីទឹកសាបទាំងអស់ បូកទាំងការនេសាទសំរាប់បរិភោគខ្លួនឯងផង បង្ហាញនូវតួលេខប្រហែល ៣០០លានដុល្លារ (Gensen 2000 in Degen *et al.* 2000) ។ ដោយឡែក តំលៃជារូបិយវត្ថុនៃផលិតផលស្រូវសរុបនៅក្នុងប្រទេសកម្ពុជា គឺមានប្រហែល ៣៥០-៤០០លានដុល្លារ[២៤] ។

គ្រួសារនៅតាមជនបទជាច្រើនចិញ្ចឹមជីវិតដោយការប្រកបរបរកសិកម្មផង និងនេសាទផង ហើយមួយភាគធំយល់ថា កសិកម្ម គឺជាការងារចំបងរបស់ខ្លួន ឯការនេសាទគឺជាការងារសំខាន់ទីពីរ ឬទីបី ។ ជាលទ្ធផល ស្ថិតិជាតិដែលផ្តោតលើការងារក្នុងវិស័យបឋម អាចនៅខ្វះចន្លោះក្នុងការក្តោបយកសារៈសំខាន់នៃកសិកម្មជីវព្រឹត្តិ (សំរាប់គ្រប់ហូប) និងផលិតកម្មនេសាទសំរាប់ការបង្កើតការងារ និងប្រាក់ចំណូល ។ ឧទាហរណ៍ ជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ១៩៩៨ បានប៉ាន់ស្មានថា ១/៥ នៃកំលាំងពលកម្មកម្ពុជាបំរើការនៅក្នុងការនេសាទ រីឯ ៧៥,៧% នៅក្នុង "កសិកម្ម ប្រមាញ់ និងព្រៃឈើ"[២៥] ។ ដូចគ្នាដែរ អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជាឆ្នាំ១៩៩៩ បានប៉ាន់ស្មានថា មានកំលាំងពលកម្មប្រហែលតែ ២% ប៉ុណ្ណោះដែលបំរើការនៅក្នុង "វិស័យជលផល" រីឯ ៧៥% បំរើការនៅក្នុងវិស័យ "កសិកម្ម ប្រមាញ់ និងព្រៃឈើ" (NIS 2000) ។

ផ្ទុយមកវិញ អង្កេតគ្រួសារធ្វើឡើងដោយ Ahmed *et al.* (1998) ដូចបានពិភាក្សាខាងលើ បានប្រមូលពត៌មានអំពីការងារក្នុងវិស័យបឋម វិស័យទី២ និងវិស័យទី៣ ដែលតំណាងឱ្យប្រជាជន ២,៤លាននាក់ដែលរស់នៅក្នុងតំបន់តាមដងទន្លេបឹងបួរ និងតំបន់លិច ទឹក ។ អង្កេតនេះបានរកឃើញថា មេគ្រួសារចំនួន ៣៦% បានចូលរួមយ៉ាងសកម្មក្នុងការនេសាទ ក្នុងនេះមាន ៩,៣% បញ្ជាក់ថា ការនេសាទជាការងារចំបងរបស់ខ្លួន, ២០,៣% ថាជាការងារទី២ និង ៦,៣% ថាជាការងារទី៣ ។ ទោះបីជារបកគំហើញទាំងនេះមិនអាចយកមកអះអាងសំរាប់ប្រទេសកម្ពុជាទាំងមូលក៏ដោយ ក៏វាចង្អុលឱ្យឃើញនូវសារៈសំខាន់នៃការ

[២៣] ជាការច្បាស់លាស់ហើយដែលការបរិភោគត្រី គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់សំរាប់ជនកម្ពុជា ប៉ុន្តែគេហាក់ដូចជារកមិនឃើញប្រភពដើមថាមានអង្កេតណាមួយដែលបញ្ជាក់បង្ហាញនូវកំរិត ៤០-៦០% ឬ ៧៥% ដែលតែងត្រូវបានយកមកប្រើជាញឹកញាប់នេះទេ ។ មានការស្រាវជ្រាវថយក្រោយរហូតដល់ឆ្នាំ១៩៩២ ដើម្បីរកប្រភពតួលេខប៉ាន់ស្មាន ៧៥% ប៉ុន្តែគ្មានរកឃើញនូវអង្កេតថ្នាក់ជាតិណាមួយដែលគេបានធ្វើឡើងឡើយ ។ តួលេខប៉ាន់ស្មានទាំងនេះ ទំនងជាបានមកពីឧទាហរណ៍ជាសម្មតិកម្មមួយរបស់ MRC Secretariat (1992) ។ Gum (2000) ក៏បានប្រឹងប្រែងរកប្រភពដើមនៃតួលេខ ៧៥% នេះដែរ ហើយបានរកឃើញអង្កេតមូលដ្ឋានមួយអំពីភាពក្រីក្រ និងអាហារូបត្ថម្ភសំរាប់ UNICEF និង WFP ដែលត្រូវបានធ្វើឡើងដោយ Kenefick (1999) ។ ប៉ុន្តែក្រោយពីបានពិនិត្យល្អិតល្អន់ ការសិក្សានេះក៏មិនបានផ្តល់នូវមូលដ្ឋានជាក់ស្តែងសំរាប់តួលេខ ៧៥% នេះដែរ ។ Kenefick (1999) បានស្វែងរកពត៌មានអំពីការបរិភោគអាហាររបស់កុមារនៅក្នុងគ្រួសារមួយចំនួនដែលគេបានជ្រើសរើសដោយមិនប្រើវិធីចៃដន្យនៅក្នុង ៨ខេត្ត ហើយវាក៏មិនមែនជាការសិក្សាតំណាងឱ្យថ្នាក់ជាតិស្តីពីការបរិភោគប្រូតេអ៊ីនសត្វឡើយ ។ ម្យ៉ាងវិញទៀត អង្កេតនេះបានស្រង់ពត៌មានអំពីប្រភេទចំណីអាហារដែលកុមារបានបរិភោគក្នុងមួយថ្ងៃដែលទើបកន្លងទៅ មិនបានសួរពីបរិមាណនៃប្រភេទអាហារនីមួយៗដែលកុមារបានបរិភោគនោះទេ ។

[២៤] ការប៉ាន់ស្មាននេះបានពីការយកផលស្រូវសរុបប្រហែល ៤លានតោន គុណនឹងថ្លៃស្រូវជាមធ្យមនៅកសិដ្ឋានគឺ ៣៥០-៤០០រៀល/គ.ក ។

[២៥] ការងារនេសាទសំដៅដល់ "ការនេសាទ ប្រតិបត្តិការភ្ញាស់ត្រី ការចិញ្ចឹមត្រី និងបណ្តាសកម្មភាពសេវាបន្ទាប់បន្សំនឹងការនេសាទ" ។

ប្រមូលពតិមានឱ្យបានលើសពីការងារចំបង ដើម្បីរាយការណ៍ឱ្យបានកាន់តែពេលលេញថែមទៀតពីប្រភេទផ្សេងៗនៃសកម្មភាពការងារសំរាប់ទ្រទ្រង់ជីវភាពជនបទ ។

**តារាង៣.២ ការប៉ាន់ស្មានការបរិភោគត្រីក្នុងមនុស្សម្នាក់នៅកម្ពុជា**

| ការបរិភោគត្រីជាមធ្យម ក្នុងមនុស្សម្នាក់ (គ.ក/ឆ្នាំ) | កំលុងពេលសិក្សា | ប្រជាជន ឬតំបន់ដែលបានធ្វើការសិក្សា | ប្រភពពតិមាន |
|---|---|---|---|
| 21.6 | 1957 | កម្ពុជា | Bardach 1959 |
| 20-25 | 1970 | កម្ពុជា | Lagler 1976 in Csavas 1994 |
| 13.3 | 1991 | កម្ពុជា | Mekong River Commission Secretariat 1992 in Csavas 1994 |
| 16.0 | 1991 | កម្ពុជា | Department of Fisheries 1992 in Csavas 1994 |
| 25 | 1993 | ខេត្តស្វាយរៀង | Touch 1993 in Nao and Ly 1997 |
| 27-38 | 1994-97 | កម្ពុជា - ផ្អែកលើចំនួនត្រីចាប់បានសរុបប្រហែល ២៩០- ៤៣០ ពាន់តោន/ឆ្នាំ | Van Zalinge *et al.* 2000 |
| 32 | 1995 | តំបន់ខ្ពង់រាបក្នុងខេត្តសៀមរាប | Hy 1995 in Nao and Ly 1997 |
| 71 | 1995 | ភូមិបណ្តែតទឹកក្នុងខេត្តសៀមរាប | |
| 75.6* | 1995-96 | ប្រជាជន ២,៤លាននាក់ក្នុង "ឃុំពឹងពាក់លើការនេសាទ" ក្នុងខេត្តចំនួន ៨ | Ahmed *et al.* 1998 |
| 31/6 (ក្នុងរយៈប្រហែល៧ខែ) | សីហា 1995- កុម្ភៈ 1996 | ខេត្តស្វាយរៀង - ១៥គ្រួសារក្នុងភូមិ៣ខុសគ្នា | Gregory 1997 |

* *តួលេខសរុបនេះតំណាងឱ្យការបរិភោគត្រីស្រស់ពិត ៤៣,៥គ.ក. ត្រីកែច្នៃ១៤គ.ក ដែលស្មើនឹងត្រីស្រស់២៧,៥គ.ក. និងទឹកត្រី៥.៦លីត្រ ដែលស្មើនឹងត្រីស្រស់ ៤.៥គ.ក ។*

## ៣.៤. បញ្ហាជនជាតិ និងយេនឌ័រ

បញ្ហាជនជាតិដើរតួនាទីសំខាន់ ជួនកាលគឺជាចំណុចរសើបនៅក្នុងវិស័យជលផលនៅកម្ពុជា ។ សកម្មភាពនេសាទខ្នាតតូច និងមធ្យម ច្រើនតែធ្វើឡើងដោយផ្អែកលើបណ្តាញសាច់ញាតិជាជាងសមាគមនេសាទ ឬសហគមន៍នេសាទ ។ ជាទូទៅជនជាតិវៀតណាម និងចាម ច្រើនតែពឹងផ្អែកខ្លាំងលើធនធាននេសាទសំរាប់ជីវភាពពួកគេ រីឯជនជាតិខ្មែរច្រើនតែផ្អែកលើកសិកម្ម ។ មានជនជាតិវៀតណាម និងជនជាតិចាមតិចនាក់ទេដែលកាន់កាប់ដីកសិកម្ម (Swiff 1997, Degen and Nao 2000, Gum 2000) ។ ឧទាហរណ៍ ភាគច្រើននៃប្រជាជន ៨៣.000នាក់ដែលរស់នៅក្នុងភូមិនេសាទបណ្តែតទឹកនៅក្នុងបឹងទន្លេសាប គឺជាជនជាតិវៀតណាម (Nedeco 1998) ។

ម្ចាស់ឡូត៍នេសាទច្រើនតែជាខ្មែរ ឬខ្មែរកាត់ចិន ប៉ុន្តែពួកគេច្រើនជួលមេការជនជាតិវៀតណាម មកធ្វើប្រតិបត្តិការនេសាទនៅក្នុងឡូត៍របស់ពួកគេ (Degen and Nao 2000) ។ ម្ចាស់ឡូត៍នេសាទរាយការណ៍ថា ក្រៅពីជាអ្នកនេសាទជនជាតិវៀតណាម និងចាមដ៏ជំនាញ ក៏រមានទំនាស់ជាមួយម្ចាស់ឡូត៍ណាស់ ហើយច្រើនអនុវត្តទិញអាជ្ញាប័ណ្ណនេសាទបានទៀងទាត់ជាងជនជាតិខ្មែរផង ។ ប៉ុន្តែក៏រិតទិញអាជ្ញាប័ណ្ណក៏អាចឆ្លុះបញ្ចាំងពីការអនុវត្តន៏ច្បាប់ដោយមានការបែងចែក និងមិនសព្វជ្រុងជ្រោយពីសំណាក់អាជ្ញាធរខ្មែរនៅមូលដ្ឋានផងដែរ (Gum 2000) ។ បុរេវិនិច្ឆ័យមិនល្អជាទូទៅចំពោះជនជាតិវៀតណាម ក៏អាចមានឥទ្ធិពលមួយចំណែកដែរចំពោះកន្លែងដែលពួកគេរស់នៅ និងនេសាទ ។ Degen and Nao (2000) បានកត់សំគាល់ថា ជនជាតិវៀតណាមច្រើនតែតាំងលំនៅក្បែរប៉ុស្តិ៍ប៉ូលីស និងយោធា ហើយពួកគេកំរធ្វើដំណើរទៅនេសាទឆ្ងាយពីផ្ទះណាស់ ។ ផ្ទុយទៅវិញ ជនជាតិចាមច្រើនធ្វើដំណើរទៅនេសាទឆ្ងាយៗ ជួនកាលចេញពីផ្ទះរហូតពេញមួយរដូវនេសាទតែម្តង ។

បញ្ហាជែនឌ័រនៅក្នុងការនេសាទ ពុំមានឯកសារបញ្ជាក់បានច្បាស់លាស់ល្អទេ ។ ជាទូទៅគេយល់ថា ស្ត្រីមិនចូលរួមនៅក្នុងវិស័យជលផលទេ ពីព្រោះពួកគេច្រើនតែមិនធ្វើនេសាទ លើកលែងតែការនេសាទបន្តិចបន្តួចក្នុងពេលថ្ងៃប៉ុណ្ណោះ ។ ប៉ុន្តែស្ត្រីមានសកម្មភាពច្រើននៅលើដីគោក ដូចជា ការកែច្នៃ ការរកទីផ្សារ ការលក់ ការមើលថែទាំស្រះចិញ្ចឹមត្រី និងបៃត្រី និងការថែទាំឧបករណ៍នេសាទ ។ បុរសច្រើនបំពេញសកម្មភាពដែលត្រូវការកំលាំងកាយច្រើន ដូចជា ការប្រើប្រាស់ឧបករណ៍នេសាទខ្នាតមធ្យម ឬធ្វើដំណើរទៅកន្លែងឆ្ងាយៗដើម្បីនេសាទ ឬកាប់អុស (Ahmed *et al.* 1998, Gum 1998) ។

## ៣.៥. ប្រវត្តិនៃការគ្រប់គ្រងវិស័យជលផល

ការគ្រប់គ្រងនេសាទនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន រួមមាន របៀបរបបជាផ្លូវការ និងក្រៅផ្លូវការច្រើនបែបយ៉ាង ហើយស្មុគស្មាញក្នុងការគ្រប់គ្រងលើលទ្ធភាព សិទ្ធិ និងការនេសាទរបស់ប្រជាជន ។ ប្រព័ន្ធគ្រប់គ្រងនេះមានឫសគល់តាំងពីជំនាន់ស្តេចនរោត្តម (១៨៥៩-១៨៩៧) និងស្តេចពីមុនៗនោះទៀត ។ ក្នុងរាជស្តេចទាំងនោះ ចំណូលពីវិស័យជលផលត្រូវបានប្រមូលពីការលក់សិទ្ធិប្រើប្រាស់តំបន់នេសាទ ។ អ្នកវិនិយោគ និងអ្នកជំនួញជនជាតិចិន បានទិញសម្បទាននេសាទពីស្តេច ហើយជួលបន្តទៅឱ្យ អ្នកនេសាទនានា ដោយភាគច្រើនអាចបានចំណេញរហូតដល់ពីរដងលើសពីចំនួនត្រូវបង់ឱ្យរាជរតនាគារ ។ សម្បទាននេសាទនៅ ពេលនោះត្រូវបានជួលបន្តជាច្រើនដំណាក់ ដែលធ្វើឱ្យឈ្មួញកណ្តាលមួយចំនួនទទួលបានចំណេញខ្ពស់គួរសមសំរាប់ការប្រឹងប្រែង និងហានិភ័យតែបន្តិចបន្តួចរបស់ខ្លួន (Darboux *et al.*1906 and Pétillot 1911 in Degen and Nao 2000) ។

ការបង្កើតឡើងនូវអាណាព្យាបាលបារាំងនៅកម្ពុជា មិនបានកែប្រែអ្វីច្រើនទេចំពោះវិធីអនុវត្តដែលមានពីមុនស្រាប់នៅក្នុងការធ្វើអាជីវកម្មនេសាទ ។ ច្បាប់ និងបទប្បញ្ញត្តិជលផល ត្រូវបានអនុម័តជាផ្លូវការ និងបានចេញផ្សាយដោយរដ្ឋបាលអាណានិគមនៅឆ្នាំ១៩០៨ ប៉ុន្តែគោលដៅនៃរាជបង្គាប់ទាំងនេះ គឺដើម្បីបង្កើតចំណូលសំរាប់រដ្ឋបាលអាណានិគម មិនមែនដើម្បីកែប្រែបែបផែនអាជីវកម្មជលផលដែលមានស្រាប់នោះទេ (Degen and Nao 2000) ។

នៅក្នុងទសវត្សរ៍នានាជាបន្តមកទៀត គ្មានការប្រែប្រួលអ្វីធំដុំនៅក្នុងប្រព័ន្ធសម្បទាន និងជួលបន្តការគ្រប់គ្រងជលផលទេ គឺរហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយប៉ុលពត ដែលក្នុងកំលុងពេលនោះ សកម្មភាពនេសាទមានកំរិតតិចតួច និងមានអង្គភាពនេសាទតែមួយចំនួនតូចដែលធ្វើការប្រមូលផល និងកែច្នៃត្រី ។ ក្នុងករណីភាគច្រើន ធនធានជលផលត្រូវបានបំភ្លេចចោល ហើយគេយកចិត្តទុកដាក់តែទៅលើការអភិវឌ្ឍន៍កសិកម្ម ដោយរួមទាំងការរុនរានព្រៃលិចទឹក និងដីសើម (Degen *et al.* 2000) ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ របបនេសាទជាសមូហភាពត្រូវបានលើកទឹកចិត្តរហូតដល់ចុងទសវត្សរ៍១៩៩០ ។ ក្នុងកំលុងពេលនោះ ជលផលនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយប្រព័ន្ធក្រុមសាមគ្គី ។ ក្នុងការអនុវត្តន៍ជាក់ស្តែង លទ្ធភាពនេសាទនៅតាមកន្លែងជាច្រើន ត្រូវបានបើកចំហសំរាប់ប្រជាជនទាំងអស់ ហើយការអនុវត្តន៍ប្រព័ន្ធសមូហភាពត្រូវបានគេបំភ្លេចចោល លើកលែងតែការប្រគល់ផលិតផលត្រីមួយចំនួនដែលគេបានកំណត់ជាកូតា ទៅឱ្យមន្ត្រីស៊ីវិល និងយោធា (Chheng 2000, Degen *et al.* 2000) ។

ប្រព័ន្ធសម្បទាននេសាទត្រូវបានបង្កើតឡើងជាថ្មីនៅចុងទសវត្សរ៍១៩៨០ និងមានលក្ខណៈស្រដៀងគ្នាទៅនឹងរបៀបរបបដែលធ្លាប់បានអនុវត្តជាងមួយសតវត្សរ៍មកហើយ កាលពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រព័ន្ធនេះនៅតែជាវិធីចំបងក្នុងការគ្រប់គ្រងជលផលរហូតមកដល់បច្ចុប្បន្ន ។ ហេតុផលចំបងបំផុតរបស់រដ្ឋាភិបាលក្នុងការដាក់អនុវត្តន៍ប្រព័ន្ធសម្បទានជាថ្មីនៅចុងទសវត្សរ៍១៩៨០ គឺប្រហែលជាតំរូវការបង្កើនចំណូលរដ្ឋ (Degen *et al.* 2000) ។

## ៣.៦. ការគ្រប់គ្រងវិស័យជលផលក្នុងពេលបច្ចុប្បន្ន

នាយកដ្ឋានជលផលដែលនៅក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានសមត្ថកិច្ចគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលកម្ពុជា ។ ដោយមានបុគ្គលិកជាង ១.៥០០នាក់ និងមានទីតាំងសាខានៅតាមខេត្តនិមួយៗ នាយដ្ឋានជលផលទទួលខុសត្រូវក្នុងការដាក់អនុវត្តន៍បទប្បញ្ញតិ ការផ្តល់សម្បទាន និងការចេញអាជ្ញាប័ណ្ណ (រួមទាំងការចេញអាជ្ញាប័ណ្ណឱ្យទូកបរទេសដែលធ្វើប្រតិបត្តិការនៅក្នុងដែនសមុទ្រកម្ពុជាផងដែរ) ការប្រមូលកំរៃ និងការត្រួតពិនិត្យសកម្មភាពកែច្នៃពាណិជ្ជកម្ម និងការនាំចេញ ។

នាយកដ្ឋានជលផលទទួលបានចំណូលភាគច្រើនមកពីការបង់ថ្លៃសំរាប់សម្បទានឡូត៍នេសាទ ។ ចំណូលផ្សេងទៀតបានមកពីការចេញអាជ្ញាប័ណ្ណ ការផាកពិន័យ និងការអនុវត្តន៍គំរោងនានាដែលទទួលមូលនិធិពីអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល ។

ក្នុងកំលុងពេលមួយទសវត្សរ៍កន្លងមកនេះ នាយកដ្ឋានជលផលប្រមូលថវិកាជាផ្លូវការបានពី ១លានដល់ ៤លានដុល្លារក្នុងមួយឆ្នាំៗ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០០២) ។ ឯអាជ្ញាធរមូលដ្ឋានប្រហែលប្រមូលចំណូលក្រៅផ្លូវការពីដែននេសាទបានលើសនេះច្រើនណាស់ (Swift 1997, Gum 1998) ។

ប្រព័ន្ធសម្បទានឡូត៍នេសាទ នៅតែជាមធ្យោបាយចំបងសំរាប់ឱ្យនាយកដ្ឋានជលផលធ្វើការគ្រប់គ្រងលើជលផលនៅកម្ពុជា ប៉ុន្តែកំណែទំរង់ដែលបានចាប់ធ្វើនៅចុងឆ្នាំ២០០០ កំពុងតែផ្តើមពិនិត្យមើល និងកែប្រែវិធីសាស្ត្រគ្រប់គ្រងបែបនេះ ។ ចំណុចគន្លឹះនៃកំណែទំរង់រួមមាន ការកាត់បន្ថយផ្ទៃឡូត៍នេសាទ និងការលើកកំពស់ការគ្រប់គ្រងឡូត៍នេសាទដោយសហគមន៍តាមរយៈការបង្កើតនូវអនុក្រឹត្យស្តីពីសហគមន៍នេសាទ និងការបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៅក្នុងនាយកដ្ឋានជលផល ។ កំណែទំរង់បែបនេះបានចាប់ផ្តើមបន្ទាប់ពីសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០០ នៅខណៈដែលសម្តេចបានកត់សំគាល់ពីជម្លោះធ្ងន់ធ្ងររវាងម្ចាស់ឡូត៍ និងប្រជាជនអ្នកនេសាទ និងពីតំរូវការកែលំអការគ្រប់គ្រងជលផល (គណបក្សប្រជាជនកម្ពុជា ២០០១) ។

ឥឡូវនេះ កំណែទំរង់ជលផល ត្រូវពិនិត្យមើលក្នុងបរិបទច្បាប់កម្ពុជាបច្ចុប្បន្ន និងរបៀបរបបគ្រប់គ្រងជលផលជាប្រពៃណី ។ ផ្នែកនេះពិនិត្យមើលទិដ្ឋភាពនៃច្បាប់សំរាប់ការនេសាទ ការចាត់ចែងក្នុងបញ្ហាកម្មសិទ្ធិនិងប្រតិបត្តិការឡូត៍នេសាទ ស្ថានភាពឡូត៍នេសាទនៅមុន និងក្រោយពេលអនុវត្តន៍កំណែទំរង់ថ្មីៗនេះ និងការកកើតឡើងនូវសហគមន៍នេសាទ ។

### *៣.៦.១. ទិដ្ឋភាពច្បាប់នៃការនេសាទ*

ការគ្រប់គ្រងជលផលនៅកម្ពុជា អាស្រ័យលើប្រព័ន្ធបទប្បញ្ញត្តិដែលកំណត់ពីលទ្ធភាព សិទ្ធិអ្នកនេសាទ ព្រំប្រទល់ឡូត៍ រដ្ឋអំណាច និងលក្ខខណ្ឌនៃការអនុវត្តន៍ច្បាប់ ។ បទប្បញ្ញត្តិទាំងនេះត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រង និងរដ្ឋបាលជលផលឆ្នាំ១៩៨៧, ព្រមទាំងអនុក្រឹត្យ និងសេចក្តីប្រកាសមួយចំនួនតាមក្រោយមកទៀត (Touch Seang 1990) ។ បច្ចុប្បន្ននេះគេកំពុងតាក់តែងច្បាប់ជលផលថ្មី ដែលទំនងជាមានរក្សាទុកនូវបញ្ញតិ និងរចនាសម្ព័ន្ធជាច្រើននៃច្បាប់ជលផលឆ្នាំ១៩៨៧ (DoF 2001a) ។

មូលដ្ឋាននៃការគ្រប់គ្រងជលផល គឺការបែងចែករវាងការនេសាទជាលក្ខណៈជំនួញ និងការនេសាទជីវព្រឹត្តិ (សំរាប់បរិភោគ) ។ នៅក្នុងច្បាប់នៃការគ្រប់គ្រង និងរដ្ឋបាលជលផលឆ្នាំ១៩៨៧ នេសាទទឹកសាប ត្រូវបានបែងចែកជាការនេសាទខ្នាតធំ និងខ្នាតមធ្យមសំរាប់គោលដៅពាណិជ្ជកម្ម និងការនេសាទខ្នាតតូចសំរាប់បរិភោគខ្លួនឯង (State of Cambodia 1987) ដូចមានពិពណ៌នាលំអិតនៅខាងក្រោម រីឯបទប្បញ្ញតិស្តីពីលទ្ធភាពធ្វើនេសាទ ព្រំប្រទល់ និងរដូវនេសាទ មានចុះសង្ខេបនៅក្នុង

តារាង៣.៣ ។

- **ការនេសាទខ្នាតធំ** រួមមាន ឡូត៍នេសាទ និងឡូត៍ដាយ ជួលទៅឱ្យអ្នកហ៊ានដេញថ្លៃខ្ពស់ជាងគេដែលទទួលបាននូវសិទ្ធិផ្តាច់មុខក្នុងការធ្វើនេសាទជាលក្ខណៈជំនួញសំរាប់រយៈពេល ២ឆ្នាំ[២៦] ។ ឡូត៍ទាំងនេះ ច្រើនតែជាកន្លែងមានទិន្នផលត្រីខ្ពស់បំផុតនៅក្នុងតំបន់ ។ ក្រៅពីច្បាប់ និងបទប្បញ្ញត្តិជលផល ការគ្រប់គ្រងឡូត៍និមួយៗត្រូវអនុវត្តទៅតាម "សៀវភៅបន្ទុក" ដែលគូសបញ្ជាក់អំពីព្រំប្រទល់សំរាប់សិទ្ធិនេសាទផ្តាច់មុខ និងតំបន់បើកចំហ ពេលបើក និងបិទរដូវនេសាទ បទប្បញ្ញត្តិស្តីពីប្រតិបត្តិការនេសាទដែលអាចអនុវត្តបាន និងលក្ខខណ្ឌនៃការទូទាត់ ។
- **ការនេសាទខ្នាតមធ្យម** គឺមានការប្រើឧបករណ៍នេសាទមានខ្នាតធំជាងការនេសាទជាលក្ខណៈគ្រួសារ ប៉ុន្តែមានខ្នាតតូចជាងក្នុងប្រតិបត្តិការឡូត៍នេសាទពាណិជ្ជកម្ម ។ នាយកដ្ឋានជលផល តំរូវឱ្យអ្នកប្រើប្រាស់ឧបករណ៍បែបនេះ ស្នើសុំអាជ្ញាប័ណ្ណ ដាក់កំរិតឱ្យធ្វើការនេសាទក្នុងរដូវបើកចំហ តែអនុញ្ញាតឱ្យធ្វើការនេសាទនៅកន្លែងណាក៏បានក្នុងដែនសាធារណៈ (គឺនៅក្រៅឡូត៍នេសាទ និងក្រៅតំបន់អភិរក្ស) ។
- **អ្នកនេសាទខ្នាតតូច** ត្រូវបានកំណត់ឱ្យប្រើតែឧបករណ៍នេសាទខ្នាតតូច និងត្រូវបានអនុញ្ញាតឱ្យនេសាទនៅក្នុងតំបន់នេសាទបើកចំហ នៅក្នុងពេលណាក៏បាន លើកលែងតែនៅក្នុងឡូត៍នេសាទក្នុងរដូវបើក និងក្នុងតំបន់អភិរក្ស ។ ក្នុងការអនុវត្តន៍ជាក់ស្តែង សញ្ញាណនៃតំបន់បើកចំហ (ឬដែននេសាទសាធារណៈ) មានបញ្ហាស្មុគស្មាញ ពីព្រោះតំបន់ទាំងនេះភាគច្រើនស្ថិតនៅក្រោមកម្មសិទ្ធិ ឬការគ្រប់គ្រងក្រៅផ្លូវការ ដែលច្រើនតែបង្កើតឡើងដោយម្ចាស់ឡូត៍ និងអ្នកមានអំណាចដែលស្វែងរកផលប្រយោជន៍នៅតាមមូលដ្ឋាន (Degen *et al.* 2000) ។

**តារាង ៣.៣ ប្រភេទនៃការនេសាទទឹកសាបស្របច្បាប់**

| ប្រភេទនៃការនេសាទ | សិទ្ធិប្រើប្រាស់ | តំបន់នេសាទ | រដូវនេសាទ |
|---|---|---|---|
| ខ្នាតធំ (ការនេសាទបែបឧស្សាហកម្មសំរាប់គោលដៅពាណិជ្ជកម្ម) | ឡូត៍ជួលតាមរយៈការដេញថ្លៃ | នេសាទក្នុងតំបន់ឡូត៍ ដែលមិនរួមបញ្ចូលតំបន់នេសាទបើកចំហទេ | ចំពោះភាគខាងជើងភ្នំពេញ ពីថ្ងៃទី១ តុលា ដល់ ៣១ ឧសភា, ចំពោះភាគខាងត្បូងភ្នំពេញ ពីថ្ងៃទី១ វិច្ឆិកា ដល់ ៣០ មិថុនា |
| ខ្នាតមធ្យម (ការនេសាទមានអាជ្ញាប័ណ្ណឱ្យប្រើឧបករណ៍មានទំហំក្នុងចន្លោះរវាងទំហំសំរាប់ខ្នាតធំ និងខ្នាតតូច) | តំរូវឱ្យមានអាជ្ញាប័ណ្ណ | ដែននេសាទសាធារណៈ* | ភាគខាងជើងភ្នំពេញ ពីថ្ងៃ ១ តុលា ដល់ ៣១ ឧសភា, ភាគខាងត្បូងភ្នំពេញ ពីថ្ងៃ១ វិច្ឆិកា ដល់ ៣០ មិថុនា |
| ខ្នាតតូច (ការនេសាទជាលក្ខណៈគ្រួសារបរិភោគ) | សិទ្ធិបើកចំហ មិនចាំបាច់មានអាជ្ញាប័ណ្ណ | ដែននេសាទសាធារណៈ* និងក្នុងឡូត៍នេសាទក្នុងរដូវហាមឃាត់ | ពេញមួយឆ្នាំ |

** ដែននេសាទសាធារណៈសំដៅដល់តំបន់ក្រៅឡូត៍នេសាទ, ដែនជំរកត្រី, និងតំបន់ព្រៃលិចទឹកដែលត្រូវការពារ ។*

*ប្រភព: Ly et al. 2000*

### *៣.៦.២. រចនាសម្ព័ន្ធអ្នកកាន់កាប់ឡូត៍នេសាទ*

របៀបរបបជួលឡូត៍បច្ចុប្បន្ន មានលក្ខណៈដូចគ្នានឹងរបៀបរបបពីអតីតកាល ។ រដ្ឋាភិបាលជួលឡូត៍នេសាទសំរាប់រយៈពេល ២ឆ្នាំ ទៅឱ្យម្ចាស់ឡូត៍ដែលអាចបែងចែកការចំណាយលើមូលធន ការទទួលខុសត្រូវ និងផលចំណេញពីឡូត៍ជាមួយនឹងអ្នករួមភាគហ៊ុនច្រើននាក់ទៀត (ក្រាហ្វិក៣.១)[២៧] ។ នៅក្នុងករណីភាគច្រើន ម្ចាស់ឡូត៍ និងអ្នករួមភាគហ៊ុន បានជួលផ្ទៃ

[២៦] ឡូត៍នេសាទ មានផ្ទៃដី និងផ្ទៃទឹកច្បាស់លាស់ រីឯឡូត៍ដាយវិញ គ្រាន់តែជាទីតាំងមួយនៅក្នុងទន្លេដែលគេដាក់មងត្រងនៅមួយកន្លែងដើម្បីចាប់ត្រីចុះតាមចរន្តទឹក ។

[២៧] ឡូត៍នេសាទធំៗជាច្រើនត្រូវវផ្លាស់ប្តូរជាឡូត៍ "ស្រាវជ្រាវ" នៅពាក់កណ្តាលឆ្នាំ១៩៩៩ ក្រោមកិច្ចសន្យាជួលរយៈ ៤ឆ្នាំដោយគ្មានការដេញ

ឡូត៍មួយចំនួនជាបន្តសំរាប់ប្រតិបត្តិការនេសាទក្នុងមួយឆ្នាំៗ ។ ជាលទ្ធផល តំបន់ឡូត៍អាចត្រូវគេជួលបន្តជាច្រើនដង ។ អ្នកកាន់កាប់ឡូត៍អាចលក់សិទ្ធិនេសាទជាបន្តទៅឱ្យអ្នកនេសាទ ដូចជាការឱ្យនេសាទនៅក្នុងឡូត៍ ប៉ុន្តែត្រូវបង់ថ្លៃ ឬផលនេសាទមួយភាគ (Chheng 1999, Ly *et al.* 2000) ។ ម្ចាស់ឡូត៍អាចផ្តល់តំបន់ខ្លះនៃឡូត៍របស់ខ្លួនទៅឱ្យកងកំលាំងប្រដាប់អាវុធ ដើម្បីជាថ្នូរនៃសេវាការពារ (Ly *et al.* 2000) ។ រីឯខាងយោធា ឬក្រុមមានអាវុធ ក៏អាចដាក់ការត្រួតត្រារបស់ខ្លួនទៅលើតំបន់ ហើយតំរូវឱ្យម្ចាស់ឡូត៍បង់ថ្លៃការពារ (Gum 1998) ។

### *៣.៦.៣. ស្ថានភាពនៃឡូត៍នេសាទនៅមុន និងក្រោយការធ្វើកំណែទំរង់ក្នុងពេលថ្មីៗ*

កាលពីមុនកំណែទំរង់នៅចុងឆ្នាំ២០០០ នៅកម្ពុជាមាន ១៣៥ឡូត៍នេសាទ ដែលមានផ្ទៃសរុបប្រហែល ១លានហិកតា ដែលជាតំបន់មានទិន្នផលត្រីខ្ពស់បំផុត ។ ដោយមានបញ្ជាពីនាយករដ្ឋមន្ត្រី ក្រសួងកសិកម្មបានប្រឹងប្រែងធ្វើកំណែទំរង់ពីខែវិច្ឆិកា ឆ្នាំ២០០០ ដល់ខែកុម្ភៈ ឆ្នាំ២០០១ ក្នុងគោលដៅកាត់បន្ថយចំនួន និងទំហំនៃឡូត៍នេសាទ ។ ដំណើរការនេះរួមមាន ការអនុវត្តនីអនុក្រឹត្យមួយចំនួននៅថ្នាក់ខេត្ត និងការពិគ្រោះយោបល់ និងចរចា ក្នុងកិរិតផ្សេងៗគ្នាជាមួយនឹងភាគីពាក់ព័ន្ធនានា (Degen *et al.* ជិតចេញផ្សាយ) ។ ដូចមានបង្ហាញក្នុងតារាង៣.៤ កំណែទំរង់បានញ៉ាំងឱ្យមានការកាត់បន្ថយឡូត៍នេសាទពី ១៣៥ មក ៨២ឡូត៍ និងការកាត់បន្ថយផ្ទៃឡូត៍ពី ៩៥៤.០០០ហិកតា មកត្រឹម ៤១៧.០០០ហិកតា គឺកាត់បន្ថយអស់ប្រហែល ៥៦% ។ កំណែទំរង់នេះមានប្រសិទ្ធិភាពតាំងពីខែមិថុនា ២០០១ ។

**ក្រាហ្វិក ៣.១. រចនាសម្ព័ន្ធទូទៅនៃអ្នកកាន់កាប់ឡូត៍ និងការចាត់ចែងសិទ្ធិនេសាទសំរាប់ឡូត៍ណាមួយ**




*ប្រភព: Ly* et al. *2000*

Degen *et al.* (ជិតចេញផ្សាយ) បានធ្វើការកត់សំគាល់ទិដ្ឋភាពពីរនៃកំណែទំរង់ជលផលដែលគេសន្មតថានឹងកាត់បន្ថយទំនាស់ជលផល ។ ទីមួយ ចំនួនប្រជាជនដែលរស់នៅក្នុងរង្វង់ព្រំដែនឡូត៍នេសាទ បានថយចុះពីត្រឹម ៧៥៦.០០០ មកត្រឹម ១៤៨.០០០នាក់ ។ ទីពីរ ទំនាស់រវាងម្ចាស់ឡូត៍នេសាទ និងកសិករធ្វើស្រែលើការប្រើប្រាស់ដីទំនាបលិចទឹកសំរាប់ធ្វើនេសាទ និងកសិកម្ម ក៏គួរតែថយចុះដែរ ។ មុនពេលធ្វើកំណែទំរង់ មានដីកសិកម្មប្រមាណ ៤៤០.០០០ហិកតាដែលស្ថិតនៅក្នុងឡូត៍នេសាទ ប៉ុន្តែក្រោយការធ្វើកំណែទំរង់ គឺមាននៅសល់មិនដល់ ១/៣ នៃចំនួននេះទេ ។

ការកាត់បន្ថយទាំងចំនួន និងទំហំនៃឡូត៍នេសាទ បានផ្តល់ឱកាសល្អដើម្បីបន្ថយភាពតឹងតែង និងទំនាស់ក្នុងវិស័យ

ថ្លៃ ។ ការជួលទាំងនេះត្រូវលុបចោលវិញនៅក្នុងកំនែទំរង់នាឆ្នាំ២០០១ ព្រោះមានបញ្ហាចោទខាងនិតិវិធីនៃការជួលដែលគ្មានតម្លាភាព ។

ជលផល ប៉ុន្តែគេមានពត៌មានតិចតួចណាស់អំពីអ្វីដែលកើតមានជាក់ស្តែងនៅតាមកន្លែងនៃអតីតឡូត៍នេសាទទាំងនោះ ។ វេទិកា NGO 2001 បានលើកឡើងថា ទំនាស់អាចនៅមានបន្តទៀត ពីព្រោះផ្ទៃឡូត៍ដែលបើកចំហមិនមែនជាទីកន្លែងសំបូរត្រីដែលប្រជាជនធ្លាប់រកជាប្រពៃណីនោះទេ ហើយ "នៅក្នុងកន្លែងមួយចំនួនអាជ្ញាធរមូលដ្ឋាន កងកំលាំងប្រដាប់អាវុធ និងប្រតិបត្តិករឡូត៍នេសាទ មិនអនុវត្តតាមអនុក្រឹត្យទេ ហើយគេហាមឃាត់ប្រជាជនមូលដ្ឋានមិនឱ្យចូលនេសាទដដែល" ។ ការអនុវត្តន៏បែបនេះដោយអាជ្ញាធរមូលដ្ឋាន បានកើតឡើងរួចមកហើយ នៅតាមឡូត៍នេសាទដែលគេបានលុបចោលក្នុងពេលកន្លងមក (Chheng 2000) ។

**តារាង ៣.៤. ការប្រៀបធៀបចំនួនឡូត៍នេសាទ និងផ្ទៃនេសាទ ក្នុងឆ្នាំ២000 និង២00១**

| ខេត្ត | ឡូត៍នេសាទក្នុងឆ្នាំ២000 | | ឡូត៍នេសាទក្នុងឆ្នាំ២00១ | | ការថយចុះផ្ទៃឡូត៍ (%) |
|---|---|---|---|---|---|
| | ចំនួនឡូត៍ | ផ្ទៃនេសាទ (ហិកតា) | ចំនួនឡូត៍ | ផ្ទៃនេសាទ (ហិកតា) | |
| បន្ទាយមានជ័យ | 4 | 32,756 | 2 | 6,398 | 80.5 |
| បាត់ដំបង | 12 | 146,532 | 9 | 102,718 | 29.9 |
| កំពង់ចាម | 12 + 12[1] | 65,005 | 7 | 24,131 | 62.9 |
| កំពង់ឆ្នាំង | 19 | 62,256 | 12 | 45,085 | 27.6 |
| កំពង់ធំ | 7 | 127,126 | 7 | 69,353 | 45.5 |
| កណ្តាល | 19 + 1[1] | 179,728 | 15 + 1[1] | 51,640 | 71.3 |
| ក្រចេះ | 8 + 7[1] | 8,725 | 0 | 0 | 100.0 |
| ភ្នំពេញ | 1 | 3,475 | 0 | 0 | 100.0 |
| ព្រៃវែង | 19 | 143,069 | 14 | 55,340 | 61.3 |
| ពោធិសាត់ | 7 | 55,120 | 5 | 24,848 | 54.9 |
| សៀមរាប | 7 | 83,941 | 3 | 22,725 | 72.9 |
| តាកែវ | 20 | 46,007 | 8 | 15,201 | 67.0 |
| **សរុប** | **135 + 20[1]** | **953,740** | **82 + 1[1]** | **417,438** | **56.2** |

*[១] រួមទាំង "ឡូត៍នេសាទឆ្នេរខ្សាច់" ដែលមាន នៅកំពង់ចាម១២ នៅកណ្តាល១ និង នៅក្រចេះ៧ ។ ឡូត៍ទាំងនេះត្រូវបានលុបចោលអស់ លើកលែងតែឡូត៍នៅខេត្តកណ្តាល ។ ប្រភព: នាយកដ្ឋានជលផល, MAFF ដូចមានរាយការណ៏ក្នុង Cambodian People's Party (2001) ។*

### *៣.៦.៤. ការគ្រប់គ្រងសហគមន៏នេសាទ*

ដើម្បីឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងជលផល និងទំនាស់រវាងម្ចាស់ឡូត៍និងអ្នកនេសាទខ្នាតតូច អ្នកជំនាញការវិស័យជលផលបានផ្តល់យោបល់ជារឿយៗឱ្យបង្កើតការគ្រប់គ្រងរួមគ្នា (Co-management) ក្នុងវិស័យជលផល ដែលគេហៅម៉្យាងទៀតថា ការគ្រប់គ្រងសហគមន៏នេសាទ (Gum 2000, Degen *et al.* 2000, Ly *et al.* 2000) ។ ដូចមានពិភាក្សានៅខាងលើ នាយកដ្ឋានជលផលក្នុងពេលថ្មីៗនេះ បានប្រឹងប្រែងបង្កើតសហគមន៏នេសាទតាមរយៈអនុក្រឹត្យស្តីពីសហគមន៏នេសាទ និងបង្កើតការិយាល័យអភិវឌ្ឍន៏សហគមន៏នេសាទនៅក្នុងនាយកដ្ឋានជលផល ។

នៅប្រទេសកម្ពុជា សហគមន៏នេសាទនៅតែមាននិយមន័យទូលំទូលាយថាជាការស្ម័គ្រចិត្តរួមគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនឹងធនធានជលផល ដោយមានគោលដៅរួមក្នុងការគ្រប់គ្រងធនធានឱ្យមានចីរភាព សំរាប់ជាប្រយោជន៏ដល់អ្នកពាក់ព័ន្ធគ្រប់ៗគ្នា (Gum 2000, DoF 2001b) ។ អ្នកពាក់ព័ន្ធដែលរួមមានសមាជិកសហគមន៏មូលដ្ឋាន អាជ្ញាធរពាក់ព័ន្ធ និងអ្នកធ្វើនេសាទជាលក្ខណៈពាណិជ្ជកម្ម ត្រូវទទួលការខុសត្រូវក្នុងការកសាងផែនការគ្រប់គ្រងដោយអនុលោមទៅតាមច្បាប់ដែលមានស្រាប់ ។ ផែនការនេះគួរដោះស្រាយបញ្ហាមួយចំនួន ដូចជា ការធ្វើអាជីវកម្មប្រកបដោយចីរភាព ឧបករណ៏ និងពេលវេលានេសាទ

ការអនុវត្តន៍ ការពង្រឹងច្បាប់ ការថែរក្សា និងការដោះស្រាយទំនាស់ ។

ការសិក្សាពីកិច្ចសហការគ្រប់គ្រងជលផលនៅក្នុងទ្វីបអាស៊ី បានបង្ហាញនូវលក្ខខណ្ឌសំខាន់ៗមួយចំនួនសំរាប់ជំរុញការអនុវត្តន៍ការគ្រប់គ្រងរួមគ្នាឱ្យបានទទួលជោគជ័យ (Pomeroy *et al.* 1998) ។ លក្ខខណ្ឌទាំងនេះរួមមាន ការកំណត់ច្បាស់លាស់នូវព្រំប្រទល់ដែននេសាទ និងសមាជិកភាពក្នុងការគ្រប់គ្រងរួម, ផលចំណេញពីការគ្រប់គ្រងរួមដែលត្រូវមានកំរិតខ្ពស់ជាងចំណាយវិនិយោគ, ការពង្រឹងបទប្បញ្ញត្តិគ្រប់គ្រង, កិច្ចសហប្រតិបត្តិការនិងដឹកនាំនៅថ្នាក់សហគមន៍, និងការចូលរួមនៅក្នុងការគ្រប់គ្រងរួមដោយភាគីពាក់ព័ន្ធទាំងអស់ ។ ការសិក្សាផ្សេងទៀតបង្ហាញនូវសេចក្តីបារម្ភពីការលំបាកក្នុងការចាត់ចែងសហគមន៍ ការធានាឱ្យការចូលរួមមានរយៈពេលយូរអង្វែង និងបន្ទុកចំណាយនៃការគ្រប់គ្រងរួម (McConney 1998, Kupernan *et al.* 1998) ។ គេបានកត់សំគាល់ថា ការចាត់ចែងជាសមូហភាព និងសកម្មភាពរួម ច្រើនតែធ្វើឡើងដើម្បីឆ្លើយតបនឹងវិបត្តិនានា មិនមែនធ្វើ ឡើងតាមបែបបទដែលមានចីរភាពនោះទេ ហើយបន្ទុកចំណាយដែលពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធគ្រប់គ្រងរួម អាចមានកំរិតខ្ពស់ជាង ការគ្រប់គ្រងបែបវិមជ្ឈការ (ប៉ុន្តែក្នុងរយៈពេលវែង បន្ទុកចំណាយនៃការគ្រប់គ្រងរួម អាចទាបជាងបន្ទុកចំណាយនៃការគ្រប់គ្រងបែបវិមជ្ឈការ) ។

នៅកម្ពុជា Gum (2000) និង Degen *et al.* (2000) បានកត់សំគាល់នូវបញ្ហាប្រឈមមួយចំនួនក្នុងការបង្កើតសហគមន៍នេសាទគឺ:

- ការយល់ឃើញថា ការបង្កើតសហគមន៍នេសាទ នឹងគ្រាន់តែផ្តល់ជាមធ្យោបាយទៅឱ្យអាជ្ញាធរមូលដ្ឋានដើម្បីក្តោបក្តាប់ និងលក់សិទ្ធិនេសាទ ។
- ការយល់ឃើញរបស់បុគ្គលិកខ្លះៗនៃនាយកដ្ឋានជលផល និងមនុស្សមួយចំនួនទៀតនៅក្នុងវិស័យជលផល ដែលថាសហគមន៍នេសាទនឹងបណ្តាលឱ្យមានការនេសាទលើសកំរិត ។
- កង្វះបទពិសោធន៍ខាងសហគមន៍នេសាទនៅកម្ពុជា ។
- លទ្ធភាពនៃបន្ទុកចំណាយធ្វើប្រតិបត្តិការ (transaction costs) ក្នុងការចរចា និងការពង្រឹងសហគមន៍មូលដ្ឋាន ដែលអាចមានកំរិតខ្ពស់ជាងផលចំណេញ ។

ដើម្បីស្វែងយល់ឱ្យបានប្រសើរថែមទៀត ពីកំរិត និងទំហំនៃសកម្មភាពសហគមន៍នេសាទបច្ចុប្បន្ននៅកម្ពុជា វិបសអបានធ្វើសារពើភ័ណ្ឌគំរោងបច្ចុប្បន្ន ដោយផ្អែកលើឯកសារមានស្រាប់ ពត៌មានអំពីបណ្តាញជលផល និងធ្វើសំភាសន៍តាមទូរស័ព្ទ (ពីខែមករា ដល់មីនា ឆ្នាំ២០០២) ប៉ុន្តែ ពុំបានចុះដល់ទីកន្លែង ដើម្បីបញ្ជាក់បន្ថែមលើពត៌មានទាំងនោះឡើយ ។ សហគមន៍នេសាទប្រែប្រួលខុសគ្នាយ៉ាងខ្លាំង ទាំងចំពោះផ្ទៃនេសាទ ការរៀបចំ គោលដៅនិងវិធីសាស្ត្រគ្រប់គ្រង បញ្ហាត្រូវដោះស្រាយ ដំណើរការឆ្ពោះទៅរកការបង្កើតសហគមន៍ និងកំរិតនៃការគាំទ្រ ។ សំរាប់គោលដៅនៃសារពើភ័ណ្ឌនេះ "សកម្មភាពសហគមន៍នេសាទ" ត្រូវបានកំណត់និយមន័យយ៉ាងទូលាយដើម្បីក្តោបន័យការប្រឹងប្រែងនៅមូលដ្ឋាន ដើម្បីកែលំអការគ្រប់គ្រងជលផល និងការធ្វើអាជីវកម្មឱ្យមានចីរភាព ។ ឯកសារនេះពុំមានបំណងកំណត់និយមន័យនៃពាក្យ "សហគមន៍នេសាទ" ឱ្យបានច្បាស់លាស់ត្រឹមត្រូវ ឬក៏ធ្វើការវាយតំលៃពីប្រសិទ្ធិភាពនៃកិច្ចប្រឹងប្រែងនានាក្នុងពេលបច្ចុប្បន្ននេះឡើយ ។

CDRI បានរកឃើញ ១៦២ដែននេសាទសហគមន៍នៅកម្ពុជា (តារាង៣.៥)[២៨] ។ គំរោងទាំងនេះចែកចេញជាគំរោង

[២៨] ស្រដៀងគ្នានេះដែរ MAFF 2002 បានរាយការណ៍ថា "មានសហគមន៍នេសាទជាង ១៧០ បានបង្កើតឡើង" នៅកម្ពុជា ។ CDRI មិនអាចរកពត៌មាន (ដូចជាទីតាំង ទំហំ អ្នកពាក់ព័ន្ធ) ពីនាយកដ្ឋានជលផលស្តីពីសហគមន៍នេសាទទាំង១៧០នេះបន្ថែមបាន ។ ដូច្នេះ គេមិនទាន់

ដែលបានចាប់ផ្តើមតាំងពីមុនឆ្នាំ២០០០ និងគំរោង ដែលចាប់ផ្តើមនៅឆ្នាំ២០០០ និងឆ្នាំក្រោយមកទៀត ដើម្បីធ្វើការបែងចែក សហគមន៍នេសាទដែលទំនងជាមានបទពិសោធន៍ច្រើន និងមានសភាពមាំទាំជាង ឱ្យចេញពីសហគមន៍នេសាទដែលទើបបាន បង្កើតក្នុងពេលថ្មីៗ (ដូច្នេះអាចមានពាក់ព័ន្ធច្រើននឹងការធ្វើផែនការ និងការងាររៀបចំ) ។ គំរោងដែលចាប់ផ្តើមមុនឆ្នាំ២០០០

## តារាង ៣.៥ សកម្មភាពសហគមន៍នេសាទនៅកម្ពុជា [១]

| ខេត្ត | ចំនួនសហគមន៍នេសាទ | ចំនួនភូមិជាប់ទាក់ទិន | ចំនួនប្រជាជនពាក់ព័ន្ធ [២] | ផ្ទៃនេសាទសំរាប់សហគមន៍ (ហ.ត) | ប្រៀបធៀបផលិតភាព នឹងឡូត៍ជិតខាង [៣] | ថ្ងៃ-ខែចាប់ផ្តើមគំរោង | ទីភ្នាក់ងារ/NGOs បង្កើតសហគមន៍នេសាទ |
|---|---|---|---|---|---|---|---|
| **សកម្មភាពសហគមន៍នេសាទដែលបានចាប់ផ្តើមមុនឆ្នាំ២០០០** | | | | | | | |
| បន្ទាយមានជ័យ | 2 | 11 | 6,721 | 26,231 | ដូចគ្នា | វិច្ឆិកា 1999 | VSG |
| បាត់ដំបង | _* | 6 | 7,226 | 12,844 | ដូចគ្នា | មេសា 1998 | Leucaena |
| | 3 | 6 | 1,300 | N/A | អន់ជាង | តុលា 1999 | AS |
| កោះកុង | 2 | 2 | 2,143 | 4,560 | - | ធ្នូ 1997 | PMMR/MoE |
| កំពង់ចាម | 1 | 10 | 3,600 | 6,000 | ដូចគ្នា | សីហា 1998 | ADHOC |
| កំពង់ឆ្នាំង | 19 | N/A | 10,100 | 9,843 | ដូចគ្នា | កក្កដា 1999 | CCD/MRC |
| កំពង់ធំ | 8 | N/A | 3,191 | N/A | អន់ជាង | ធ្នូ 1999 | AACK |
| ក្រចេះ | 27 | 27 | 28,836 | 7,500 | - | 1996 | CAA |
| រតនគិរី | 3 | N/A | 3,372 | N/A | - | 1999 | Seila/IDRC |
| សៀមរាប | 10 | 111 | 83,000 | 108,000 | ដូចគ្នា | 1995 | FAO |
| | 1 | 1 | 1,641 | 60 | ដូចគ្នា | មេសា 1998 | FLOW |
| ស្ទឹងត្រែង | 29 | 29 | 9,848 | 10,000 | - | មករា 1998 | CAA |
| ស្វាយរៀង | 3 | 3 | 270 | 2 | - | 1994 | AIT |
| | 2 | 29 | 18,360 | N/A | - | 1998 | CRS/Santi Sena |
| *សរុបរង* | *110* | *235* | *179,608* | *185,040* | | | |
| **សកម្មភាពសហគមន៍នេសាទបានចាប់ផ្តើមនៅឆ្នាំ២០០០ ឬក្រោយឆ្នាំ២០០០** | | | | | | | |
| បាត់ដំបង | 1 | 1 | 802 | - | - | វិច្ឆិកា 2000 | CFDS |
| | 5 | - | 8,019 | - | - | ធ្នូ 2000 | KNCED |
| | 2 | 9 | 53,500 | 5,625 | ដូចគ្នា | កក្កដា 2001 | VSG |
| | 1 | 3 | 3,408 | 3,308 | អន់ជាង | 2002 | KAWP |
| កណ្តាល | 16 | 16 | 14,600 | 7,327 | ដូចគ្នា | មករា 2000 | MRC |
| កំពត | 1 | 4 | 5,432 | - | - | មេសា 2000 | Dayku Aphiwat |
| កោះកុង | 1 | 4 | 3,387 | 10,000 | - | មករា 2001 | AFSC |
| កំពង់ឆ្នាំង | 3 | 3 | - | - | ដូចគ្នា | កក្កដា 2000 | KHReDO |
| កំពង់ធំ | 1 | 9 | - | - | - | - | GTZ |
| | 2 | 2 | - | - | - | - | CREDO |
| ពោធិសាត់ | 3 | 3 | 950 | 2,458 | អន់ជាង | មីនា 2001 | CFDS/EPDO |
| | 2 | 4 | 900 | 7 | - | 2000 | BDASE |
| ក្រុងព្រះសីហនុ | 1 | 8 | 6,672 | 20 | - | ធ្នូ 1999 | WI/MoE/ADB |
| ស្ទឹងត្រែង | 9 | 9 | 4,528 | 13,500 | - | ឧសភា 2000 | CEPA |
| តាកែវ | 1 | 7 | 3,570 | - | - | 2001 | CCD |
| | 3 | 34 | 17,329 | 500 | អន់ជាង | ធ្នូ 2001 | CCK |
| *សរុបរង* | *52* | *116* | *123,097* | *42,745* | | | |
| សរុបរួម | **162** | **351** | **302,705** | **227,785**** | | | |

ច្បាស់ថាតើសហគមន៍នេសាទដែលកំនត់ដោយ វបសអ ដូចគ្នានឹងសហគមន៍នេសាទដែលកំនត់ដោយនាយកដ្ឋានជលផលក្នុងចំនួនប៉ុណ្ណា ។

*១ "សកម្មភាពសហគមន៍នេសាទ" ត្រូវបានកំណត់និយមន័យយ៉ាងទូលាយដើម្បីរាប់បញ្ចូលការប្រឹងប្រែងនៅថ្នាក់មូលដ្ឋាន ដើម្បីកែលំអការគ្រប់គ្រង និងការប្រើប្រាស់ជលផលឱ្យមានចីរភាព ។*

*២. ក្នុងករណីខ្លះ ការប៉ាន់ស្មានផ្ទះបញ្ចាំងនូវ ចំនួនគ្រួសារដែលគេប៉ាន់ស្មាន គុណនឹងទំហំគ្រួសារមធ្យមសំរាប់ខេត្ត ។*

*៣ គំរោងសហគមន៍នេសាទត្រូវបានស្នើឱ្យប្រៀបធៀប ផលិតភាពនៃតំបន់នេសាទសហគមន៍ ទៅនឹងឡូត៍ពាណិជ្ជកម្មដែលនៅក្បែរ ថាតើ (១) ប្រសើរជាង (២) ដូចគ្នា ឬ (៣) អន់ជាង ។ បើសិនគ្មានពតិមាន ឬគ្មានឡូត៍នេសាទនៅជិតគំរោងនោះ មានដាក់សញ្ញា - ។*

** មានន័យថា ពតិមានមិនអាចរកបាន ឬមិនអាចយកជាការបាន ។*

*** ពតិមានស្តីពីទំហំសហគមន៍នេសាទគិតជាហិកតា មិនអាចរកបានសំរាប់សហគមន៍នេសាទចំនួន ៣០ ។*

*ប្រភព: ការសំភាសន៍តាមទូរស័ព្ទ (មករា - មីនា ២០០២) ។ គ្មានការធ្វើទស្សនកិច្ចដល់ទីកន្លែងដើម្បីបញ្ជាក់ភាពពិតនៃពតិមានទេ ។*

បានបង្កើត ១១០ដែននេសាទសហគមន៍មានភូមិចំនួន ២៣៥ពាក់ព័ន្ធ (ឬមនុស្សប្រហែល ១៨០.០០០នាក់) និងមានផ្ទៃដីប្រហែល ១៨៥.០០០ហិកតា ។ ដើម្បីបញ្ជាក់អំពីគុណភាពនៃធនធានជលផល គំរោងបានស្នើអ្នកតំណាងឱ្យធ្វើការប្រៀបធៀបទិន្នផលនៃដែននេសាទសហគមន៍ ជាមួយនឹងឡូត៍នេសាទពាណិជ្ជកម្មដែលនៅក្បែរនោះ ។ ចំពោះកន្លែងដែលអាចប្រៀបធៀបបាន អ្នកតំណាងភាគច្រើននិយាយថា ទិន្នផលនៅក្នុងសហគមន៍នេសាទ មានកំរិតដូចគ្នា ឬអន់ជាងឡូត៍នេសាទដែលនៅក្បែរ ។

កំណែទំរង់ជលផល ការប្រឹងប្រែងធ្វើវិមជ្ឈការ និងការផ្តោតខ្លាំងទៅលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ សុទ្ធតែបាននាំមកនូវកំនើនសកម្មភាពសហគមន៍នេសាទក្នុងរយៈពេល ២ឆ្នាំកន្លងមក ។ គំរោងដែលបានចាប់ផ្តើមចាប់តាំងពីឆ្នាំ២០០០ កំពុងស្ថិតនៅក្នុងដំណើរការកសាងដែននេសាទសហគមន៍ (យ៉ាងតិច ៥២សហគមន៍ ទាក់ទិននឹង ១១៦ភូមិ ឬមនុស្សប្រហែល ១២៣.០០០នាក់) ។ ទំហំផ្ទៃទឹករបស់សហគមន៍នេសាទទាំងនេះ ភាគច្រើនមិនទាន់ដឹងច្បាស់នៅឡើយ ពីព្រោះគំរោងជាច្រើនកំពុងស្វះស្វែងបង្កើតសហគមន៍នេសាទនៅក្នុងតំបន់សម្បូរទាននានាដែលទើបត្រូវបានរំលាយចោលក្នុងពេលថ្មីៗ ។

## ៣.៧. បញ្ហាគ្រប់គ្រងជលផល

គេនៅតែស្រពិចស្រពិលនៅឡើយថាតើកំណែទំរង់ជលផលក្នុងពេលថ្មីៗ បានជួយដោះស្រាយដល់កំរិតណាហើយនូវបញ្ហា ខាងការគ្រប់គ្រងនៅក្នុងវិស័យជលផល ដែលកើតមានតាំងពីយូរយារមកហើយ ដូចជា កង្វះលទ្ធភាព និងសិទ្ធិទៅកាន់តំបន់បើក ចំហ សំរាប់អ្នកនេសាទខ្នាតតូច, ការអនុវត្តន៍ការនេសាទខុសច្បាប់ ឬបែបបំផ្លាញដោយអ្នកនេសាទខ្នាតតូចផង និងអ្នកនេសាទ ដើម្បីពាណិជ្ជកម្មផង និងការអះអាងរៀងៗខ្លួននៅក្នុងការកាន់កាប់ជលផល ទំនាបលិចទឹក និងធនធានទឹក ។ បន្ថែមទៅលើ បញ្ហាគ្រប់គ្រងទាំងនេះ គឺមានអ្នកចូលនេសាទកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ (រួមបញ្ចូលទាំងអ្នកបំលាស់ទីមកពីតំបន់ ខ្ពង់រាប) ការគ្រប់គ្រង និងពង្រឹងការអនុវត្តន៍ច្បាប់ នៅមានភាពទន់ខ្សោយ និងកង្វះខាតស្ថិតិជលផលមួយដែលត្រឹមត្រូវ និង ច្បាស់លាស់ ដើម្បីអាចធ្វើការតាមដានឱ្យមានប្រសិទ្ធិភាព ។ តទៅនេះ គឺជាការពិភាក្សាលំអិតអំពីបញ្ហាគ្រប់គ្រងជលផល សំខាន់ៗ:

- **ការនេសាទខុសច្បាប់បែបបំផ្លាញ** ស្ទើរតែគ្រប់របាយការណ៍ស្តីពីការនេសាទនៅកម្ពុជា ទាំងការនេសាទទឹកសាប និងការនេសាទសមុទ្រ បានកត់សំគាល់ថា ការនេសាទខុសច្បាប់គឺជាបញ្ហាធ្ងន់ធ្ងរមួយ ពីព្រោះវាមានចំនួនច្រើន និងមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើស្តុកត្រី និងជំរកត្រី (ឧទាហរណ៍ របាយការណ៍របស់ Swift 1997, Gum 1998, Mastaller 1999, Degen *et al.* 2000, Mak 2000a) ។ សកម្មភាពខុសច្បាប់ច្រើនជាងគេ រួមមាន ការបំពុល ការឆក់ត្រី ការប្រើប្រាស់សំរាស់[២៩] ការបូមទឹកពង្រីងកន្លែងនេសាទ ការប្រើប្រាស់មងក្រឡាល្អិតពេក ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ផ្សេងទៀត ប្រតិបត្តិការអូសអួនច្រើនលើកច្រើនសារ ការនេសាទក្នុងរដូវហាមឃាត់ ដោយប្រើឧបករណ៍ខ្នាតធំ/មធ្យម និងការប្រមូលកូនត្រីធម្មជាតិ ។ ទោះបីអំពើទាំងនេះសុទ្ធតែខុសច្បាប់ក៏ដោយ

[២៩] គេសង់សំរាស់ដោយប្រើអង្កត់ឈើ ឫស្សី មែកឈើ ខ្សែលួស និងសំភារៈផ្សេងៗទៀត ដើម្បីបង្កើតជាជំរកសំរាប់ត្រីនៅ ។ នៅពេលដែលទឹកស្រកចុះ អ្នកនេសាទយកអួនមកហ៊ុំព័ទ្ធសំរាស់ បន្ទាប់មករើសំភារៈសំរាស់ចេញ ហើយចាប់យកត្រីទាំងអស់ ។

ក៏អង្កេតបានបង្ហាញថា សកម្មភាពទាំងនេះកើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ។ ឧទាហរណ៍ អង្កេតឡូត៍នេសាទចំនួន៣0 នៅក្នុង ៧ខេត្ត នៅឆ្នាំ១៩៩៨-៩៩ បានរកឃើញថា មានការអនុវត្តន៍ខុសច្បាប់ជាច្រើនដោយម្ចាស់ឡូត៍ផង និងអ្នកនេសាទតូចតាចផង (Ly *et al.* 2000) ។ ការបំពានច្បាប់ដោយម្ចាស់ឡូត៍រួមមាន ការនេសាទដោយដាក់សំរាស់ (២២ឡូត៍) ការអូសអួនយកទាំងអស់លើសពីមួយដង (២១ឡូត៍) ការឆក់ត្រី (១២ឡូត៍) និងការបូមទឹកពង្រីងដើម្បីចាប់ត្រី (៨ឡូត៍) ។ ការបំពានច្បាប់ដោយអ្នកនេសាទតូចតាចនៅក្នុងឡូត៍នេសាទរួមមាន ការលបលួចនេសាទ (២៤ឡូត៍) ការកាប់ព្រៃលិចទឹក (២១ឡូត៍) និងការឆក់ត្រី (១៧ឡូត៍) ។ ស្រដៀងគ្នានេះដែរ អង្កេតលើ ២៩៧គ្រួសារដែលរស់នៅក្នុងឬក្បែរតំបន់ឡូត៍នេសាទក្នុង ៤ខេត្តខុសៗគ្នា បានរកឃើញថា មានសកម្មភាពខុសច្បាប់ជាច្រើនក្នុងឡូត៍នេសាទ និងតំបន់បើកចំហ (Van Acker 1999 in Degen *et al.* 2000) ។

- **ការពង្រីកព្រំដែនឡូត៍នេសាទ ការចាប់យក និងការលក់តំបន់បើកចំហដោយខុសច្បាប់:** ម្ចាស់ឡូត៍ យោធា និងរដ្ឋអំណាចមូលដ្ឋាន ជាញឹកញាយបានរឹបយកតំបន់បើកចំហ ហើយជួលទៅឱ្យឈ្មួញ ឬតំរូវឱ្យអ្នកនេសាទតូចតាចបង់ ថ្លៃដើម្បីចូលនេសាទ (Gum 1998, Nao and Srun 1999, Ly *et al.* 2000) ។ ពួកគេបានឆ្លៀតយកប្រយោជន៍ពី ការបោះបង្គោលព្រំមិនបានច្បាស់លាស់ក្នុងឡូត៍នេសាទ និងកន្លែងបើកចំហដើម្បីពង្រីកឡូត៍នេសាទដោយខុស ច្បាប់លើសពីព្រំប្រទល់ពិតប្រាកដ គឺឆ្លងចូលទៅកន្លែងឯទៀតដែលសំបូរត្រី ។ ក្នុងករណីជាច្រើន ព្រំដែននេសាទ ត្រូវបានពង្រីកដើម្បីកាត់បញ្ចូលតំបន់លិចទឹកក្នុងរដូវវស្សា (Nao and Srun 1999, Swift 1999, Mak 2000a, Star Kampuchea 2000) ។ កងកំលាំងប្រដាប់អាវុធដើរតួនាទីសំខាន់នៅក្នុងការការពារ និងត្រួតពិនិត្យឡូត៍នេសាទ ។
- **ការប្រជែងគ្នាក្នុងការប្រើប្រាស់ដី និងទឹកសំរាប់គោលដៅកសិកម្ម និងនេសាទ:** ទំនាស់បានកើតឡើងលើការប្រើប្រាស់ដី និងទឹក នៅក្នុងតំបន់ឡូត៍ ពីព្រោះធនធានទាំងនេះដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់ទាំងកសិកម្ម និងជលផល ។ ម្ចាស់ឡូត៍ចង់ការពារព្រៃលិចទឹកនិងព្រៃគម្ពោត ពីព្រោះវាផ្តល់ជាជំរកត្រីដ៏សំខាន់ និងបង្កើនទិន្នផលត្រី ចំណែកកសិករច្រើនព្យាយាមកាប់រានព្រៃទាំងនេះ ដើម្បីដាំស្រូវ (Swift 1997, Degen *et al.* 2000) ។ ស្រដៀងគ្នានេះដែរ ម្ចាស់ឡូត៍អាចព្យាយាមបូមពង្រីងអាងទឹកនិងស្រះដើម្បីងាយចាប់ត្រី ប៉ុន្តែកសិករចង់បានទឹកនេះសំរាប់កសិកម្ម ហើយចង់ប្រើប្រាស់វាបន្តិចម្តងៗ (Ly *et al.* 2000) ។ អ្នកភូមិមួយចំនួនបានអះអាងថា ម្ចាស់ឡូត៍ហាមមិនឱ្យពួកគេប្រើប្រាស់ទឹក បំផ្លាញប្រព័ន្ធធារាសាស្ត្ររបស់ពួកគេ ហើយរារាំងមិនឱ្យពួកគេជីកស្រះសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ឬការស្រោចស្រព (Swift 1999, Mak 2000a) ។ ការប្រជែងគ្នារវាងការអភិវឌ្ឍន៍កសិកម្ម និងជលផលមានពិភាក្សាលំអិតនៅខាងក្រោម (សូមអានចំនុច៣.៨ ផលប៉ះពាល់ពីផ្នែកដទៃដល់ការនេសាទទឹកសាប) ។
- **ការលបលួចនេសាទ និងការកាប់អុសក្នុងតំបន់ឡូត៍នេសាទ និងការកាប់ព្រៃកោងកាងនៅតំបន់ឆ្នេរសមុទ្រ:** ការលបលួចនេសាទកើតមាននៅក្នុងគ្រប់ឡូត៍នេសាទទាំងអស់ ជាពិសេសនៅកន្លែងណាដែលមានដែនសាធារណៈតូចឬក៏ត្រូវបានគេរំលោភយក ។ ការលបលួចនេសាទច្រើនតែធ្វើតាមការឆក់ត្រីដែលជាអំពើខុសច្បាប់ ដោយសារវិធីនេះកាត់បន្ថយនូវហានិភ័យនៃការលបលួចពីព្រោះអាចចាប់ត្រីបានឆាប់រហ័ស ។ អ្នកភូមិច្រើនតែចូលកាប់យកអុសពីតំបន់ព្រៃលិចទឹកនៅក្នុងឡូត៍នេសាទផងដែរ ។ ទង្វើទាំងនេះ អាចធ្វើឱ្យជំរកត្រីកាន់តែហិនហោចទៅ បំផ្លាញតំបន់បន្តពូជ និងការលូតលាស់នៃកូនត្រី (Swift 1997, Gum 1998, Swift 1999) ។ ស្រដៀងគ្នានឹងព្រៃលិចទឹកក្នុងតំបន់ទឹកសាបដែរ ការបាត់បង់ព្រៃកោងកាងនៅតំបន់ឆ្នេរសមុទ្រមានសន្ទុះយ៉ាងលឿន ។ មូលហេតុនៃការកាប់និងថយចុះព្រៃកោងកាងរួមមាន ការប្រមូលផលព្រៃកោងកាងធ្វើអុសនិងធ្យូង ការចិញ្ចឹមបង្គារ ការធ្វើស្រែអំបិល និងសកម្មភាពនេសាទខុសច្បាប់ ដូចជាការដាក់គ្រឿងផ្ទុះ និងបំពុល (Mastaller 1999, Marschke 2000b) ។

- **ការបិទផ្លូវទឹកមិនឱ្យធ្វើដំណើរៈ** ម្ចាស់ឡូត៍អាចបិទស្ទឹង ព្រែក ឬផ្លូវទឹកផ្សេងៗទៀត ដើម្បីធ្វើការចាប់ត្រី ឬការពារតំបន់នេសាទ ។ ទង្វើនេះប៉ះពាល់ដល់ការធ្វើដំណើរ និងសកម្មភាពពាណិជ្ជកម្មរបស់សហគមន៍ដែលរស់នៅក្នុងតំបន់ឡូត៍នេសាទ (Nao and Srun 1999, Ly *et al.* 2000) ។ ក្នុងពេលខ្លះប្រជាជនដែលធ្វើដំណើរឆ្លងកាត់តំបន់ឡូត៍អាចត្រូវបានគេតំរូវឱ្យបង់ថ្លៃ (Chheng 1999, Mak 2000a) ។
- **ការគ្រប់គ្រង និងការអនុវត្តន៍ច្បាប់ទន់ខ្សោយដោយអាជ្ញាធរមូលដ្ឋានៈ** ជារឿយៗគេបានលើកឡើងថា បៀវត្សរ៍ និងធនធាន មិនគ្រប់គ្រាន់គឺជាមូលហេតុចំបងដែលធ្វើឱ្យ អាជ្ញាធរមូលដ្ឋានមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយមានប្រសិទ្ធិភាព ។ គេបានរាយការណ៍ថា អាជ្ញាធរមូលដ្ឋានផ្តោតលើការប្រមូលចំណូលក្រៅផ្លូវការក្នុងរយៈពេលខ្លីច្រើនជាង ការគ្រប់គ្រងជលផលរយៈពេលវែង ។ បញ្ហាសំខាន់ៗក្នុងការគ្រប់គ្រង និងការពង្រឹងការអនុវត្តន៍ច្បាប់ រួមមាន កង្វះខាតតម្លាភាពនៅក្នុងការផ្តល់ឡូត៍នេសាទ, "ភាពមិនប្រក្រតី" ក្នុងការប្រមូលចំណូល, ការអនុវត្តន៍បទប្បញ្ញត្តិជលផលដោយចោះៗ ដោយមានការលំអៀងទៅខាងម្ចាស់ឡូត៍ និងអ្នកនេសាទខ្នាតធំ (ដោយរួមទាំងទូកបរទេសនៅក្នុងដែនសមុទ្រ) និងកង្វះយន្តការសំរាប់ដាក់ពាក្យបណ្តឹង និងដោះស្រាយទំនាស់ (Swift 1997, Gum 1998, Mak 2000a) ។

បញ្ហាគ្រប់គ្រងជលផលទាំងនេះ កើតចេញពីទំនាស់កាន់តែច្រើនឡើងៗ មុននឹងការធ្វើកំណែទំរង់ក្នុងពេលថ្មីៗ ។ ទោះបីទិន្នន័យផ្លូវការស្តីពីទំនាស់ជលផលពិបាករកបាន មិនពេញលេញ ឬមានដោយអន្លើៗក៏ដោយ ប៉ុន្តែនាយកដ្ឋានជលផលមានទិន្នន័យស្តីពីពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរពីខេត្តចំនួន៩ ។ ទិន្នន័យទាំងនេះបង្ហាញនូវកំនើននៃពាក្យបណ្តឹងពី ១៦៨ពាក្យក្នុងឆ្នាំ១៩៩៨ ដល់ ៣៥៦ពាក្យក្នុងឆ្នាំ១៩៩៩ ដោយ ៣ខេត្តនៅជុំវិញបឹងទន្លេសាបមានកំណើនខ្លាំងជាងគេ (Degen *et al.* 2000) ។ ការមិនទុកចិត្តចំពោះអាជ្ញាធររដ្ឋាភិបាល ទំនងជារារាំងមិនឱ្យប្រជាជនធ្វើពាក្យបណ្តឹងឡើងមកទេ ហើយពាក្យបណ្តឹងជាច្រើន ក៏មិនត្រូវបានបញ្ជូនតាមខ្សែរយៈរដ្ឋបាលត្រឹមត្រូវ ដូច្នេះទិន្នន័យទាំងនេះទំនងជា តំណាងឱ្យតែមួយភាគតូចនៃពាក្យបណ្តឹងពិតប្រាកដប៉ុណ្ណោះ ។

ក្រៅពីពាក្យបណ្តឹងជាផ្លូវការ ករណីសិក្សាជាច្រើនបានបង្ហាញពីទំនាស់គ្រប់ទីកន្លែងស្តីពីធនធានជលផល ។ ឧទាហរណ៍ទំនាស់ត្រូវបានកត់សំគាល់នៅក្នុងខេត្តបាត់ដំបង (Gum 1998, Mak 2000a), ខេត្តសៀមរាប (Nao and Srun 1999, Chan *et al.* 2001), ខេត្តកំពង់ចាម (Star Kampuchea 2000), ខេត្តកំពង់ឆ្នាំង (Swift 1997, Swift 1999), ខេត្តកំពង់ធំ (Gum 2000), ខេត្តស្ទឹងត្រែង (Mak 2000b, Gum 2000), និងខេត្តតាកែវ (Swift 1997, Kato 1999) ។

## ៣.៨. ផលប៉ះពាល់ពីវិស័យផ្សេងៗលើជលផលទឹកសាប

ក្រៅពីការនេសាទខុសច្បាប់ និងការគ្រប់គ្រងទន់ខ្សោយ សកម្មភាពអភិវឌ្ឍន៍នៅក្នុងវិស័យផ្សេងៗ បានគំរាមកំហែងដល់និរន្តរភាពនៃជលផលនៅកម្ពុជា ។ ផលប៉ះពាល់ពីវិស័យផ្សេងៗមកលើជលផល ជាចំបងគឺបណ្តាលមកពីការពង្រីកវិស័យកសិកម្ម ការកាប់ព្រៃឈើច្រើនកន្លែង និងគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។

### *៣.៨.១. កសិកម្មប្រជែងជាមួយជលផលដណ្តើមធនធានដី និងទឹក*

ប្រទេសកម្ពុជាមានផ្ទៃដីប្រហែល ២,៤លានហិកតាសំរាប់ធ្វើដំណាំស្រូវ នៅក្នុងនេះប្រហែល ១,៨លានហិកតាជាដីកសិកម្មអចិន្ត្រៃយ៍ និង ០,៦លានហិកតា ជាតំបន់វាលទំនាបលិចទឹកអាស្រ័យដោយកំរិតទឹកឡើងប្រចាំឆ្នាំ ។ តំបន់វាលទំនាបលិចទឹកទាំងនេះទ្រទ្រង់សកម្មភាពជាច្រើន ដូចជាកសិកម្ម ការប្រមូលផលិតផលព្រៃលិចទឹក និងការនេសាទ ។ សកម្មភាពទាំងនេះច្រើនតែមានការប្រជែងគ្នា ។

- **គំរោងស្រោចស្រពនិងគ្រប់គ្រងទឹកលើកកំពស់ទិន្នផលកសិកម្ម ប៉ុន្តែកាត់បន្ថយទិន្នផលត្រីតាមការកាត់បន្ថយជំរកត្រី ជាពិសេសជំរកត្រីក្នុងរដូវប្រាំង:** ជាញឹកញយម្ចាស់ឡូត៍នេសាទបានអះអាងថា ទឹក និងត្រីនៅក្នុងអាងស្តុកទឹកដែលត្រូវបានកសាងឡើងដើម្បីស្តុកទឹកសំរាប់ស្រោចស្រពក្នុងរដូវប្រាំង គឺជាចំណែកនៃឡូត៍ដែលពួកគេបានជួល ។ ពួកគេអាចទំលាយទំនប់អាងទឹក ដើម្បីរារាំងការស្តុកទឹក ឬបូមទឹកចេញដោយខុសច្បាប់ពីអាងស្តុកនៅចុងរដូវនេសាទ (ដែលជារដូវប្រាំងសំរាប់ការងារកសិកម្ម) ។ ទង្វើបែបនេះនាំឱ្យអស់ទឹកសំរាប់ស្រោចស្រពនៅរដូវប្រាំង ។ ក្រៅពីរឿងស្តុកទឹក កសិករអាចធ្វើឱ្យប៉ះពាល់ដល់ទិន្នផលនេសាទតាមការបង្វែរចរន្តទឹកធម្មជាតិ ឱ្យហូរតាមប្រឡាយស្រោចស្រពក្នុងកំលុងពេលទឹកឡើង ឬទឹកស្រក ។ ក្នុងពេលទឹកឡើង ការបង្វែរទឹកសំរាប់កសិកម្មអាចកាត់បន្ថយទឹកជំនន់ក្នុងតំបន់ឡូត៍នេសាទ គឺធ្វើឱ្យថយចំនួនត្រីដែលត្រូវហូរចូលក្នុងឡូត៍ ។ ក្នុងពេលទឹកស្រក ការរារាំងលំហូរទឹកស្រក អាចប៉ះពាល់ដល់សមត្ថភាពនៃប្រតិបត្តិករឡូត៍នេសាទក្នុងការចាប់ត្រី នៅចំពេលសមស្របបំផុត ដែលជាពេលត្រីត្រូវត្រលប់ចូលទៅក្នុងទន្លេធំៗជាមួយនឹងទឹកសំរក (Degen *et al.* 2000) ។
- **ការរានព្រៃលិចទឹក និងព្រៃគម្ពោតសំរាប់ធ្វើកសិកម្ម កាត់បន្ថយទិន្នផលជលផល ពីព្រោះព្រៃទាំងនេះផ្តល់នូវជំរកដ៏ល្អសំរាប់ត្រីពង ការចិញ្ចឹមកូន និងការរកចំណីរបស់ត្រី:** មួយភាគធំនៃព្រៃលិចទឹក និងដីសើមនៅកម្ពុជាត្រូវបានកែប្រែមកជាដីកសិកម្មរួចទៅហើយ ។ តំបន់ព្រៃលិចទឹកបានថយចុះពីប្រហែល ៩៣៧.៩០០ហិកតាក្នុងឆ្នាំ ១៩៧៣ មកត្រឹមប្រហែល ៣៧០.០០០ហិកតាក្នុងឆ្នាំ១៩៩៧ (សូមអាន "៤.១ ផ្ទៃព្រៃឈើ") ។ សំខាន់គួរកត់សំគាល់ថា នៅពេលមានព្រៃតិច ការច្រោះសឹកដីក៏កើតមាន ចំនួនដីល្បាប់ចាក់បំពេញក្នុងពេលទឹកឡើងត្រូវថយចុះ ដែលជារឿយៗធ្វើឱ្យធ្លាក់ចុះនូវគុណភាពដី និងទិន្នផលដំណាំនៅក្នុងតំបន់ដែលគេបានកែប្រែដីព្រៃលិចទឹក ។
- **ថ្នាំសំលាប់សត្វល្អិត និងជីគីមីអាចកាត់បន្ថយគុណភាពទឹក និងផលិតភាពជលផល:** ការហូរជាតិគីមីពីដីកសិកម្មអាចប៉ះពាល់ដល់ជលផលនៅក្បែរខាង និងប៉ះពាល់ដោយផ្ទាល់ដល់ទិន្នផលត្រីនៅក្នុងស្រែ (Nao and Ly, 1997) ។ ដោយសារខ្វះការស្រាវជ្រាវពីប្រធានបទនេះនៅកម្ពុជា គេមិនអាចកំណត់បានទេថា តើការហូរជាតិគីមីកសិកម្មវាមានច្រើនដល់កំរិតអាចប៉ះពាល់ដល់សុខភាពត្រីឬយ៉ាងណា ។ ភស្តុតាងខ្លះៗបង្ហាញថា ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតច្រើនក្នុងតំបន់មួយចំនួន បានប៉ះពាល់ដល់ទិន្នផលត្រីក្នុងស្រែ និងក្នុងស្រះត្រីដែលនៅក្បែរ (Gregory 1997, Shams and Try 1998, Gum 2000) ។

### *៣.៨.២. ការកាប់ព្រៃឈើសំរុកច្រើនពេក អាចធ្វើឱ្យមានល្បាប់ហូរចូលបឹងទន្លេសាបកាន់តែច្រើនឡើង*

កំណើនកំណកដីល្បាប់នៅក្នុងបឹងទន្លេសាប អាចកាត់បន្ថយជំរៅនៅរដូវប្រាំង បានដាក់សំពាធមួយយ៉ាងខ្លាំងដល់វិស័យជលផល (ជាពិសេសតាមរយៈការថយចុះអុកស៊ីសែននៅក្នុងទឹក) និងនៅក្នុងរយៈពេលវែង គឺអាចគំរាមកំហែងដល់អាយុជីវិតនៃបឹងទន្លេសាបតែម្តង ។ មានគេលើកពីការបារម្ភយ៉ាងច្រើនថា អត្រាកកល្បាប់ បានកើនឡើងខ្ពស់គួរឱ្យកត់សំគាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែសកម្មភាពកាប់ព្រៃឈើយ៉ាងខ្លាំង ការបន្តរុករានដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងសកម្មភាពជីកត្បូងនៅតំបន់ក្បាលស្ទឹងនានាដែលហូរចាក់ទៅក្នុងបឹងទន្លេសាប (Csavas 1994, Nao and Ly 1997; Azimi *et al.* 2001) ។ អ្នកខ្លះនិយាយថា ការបារម្ភអំពីកំណកល្បាប់ ដូចជា បំប៉ោងជ្រុលពេក ដោយគេបានលើកហេតុផលថា: (ក) នៅក្នុងអាកាសធាតុ ត្រូពិច រុក្ខជាតិដុះឡើងយ៉ាងឆាប់នៅក្នុងតំបន់ដែលកាប់ព្រៃអស់ ហើយវាជួយកាត់បន្ថយសក្តានុពលភាពសំណឹកដីឱ្យនៅតិចជាង កំរិតបច្ចុប្បន្ន (ខ) ល្បាប់មួយភាគធំដែលកើតឡើងដោយសំណឹកដី គឺបានរង/កកនៅជិតៗកន្លែងកាប់ឈើ មិនមែនហូរទៅបឹង ទន្លេសាបទេ (គ) ផ្លូវជាតិលេខ ៥ និង ៦ ដែលនៅជុំវិញបឹង គឺជាកន្លែងរាំងល្បាប់មួយចំនួនធំ (NEDECO 1998, Chaktomuk Project Management Unit 2000) ។

ការពិភាក្សាក្នុងពេលថ្មីៗស្តីពីការកកល្បាប់នៅបឹងទន្លេសាប គឺវាបន្តនូវការពិភាក្សាយ៉ាងយូរមកហើយនៅលើប្រធានបទនេះ ហើយវាបង្កឱ្យមានការទស្សន៍ទាយមួយចំនួនពីអនាគតនៃបឹងទន្លេសាប ។ ឧទាហរណ៍ អ្នកភូមិវិទ្យាបារាំងមួយចំនួនបានប៉ាន់ស្មានកាលពីឆ្នាំ១៩២៣ ថា បឹងទន្លេសាបនឹងបន្តនៅជាអចិន្ត្រៃយ៍ក្នុងរយៈពេល២០០ឆ្នាំទៀត ក្រោយពីនោះបឹងនេះនឹងមានរូបរាងតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ ។ នៅទសវត្សរ៍១៩៥០ ការសិក្សាបែបគុណភាពមួយដែលពឹងផ្អែកលើការសង្កេតផ្ទាល់របស់អ្នកនេសាទបានប៉ាន់ថា ក្នុង៥០ឆ្នាំទៀតបឹងទន្លេសាបនឹងបាត់រូបរាងនៅក្នុងរដូវប្រាំង (Bardarch 1959) ។ នៅឆ្នាំ១៩៦២-៦៣ អ្នកបច្ចេកទេសបារាំងមួយក្រុម បានធ្វើការសិក្សាទូលំទូលាយមួយដើម្បីវាស់វែងដីល្បាប់ដែលហូរចូលបឹងទន្លេសាប ដោយបានខួងពិនិត្យដីបាតបឹងចំនួន ១៩កន្លែង (Carbonnel 1964 in NEDECO 1998) ។ ការសិក្សាបានរកឃើញថា មានល្បាប់ប្រហែល ៤,៧លានតោនហូរចូលបឹងទន្លេសាប ក្នុងកំលុងឆ្នាំ១៩៦២-៦៣ ក្នុងនេះ ២,៧លានតោនហូរមកពីទន្លេមេគង្គតាមរយៈទន្លេសាប និង ១,៩លានតោន ហូរចូលតាមស្ទឹង-អូរជាដៃរបស់បឹងទន្លេសាប ។ ចំនួនល្បាប់នេះនាំឱ្យមានអត្រាកកល្បាប់ជាមធ្យមពី ០,៣-០,៥មម/ឆ្នាំ ។ តាមអត្រានេះ ការសិក្សាបានប៉ាន់ស្មានថា បឹងទន្លេសាបនឹងមិនបាត់រូបរាងឡើយក្នុង ១.៥០០ឆ្នាំខាងមុខ (Carbonnel 1964 in NEDECO 1998) ។

នៅក្នុងរយៈពេលថ្មីៗនេះ Csavas (1990) បានលើកឡើងថា អត្រាកកល្បាប់នៅក្នុងបឹងទន្លេសាប មានកំរិតដល់ទៅបួនសង់ទីម៉ែត្រក្នុងមួយឆ្នាំ ដែលបណ្តាលឱ្យមានការទស្សន៍ទាយថា បឹងទន្លេសាបនឹងគោក នៅក្នុងរយៈមួយទសវត្សរ៍ប៉ុណ្ណោះ (NEDECO 1998) ។ អស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកហើយ គេឃើញច្បាស់ថា បឹងទន្លេសាបមិនបានគោកឆាប់រហ័សដោយសារកំណកល្បាប់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារគ្មានទិន្នន័យ និងការវិភាគអំពីអត្រាកំណកល្បាប់ក្នុងរយៈពេលថ្មីៗនេះ គេនៅតែអាចចោទសួរបានអំពីថាតើការកាប់ឈើយ៉ាងច្រើនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ បានបង្កើនអត្រាកកល្បាប់ដល់កំរិតដែលគំរាមកំហែងដល់អត្ថិភាពនៃបឹងទន្លេសាបក្នុងអនាគតយូរអង្វែងឬទេ ។

### ៣.៨.៣. គំរោងហេដ្ឋារចនាសម្ព័ន្ធ អាចប៉ះពាល់ដល់បំលាស់ទី, ជំរក, និងផលិតផលត្រី

គំរោងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ទំនប់ ផ្លូវថ្នល់ និងលូផ្លូវទឹក អាចធ្វើឱ្យប៉ះពាល់ជាដុំកំភួនដល់ផលិតផលត្រី តាមរយៈការរាំងស្ទះបំលាស់ទីត្រី កាត់បន្ថយគុណភាពទឹក និងកាត់បន្ថយទំហំឬគុណភាពនៃជំរកត្រី ។ ជាពិសេសគំរោងសង់ទំនប់អាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជលផល និងគុណភាពទឹកជាទូទៅ ។ ឧទាហរណ៍ ការសាងសង់ទំនប់ទឹកធ្លាក់យ៉ាលី នៅវៀតណាមចំងាយតែ ៧០គ.ម ពីព្រំប្រទល់កម្ពុជា បានជះឥទ្ធិពលធំសំបើមមកលើជីវភាពប្រជាជនប្រហែល ២០.០០០នាក់ ដែលរស់នៅខាងក្រោមទំនប់ ។ ក្រៅពីទឹកជំនន់ពីការបើកទំនប់នេះ អ្នកភូមិរាយការណ៍ថា គុណភាពទឹក និងផលត្រី បានថយចុះយ៉ាងធ្ងន់ធ្ងរ (Ratanakiri Provincial Fisheries Office 2000, McKenney 2001) ។

ទំនប់នៅក្នុងអាងទន្លេមេគង្គ ក៏អាចប៉ះពាល់ដល់ចរន្តទឹកស្ទឹង-អូរតាមរដូវកាល ពីព្រោះវាធ្វើឱ្យលំហូរទឹកថយចុះនៅក្នុងរដូវវស្សា និងបង្កើនលំហូរទឹកក្នុងរដូវប្រាំង ។ លទ្ធភាពគ្រប់គ្រងទឹកជំនន់នេះគេតែងលើកជារឿយៗថា ជាអត្ថប្រយោជន៍នៃទំនប់ទឹក ប៉ុន្តែនៅក្នុងតំបន់ដូចជាអាងទន្លេមេគង្គដែលផលិតភាពនៃកសិកម្ម និងជលផល ពឹងផ្អែកយ៉ាងខ្លាំងទៅលើទឹកជំនន់តាមរដូវ ការប្រែប្រួលជាដុំកំភួននៅក្នុងរបបទឹកជំនន់អាចបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។ ផលិតភាពត្រីនៅកម្ពុជា មានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកំរិត និងរយៈពេលនៃទឹកជំនន់នៅរដូវវស្សា ដែលជាចំបងបណ្តាលមកពីទឹកនៅក្នុងទន្លេមេគង្គឡើងខ្ពស់ (Van Zalinge *et al.* 2000) ។ នៅពេលដែលទឹកឡើងក្នុងទន្លេមេគង្គមានកំរិតទាបជាងធម្មតា ការលិចទឹកនៅក្នុងតំបន់វាលទំនាបដែលផ្តល់ប្រយោជន៍ដល់ជលផលក៏មានកំរិតទាបដែរ ។ ចាប់តាំងពីទសវត្ស១៩៥០មក ទំនប់តូចធំរាប់ពាន់ត្រូវបានកសាងនៅក្នុងអាងទន្លេមេគង្គសំរាប់ការស្រោចស្រព ការគ្រប់គ្រងទឹកជំនន់ វារីអគ្គិសនី និងគោលដៅផ្សេងទៀត ។ គំរោងគ្រប់គ្រងទឹកទាំងនេះ បានកាត់ផ្តាច់ជាកង់ៗនូវជំរកវារីសាស្ត្រ បិទច្រកតំបន់បំលាស់ទីត្រីនិងតំបន់ត្រីពង និងកាត់បន្ថយគុណភាព

និងបរិមាណទឹក (Coates 2001) ។ គេបានប៉ាន់ស្មានថា លំហូរទឹកទន្លេមេគង្គក្នុងរដូវវស្សាបានថយចុះប្រហែល ១២-១៥% ក្នុងកំលុងទសវត្សរ៍១៩៨០ និង ១៩៩០ (Nam 2000, Van Zalinge *et al.* 2000) ។ គំរោងគ្រប់គ្រងទឹកទំនងជាមូលហេតុចំបង ដែលធ្វើឱ្យលំហូរទឹកថយចុះ ពីព្រោះគេយល់ថាការប្រែប្រួលអាកាសធាតុមិនមែនជាមូលហេតុទេ ។

ការសិក្សាដោយ MRC បង្ហាញថា ការអនុវត្តន៍គំរោងគ្រប់គ្រងទឹកដែលគេបានស្នើឡើងសំរាប់ពេលអនាគតអាចកាត់បន្ថយលំហូរទឹកទន្លេនៅភ្នំពេញអស់ ១៥% ថែមទៀត ព្រមទាំងកាត់បន្ថយលំហូរទឹកនៅរដូវវស្សាពីទន្លេសាប ចូលក្នុងបឹងទន្លេសាបថយអស់ ២០% (Van Zalinge *et al.* 2000) ។ ផ្ទៃដីលិចទឹកជារៀងរាល់ឆ្នាំប្រមាណ ២៨០.០០០ហិកតានៅជុំវិញបឹងទន្លេសាបនឹងមិនត្រូវបានជន់លិចទៀតឡើយ ។ ការសិក្សាបានចង្អុលបង្ហាញទៀតថា ទឹកជំនន់លើដីសើមនៅភាគឦសាននៃប្រទេសកម្ពុជា នឹងថយចុះគួរកត់សំគាល់ ។ ការបាត់បង់ជំរកត្រីច្រើនបែបនេះ នឹងមានផលប៉ះពាល់ទៅលើផលិតភាពជលផល ។

## ៣.៩. បញ្ហាទីផ្សារ ពាណិជ្ជកម្ម និងការនាំចេញត្រី

ភាគច្រើននៃផលនេសាទទឹកសាបនៅកម្ពុជា ត្រូវបានបរិភោគនៅក្នុងស្រុក ជាត្រីស្រស់ ឬផលិតផលកែច្នៃ ដូចជាត្រីងៀត ផ្អក ប្រហុក និងទឹកត្រី ។ ជាទូទៅ ត្រីត្រូវបានកែច្នៃ និងថែរក្សាទុក ដោយប្រើបច្ចេកទេសប្រពៃណី ដូចជា ហាលថ្ងៃ ប្រឡាក់អំបិលហាល ឆ្អើរ និងចំហុយ ។ ការកែច្នៃភាគច្រើនធ្វើឡើងក្នុងកំលុងរដូវសំបូរត្រីបំផុត (ខែធ្នូ ដល់ កុម្ភៈ) នៅពេលអ្នកនេសាទចាប់បានត្រីតូចៗយ៉ាងច្រើន (Nao and Ly 1997) ។

ការនាំត្រីចេញពីប្រទេសកម្ពុជា តំណាងឱ្យតែមួយភាគតូចនៃផលនេសាទសរុបប្រចាំឆ្នាំប៉ុណ្ណោះ ។ ក្រសួងពាណិជ្ជកម្ម (២០០១) បានប៉ាន់ស្មានថា មានត្រីទឹកសាប និងត្រីទឹកប្រៃ ពី ៣០.០០០-១០០.០០០តោន ត្រូវបាននាំចេញនៅឆ្នាំ១៩៩៨ ។ ក្នុងនេះមានប្រហែល ៧៥% នាំចេញទៅប្រទេសថៃ ហើយភាគច្រើននៃត្រីនៅសល់ គេនាំចេញទៅប្រទេសវៀតណាម ។ ថៃ និងវៀតណាម ទំនងជាធ្វើការកែច្នៃ ត្រីស្រស់ទាំងនេះសំរាប់ទីផ្សារនៅក្រុងបាងកក ហុងកុង ម៉ាឡេស៊ី សិង្ហបុរី អឺរ៉ុប និង សហរដ្ឋអាមេរិក ។ ជាការច្បាស់លាស់ណាស់ បើសិនជាកម្ពុជាមានសមត្ថភាពនាំចេញផ្ទាល់ទៅទីផ្សារអ្នកមានទាំងនេះ វិស័យជលផលនឹងទទួលបានផលចំណេញយ៉ាងច្រើនថែមទៀត ។

អន្តរាគមន៍ផ្សេងៗរបស់រដ្ឋាភិបាល និងរបៀបរបបរកស៊ីដោយគ្មានការប្រកួតប្រជែង បានដាក់កំហិតទៅលើសកម្មភាពពាណិជ្ជកម្ម និងការនាំចេញ គឺមានដូចជា ការបង់ពន្ធ, ការបង់ប្រាក់កំរៃតាមផ្លូវការ និងក្រៅផ្លូវការ, របាំងផ្លូវការ និងមិនផ្លូវការ, ចំពោះការចូលធ្វើជំនួញ និងការនាំចេញ (ឧទាហរណ៍ ការតំរូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ និងការស៊ុំគ្រំលំផ្តាមិនប្រកួតប្រជែង) ។ ដោយសារឧបសគ្គរាំងស្ទះទាំងនេះ អ្នកនេសាទ និងអ្នកកែច្នៃត្រី អាចចូលចិត្តលក់ចេញនៅទីផ្សារក្នុងស្រុក ជាជាងខិតខំនាំចេញទៅក្រៅប្រទេសដែលអាចបានថ្លៃខ្ពស់ជាង (Csavas 1994, Ministry of Commerce 2001) ។

ក្រុមហ៊ុនទីហ័រណអាហ័រណត្រីនៅកម្ពុជា (KAMFIMEX) ទំនងជាដើរតួនាទីខ្លាំងជាងគេបំផុតនៅក្នុងការរារាំងពាណិជ្ជកម្ម និងនាំចេញត្រី ។ KAMFIMEX គឺជាសហគ្រាសរដ្ឋគ្រប់គ្រងដោយក្រសួងកសិកម្ម ដែលទទួលបានសិទ្ធិអំណាចផ្តាច់មុខក្នុងការគ្រប់គ្រងការនាំចេញត្រី ។ ការិយាល័យ KAMFIMEX មានទីតាំងនៅចំណុចនាំចេញជាផ្លូវការនៅភាគពាយ័ព្យ (ច្រកទៅថៃ) និងភាគអគ្នេយ៍ (ទៅវៀតណាម) នៅកំពង់ផែកំពង់សោម និងនៅអាកាសយានដ្ឋានពោធិចិនតុង (Ministry of Commerce 2001) ។ អ្នកនាំចេញត្រូវតែលក់ផលិតផលត្រីទាំងអស់ឱ្យ KAMFIMEX គ្មានមធ្យោបាយស្របច្បាប់ណាផ្សេងទៀតដើម្បីនាំចេញឡើយ ។ តួនាទីផ្តាច់មុខនេះ ផ្តល់ឱ្យ KAMFIMEX នូវសិទ្ធិអំណាចកំនត់ថ្លៃទិញដោយខ្លួនឯងផ្ទាល់ ។ ដោយសារមានប្រព័ន្ធនាំចេញបែបនេះ ដូច្នេះគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលប្រហែលពាក់កណ្តាលនៃការនាំត្រីចេញពីកម្ពុជា គឺជាការរត់ពន្ធដោយខុសច្បាប់ ។ ក្រសួងពាណិជ្ជកម្ម (២០០១) បានកត់សំគាល់ពីវិធីមួយចំនួនផ្សេងទៀតដែល KAMFIMEX បានរារាំងដល់

ពាណិជ្ជកម្ម និងការនាំចេញ គឺមាន :

- **ការអនុញ្ញាតឱ្យអ្នកចែកចាយប្រមូលប្រាក់កំរៃ ៤% នៃថ្លៃត្រីក្រោយពេលចាប់បានក្នុងខេត្តនិមួយៗ:** KAMFIMEX ជាអ្នកមានអនុញ្ញាតការលក់អាជ្ញាប័ណ្ណចែកចាយមួយមានរយៈពេល៥ឆ្នាំសំរាប់ខេត្តនិមួយៗ ។ គេរាយការណ៍ថា អាជ្ញាប័ណ្ណមួយថ្លៃរហូតដល់ ៥០.០០០ដុល្លារ ។ អាជ្ញាប័ណ្ណនេះប្រគល់សិទ្ធិឱ្យអ្នកចែកចាយបង្កើតការិយាល័យ និង ប្រមូលកំរៃ ៤% លើត្រីដែលនាំចេញតាមរយៈខេត្តនោះ ។ គ្មានការផ្តល់សេវាអ្វីទាំងអស់ជាថ្នូរនឹងការយកកំរៃនេះ ។
- **ការយកកំរៃនាំចេញត្រីនៅកំពង់ផែកំពង់សោម និងអាកាសយានដ្ឋានពោធិចិនតុង:** KAMFIMEX ប្រមូលកំរៃ អាជ្ញាប័ណ្ណនាំចេញ ១ដុល្លារក្នុងត្រីមួយគីឡូក្រាម ។
- **ការត្រួតពិនិត្យការកែច្នៃត្រីជាលក្ខណៈពាណិជ្ជកម្ម:** KAMFIMEX កាន់កាប់ ៤សហគ្រាសកែច្នៃដែលបានជួលទៅឱ្យ វិស័យឯកជនគឺ ១នៅភ្នំពេញ និង ៣ទៀតនៅកំពង់សោម ។ គ្មានឧបករណ៍កែច្នៃត្រីខ្នាតធំនៅជិតបឹងទន្លេសាបទេ ។

ក្រៅពីអប្រសិទ្ធិភាពនៅក្នុងពាណិជ្ជកម្ម និងការនាំចេញ ដែលជាប់ទាក់ទងនឹង KAMFIMEX, ក្រសួងពាណិជ្ជកម្ម (២០០១) បានធ្វើការកត់សំគាល់នូវការយកកំរៃ និងឧបសគ្គមួយចំនួនទៀត ចំពោះការធ្វើពាណិជ្ជកម្ម ជាអាទិ៍:

- **ពន្ធ ១០% លើការនាំត្រីចេញត្រីគ្រប់ប្រភេទ:** ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយកដ្ឋានជលផលមាន ភារកិច្ចធានាប្រមូលឱ្យបាននូវពន្ធនាំចេញនេះ ។ កម្ពុជាគឺជាប្រទេសតែមួយគត់នៅក្នុងតំបន់ ដែលយកពន្ធលើការ នាំចេញផលិតផលត្រី ។
- **ការបង់កំរៃលើការចុះបញ្ជីលើការដឹកជញ្ជូន កុងត្រូលតាមផ្លូវ និងកំរៃនាំចេញ:** អ្នកដឹកជញ្ជូនត្រីត្រូវចំណាយលើ ការចុះបញ្ជីនៅនាយកដ្ឋានជលផល និងបង់កំរៃក្រៅផ្លូវការនៅតាមកុងត្រូលមួយចំនួនពីកន្លែងចាប់ត្រីរហូតដល់ ព្រំដែន ។ អាជ្ញាធរព្រំដែនកំណត់កំរៃបន្ថែមប្រហែល ២៥ដុល្លារក្នុងត្រីមួយតោនទើបអនុញ្ញាតនាំត្រីឆ្លងដែនទៅ ទីផ្សារអារ៉ានីយ៉ាផាថេត នៅប្រទេសថៃ ។
- **អត្រាខូចខាតមានកំរិតខ្ពស់:** ភាគច្រើននៃត្រីភាគនាំចេញទៅថៃ គេដឹកតាមឡាន ដោយដាក់គរវាជាមួយនឹង ទឹកកក ។ ត្រីរហូតដល់ ៥០% ត្រូវខូចខាតមុនទៅដល់គោលដៅ ដោយសារសំភារៈស្តុកត្រីមានលក្ខណៈអន់ថយ ផ្លូវ ថ្នល់ពិបាកខ្លាំង និងការយឺតយ៉ាវដោយសារការយក ពន្ធក្រៅផ្លូវការតាមផ្លូវ និងកំរៃអាជ្ញាប័ណ្ណ ។ គ្រោះថ្នាក់ទាក់ ទិននឹងត្រីចុះអន់សាច់ជាបណ្តើរៗ គឺកាត់បន្ថយនូវលទ្ធភាពតថ្លៃរបស់អ្នកដឹកជញ្ជូនក្នុងការចរចាលើការបង់កំរៃតាម កុងត្រូល និងការចរចាលើថ្លៃលក់ចេញ ។

## ៣.១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ

កំណើននៃតំរូវការធ្វើនេសាទ គួបផ្សំនឹងរបៀបនេសាទបែបបំផ្លិចបំផ្លាញ និងការខូចខាត ឬការបាត់បង់ជំរកត្រី បាន គំរាមកំហែងចំពោះចីរភាពនៃវិស័យជលផលនៅក្នុងប្រទេសកម្ពុជា ។ ការបន្តទង្វើបែបនេះ អាចគំរាមកំហែងដល់សន្តិសុខ ស្បៀង និងចំណូលរបស់ប្រជាជនកម្ពុជា ជាងមួយលាននាក់ដែលរស់នៅដោយពឹងផ្អែកទៅលើវិស័យជលផល ។ ការប៉ាន់ស្មាន អំពីកំណើនប្រជាជន បានបង្ហាញកំណើនគួរឱ្យកត់សំគាល់នូវចំនួនយុវជននៅតាមជនបទ ដែលត្រូវចូលទៅក្នុងកំលាំងពលកម្ម នាពេលអនាគត ហើយរឿងនេះប្រហែលជានឹងធ្វើឱ្យវិស័យជលផលកាន់តែរងសម្ពាធយ៉ាប់យ៉ឺនខ្លាំងថែមទៀត ។ យុវជនជាច្រើន នឹងរកចិញ្ចឹមជីវិត ឬរកចំណូលបន្ថែម តាមរយៈការនេសាទជីវព្រឹត្តិ (ជាលក្ខណៈគ្រួសារ) ពីព្រោះវាមានឧបសគ្គតិចតួច ដោយ សារពួកគេមិនចាំបាច់មានដី ឬទុនវិនិយោគច្រើនទេ ។ ដូច្នេះដើម្បីធានាឱ្យជលផល និងជីវភាពប្រជាជនមានចីរភាព គេត្រូវ

កែលំអកត្តាជាច្រើន ជាអាទិ៍ :

- ការដាក់អនុវត្តន៍វិធានការណ៍មួយចំនួនដើម្បីកាត់បន្ថយ ការនេសាទខុសច្បាប់ និងការបាត់បង់ព្រៃលិចទឹក ។
- កំណែទំរង់ការគ្រប់គ្រង ដើម្បីដោះស្រាយឱ្យបានសមស្របនូវបញ្ហា តំបន់ដែលប្រជាជនអាចនេសាទបាន សិទ្ធិធ្វើនេសាទរបស់អ្នកនេសាទខ្នាតតូច និងចីរភាពនៃការនេសាទ ។
- ការធ្វើផែនការអភិវឌ្ឍន៍ ដោយពិចារណាពីផលប៉ះពាល់ចំពោះជលផលដែលកើតចេញពីវិស័យនានា ដូចជា កសិកម្ម និងរុក្ខវប្បកម្ម និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។

ការធ្វើគោលនយោបាយសំរាប់វិស័យជលផលឱ្យបានត្រឹមត្រូវ ត្រូវឱ្យមានទិន្នន័យ និងពត៌មានជាច្រើន ដែលភាគច្រើនមិនទាន់មាននៅឡើយ ។ ឧទាហរណ៍ គេមានពត៌មានតិចតួចណាស់ពីស្ថានភាពនៃស្តុកត្រីក្នុងទឹក, បំរែបំរួលផលនេសាទ និងប្រភេទត្រីពីមួយឆ្នាំទៅមួយឆ្នាំ, បរិមាណចាប់ត្រីមានចីរភាពនៅក្នុងបឹងទន្លេសាប, បំរែបំរួលខាងធារាសាស្ត្រ ទឹកជំនន់ និងការកករងដុះល្បាប់ និងលំនាំ បំលាស់ទី/ការពងកូនរបស់ត្រី ។ ដើម្បីបង្កើនពត៌មានលើវិស័យទាំងនេះ ត្រូវមានការសិក្សាផ្នែកវិទ្យាសាស្ត្រធារាសាស្ត្រ និងជីវសាស្ត្រ ហើយក្នុងនេះ MRC និងនាយកដ្ឋានជលផល ក៏អនុវត្តបានមួយចំនួនដែរហើយ (Nao and Van Zalinge 2000) ។

ក្រៅពីការសិក្សាបែបវិទ្យាសាស្ត្រដូចខាងលើ ត្រូវធ្វើការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ច អំពីទំនាក់ទំនងរវាងធនធានត្រី និងជីវភាពជនបទឱ្យបានច្រើនថែមទៀត ។ សព្វថ្ងៃមានការទទួលស្គាល់ជាទូទៅថា ប្រជាជននៅជនបទជាច្រើន មានជីវភាពពឹងផ្អែកតែទៅលើវិស័យជលផល ប៉ុន្តែនៅមានសំនួរធំៗមួយចំនួនទៀតដូចជា តើត្រូវគ្រប់គ្រងធនធានជលផលយ៉ាងដូចម្តេច ដើម្បីបំរើគោលដៅខាងអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្របានប្រសើរបំផុត ។ ដើម្បីឆ្លើយតបនឹងសំនួរទាំងនេះ គេគួរ ធ្វើការស្រាវជ្រាវខាងសេដ្ឋកិច្ច-សង្គមកិច្ចមួយចំនួនក្នុងពេលអនាគត ដូចជា:

## ១. តើប្រព័ន្ធគ្រប់គ្រងឡូត៍នេសាទមានប្រសិទ្ធិភាពប៉ុណ្ណា ក្នុងការសំរេចគោលដៅនៃការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

ទោះបីជាកំណែទំរង់បច្ចុប្បន្នបានកាត់បន្ថយឡូត៍នេសាទអស់ពាក់កណ្តាលហើយក៏ដោយ គេក៏នៅតែត្រូវការវិធីសាស្ត្រសំរាប់គ្រប់គ្រងផ្ទៃនេសាទជាង ៤០០.០០០ហិកតាទៀតដែលជាតំបន់មានផលិតភាពនេសាទខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ។ ក្នុងនេះគេរំពឹងថា ការជួលឡូត៍នេសាទនឹងអាចជួយឱ្យសំរេចបាននូវគោលដៅមួយចំនួនដូចជា :

- គ្រប់គ្រងជលផលឱ្យមានចីរភាព ដើម្បីធានាថាអ្នកជំនាន់ក្រោយបន្តទទួលបានអត្ថប្រយោជន៍ពីធនធានជលផល ។
- បង្កើនចំនួលថវិការដ្ឋតាមការជួលឡូត៍នេសាទ និងកំរៃផ្សេងទៀត ។ ជាការប្រសើរថវិកាទាំងនេះគួរជួយឧបត្ថម្ភដល់ការអភិវឌ្ឍន៍ជនបទ និងគំរោងកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ដែលទទួលឥទ្ធិពលអាក្រក់ពីឡូត៍នេសាទ ។
- បង្កើតការងារ និងធ្វើអភិវឌ្ឍន៍ជនបទនៅក្នុងតំបន់នោះ ។ ឧទាហរណ៍ ឡូត៍នេសាទអាចជួយដល់ពាណិជ្ជកម្មកែច្នៃ និងសហគ្រាសជាប់ទាក់ទិន ដែលផ្តល់ការងារឱ្យប្រជាជនរស់នៅក្នុង ឬនៅក្បែរឡូត៍នេសាទ ។

ការគ្រប់គ្រងឡូត៍នេសាទ និងបញ្ហាចីរភាព គឺជាចំណុចផ្តោតនៃករណីសិក្សាជាច្រើនក្នុងពេលកន្លងមក ប៉ុន្តែគេពុំសូវបានយកចិត្តទុកដាក់ទេពីតួនាទីឡូត៍នេសាទក្នុងការបំរើគោលដៅនៃការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ សំណួរដែលអាចយកទៅធ្វើការសិក្សាស្រាវជ្រាវមានជាអាទិ៍ :

- តើចំណូលថវិកាប៉ុន្មាន (ផ្លូវការ និងក្រៅផ្លូវការ) ដែលរដ្ឋទទួលបានពីការជួលឡូត៍នេសាទ និងពីកំរៃផ្សេងៗខាងជលផល និងតើគេប្រើប្រាស់ថវិកានេះយ៉ាងដូចម្តេចដើម្បីបំរើគោលដៅអភិវឌ្ឍន៍ជនបទ ?

- តើឡូត៍នេសាទផ្តល់អត្ថប្រយោជន៍អ្វីខ្លះទៀតដល់ការអភិវឌ្ឍន៍ជនបទ ដូចជា ផ្តល់ការងារក្នុងកិច្ចដំណើរការឡូត៍នេសាទ និង/ឬ ក្នុងការកែច្នៃនិងបញ្ជូនលក់ទៅទីផ្សារ?
- យោងតាមគោលដៅរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ តើគេគួរមានមូលដ្ឋាន ឬលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីសំរេចថាត្រូវរក្សាទុកឡូត៍នេសាទ ឬត្រូវលុបចោលដើម្បីប្តូរប្រភេទនៃការគ្រប់គ្រង?
- តើឡូត៍នេសាទមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើលទ្ធភាពនេសាទ សន្តិសុខស្បៀង និងចំណូលទ្រទ្រង់ជីវភាពរបស់ប្រជាជននៅជនបទកម្ពុជា?

## ២. តើមានបន្ទុកចំណាយ និងអត្ថប្រយោជន៍អ្វីខ្លះ ក្នុងការបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ?

អង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍នេសាទ ហើយក្នុងពេលថ្មីៗ នាយកដ្ឋានជលផលក៏បានខិតខំធ្វើដូច្នេះដែរ ។ ការបង្កើតសហគមន៍នេសាទ អាចជាការងារមួយដ៏ធំ និងមានការចំណាយយ៉ាងច្រើន ។ ចំណាយទាំងនេះរួមមាន សកម្មភាពរៀបចំសហគមន៍ ការចរចាជាមួយអ្នកនេសាទខ្នាតតូច អាជ្ញាធរដែនដី និងអ្នកជាប់ពាក់ព័ន្ធផ្សេងទៀត, ការកសាងផែនការនិងបទបញ្ជានៃការគ្រប់គ្រង, ការតាមដាននិងពង្រឹងការអនុវត្តន៍, ហើយនិងការដោះស្រាយទំនាស់ ។ ដូច្នេះជោគជ័យនៃការបង្កើតសហគមន៍នេសាទ នឹងអាស្រ័យលើការបន្ទាបចំណាយនៅពេលចាប់ផ្តើម និងចំណាយគ្រប់គ្រង និងលើការបង្កើនសក្តានុពលមានផលចំណេញ ។

ជាការច្បាស់ណាស់ សក្តានុពលនៃផលចំណេញរបស់សហគមន៍នេសាទ មានចំណងទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងផលិតភាពនៃតំបន់នេសាទ ។ NGO Forum (2001) បានលើកថា ក្នុងចំណោមឡូត៍នេសាទទើបរំសាយក្នុងពេលថ្មីៗ ពុំមានដាក់បញ្ចូលតំបន់សំបូរត្រីដែលអ្នកនេសាទក្នុងស្រុកតែងតែនេសាទជាយូរមកហើយនោះទេ ។ បើសិនជា តំបន់សំបូរត្រីភាគច្រើននៅតែរក្សាទុកជាឡូត៍នេសាទ ហើយតំបន់មិនសូវសំបូរត្រី ត្រូវបានជ្រើសរើសជាសហគមន៍នេសាទ ពួកអ្នកជាប់ពាក់ព័ន្ធនានានឹងមានទឹកចិត្តតិចតួចក្នុងការវិនិយោគពេលវេលា និងកំលាំងប្រឹងប្រែង ដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ។ សំនួរជាគន្លឹះមួយចំនួនសំរាប់ស្រាវជ្រាវមានជាអាទិ៍ :

- តើសហគមន៍នេសាទមានប្រវត្តិផលិតភាពនេសាទយ៉ាងដូចម្តេច? តើផលិតភាពនេះល្អប៉ុណ្ណា បើធៀបនឹងតំបន់ជិតខាង? តើការបង្កើតសហគមន៍នេសាទ មានផលប៉ះពាល់អ្វីខ្លះ? តើត្រូវធ្វើដូចម្តេចដើម្បីបង្កើនសក្តានុពលនៃផលចំណេញរបស់សហគមន៍នេសាទ?
- តើចំណាយទាក់ទិននឹងការចាប់ផ្តើម និងកិច្ចដំណើរការនៃការគ្រប់គ្រងសហគមន៍នេសាទមានទំហំប៉ុណ្ណា? តើត្រូវធ្វើដូចម្តេចដើម្បីកាត់បន្ថយចំណាយនេះ?
- តើមានមេរៀនអ្វីខ្លះ ដែលអាចដកស្រង់ពីបទពិសោធន៍នៃការចាប់ផ្តើមធ្វើសហគមន៍នេសាទ ហើយដែលអាចយកទៅអនុវត្តបាននៅពេលអនាគត ។

## ៣. តើមានបំរែបំរួលអ្វីខ្លះនៅក្នុងតំបន់ដែលជាឡូត៍នេសាទចាស់ ហើយតើវាបានប៉ះពាល់អ្វីខ្លះដល់ជីវភាពជនបទ? តើសហគមន៍នេសាទមានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការគ្រប់គ្រងតំបន់ជាអតីតឡូត៍នេសាទ

យោងតាមបទបញ្ជាពីនាយករដ្ឋមន្ត្រីនៅចុងឆ្នាំ២០០១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរំសាយប្រហែល ៥៦%នៃតំបន់ឡូត៍នេសាទ ដើម្បីបើកឱ្យប្រើប្រាស់ជាសាធារណៈ ។ នាយកដ្ឋានជលផល បានរាយការណ៍កាលពីនៅដើមឆ្នាំ ២០០១ ថា នាយកដ្ឋានបង្កើតបាន ១៧០សហគមន៍នេសាទ និងគ្រោងបង្កើនថែមប៉ុណ្ណេះទៀតក្នុងរយៈមួយឆ្នាំខាងមុខ (MAFF 2002) ។ មកដល់ពេលនេះ មានពតិមានតិចតួចណាស់ពីសហគមន៍នេសាទទាំង១៧០ ឬពីអ្វីដែលកំពុងកើតមានជាក់ស្តែងនៅ

តាមតំបន់ជាអតីតឡូត៍នេសាទ ។ កំណែទំរង់សព្វថ្ងៃដែលផ្តោតលើការធ្វើវិមជ្ឈការនៃគ្រប់គ្រងជលផល បានផ្តល់ឱកាសល្អសំរាប់ ការកែលំអជីវភាពនៅជនបទ តាមរយៈការចែកចាយផលចំណេញនៃការនេសាទបានស្មើភាពជាងមុន ។ ការស្រាវជ្រាវសំរាប់ ជួយទ្រទ្រង់ដល់ការប្រឹងប្រែងធ្វើកំណែទំរង់ អាចផ្តោតលើសំនួរមួយចំនួនដូចតទៅ:

- នៅក្នុងតំបន់ដែលមានការរំសាយឡូត៍នេសាទ តើគេប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងបែបណា ដើម្បីជំនួសរបបឡូត៍នេសាទវិញ? តើមានការប្រែប្រួលអ្វីខ្លះចំពោះប្រជាជនដែលដឹកសិកម្ម ឬផ្ទះរបស់ពួកគេ លែងស្ថិតនៅក្នុងឡូត៍នេសាទទៀត? តើការគ្រប់គ្រងទឹកមានការប្រែប្រួលយ៉ាងដូចម្តេច? តើការគ្រប់គ្រងព្រៃលិចទឹកមានការប្រែប្រួលយ៉ាងដូចម្តេច?
- តើនាយដ្ឋានជលផលបានដំណើរយ៉ាងដូចម្តេចក្នុងការបង្កើតសហគមន៍នេសាទទាំង ១៧០? អ្នកណាខ្លះចូលរួមក្នុងដំណើរការនេះ? តើសហគមន៍នេសាទទាំង១៧០ ដែលបង្កើតឡើងដោយនាយកដ្ឋានជលផលស្ថិតក្នុងតំបន់ណាខ្លះ ហើយការគ្រប់គ្រងមានការប្រែប្រួលយ៉ាងដូចម្តេចនៅក្នុងតំបន់ទាំងនោះ? ឧទាហរណ៍ តើតំបន់នេសាទនៅក្នុងសហគមន៍នេសាទត្រូវបានជួលបន្តឱ្យគេឬយ៉ាងណា? តើមានការចាត់ចែងយ៉ាងដូចម្តេចនៅក្នុងការជួលបន្តឱ្យគេ ហើយសមាជិកសហគមន៍មានសិទ្ធិនេសាទយ៉ាងដូចម្តេចខ្លះ ? តើរដ្ឋអំណាចមូលដ្ឋានមានតួនាទីដូចម្តេច? តើគេត្រូវតាមដាន និងដាក់អនុវត្តវិធានគ្រប់គ្រងយ៉ាងដូចម្តេច? តើគេដោះស្រាយទំនាស់ដោយវិធីណា?

## ៤. តើការនេសាទតាមវាលស្រែមានសារៈសំខាន់ដូចម្តេចខ្លះចំពោះជីវភាពជនបទ ហើយវាមានផលប៉ះពាល់យ៉ាងដូចម្តេចចំពោះការអភិវឌ្ឍន៍កសិកម្ម និងការនេសាទ?

យោងតាមតួលេខប៉ាន់ស្មាននៃការនេសាទប្រចាំឆ្នាំ ការនេសាទតាមវាលស្រែតំណាងឱ្យប្រហែល ២០% នៃផលនេសាទត្រីទឹកសាបសរុប ។ ប៉ុន្តែការប៉ាន់ស្មាននេះផ្អែកលើតែការសិក្សាតាមភូមិមួយចំនួនតូចដែលមិនអាចតំណាងឱ្យការនេសាទតាមវាលស្រែក្នុងទូទាំងប្រទេសឡើយ ។ គេត្រូវមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីកំណត់ឱ្យច្បាស់អំពីសារៈសំខាន់នៃការនេសាទតាមវាលស្រែចំពោះជីវភាពនៅជនបទ ។ សំនួរសំខាន់ៗសំរាប់ការស្រាវជ្រាវមានជាអាទិ៍:

- តើផលនេសាទពីវាលស្រែមានប៉ុន្មានជាមធ្យមក្នុងមួយឆ្នាំៗ នៅក្នុងភូមិគំរូតាងមួយចំនួនដែលអាចតំណាងឱ្យភូមិទូទៅនៅកម្ពុជា? តើផលិតភាពបានប្រែប្រួលដូចម្តេចខ្លះពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងការនេសាទតាមវាលស្រែ?
- តើការពង្រីកកសិកម្ម ការធ្វើប្រពលវប្បកម្ម និងការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត មានផលប៉ះពាល់ដូចម្តេចខ្លះចំពោះផលិតភាពនៃការនេសាទតាមវាលស្រែ?
- តើគេអាចចាត់វិធានការណ៍អ្វីខ្លះ ដើម្បីធានាឱ្យកសិករទទួលបានផលចំណេញខ្ពស់បំផុតពីកសិកម្ម និងការនេសាទតាមវាលស្រែ?

## ៥. តើទំនាស់អំពីតំបន់នេសាទត្រូវបានដោះស្រាយយ៉ាងដូចម្តេចក្នុងពេលបច្ចុប្បន្ន និង តើគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

ទោះបីកំណែទំរង់ជលផលក្នុងពេលថ្មីៗអាចជួយកាត់បន្ថយទំនាស់អំពីតំបន់នេសាទក៏ដោយ ក៏គេនៅតែត្រូវការយ៉ាងខ្លាំងនូវដំណើរការដ៏ត្រឹមត្រូវមួយសំរាប់ដោះស្រាយទំនាស់ជលផល ។ មានពត៌មានតិចតួចណាស់ស្តីពីរបៀបរបបដោះស្រាយទំនាស់ក្នុងពេលបច្ចុប្បន្ន ។ ការស្រាវជ្រាវពីដំបូងៗនៅក្នុងរឿងនេះ អាចធ្វើការវាយតំលៃលើចំណុចមួយចំនួនដូចខាងក្រោម:

- តើអ្វីទៅជាដំណើរការផ្លូវការក្នុងការដោះស្រាយទំនាស់ជលផល ដោយយោងទៅតាមច្បាប់ជលផល អនុក្រឹត្យ និងបទប្បញ្ញត្តិជាប់ទាក់ទិនផ្សេងៗទៀត? តើអ្នកណាខ្លះចូលរួម ហើយពួកគេមានតួនាទីដូចម្តេច?

- ក្នុងការអនុវត្តន៍ជាក់ស្តែង តើទំនាស់ជលផលច្រើនតែដោះស្រាយយ៉ាងដូចម្តេច?
- តើមានមេរៀន និងគំរូអ្វីខ្លះក្នុងការដោះស្រាយទំនាស់ជលផលដែលគេអាចរៀនសូត្របានពីបទពិសោធន៍នៅក្នុងប្រទេសឯទៀតៗ?
- តើមានវិធីណាដើម្បីកែលំអដំណើរការនៃការដោះស្រាយទំនាស់? ឧទាហរណ៍ តើក្រុមប្រឹក្សាឃុំដែលទើបជាប់ឆ្នោតថ្មីៗ មានតួនាទីសមស្របឬទេ នៅក្នុងការដោះស្រាយទំនាស់?

## ៦. តើការកែច្នៃត្រី សកម្មភាពពាណិជ្ជកម្ម និងការនាំចេញត្រី មានស្ថានភាពយ៉ាងដូចម្តេចក្នុងពេលបច្ចុប្បន្ន? តើគេធ្វើយ៉ាងណាដើម្បីអាចលើកកំពស់ជីវភាពជនបទ តាមរយៈការកែប្រែរបៀបរបបសព្វថ្ងៃក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ?

ក្រសួងពាណិជ្ជកម្ម (២០០១) គូសបញ្ជាក់នូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការកែច្នៃ ការធ្វើពាណិជ្ជកម្ម និងការនាំចេញត្រីរបស់កម្ពុជា ។ ការសិក្សានេះ បានកត់សំគាល់នូវតំរូវការកែលំអ ការកែច្នៃ និងការបញ្ចេញត្រីទៅទីផ្សារ ដើម្បីបង្កើនតំលៃបន្ថែមលើផលិតផលត្រី និងបង្កើនប្រាក់ចំណេញ ។ ការសិក្សាបានអំពាវនាវឱ្យមានការលើកកំពស់ពាណិជ្ជកម្ម និងការផ្សព្វផ្សាយជំរុញការនាំចេញត្រី ដើម្បីបង្កើនប្រាក់ចំណូលនៅក្នុងវិស័យជលផលផងដែរ ។

ក្រៅពីរបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម (២០០១) មានការសិក្សាតិចតួចណាស់ដែលពិភាក្សាអំពីស្ថានភាពនៃសកម្មភាពកែច្នៃ ពាណិជ្ជកម្ម និងនាំចេញត្រីរបស់កម្ពុជា ។ ដោយសារកម្ពុជាត្រូវបានគេប៉ាន់ស្មានថា មានផលិតភាពត្រីទឹកសាបខ្ពស់ជាងគេក្នុងលំដាប់ទីបួននៅក្នុងពិភពលោក ហើយត្រីគឺជាផលិតផលមានតំលៃខ្ពស់ ដូច្នេះការស្រាវជ្រាវបន្ថែមទៀតចំពោះសក្កានុពលនៃការកែច្នៃបង្កើនតំលៃបន្ថែម និងចំពោះការអនុវត្តន៍ដោយគ្មានការប្រកួតប្រជែងនៅក្នុងការគ្រប់គ្រងពាណិជ្ជកម្មត្រី គឺជាប្រការចាំបាច់មួយ ។ កំណើនការប្រកួតប្រជែងក្នុងចំណោមអ្នកជួញដូរ និងអ្នកនាំចេញត្រីក្នុងការទិញត្រី គួបផ្សំនឹងការផ្តល់ពត៌មានប្រសើរថែមទៀតពីថ្លៃទីផ្សារដល់អ្នកនេសាទនៅមូលដ្ឋាន ប្រហែលជាអាចជួយបង្កើនកំលាំងចរចារបស់អ្នកនេសាទនៅមូលដ្ឋានដោយធ្វើឱ្យពួកគេទទួលបានចំណេញកាន់តែច្រើនពីផលនេសាទ ។ លើសពីនេះទៀត វិស័យជលផលមានការប្រកួតប្រជែង នឹងផ្តល់ឱកាសថែមទៀតសំរាប់គំនិតច្នៃប្រឌិតធ្វើអាជីវកម្ម ការវិនិយោគ និងសហគ្រាសបង្កើតតំលៃបន្ថែមនៅកំរិតមូលដ្ឋាន ។ ការស្រាវជ្រាវបន្ថែមស្តីពីការកែច្នៃត្រី និងបញ្ហាពាណិជ្ជកម្ម អាចធ្វើឡើងដើម្បីដោះស្រាយសំនួរជាច្រើនដូចតទៅ:

- តើត្រីត្រូវបានគេលក់ដូរយ៉ាងដូចម្តេចមុននឹងនាំចេញ? តើការយកកំរៃជាផ្លូវការ និងក្រៅផ្លូវការ ដែលទាក់ទិននឹងពាណិជ្ជកម្មត្រីមានអ្វីខ្លះ? ក្នុងការអនុវត្តន៍ជាក់ស្តែង តើអ្នកចូលរួមនានានៅក្នុងពាណិជ្ជកម្មត្រី (អ្នកនេសាទ អ្នកទិញ ពាណិជ្ជករ អ្នកដឹកជញ្ជូន អ្នកនាំចេញ) មានកំរិតចំណេញប៉ុណ្ណា? តើកំរិតចំណេញទាំងនេះសមរម្យឬទេសំរាប់ផលិតផល ឬសេវារបស់ជននានាខាងលើដែលជាអ្នកចូលរួមក្នុងទីផ្សារត្រី?
- តើមានវិធានការណ៍អ្វីខ្លះដែលគេអាចដាក់អនុវត្ត ដូចជា ការបង្កើនការប្រកួតប្រជែងក្នុងចំណោមអ្នកទិញ និងការកែលំអលទ្ធភាពទទួលបានពត៌មានស្តីពីថ្លៃនៅទីផ្សារ និងអាចបង្កើនកំលាំងចរចារបស់អ្នកនេសាទខ្នាតតូចនៅក្នុងការលក់ដូរផលនេសាទរបស់ខ្លួន?
- តើប្រព័ន្ធគ្រប់គ្រងអ្នកចែកចាយមានគោលដៅយ៉ាងដូចម្តេច? តើមានសេវាអ្វីខ្លះដែលបានផ្តល់ជាថ្នូរនឹងការបង់កំរៃ ៤% ដោយអ្នកចែកចាយ? ហេតុអ្វីបានជាខេត្តមួយចំនួននៅជុំវិញបឹងទន្លេសាបមានអ្នកចែកចាយ ឯខេត្តមួយចំនួនទៀតគ្មានអ្នកចែកចាយ? ស្រដៀងគ្នាដែរ ហេតុអ្វីបានជា KAMFIMEX មានសិទ្ធិផ្តាច់មុខក្នុងការនាំចេញត្រី? តើ KAMFIMEX មានផ្តល់សេវាម៉ាឃីទីង និងសេវាចែកចាយអ្វីខ្លះ ជាថ្នូរនឹងប្រាក់កំរៃដែលខ្លួនបានប្រមូលយក?
- តើមានរបាំងផ្លូវការ និងក្រៅផ្លូវការអ្វីខ្លះ ចំពោះការចូលធ្វើជំនួញកែច្នៃត្រី និងការធ្វើពាណិជ្ជកម្មត្រី? នៅក្នុងការ

កែច្នៃ និងពាណិជ្ជកម្មត្រី តើមានចំណុចអ្វីខ្លះដែលគេអាចចាត់ទុកការត្រួតត្រាបែបផ្តាច់មុខ ឬស៊ុំគ្រលំគ្នា? តើសហគ្រិនតូចតាច និងសហគ្រាសបង្កើតតំលៃបន្ថែមនៅថ្នាក់មូលដ្ឋាន គេមានឱកាសល្អដូចម្តេចខ្លះ?

## ឯកសារយោង


Ahmed, M., N. Hap, V. Ly, and M. Tiongco (1998), *Socio-economic Assessment of Freshwater Capture Fisheries of Cambodia: Report on a Household Survey*, (Phnom Penh: Department of Fisheries, DANIDA, and Mekong River Commission)

Azimi, A., W. Knowland, J. Carew-Reid, I. Ruzicka, and A. Zola (2001), *Environments in Transition: Cambodia, Lao PDR, Thailand, Viet Nam,* (Manila: Asian Development Bank)

Bann, C. (1997), *An Economic Analysis of Alternative Mangrove Management Strategies in Koh Kong Province, Cambodia* (Singapore: Economy and Environment Program for SE Asia)

Bardach, J. (1959), *Report on Fisheries in Cambodia*, (Phnom Penh: USOM/Cambodia)

Cambodian People's Party (2001), "Fisheries Reform" in *The Pracheachun Magazine* (08/2001) available at http://www.cambodianpeopleparty.org/magazie.htm

Chaktomuk Project Management Unit (2000), *Chaktomuk Area: Environment, Hydraulics and Morphology Phase 1 Inception Report*, (Phnom Penh: Mekong River Commission Secretariat)

Chan, T., S. Kim, T. Em, S. Thay, and S.M. So (2001), "Changes in Fisheries Resources Use and Management in Lot No. 3 Peam Taour Village, Keo Por Commune, Pouk District, Siem Reap Province: A Case Study", in CBNRM Team, *CBNRM Lessons Shared: A Series of CBNRM Case Studies from the Tonle Sap, Siem Reap Province* (Phnom Penh: WWF Conservation Program in Cambodia)

Chea, V. (1999), "Fisheries activities in Stung Treng Province, Cambodia" in N. Van Zalinge, T. Nao, and L. Deap (eds.), *Present Status of Cambodia's Freshwater Capture Fisheries and Management Implications: Nine presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries, 19-21 January 1999* (Phnom Penh: Mekong River Commission/DANIDA) pp. 59-66

Chheng, V. (2000), "Evaluation of ex-fishing lot no. 5 after its abolishment in 1988, Siem Reap province, Cambodia" in Van Zalinge, N., T. Nao, and S. Lieng (eds.) *Management aspects of Cambodia's Freshwater Capture Fisheries: Eleven presentations given at the Annual Meeting of the Department of Fisheries of the Ministry of Agriculture, Forestry and Fisheries, 27-28 January 2000,* (Phnom Penh: Mekong River Commission and Department of Fisheries) pp. 129-134

Chheng, V. (1999), "Case study of fishing lot no. 3 in Siem Reap Province, Cambodia" in N. Van Zalinge, T. Nao, and L. Deap (eds.), *Present Status of Cambodia's Freshwater Capture Fisheries and Management Implications: Nine presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries, 19-21 January 1999* (Phnom Penh: Mekong River Commission/DANIDA) pp. 111-114

Coates, D. (2001), *Biodiversity and Fisheries Management Opportunities in the Mekong River Basin*, (Vientiane: Mekong River Commission Secretariat)

Csavas, I., D. J. Doulman, T. O. Petr, J. Prado, and L. Debas (1994), *Cambodia – Rehabilitation and development needs of the fishery sector*, (Rome: *FAO Fisheries Circular*, No. 873)

Deap, L. (1999), "The Bagnet (Dai) Fishery in the Tonle Sap River" in N. Van Zalinge, T. Nao, and L. Deap (eds.), *Present Status of Cambodia's Freshwater Capture Fisheries and Management Implications: Nine presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries, 19-21 January 1999* (Phnom Penh: Mekong River Commission/DANIDA) pp. 141-149

Degen, P., V. Ly, C.T. Prum, D. Yin, P. Chap, and S. Lieng (forthcoming), *(Draft) People,*

*Power and Fishery Policy: Fisheries Management Reform Addressing Community Fisheries in Cambodia*, (Phnom Penh: Department of Fisheries, Inland Fisheries Research Institute)

Degen, P. and T. Nao (2000), "Historical, cultural and legal perspectives on the fishing lot system in Cambodia", p. 49-60 in M. Ahmed and P. Hirsch (eds.), *Common property in the Mekong: issues of sustainability and subsistence*, (Manila: ICLARM Study Review 26)

Degen, P., F. Van Acker, N. van Zalinge, N. Thuok, and D. Loeung (2000), *Taken for granted: Conflicts over Cambodia's freshwater fish resources*, (Bloomington, Indiana: 8th IASCP Conference, 31 May to 4 June 2000)

Degen, P. and L. Mong (1999), "Socio-economic issues: fisheries research activities and 'awareness building'" in N. Van Zalinge, T. Nao, and L. Deap (eds.), *Present Status of Cambodia's Freshwater Capture Fisheries and Management Implications: Nine presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries, 19-21 January 1999* (Phnom Penh: Mekong River Commission/DANIDA) pp. 25-32

Degen, P. and T. Nao (1998), *Inland Fishery Management in Cambodia: Is the concept of community-based management appropriate for fishing lots?* (Vancouver, Canada: Mekong Panel at the Seventh Common Property Conference of the International Association for the Study of Common Property, 10-14 June 1998)

Department of Fisheries (2001a), *Draft Fisheries Law – 18 May 2001*, (Phnom Penh: Agriculture Productivity Improvement Project, PIU – The Fisheries Component)

Department of Fisheries (2001b), *Draft Sub-Decree on Community Fisheries – 16 August 2001*, (Phnom Penh: unofficial translation by Oxfam GB Cambodia Livelihoods Study Project)

DFID (no date), *An Analysis of Poverty and Aquatic Resources Use – focusing especially on the Livelihoods of the Poor of Cambodia*, (Bangkok: DFID Aquatic Resources Management Programme)

Fisheries Action Coalition Team (FACT) (2002), *Feast or Famine? Solutions to Cambodia's fisheries conflicts*, (London: Environmental Justice Foundation, Phnom Penh: NGO Forum)

Gregory, R. (1997), *Ricefield Fisheries Handbook*, (Phnom Penh: Cambodia-IRRI-Australia Project)

Gregory, R. and H. Guttman (1997), "Capture and culture ricefield fisheries in Cambodia" in H.J. Nesbitt (ed.), *Rice Production in Cambodia*, (Phnom Penh: Cambodia-IRRI-Australia Project) pp. 99-106

Gum, W. (2000), *Inland Aquatic Resources and Livelihoods in Cambodia: A Guide to the Literature, Legislation, Institutional Framework and Recommendations*, (Phnom Penh: Oxfam GB Cambodia Land Study Project)

Gum, W. (1998), *Natural Resource Management in the Tonle Sap Biosphere Reserve in Battambang Province*, (Phnom Penh: European Commission Support Programme (SPEC))

Gum, W. (1997), *Consultancy Report on Fisheries Development in Northwest Cambodia*, (Phnom Penh: UNDP/UNOPS/CARERE)

Hirsch, P. (1998), *Holding and Managing Resources in Common: Issues of Scale in Mekong Development* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June 10-14)

Kato, E. (1999), *Where Has All the Land Gone? Land Rights and Access in Cambodia, Volume 1, Case Studies*, (Phnom Penh: Oxfam Great Britain)

Kenefick, E. (1998), *Report on the Cambodian 1998 Joint Unicef-WFP Baseline Survey of CASD Project and WFP Target Areas*, (Phnom Penh: U.N. Children's Fund, U.N. World Food Programme, and Ministry of Planning)

Kuperan, K., N. Mustapha, R. Abdullah, R.S. Pomeroy, E. Genio, and A. Salamanca (1998), *Measuring Transaction Costs of Fisheries Co-Management* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June

10-14)

Lagler, K. F. (1976), "Fisheries and integrated Mekong River Basin development", *TermInal Report of the Mekong Basinwide Fishery Studies* (Ann Arbor: University of Michigan)

Ly, V., D. Yin, and P. Degen (2000), "The management of the freshwater capture fisheries in Cambodia: Legal principles and field implementation" in Van Zalinge, N., T. Nao, and S. Lieng (eds.) *Management aspects of Cambodia's Freshwater Capture Fisheries: Eleven presentations given at the Annual Meeting of the Department of Fisheries of the Ministry of Agriculture, Forestry and Fisheries, 27-28 January 2000,* (Phnom Penh: Mekong River Commission and Department of Fisheries) pp. 90-98

Mak, S. (2000a), *Fishing Conflict in Battambang*, (Phnom Penh: Environmental Working Group, NGO Forum)

Mak, S. (2000b), *Review of the Fishery Conflict in Stung Treng*, (Phnom Penh: Environmental Working Group, NGO Forum)

Marschke, M. (ed.) (2000a), *Mangrove Meanderings: Learning about Life in Peam Krasaop Wildlife Sanctuary* (Phnom Penh: Ministry of Environment, Participatory Management of Mangrove Resources)

Marschke, M. (ed.) (2000b), *Smashed Livelihoods: Life as a Charcoal Producer in PKWS, Koh Kong: A Case Study* (Phnom Penh: Ministry of Environment, IDRC)

Mastaller, M. (1999), *Environmental Management of the Coastal Zone of Cambodia: Assessment of Sustainable Livelihood Alternatives to Mangrove Exploitation* (KAMPSAX International, prepared for DANIDA)

McConney, P. (1998), *Climate for Co-Management* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June 10-14)

McKenney, B. (2001), *Economic Valuation of Livelihood Income Losses and Other Tangible Downstream Impacts from the Yali Falls Dam to the Se San River Basin in Ratanakiri Province, Cambodia*, (Phnom Penh: Oxfam America)

Mekong River Commission, (2000), *Chaktomouk Area: Environment, Hydraulics and Morphology, Phase 1*, (Phnom Penh: MRC Chaktomouk Project Management Unit)

Mekong River Commission Secretariat (1992), *Fisheries in the Lower Mekong Basin*, (Bangkok: Interim Mekong Committee)

Ministry of Agriculture, Forestry and Fisheries (2002), *Progress Report on Natural Resource Management to the Follow Up Meeting Second Semester 2001 between the Royal Government of Cambodia and Donor Community, 16 January 2002*, (Phnom Penh: MAFF)

Ministry of Commerce (2001), *Integration and competitiveness study – Part C: Sector studies – rice, diversified agriculture, handicrafts, fisheries, garments, tourism, labor services,* (Phnom Penh: Ministry of Commerce)

Nam, S. (2000), "Mekong River Flow Data Analysis" in Van Zalinge, N., T. Nao, and S. Lieng (eds.) *Management aspects of Cambodia's Freshwater Capture Fisheries: Eleven presentations given at the Annual Meeting of the Department of Fisheries of the Ministry of Agriculture, Forestry and Fisheries, 27-28 January 2000,* (Phnom Penh: Mekong River Commission and Department of Fisheries) pp. 23-29

Nao, T., and N. Van Zalinge (2000), "Challenges in managing Cambodia's inland fisheries: How can we meet them?" in Van Zalinge, N., T. Nao, and S. Lieng (eds.) *Management aspects of Cambodia's Freshwater Capture Fisheries: Eleven presentations given at the Annual Meeting of the Department of Fisheries of the Ministry of Agriculture, Forestry and Fisheries, 27-28 January 2000,* (Phnom Penh: Mekong River Commission and Department of Fisheries) pp. 10-17

Nao, T. and L.S. Srun (1999), *Report on Field Survey Work of Fishing Lot #6, Kompong Khleang Commune, Sotr Nikum District, Siem Reap Province, Cambodia* (Phnom Penh: Department of Fisheries)

Nao, T. (1998), "Inland Fishery Management and Enhancement in Cambodia" in T. Petr (ed.), *Inland Fishery Enhancements* (Rome, FAO Fisheries Technical Paper)

Nao, T., and S. Ly (1997), *Review of the Fisheries and Aquaculture Sector in Cambodia,*

prepared for the Project: CMB/95/003, "Natural Resources-Based Development Strategy for the Tonle Sap Area", (Phnom Penh: Department of Fisheries)

National Institute of Statistics (2001), *Cambodia Statistical Yearbook 2000*, (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *Report on the Cambodia Socio-Economic Survey 1999,* (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *General Population Census of Cambodia*, (Phnom Penh: Ministry of Planning)

NEDECO (1998), *Natural Resources-Based Development Strategy for the Tonle Sap Area, Cambodia: Final Report, Volume 2, Part B, Sectoral Studies* (Phnom Penh: Cambodia National Mekong Committee)

Nesbitt, H.J. (ed.) (1997), *Rice Production in Cambodia*, (Phnom Penh: Cambodia-IRRI-Australia Project)

NGO Forum (2001), "NGO Statement to the 2001 Consultative Group Meeting on Cambodia", available at http://www.bigpond.com.kh/users/ngoforum/cg2001/fisheries.htm

Nguyen, X. T. (1991), *Summary of the Report on the Freshwater Fishery Resources Survey in Cambodia (1986-1988),* (Hanoi: Socialist Republic of Vietnam, Ministry of Fisheries)

Paul, N.C. (1998), *Mangrove Area Encroachment in Cambodia: Problems and Findings* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June 10-14)

Pomeroy, R.S., B. M. Katon, and I. Harkes (1998), *Fisheries Co-Management: Key Conditions and Principles Drawn from Asian Experiences* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June 10-14)

Rainboth, W.J. (1996), *FAO species identification field guide for fishery purposes: Fishes of the Cambodian Mekong*, (Rome: FAO)

Ratanakiri Provincial Fisheries Office (2000), *A Study of the Downstream Impacts of the Yali Falls Dam in the Se San River Basin in Ratanakiri Province, Northeast Cambodia*, (Ratanakiri: Fisheries Office and Non-Timber Forest Products Project)

Ring, M.W., R.S. Pomeroy, B.M. Katon, and L. Garces (1998), *Measuring Co-Management* (Vancouver, Canada: seventh annual conference of the International Association for the Study of Common Property, June 10-14)

Shams, N. and H. Try (1998), *Cambodia's Rice Field Ecosystem Biodiversity: Resources and Benefits*, (Phnom Penh: GTZ)

Smith, J. D. (ed.) (2001), *Biodiversity, The Life of Cambodia – Cambodian Biodiversity Status Report 2001*, (Phnom Penh: Cambodia Biodiversity Enabling Activity)

Star Kampuchea (2000), *Conflict in Fishing Lot Number 2 and Experiences in Solving the Problem through Advocacy in Kompong Cham Province*, (Phnom Penh: Star Kampuchea)

State of Cambodia (1987), *Fiat-Law on Fisheries Management and Administration*, No. 33 KRO. CHOR., 19 March 1987, translated in Touch Seang, T. (1990), *Compiled Theme of Fishery Laws* (Phnom Penh: Department of Fisheries)

Swift, P. (1999), *Long-term Case Study of the Fishery Setting in Phlong Village, Kompong Chhnang Province, Initial Information Gathering and Outline of Future Work Program* (Phnom Penh: SADP)

Swift, P. (1997), *Developing a Research Framework for the Fishing Lot System in Cambodia: Two PrelimInary Case Studies on Fishing Lots in Takeo and Kompong Chhnang Provinces,* (Phnom Penh: Mekong River Commission, Department of Fisheries, and DANIDA)

Tes, S. (1997), "Hydrological Studies of the Tonle Sap/Great Lake Area" in *Natural Resources-Based Development Strategy for the Tonle Sap Area, Cambodia: Final Report, Volume 2, Part B, Sectoral Studies* (Phnom Penh: Cambodia National Mekong Committee)

Touch Seang, T. (1990), *Compiled Theme of Fishery Laws* (Phnom Penh: Department of Fisheries)

Van Zalinge, N., T. Nao, S. T. Touch, and L. Deap (2000), "Where there is water, there is fish? Cambodian fisheries issues in a Mekong River basin perspective", p. 37-48 in M. Ahmed and P. Hirsch (eds.), *Common property in the Mekong: issues of sustainability and subsistence*, (Manila: ICLARM Study Review 26)

Van Zalinge, N. and T. Nao (1999), "Present status of Cambodia's freshwater capture fisheries and management implications" in N. Van Zalinge, T. Nao, and L. Deap (eds.), *Present Status of Cambodia's Freshwater Capture Fisheries and Management Implications: Nine presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries, 19-21 January 1999* (Phnom Penh: Mekong River Commission/DANIDA) pp. 11-16

# ជំពូកទី ៤

# វិស័យព្រៃឈើ

ព្រៃឈើមានតួនាទីសំខាន់ជាសារវន្តក្នុងការជួយទ្រទ្រង់ជីវភាពនៅតាមជនបទកម្ពុជា ។ ព្រៃឈើផ្តល់ជាអុសសំរាប់ដាំស្ល ឈើសំរាប់ធ្វើសំណង់ សំភារៈសំរាប់ធ្វើឧបករណ៍ និងគ្រឿងប្រើប្រាស់ផ្សេងៗនៅក្នុងផ្ទះ ជ័រ វល្លិ៍ ផ្លែឈើ-បន្លែព្រៃ ចំណីសត្វ និង ឱសថ ។ ប្រជាជនកម្ពុជានៅជនបទ ក៏បានទទួលអត្ថប្រយោជន៍សំខាន់ៗជាច្រើនទៀតផងដែរ ពីព្រៃឈើក្រៅពីការប្រមូលផល ព្រៃឈើ គឺមានតំលៃខាងស្មារតីនិងវប្បធម៌ ភាពសំបូរបែបនៃសត្វ/រុក្ខជាតិ និងសេវាអេកូឡូស៊ីសំខាន់ៗ ដូចជាការទប់ជំរាលឱ្យមានស្ថិរភាពដើម្បីគ្រប់គ្រងការហូរច្រោះដី និងទឹកជំនន់ ។

ជំពូកនេះពិនិត្យពីស្ថានភាពបច្ចុប្បន្ននៃព្រៃឈើកម្ពុជា ដោយផ្តោតលើផ្ទៃព្រៃឈើ និងពត៌មានស្តីពីការប្រមូលផលប្រចាំឆ្នាំ សារៈសំខាន់នៃព្រៃឈើចំពោះជីវភាពជនបទ ស្ថានភាពនិងបញ្ហាប្រឈមនៃការគ្រប់គ្រងព្រៃឈើ និងការប្រឹងប្រែងធ្វើកំណែទំរង់ព្រៃឈើ ។ បន្ទាប់មក ដោយផ្អែកលើការវាយតំលៃពីកង្វះខាត និងតំរូវការក្នុងការស្រាវជ្រាវ នឹងមានការផ្តល់មតិពីបញ្ហាមួយចំនួនដែលអាចយកមកធ្វើការស្រាវជ្រាវក្នុងពេលអនាគត ។

## ៤.១. ផ្ទៃព្រៃឈើ

ប្រភេទព្រៃឈើនៅកម្ពុជា ជាទូទៅអាចចែកចេញជា ព្រៃបៃតងគ្រប់រដូវ ព្រៃបៃតងដោយរដូវ និងព្រៃលិចទឹក ។ ព្រៃបៃតងគ្រប់រដូវមានស្រទាប់ស្លឹកឈើក្រាស់ និងជិតជាង ហើយស្ថិតក្នុងតំបន់ដែលទទួលទឹកភ្លៀងកំរិតខ្ពស់ ។ នៅកម្ពុជា ព្រៃបៃតងគ្រប់រដូវភាគច្រើនស្ថិតនៅក្នុងជួរភ្នំក្រវាញ តំបន់ខ្ពង់រាបនៅភាគឦសាន និងក្នុងបណ្តាខេត្តភាគខាងជើង គឺកំពង់ធំ និងព្រះវិហារ (ផែនទី៤.១) ។ ព្រៃដែលស្រឡះ និងមិនសូវក្រាស់ខ្លាំងគឺជាព្រៃដែលមានពណ៌បៃតងដោយរដូវ (ស្លឹកឈើទុំជ្រុះ ដោយសារកង្វះខាតទឹកនៅរដូវប្រាំង) ។ ព្រៃឈើទាំងនេះភាគច្រើនស្ថិតនៅតំបន់ដីទាបនៅភាគខាងជើង ភាគឦសាន និង ភាគនិរតី គឺមានខេត្តមណ្ឌលគីរី ក្រចេះ រតនគីរីភាគខាងត្បូង ស្ទឹងត្រែង ព្រះវិហារ និងពោធិសាត់ ។ ព្រៃលិចទឹក និងវាលស្មៅ មានរាយប៉ាយនៅជុំវិញបឹងទន្លេសាប និងតាមតំបន់ដីសណ្តរទន្លេមេគង្គ និងទន្លេបាសាក់ ។ តំបន់ទាំងនេះកាលពីមុន ធ្លាប់មានព្រៃលិចទឹក និងវាលស្មៅជាច្រើន ក៏ប៉ុន្តែមួយភាគធំត្រូវបានគេកែប្រែទៅជាដីស្រែអស់ហើយ ។

ទិន្នន័យអំពីផ្ទៃព្រៃឈើនៅកម្ពុជា មិនដែលបានធ្វើបច្ចុប្បន្នភាពទេតាំងពីឆ្នាំ១៩៩៧ មក ។ ដូច្នេះគេពិបាកនឹងវាយតំលៃ ឱ្យបានច្បាស់លាស់អំពីស្ថានភាពនៃមូលដ្ឋានធនធានព្រៃឈើក្នុងពេលបច្ចុប្បន្ន ។ ទិន្នន័យជាប្រវត្តិសាស្ត្រអំពីផ្ទៃព្រៃឈើពីឆ្នាំ ១៩៦៤ ដល់ ១៩៩៧ ផ្តល់ពត៌មានដ៏មានប្រយោជន៍ពីនិន្នាការនៃផ្ទៃព្រៃឈើ ប៉ុន្តែគេគួរកត់សំគាល់ថា ទិន្នន័យទាំងនេះត្រូវបាន ប្រមូលដោយប្រើរបៀបបែងចែកប្រភេទព្រៃឈើខុសៗគ្នា ដែលចោទការលំបាកដល់ការវាយតំលៃពីការប្រែប្រួលក្នុងរយៈពេល កន្លងមក ។ លើសពីនេះ ទិន្នន័យផ្ទៃព្រៃឈើត្រូវបានកសាងឡើងដោយផ្អែកលើការបកស្រាយរូបថតពីផ្កាយរណប ដោយគ្មាន

ការធ្វើសារពើភ័ណ្ឌធនធានព្រៃឈើ "នៅខាងក្រោមដំបូលស្លឹកឈើ" ដែលអាចផ្តល់ពត៌មានយ៉ាងច្រើនពីគុណភាព/ការខូចខាតចំពោះព្រៃឈើដែលនៅសេសសល់ ។ ទោះយ៉ាងនេះក៏ដោយ ក៏គេនៅតែអាចធ្វើការសន្និដ្ឋានបានមួយចំនួនដែរ ដោយផ្អែកលើទិន្នន័យផ្ទៃព្រៃឈើដែលមានស្រាប់ (តារាង៤.១ និង៤.២):

- **ផ្ទៃព្រៃឈើកម្ពុជាភាគច្រើន គ្មានលក្ខណៈទាក់ទាញសំរាប់ការធ្វើអាជីវកម្មទេះ** គិតត្រឹមឆ្នាំ១៩៩៧ មានតែ ៦% (ប្រហែល ៦៣០.០០០ហិកតា) នៃព្រៃកម្ពុជាប៉ុណ្ណោះ ដែលស្ថិតក្នុងប្រភេទ "បៃតងក្រាស់គ្រប់រដូវ (dense evergreen)" និងដែលទាក់ទាញសំរាប់ការធ្វើអាជីវកម្ម រីឯ ៣០% (ប្រហែល ៣.២០០.០០០ហិកតា) ទៀតត្រូវបានសំគាល់ជាប្រភេទព្រៃ "បៃតងគ្រប់រដូវមានកាប់ខ្លះៗ (disturbed evergreen)" ដែលឆ្លុះបញ្ចាំងនូវការកាប់ពីកំរិតស្រាល ទៅដល់កំរិតធ្ងន់ ។ ព្រៃបៃតងគ្រប់រដូវចំរុះគ្នា និងរបោះ (mixed and mosaic evergreen) ដែលមានប្រហែល ១៥% នៃផ្ទៃព្រៃ (ឬ ១.៦០០.០០០ហិកតា) ទំនងជាគ្មានតំលៃគ្រប់គ្រាន់សំរាប់ការធ្វើអាជីវកម្មឈើទេ ។ ចំពោះព្រៃនៅសល់ ភាគច្រើន គឺជាព្រៃបៃតងដោយរដូវ (deciduous) ដែលគេសំគាល់ថា ពុំអាចផ្តល់ផលចំណេញគ្រប់គ្រាន់សំរាប់ការធ្វើអាជីវកម្មឡើយ ។
- **អត្រាកាប់ព្រៃឈើទំនងជាកើនឡើងនៅពាក់កណ្តាលទសវត្សរ៍១៩៩០:** ចាប់ពីឆ្នាំ១៩៧៣ ដល់ ១៩៩៣ អត្រាកាប់ព្រៃឈើជាមធ្យមគឺ ៧០.០០០ - ៩០.០០០ហិកតាក្នុងមួយឆ្នាំ ។ ទោះបីជាមិនច្បាស់លាស់ច្រើនស្តីពីអត្រាកាប់ព្រៃឈើពីឆ្នាំ១៩៩៣-១៩៩៧ ក៏ដោយ ក៏ទិន្នន័យបានបង្ហាញថា អត្រាកាប់ព្រៃឈើស្ថិតក្នុងចន្លោះពី ៥៥.០០០-១៩០.០០០ហិកតាក្នុងមួយឆ្នាំ ។ ឯកសារ World Bank (1999) បង្ហាញថា កំណើនអត្រាកាប់ព្រៃឈើ គឺកើតចេញភាគច្រើនពីពួកអ្នកកាប់ឈើដែលសំរុកកាប់ខ្លាំង ។
- **តំបន់ព្រៃលិចទឹកមួយភាគធំត្រូវបានគេកាប់ និង/ឬ កែប្រែយកមកបំរើការងារកសិកម្ម:** ដោយមានចំនួនជាង ១លានហិកតាក្នុងឆ្នាំ១៩៧៣ ព្រៃលិចទឹកបានថយចុះមកប្រហែល ៤៥០.០០០ហិកតាក្នុងឆ្នាំ១៩៩៧ ក្នុងនេះប្រហែល ៣០% ស្ថិតនៅក្នុងប្រភេទព្រៃចំរុះ និងព្រៃកំពុងលូតលាស់វិញ ដែលអន់គុណភាព ។
- **ការធ្វើបច្ចុប្បន្នភាពទិន្នន័យធនធានព្រៃឈើគឺជាការចាំបាច់:** បន្ទាប់ពីការធ្វើបច្ចុបន្នភាពលើកក្រោយបំផុតនូវទិន្នន័យផ្ទៃព្រៃឈើ គឺមានការកាប់ឈើ ៥រដូវថែមទៀតហើយ ។ ដូច្នេះការធ្វើបច្ចុប្បន្នភាពទិន្នន័យជាបន្ត នឹងផ្តល់នូវអាំងឌីកាទ័រដ៏សំខាន់សំរាប់វាយតំលៃការរីកចំរើននៅក្នុងការងារគ្រប់គ្រងព្រៃឈើចាប់ពីឆ្នាំ១៩៩៧ មក[៣០] ។

[៣០] ទិន្នន័យផ្កាយរណបដ៏ចាំបាច់ៗគេអាចរកទិញបានពីប្រភពពាណិជ្ជកម្ម ក្នុងតំលៃប្រហែល ៦.០០០-១០.០០០ដុល្លារ ។ គេត្រូវការថវិកាបន្ថែមប្រហែល ១៥.០០០ដុល្លារ ដើម្បីទ្រទ្រង់ការងារបកស្រាយទិន្នន័យ (យោងតាមការសន្ទនាផ្ទាល់ជាមួយ Martin Geiger Forest programme coordinator, WWF Indochina Programme Office) ។ ការវិនិយោគនេះ នឹងអាចបង្កើតបាននូវពត៌មានដ៏សំខាន់ៗស្តីពីស្ថានភាពបច្ចុប្បន្ននៃធនធានព្រៃឈើ ។ ការវាយតំលៃបែបនេះ អាចយកទៅផ្គុំជាមួយនឹងទិន្នន័យពីខាងក្រោមដំបូលស្លឹកឈើ (below-the-canopy data) ស្តីពីសារពើភ័ណ្ឌ និងសមាសភាពព្រៃឈើ (ដែលគេកំពុងប្រមូលដើម្បីកសាងផែនការថ្មីសំរាប់គ្រប់គ្រងព្រៃសម្បទាន) ។

**ផែនទី៤.១. ព្រៃសម្បទាន និងការគ្រប់គ្រងដី ១៩៩៦/៩៧**

បច្ចុប្បន្ននេះ គេមិនអាចកំណត់បានច្បាស់លាស់ទេថា នៅក្នុងផ្ទៃព្រៃឈើកម្ពុជាប្រហែល ១០,៦លានហិកតា តើប្រភេទព្រៃឈើនិមួយៗមានប៉ុន្មាន និងស្ថិតនៅក្រោមអាជ្ញាធរត្រួតពិនិត្យណាខ្លះ ។ ទោះបីជាក្នុងពង្រាងច្បាប់ព្រៃឈើ គេបានខិតខំបំភ្លឺពីការគ្រប់គ្រង និងអាជ្ញាធរមានសមត្ថកិច្ចលើព្រៃឈើ ព្រមទាំងកំណត់និយមន័យប្រភេទព្រៃឈើក៏ដោយ ក៏ការខិតខំខាងផ្លូវច្បាប់ និងខាងគោលគំនិតទាំងនេះ នៅមិនទាន់បានអនុវត្ត ឬដៅព្រំប្រទល់នៅលើផែនទីព្រៃឈើរបស់កម្ពុជាឡើយ[៣១] ។ ពង្រាងច្បាប់បានចែងច្បាស់ថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តមានសមត្ថកិច្ចនៅលើព្រៃឈើកម្ពុជាភាគច្រើន រីឯតំបន់ការពារស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ហើយព្រៃលិចទឹកស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជលផល ។ ដោយឈរលើមូលដ្ឋាននេះ នៅខាងក្រោមមានចុះពតិមានពីអាជ្ញាធរមានសមត្ថកិច្ចបច្ចុប្បន្ន សំរាប់ព្រៃឈើកម្ពុជាភាគច្រើនះ

**តារាង៤.១. ទិន្នន័យស្ដីពីព្រៃឈើកម្ពុជា ១៩៦៤-១៩៩៧**

| ប្រភេទព្រៃឈើ | 1964 (ha)[1] | 1973 (ha)[2] | 1993 (ha)[2] | ប្រភេទព្រៃឈើ | 1992/93 (ha)[3] | 1996/97 (ha)[3] | 1997 (ha)[4] |
|---|---|---|---|---|---|---|---|
| ព្រៃបៃតងគ្រប់រដូវ | 3,955,300 | 6,876,400 | 4,763,300 | បៃតងក្រាស់គ្រប់រដូវ | 654,442 | 625,177 | 634,869 |
| បៃតងគ្រប់រដូវរិញ Dwarf Evergreen | 288,700 | | | បៃតងគ្រប់រដូវ មានកាប់ខ្លះៗ | 3,255,533 | 3,183,395 | 3,223,527 |
| ព្រៃស្រល់ | 17,800 | 9,300 | 9,800 | បៃតងគ្រប់រដូវ Mosaic | 129,902 | 178,147 | 135,632 |
| ព្រៃចំរុះ Mixed | 2,504,000 | | 977,300 | ព្រៃក្រាស់ចំរុះ | 99,124 | 95,560 | 111,842 |
| ព្រៃប្រភេទទី២ | | | 517,000 | ព្រៃចំរុះកាប់ខ្លះៗ | 1,325,353 | 1,284,446 | 1,184,689 |
| | | | | Mixed Mosaic | 110,066 | 125,320 | 97,905 |
| *ររុបរងព្រៃបៃតងគប់រដូវនិងព្រៃចំរុះ* | *6,765,8(* | *6,885,7(* | *6,267,400* | *ររុបរងព្រៃបៃតងគប់រដូវនិងព្រៃចំរុះ* | *5,574,4:* | *5,492,0:* | *5,388,4(* |
| បៃតងដោយរដូវ | 5,296,700 | 4,792,900 | 4,301,200 | បៃតងដោយរដូវ | 4,008,000 | 3,931,219 | 3,777,678 |
| | | | | បៃតងដោយរដូវmosaic | 342,204 | 350,178 | 274,553 |
| | | | | ព្រៃដុះឡើងវិញ | 435,618 | 374,197 | 544,778 |
| | | | | ព្រៃដាំ | 72,307 | 82,425 | |
| *សរុបរងបៃតងដោយរដូវ /ព្រៃឯទៀត* | *5,296,700* | *4,792,900* | *4,301,200* | *សរុបរងបៃតងដោយរដូវ និងព្រៃឯទៀត* | *4,858,129* | *4,738,019* | *4,597,009* |
| ព្រៃលិចទឹក | 681,400 | 937,900 | 370,700 | ព្រៃលិចទឹក | 229,266 | 219,906 | 222,150 |
| ព្រៃលិចទឹកប្រភេទទី២ | | | 259,800 | ព្រៃលិចទឹក Mosaic | 98,587 | 94,582 | 105,465 |
| | | | | ព្រៃលិចទឹកដុះថ្មី | 21,623 | 20,819 | 23,591 |
| ព្រៃឫស្សី | 387,400 | | | ព្រៃឫស្សី | 32,224 | 33,730 | 21,823 |
| ព្រៃកោងកាង | 96,300 | 94,600 | 85,100 | ព្រៃកោងកាង | 77,669 | 72,835 | 77,260 |
| *ររុបរងព្រៃលិចទឹក* | *1,165,1(* | *1,032,5(* | *715,600* | *ររុបព្រៃលិចទឹក* | *459,3(* | *441,8:* | *450,2(* |
| សរុប | **13,227,100** | **12,711,100** | **11,284,200** | សរុប | **10,891,939** | **10,671,956** | **10,535,762** |
| ជា %នៃព្រៃសរុប | **73.0%** | **70.2%** | **62.3%** | ជា %នៃព្រៃសរុប | **60.2%** | **58.9%** | **58.2%** |

*[1] Report No. 2 of Ministry of Water, Forest and Hunting (1965) in Ung (1991).*
*[2] FAO (1994) in World Bank, UNDP, and FAO (1996).*
*[3] MAFF in Chan et al. (2001).*
*[4] Mekong River Commission Forest Cover Monitoring Project in World Bank (1999)*

[៣១] ឧទាហរណ៍ ពង្រាងច្បាប់ព្រៃឈើកំណត់នូវប្រភេទព្រៃជាច្រើនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនេះមាន "ព្រៃផលិតកម្ម" សំរាប់ផលិតកម្មមានចីរភាពនូវ ឈើ និងផលិតផលក្រៅពីឈើ, "ព្រៃការពារ" សំរាប់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី, និង "ព្រៃដែលអាចកែប្រែសំរាប់គោលដៅអភិវឌ្ឍន៍ផ្សេងទៀត" ចំពោះតំបន់ព្រៃរដ្ឋដែលមិនទាន់កំណត់សំរាប់ការប្រើប្រាស់ណាមួយ (Royal Government of Cambodia 2001) ។ គ្មានតួលេខច្បាស់ពីទំហំព្រៃមួយប្រភេទៗ ក្នុងពេលបច្ចុប្បន្នទេ ។

- ពីឆ្នាំ១៩៩៤-១៩៩៧ ព្រៃឈើ ៦,៥លានហិកតា ត្រូវបានផ្តល់ឱ្យជាង ៣០ក្រុមហ៊ុនសម្បទាន នៅក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ដោយមានការលុបចោលមួយចំនួន សព្វថ្ងៃមានតែ ១៩ក្រុមហ៊ុនសម្បទានប៉ុណ្ណោះដែលធ្វើអាជីវកម្មលើផ្ទៃដី ៤,២លានហិកតា ។ ចំពោះព្រៃ ៤,២លានហិកតានេះ មានតែ ៥០% ប៉ុណ្ណោះ ដែលស្ថិតនៅជាព្រៃខ្ពស់ (Fraser Thomas *et al.* 2000) ។
- ដី ៣,៣លានហិកតា ត្រូវបានរក្សាទុកជាតំបន់ការពារនៅក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន ។ ប្រព័ន្ធតំបន់ការពាររួមមាន សួនឧទ្យានជាតិ៧ ជំរកសត្វព្រៃ១០ តំបន់ទេសភាពការពារ៣ និង តំបន់ប្រើប្រាស់ចំរុះ៣ ហើយទាំងអស់នេះមិនមែនសុទ្ធតែមានឈើព្រៃគ្របឡើយ ។ នៅក្នុងអតីតកាល មានការកាប់ឈើយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងតំបន់ការពារ ។
- ដី ០,៨លានហិកតា ត្រូវបានផ្តល់ជាសម្បទានកសិកម្ម ក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សូមអានជំពូក២) ។ សម្បទានភាគច្រើន គឺស្ថិតក្នុងតំបន់មានព្រៃ ក្នុងពេលបច្ចុប្បន្ន ឬកាលពីមុន ។
- ដី ០,៤៥លានហិកតា គឺជាតំបន់ព្រៃលិចទឹក ក្រោមសមត្ថកិច្ចនាយកដ្ឋានជលផល ។

**តារាង ៤.២. ការបាត់បង់គំរបព្រៃឈើ នៅកម្ពុជា ១៩៦៤-១៩៩៧**

| ការបាត់បង់គំរបព្រៃឈើ | 1964-1973 | 1973-1993 | 1993-1997 | 1964-1997 |
|---|---|---|---|---|
| ការបាត់បង់គំរបព្រៃឈើសរុប(ha) | 516,000 | 1,426,900 - 1,819,161 | 219,983 - 748,438 | 2,555,144 - 2,691,338 |
| ការបាត់បង់គំរបព្រៃឈើសរុបគិតជា % | 3.9% | 11.2-14.3% | 2.0-6.6% | 19.3-20.3% |
| ការបាត់បង់គំរបព្រៃឈើមធ្យមប្រចាំឆ្នាំ (ha) | 57,333 | 71,345- 90,958 | 54,996-187,110 | 77,429-81,556 |
| ការបាត់បង់គំរបព្រៃឈើមធ្យមប្រចាំឆ្នាំជា % | 0.43% | 0.56-0.72% | 0.50-1.66% | 0.59-0.62% |

## ៤.២. ការប្រមូលផល ការកែច្នៃ និងពាណិជ្ជកម្មឈើ

នៅកំលុងពាក់កណ្តាលទសវត្សរ៍១៩៩០ ការកាប់ព្រៃឈើបានកើតមានយ៉ាងគគ្រឹកគគ្រេងនៅកម្ពុជា ។ សកម្មភាពកាប់ឈើមានលក្ខណៈជាការប្រមូលផលឈើខុសច្បាប់ និងគ្មានចីរភាព ការនាំចេញឈើដោយខុសច្បាប់យ៉ាងច្រើន និងការគ្រប់គ្រង និងការដាក់អនុវត្តន៍ច្បាប់ទន់ខ្សោយដែលបណ្តាលឱ្យមានការបាត់បង់ និងការរេចរិលព្រៃឈើគួរឱ្យកត់សំគាល់ ។ នៅដើមឆ្នាំ ១៩៩៩ ការបង្ក្រាបការកាប់ឈើខុសច្បាប់របស់រដ្ឋាភិបាល គឺមានប្រសិទ្ធិភាពនៅក្នុងការទប់ស្កាត់ការកាប់ព្រៃឈើដ៏គគ្រឹកគគ្រេង ប៉ុន្តែនៅមានការកាប់ក្នុងកំរិតមិនច្បាស់លាស់មួយដែលបានបន្តរហូតដល់ពេលមានបំរាមកាប់ឈើនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ ។ ទិន្នន័យអាចទុកចិត្តបានស្តីពីការកាប់ឈើ សមត្ថភាពកែច្នៃ និងពាណិជ្ជកម្មឈើ មិនដែលបានប្រមូលទេតាំងពីចុងទសវត្សរ៍១៩៩០ មក ដែលនាំឱ្យពិបាកធ្វើការវាយតំលៃពីប្រសិទ្ធិភាពនៃកំណែទំរង់ព្រៃឈើ ។

### *៤.២.១. ការប្រមូលផលឈើ*

ស្ថិតិរបស់នាយកដ្ឋានរុក្ខាប្រមាញ់ បង្ហាញថា ពីឆ្នាំ១៩៨៥-១៩៩៩ ការប្រមូលផលឈើប្រចាំឆ្នាំមានកំរិតពី ២០០.០០០ ទៅ ៥០០.០០០ម៉ែត្រគូប ។ ដោយសារតែមានការកាប់ឈើខុសច្បាប់ និងសេចក្តីរាយការណ៍លាក់លៀមតួលេខយ៉ាងច្រើន ស្ថិតិនេះមិនមែនជាអាំងឌីកាទ័រដ៏ល្អមួយទេសំរាប់បញ្ជាក់ពីកំរិតប្រមូលផលឈើពិតប្រាកដ ។ ឧទាហរណ៍ ការសិក្សាមួយក្នុងគំរោងតាមដានឈើ និងត្រួតពិនិត្យការកាប់ព្រៃឈើ ដែលបានឧបត្ថម្ភពីធនាគារពិភពលោក បានប៉ាន់ស្មានថា ការប្រមូលផលឈើសរុបក្នុងឆ្នាំ១៩៩៧ គឺពី ៣,២ ដល់ ៤,៣លានម៉ែត្រគូបនៃឈើមូល ក្នុងនេះមានតែ ៦% ទៅ ៧% ប៉ុណ្ណោះដែលស្របច្បាប់ (តារាង ៤.៣) ។

## តារាង ៤.៣. ការប៉ាន់ស្មានផលិតផលព្រៃឈើនៅកម្ពុជា ១៩៩៧

| ប្រភេទនៃ ផលិតផល/ការជួញដូរ | បរិមាណប៉ាន់ស្មាន់ (ត្រូវជា ម³ នៃឈើមូល) |
|---|---|
| ការនាំឈើមូលចេញខុសច្បាប់ដោយផ្ទាល់ទៅប្រទេសជិតខាង[១] | 902,500 |
| ការនាំឈើអារចេញខុសច្បាប់ដោយផ្ទាល់ទៅប្រទេសជិតខាង | 954,900 – 2,085,900 |
| ផលិតផលសំរាប់ការប្រើប្រាស់ក្នុងស្រុក (គ្មានការត្រួតពិនិត្យ, ភាពស្របច្បាប់: មិនដឹង)[២] | 670,000 |
| ផលិតផលព្រៃសម្បទានមិនបានរាយការណ៍[៣] | 166,200 |
| លិខិតអនុញ្ញាតឱ្យប្រមូលឈើដែលកាប់រំលំខុសច្បាប់ (មានយកពន្ធ) | 214,700 |
| លិខិតអនុញ្ញាតឱ្យប្រមូលឈើដែលកាប់រំលំខុសច្បាប់ (គ្មានយកពន្ធ)[៤] | Unknown |
| ផលិតផលសម្បទានដែលរាយការណ៍ជូន DoF (ស្របច្បាប់ និងមានយកពន្ធ) | 248,000 |
| **ការប្រមូលផលសរុបប៉ាន់ស្មាន** | **3,156,300 – 4,287,300** |

[១] *ប្រទេសជិតខាងគឺ ថៃ វៀតណាម និងឡាវ ។*
[២] *ផ្អែកលើលើផលិតផលប៉ាន់ស្មានប្រចាំឆ្នាំ 0.0៦៧ម៉ែត្រគូបក្នុងមនុស្សម្នាក់ ដែលបានពីព្រៃមិនមែនសម្បទានសំរាប់ការប្រើប្រាស់ក្នុងស្រុក*
[៣] *ផ្អែកទៅលើភស្តុតាងដែលថា ក្រុមហ៊ុនសម្បទានរាយការណ៍តែត្រឹម ៦០% នៃផលឈើកាប់របស់ខ្លួនប៉ុណ្ណោះ ។*
[៤] *លិខិតអនុញ្ញាតគ្មានយកពន្ធ ត្រូវបានផ្តល់សំរាប់ឈើកាប់ខុសច្បាប់ជាច្រើន ។ មានពត៌មានខ្លះនៅនាយកដ្ឋានរុក្ខាប្រមាញ់ ប៉ុន្តែគេមិនបានផ្តល់ឱ្យ Development Alternatives Incorporated (DAI) ទេ ។*

*ប្រភព: DAI 1998*

នៅឆ្នាំ១៩៩៧ ការប្រមូលផលឈើវាលើសកំរិតមានចីរភាព (០,៥-១,០លានម³/ឆ្នាំ) ច្រើនណាស់ ដែលបង្កការបារម្ភយ៉ាងខ្លាំងពីលទ្ធភាពផ្គត់ផ្គង់ឈើក្នុងពេលអនាគត (Fraser Thomas *et al.* 2000) ។ ចំនួនប៉ាន់ស្មាននៃឈើកាប់លក់ក្នុងឆ្នាំ១៩៩៧ នៅកម្ពុជាគឺ ២០លានម³ ហើយវាបង្ហាញថា ព្រៃឈើនឹងត្រូវកាប់អស់ក្នុងរយ:៥ឆ្នាំ ប្រសិនបើអត្រាកាប់បែបនេះមានជាបន្ត ។ ការកាប់ឈើខុសច្បាប់ក៏ប៉ះពាល់ផងដែរដល់តំបន់ការពារនៅឆ្នាំ១៩៩៧ ដោយមានប្រហែល ២១% នៃផ្ទៃព្រៃឈើត្រូវបានគេសំរុកកាប់ (Development Alternative Incorporated 1998) ។

ជាកុសលល្អ អត្រាកាប់ឈើខុសច្បាប់បានថយចុះគួរឱ្យកត់សំគាល់នៅក្រោយខែមករា ឆ្នាំ១៩៩៩ គឺនៅពេលដែលនាយក រដ្ឋមន្ត្រីបានចេញប្រកាសលេខ១ មាន១៧ចំណុច សំដៅបញ្ឈប់ការកាប់និងការកែច្នៃឈើខុសច្បាប់ ។ នៅពេលប្រជុំក្រុមពិគ្រោះ យោបល់ នាខែមិថុនា ឆ្នាំ១៩៩៩ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា សេចក្តីប្រកាសលេខ១ បាន ញ៉ាំងឱ្យការកាប់ឈើខុសច្បាប់ថយចុះអស់ ៩៥%ធៀបនឹងឆ្នាំមុន, រោងចក្រអារឈើខុសច្បាប់ទាំងអស់ត្រូវបានបិទ ឯសំភារ: ត្រូវបានរឹបអូស ឬកំទេចចោល ។ ទោះបីគ្មានភស្តុតាងបញ្ជាក់ពេញលេញពីការថយចុះ ៩៥% នេះក៏ដោយ ក៏ការសិក្សាដោយ Fraser Thomas *et al.* (2000) និង Global witness (2001) បានបង្ហាញថា ការកាប់ឈើខុសច្បាប់បានថយចុះយ៉ាងខ្លាំង បន្ទាប់ពី មានការបង្ក្រាប ។ ប៉ុន្តែ Global witness (2001) បានបញ្ជាក់ដែរថា ការកាប់ឈើខុសច្បាប់បានកើនជាថ្មីម្តងទៀត នៅក្នុងរដូវ កាប់ឈើឆ្នាំ២០០០-២០០១[៣២] ។

[៣២] រដូវកាប់ឈើនៅកម្ពុជា គឺរដូវប្រាំង (ពីខែវិច្ឆិកា ដល់ មេសា) នៅពេលដែលអ្នកកាប់ឈើអាចចេញចូលស្រួលទៅកាន់តំបន់ព្រៃដាច់ស្រយាល ។ គួរសំគាល់ថា នាយដ្ឋានរុក្ខាប្រមាញ់ យកឆ្នាំប្រតិទិនធ្វើជាមូលដ្ឋានសំរាប់សកម្មភាពគ្រប់គ្រងព្រៃ និងការប្រមូលទិន្នន័យ ។ ដូចនេះ ស្ថិតិកាប់ឈើសំរាប់ឆ្នាំណាមួយ វាឆ្លុះបញ្ចាំងនូវសកម្មភាពផលិតកម្មក្នុងមួយចំណែកនៃពីររដូវកាប់ឈើ (មករា ដល់ មេសា និង វិច្ឆិកា ដល់ ធ្នូ) ។ វិធីសាស្ត្រនេះអាចបង្កការពិបាកដល់ការគ្រប់គ្រង ។ ឧទាហរណ៍ លិខិតអនុញ្ញាតឱ្យកាប់ឈើសំរាប់មួយឆ្នាំប្រតិទិនជាក់ស្តែងគឺបើកឱ្យកាប់ឈើក្នុងមួយភាគ១នៃរដូវកាប់ឈើពីររដូវ ។ ក្រុមហ៊ុនឈើមួយដែលមានលិខិតអនុញ្ញាតឱ្យកាប់ឈើរហូតដល់ថ្ងៃទី៣១ ខែធ្នូ គឺអាចកាប់ឈើយ៉ាងលឿនក្នុងកំលុងពីរខែដំបូងនៃរដូវប្រាំង (ធ្នូ និងកុម្ភ:) ហើយបន្ទាប់មក គេប្រើពេលនៅសល់ក្នុងរដូវប្រាំងសំរាប់ធ្វើការកែច្នៃ និងដឹកជញ្ជូនឈើ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មន្ត្រីអ្នកអនុវត្តន៍ច្បាប់ មានការពិបាកខ្លាំងក្នុងការសំគាល់ថា ឈើណាគេកាប់ក្នុងខែវិច្ឆិកា-ធ្នូ និងឈើណាគេកាប់ក្រោយមកទៀតនៅក្នុងរដូវកាប់ឈើ ។

## *៤.២.២. ការកែច្នៃ និងពាណិជ្ជកម្មឈើ*

គេប៉ាន់ថា សមត្ថភាពកែច្នៃឈើដែលបានតំឡើងហើយនៅកម្ពុជាកាលពីឆ្នាំ១៩៩៩-២000 មានប្រហែល ១,២លានម$^{៣}$ នៃឈើមូលក្នុងមួយឆ្នាំ (Fraser Thomas *et al.* (2000) ក្នុងនេះ រោងចក្រក្តារបន្ទះតំណាងឱ្យប្រហែល ៥0% ហើយក្រៅពីនេះ ភាគច្រើនគឺជាម៉ាស៊ីនអារឈើបានចុះបញ្ជី ។ មួយភាគធំនៃសមត្ថភាពកែច្នៃត្រូវបានបង្កើតឡើងតាមកិច្ចព្រមព្រៀងវិនិយោគ រវាងក្រុមហ៊ុនអាជីវកម្មឈើ និងរដ្ឋាភិបាល ដែលអំពាវនាវឱ្យមានការវិនិយោគច្រើនទៅលើសមត្ថភាពកែច្នៃ ។

ក្រៅពីរោងចក្រកែច្នៃបានចុះបញ្ជី នៅមានប្រហែល ១.000រោងអារឈើតូចៗទៀតដែលមិនបានចុះបញ្ជី និងដែលទទួលបានឈើភាគច្រើនមកពីការកាប់ឈើខុសច្បាប់ក្នុងឆ្នាំ១៩៩៩-២000 ។ ដូចនេះ សមត្ថភាពកែច្នៃដែលបានតំឡើងហើយសំរាប់វិស័យឧស្សាហកម្មនេះ គឺមានប្រហែល ២លានម$^{៣}$ ក្នុងមួយឆ្នាំ គឺត្រូវជា ២ ទៅ ៤ដង ធំជាងបរិមាណប៉ាន់ស្មាននៃកំរិតកាប់ឈើប្រចាំឆ្នាំមានចីរភាព (Fraser Thomas *et al.* (2000) ។ ដោយសារផលចំណេញពីការវិយោគលើទ្រព្យសកម្មជាប់លាប់សំរាប់កសាងសមត្ថភាពកែច្នៃឈើ វាកើនឡើងស្របគ្នានឹងការប្រើប្រាស់សមត្ថភាពនេះបានច្រើន (គឺអារឈើហ៊ុបបានច្រើន) ដូច្នេះ វិនិយោគិន/ក្រុមហ៊ុន មានការជំរុញចិត្តជាខ្លាំងក្នុងការរក្សាសកម្មភាពកាប់ឈើក្នុងកំរិតដែលខ្ពស់ជាងកំរិតមានចីរភាព ដើម្បីប្រើប្រាស់សមត្ថភាពកែច្នៃរបស់ខ្លួនឱ្យបានពេញលេញ ។

ការប៉ាន់ស្មានពីកំរិតពាណិជ្ជកម្ម ការនាំចេញ និងការប្រើប្រាស់ឈើនៅក្នុងស្រុក គឺជាការពិបាក អាស្រ័យដោយមានការកាប់ឈើខុសច្បាប់ជាច្រើន និងការប្រមូលស្ថិតិមិនបានសព្វជ្រុងជ្រោយ ។ ប៉ុន្តែ វាច្បាស់ហើយដែលឈើកម្ពុជាជាច្រើន ត្រូវបាននាំចេញទៅ ថៃ វៀតណាម និងចិន ដើម្បីបំពេញតំរូវការក្នុងប្រទេសគេ ។ ក្នុងរយៈជាច្រើនឆ្នាំកន្លងមកនេះ ប្រទេសដូចខាងលើបានហាមឃាត់ការកាប់ឈើក្នុងស្រុក ដែលនាំឱ្យមានកំណើនតំរូវការនាំចូលឈើ ជាពិសេសការនាំចូលឈើពីកម្ពុជា និងឡាវ ។

ការសិក្សាដោយ Castren (1999) សំរាប់ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការវាយតំលៃពីកំរិតកាប់ឈើនៅអាស៊ីអគ្នេយ៍ ដោយប្រើពត៌មានស្តីពីការប្រើប្រាស់ ការផ្គត់ផ្គង់ និងពាណិជ្ជកម្មឈើ ។ តាមវិធីសាស្ត្រនេះ ការសិក្សាបានប៉ាន់ថា ថៃប្រើប្រាស់ឈើអស់ប្រហែល ១0លានម$^{៣}$/ឆ្នាំ នៅចុងទសវត្សរ៍១៩៩0 ក្នុងនេះ កម្ពុជាផ្គត់ផ្គត់ប្រហែល ២លានម$^{៣}$/ឆ្នាំ ។ ការសិក្សាបានបង្ហាញដែរថា វៀតណាមជាប្រទេសប្រើប្រាស់ឈើកម្ពុជាច្រើនជាងគេក្នុងលំដាប់ទីពីរ ដោយនាំចូល ១លានម$^{៣}$/ឆ្នាំ ។ ចំពោះឈើផ្គត់ផ្គង់ទៅវៀតណាម ភាគច្រើនគេយកទៅប្រើប្រាស់សំរាប់ឧស្សាហកម្មធ្វើសង្ហារឹមសួនច្បារ ។ ការប៉ាន់ស្មានធ្វើឡើងដោយ Castren (1999) ជាទូទៅមានភាពស៊ីគ្នានឹងតួលេខនាំចេញឈើក្នុងឆ្នាំ១៩៩៧ ដែលរកឃើញដោយគំរោងតាមដានឈើ និងត្រួតពិនិត្យការកាប់ឈើ (តារាង៤.៣) ។

សមត្ថភាពកែច្នៃ និងការនាំចេញឈើ ទំនងជាបានធ្លាក់ចុះ ដោយសារការបង្ក្រាបការកាប់ឈើខុសច្បាប់នៅឆ្នាំ១៩៩៩ ការហាមឃាត់ការកាប់ឈើដែលចាប់អនុវត្តពីថ្ងៃទី១ មករា ២00២ និងសកម្មភាពផ្សេងៗទៀតដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ (សូមអាន ៤.១0. កិច្ចប្រឹងប្រែងកែទំរង់ព្រៃឈើ ) ។ ឧទាហរណ៍ ក្រសួងកសិកម្មបានរាយការណ៍ អំពីការបំផ្លាញ ១៥៨ម៉ាស៊ីនអារឈើ នៅឆ្នាំ២00១ ។ ពាក់ព័ន្ធនឹងការនាំចេញ Global Witness បានរាយការណ៍ថា ការនាំចេញឈើពីកម្ពុជា ទៅវៀតណាម នៅឆ្នាំ១៩៩៩ ជាទូទៅមានកំរិតទាបជាងឆ្នាំមុនៗ ។ ការនាំចេញឈើទៅថៃនៅឆ្នាំ១៩៩៩ ក៏ទាបជាងមុនដែរ ប៉ុន្តែការនាំចេញឈើអារទៅថៃ នៅតែច្រើនដដែលតាមផ្លូវគោក និងផ្លូវសមុទ្រ ដែលប្រហែលជាអាចបំពេញតំរូវការទាំងអស់របស់ប្រទេសថៃភាគខាងកើតបាន ។ ឈើមូលកម្ពុជាជាច្រើន ក៏ត្រូវបានលួចដឹកចេញទៅឡាវដើម្បីកសាងឯកសារឱ្យបានត្រឹមត្រូវ សំរាប់ការនាំចេញបន្តទៅថៃផងដែរ (Global Witness 2000a) ។

## ៤.៣. សារៈសំខាន់នៃព្រៃឈើចំពោះជីវភាពជនបទ

ព្រៃឈើកម្ពុជាគឺជាធនធានដ៏មានតំលៃ ហើយវាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវភាពជនបទ ។ ធនធានព្រៃឈើជួយទ្រទ្រង់ដល់សកម្មភាពផ្សេងៗក្នុងការចិញ្ចឹមជីវិត និងការរកចំណូល ដូចជា ការកាប់ឈើទ្រង់ទ្រាយតូច ការរកអុស ការយកជ័រ និងការបេះប្រមូលផ្លែឈើព្រៃ បន្លែ និងឱសថ ។ សកម្មភាពទាំងនេះជួយបំពេញបន្ថែមលើការងារកសិកម្ម និងនេសាទ ដោយផ្តល់លទ្ធភាពឱ្យគ្រួសារជនបទធ្វើចំរុះកម្មនូវសកម្មភាពទ្រទ្រង់ជីវភាព ប្រើប្រាស់កំលាំងពលកម្មបានអស់លទ្ធភាព និងការពារខ្លួន ទល់នឹងហានិភ័យនៃការខូចផលកសិកម្ម និងការចាប់ត្រីបានតិចតួច ។ ប្រជាជនអាចគ្មានដីធ្លី អាចមានលុយកាក់តិចតួចសំរាប់វិនិយោគ ឬមានលទ្ធភាពតិចតួចក្នុងការជ្រើសរើសរបរចិញ្ចឹមជីវិត ប៉ុន្តែពួកគេអាចដើរប្រមូលធនធានពីព្រៃឈើមកចិញ្ចឹមជីវិតបានដែរ ។ ក្នុងករណីនេះ ធនធានព្រៃឈើ គឺជា "សំណាញ់សុវត្ថិភាព" យ៉ាងសំខាន់សំរាប់ជនក្រីក្រនៅជនបទ ។

គ្រួសារនៅជនបទជាច្រើនគិតថា កសិកម្មគឺជារបរទីមួយ ឯការប្រមូលផលពីធនធានព្រៃឈើ គឺជារបរសំខាន់ទីពីរ ឬទីបីរបស់ពួកគេ ។ ជាលទ្ធផល ស្ថិតិជាតិដែលផ្តោតទៅលើរបរទីមួយ គឺមិនអាចបង្ហាញបានសមស្របទេនូវសារៈសំខាន់នៃធនធានព្រៃឈើចំពោះការចិញ្ចឹមជីវិតនៅជនបទ ។ ឧទាហរណ៍ ជំរឿនប្រជាជនទូទៅនៅប្រទេសកម្ពុជាឆ្នាំ១៩៩៨ បានប៉ាន់ស្មានថា មានប្រជាជនតែ ៦.៦៥៣នាក់ ឬ ០,១៣% នៃកំលាំងពលកម្មប៉ុណ្ណោះដែលប្រកបរបរក្នុងវិស័យព្រៃឈើ ការកាប់ឈើ និងសកម្មភាពសេវាកម្មផ្សេងៗទាក់ទិននឹងព្រៃឈើ ឯ កំលាំងពលកម្ម ៧៥,៧% ប្រកបរបរ "កសិកម្ម ប្រមាញ់ និងរុក្ខកម្ម" ។ ស្រដៀងគ្នានេះដែរ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ ប៉ាន់ស្មានថា ៧៤,៧% នៃកំលាំងពលកម្ម ប្រកបរបរក្នុង "វិស័យកសិកម្ម ប្រមាញ់ និងរុក្ខកម្ម" ប៉ុន្តែការប្រកបរបរលើព្រៃឈើ មិនត្រូវបានបំបែកចេញពីសកម្មភាពកសិកម្ម និងប្រមាញ់ទេ ។

ករណីសិក្សាអំពីការប្រើប្រាស់ធនធានព្រៃឈើ បង្ហាញថា ចំនួនការងារ និងចំណូលក្រៅផ្លូវការ ដែលទាក់ទិននឹងផលិតផលព្រៃឈើ មានច្រើនគួរឱ្យកត់សំគាល់ ប៉ុន្តែវាប្រែប្រួលយ៉ាងខ្លាំងពីតំបន់មួយទៅតំបន់មួយ ។ ជាការពិត តំបន់សំបូរព្រៃអាចផ្តល់ការងារ និងចំណូល ក្នុងមួយក៏វិតខ្ពស់ ប៉ុន្តែមានតំបន់ជាច្រើនទៀតក៏បង្ហាញអំពីការពឹងពាក់ខ្លាំងលើព្រៃឈើសំរាប់តំរូវការផ្សេងៗក្នុងជីវភាព ជាពិសេសអុស ។ ដើម្បីបង្ហាញពីការពឹងពាក់នៃជីវភាពជនបទទៅលើធនធានព្រៃឈើ លទ្ធផលរកឃើញក្នុងករណីសិក្សាមួយចំនួន មានលើកយកមករៀបរាប់ដូចតទៅ:

- **ខេត្តកំពត- បួនភូមិ** (Hou *et al.* 2001): ចំណូលសុទ្ធជាមធ្យមពីធនធានព្រៃឈើ គឺប្រហែល ៣៨% នៃចំណូលសរុបក្នុង ៤ភូមិ នៃស្រុកជុំគីរី ក្នុងឆ្នាំ១៩៩៩-២០០០ ។ អ្នកភូមិបានកត់សំគាល់ថា ពួកគាត់ត្រូវចំណាយពេល ១៥-៣០ថ្ងៃ ធ្វើដំណើរទៅឆ្ងាយៗរកកាប់ឈើសំរាប់សង់ផ្ទះ បើកាលពីមុនវិញគាត់ចំណាយពេលតែ ២-៣ថ្ងៃប៉ុណ្ណោះ ។ អ្នកភូមិបានត្អូញត្អែរផងដែរ ពីប្រាក់ផ្សេងៗដែលត្រូវបង់ទៅឱ្យយោធា និងក្រុមប្រដាប់អាវុធ នៅតាមកុងត្រូលមិនផ្លូវការ ។ ជាមធ្យម ការចំណាយនេះស្មើនឹង ១១% នៃចំណូលរបស់កសិករពីផលិតផលព្រៃឈើ ក្នុងឆ្នាំ១៩៩៩-២០០០ ហើយគ្មានការផ្តល់សេវានៃការគ្រប់គ្រងព្រៃឈើអ្វី ជាការតបស្នងនៃការចំណាយនេះទេ ។ ក្រៅពីការចំណាយទៅលើកុងត្រូលទាំងនេះ អ្នកភូមិបានសំដែងការព្រួយបារម្ភពីហានិភ័យនៃការឈឺថ្កាត់ ជាពិសេសគឺជំងឺគ្រុនចាញ់ ដែលទាក់ទងនឹងការធ្វើដំណើរចូលទៅក្នុងព្រៃផ្លូវឆ្ងាយ ។
- **កំពង់ធំ - បីភូមិ** (Chea *et al.* 1998): ភូមិពីរ ក្នុងចំណោមភូមិទាំងបី ស្ថិតនៅជាប់នឹងព្រៃសម្បទាន ។ ភូមិទាំងពីរពឹងពាក់ខ្លាំងទៅលើធនធានព្រៃឈើ គឺមាន ឈើដើមធំ និងកូនឈើវែងៗសំរាប់ធ្វើសំណង់ អុស ជ័រ វល្លិ៍ ផ្តៅ ឬស្សី ផ្លែឈើព្រៃនិងស្លឹកឈើ សត្វព្រៃ រុក្ខជាតិជាឱសថ ផ្សិត និង ដំឡូងព្រៃ ។ ភូមិទីបី ដែលស្ថិតនៅឆ្ងាយពីព្រៃ មានការពឹងពាក់តិចជាងទៅលើធនធានព្រៃឈើ ។ ភូមិទាំងបីនេះ បានត្អូញត្អែរពីបញ្ហាចោទជាមួយម្ចាស់ព្រៃសម្បទានដូចជា ការកាប់ដើមឈើសំរាប់យកជ័រដោយគ្មានការអនុញ្ញាតពីអ្នកស្រុក ឬការផ្តល់ប្រាក់ប៉ះប៉ូវ, ការកាប់

ឈើខុសច្បាប់ និងការបាត់បង់ព្រៃ, ការហាមឃាត់អ្នកភូមិមិនឱ្យចូលទៅបេះប្រមូលធនធានព្រៃឈើ និងការបង្ក សំលេងរំខាន និងការខូចខាតផ្សេងៗដែលកើតឡើង ដោយសារការដឹកឈើនៅពេលយប់ ។

- **ខេត្តកំពង់ធំ - មួយភូមិ** (Chan *forthcoming*)៖ ដោយសារដីដាំដុះមានមិនគ្រប់គ្រាន់ និងមានគុណភាពអន់ ផលស្រូវសរុបក្នុងភូមិដោះស្រាយបានតែ ១/៣ នៃតំរូវការប៉ុណ្ណោះ ។ ដូច្នេះ ជីវភាពអ្នកភូមិត្រូវពឹងផ្អែកខ្លាំងលើធនធានព្រៃឈើ ។ ប៉ុន្តែការដាក់កំហិតផ្សេងៗលើការចូលព្រៃដោយម្ចាស់សម្បទាន, ការថយចុះគុណភាពព្រៃឈើ និងការបំផ្លាញព្រៃឈើ, និងកំណើនប្រជាជនយ៉ាងលឿននៅក្នុងភូមិ, បានធ្វើឱ្យអ្នកភូមិកាន់តែក្រីក្រ ។ ទោះបីអ្នកភូមិបានអត្ថប្រយោជន៍ពីសកម្មភាពកាប់ឈើអនាធិបតេយ្យក្នុងឆ្នាំ១៩៩១-១៩៩៤ (ទទួលបាន ៣000-៤000 រៀលក្នុងមួយម៉ែត្រគូបឈើពីម្ចាស់រោងអារឈើ) ក៏ដោយ ក៏ប៉ុន្តែការផ្តល់ព្រៃសម្បទានទៅឱ្យបីក្រុមហ៊ុន ចាប់ពីឆ្នាំ១៩៩៤ មក បានបញ្ឈប់សកម្មភាពទាំងនេះភ្លាម ។ ឡានដឹកឈើឯកជនត្រូវបានហាមឃាត់ ហើយ ១១រោងអារឈើ ក្នុងចំណោម ១៣រោងអារឈើក្នុងតំបន់នោះ ត្រូវបានបិទចោល ។ ចាប់ពីឆ្នាំ១៩៩៦-១៩៩៨ សម្បទានិកបានកាប់ដើមឈើយកជ័រ "ដែលជារបស់" អ្នកស្រុក (បន្តពីមួយជំនាន់ទៅមួយជំនាន់) ផងដែរ ។ មាន ២៥គ្រួសារ បានអះអាងថាបានកាន់កាប់ដើមឈើ ៣00-៧00ដើមក្នុងមួយគ្រួសារៗពីមុនមក ក៏ប៉ុន្តែបច្ចុប្បន្នពួកគាត់មានប្រហែលតែ ៥0ដើមប៉ុណ្ណោះក្នុងមួយគ្រួសារ ហើយគ្រួសារខ្លះបាត់បង់ដើមឈើទាំងអស់របស់ខ្លួន ។ បច្ចុប្បន្ននេះ មានការពិបាកនឹងទៅរកធនធានព្រៃឈើណាស់ (ជាពិសេស ឈើសំរាប់សាងសង់) ពីព្រោះកងការពារព្រៃសម្បទានធ្វើការយាមល្បាតយ៉ាងតឹងតែងទាំងថ្ងៃទាំងយប់ ។
- **ខេត្តមណ្ឌលគីរី - មួយភូមិ** (So *et al.* 2001)៖ ក្នុងភូមិជនជាតិភ្នងនេះ គេរកឃើញថា ជាងពាក់កណ្តាលនៃចំណូលសំរាប់ជីវភាពរបស់អ្នកភូមិ បានមកពីការធ្វើដំណើរចូលទៅក្នុងព្រៃ ។ ចំណូលនេះពឹងផ្អែកសំខាន់លើការប្រមូលជ័រ (៣២%), ប្រមាញ់ (៣0%), ការដាំដំណាំបន្លាស់ទី (១៩%) ការចិញ្ចឹមសត្វ (១៣%) និងការនេសាទ (៣%) ។
- **ខេត្តរតនគីរី - ប្រាំមួយភូមិ** (Ratanakiri Provincial Rural Development Department *et al.* 2000)៖ ការសិក្សាពីធនធានវប្បធម៌នេះ បានធ្វើឡើងដើម្បីកំណត់តំបន់ព្រៃដែលមានសារៈសំខាន់ខាង សាសនា និងវប្បធម៌របស់ជនជាតិគ្រឹង ដែលរស់នៅក្នុងព្រៃសម្បទានរបស់ក្រុមហ៊ុន Hero Taiwan ។ ការសិក្សាបានរកឃើញថា បរិស្ថានរូបវន្តរបស់ជនជាតិគ្រឹង ផ្សារភ្ជាប់យ៉ាងរឹងមាំទៅនឹង សាសនា និងវប្បធម៌របស់ពួកគេ ហើយសំខាន់គឺវិញ្ញាណអ្នកតាដ៏មានអំណាចនៅក្នុងតំបន់នានា គឺមានអ្នកតាព្រៃ អ្នកតាភ្នំ និងព្រៃសក្តិសិទ្ធិ ។ តំបន់និមួយៗ មានប្រវត្តិផ្ទាល់ដែលជាប់ទាក់ទងនឹងរឿងព្រេងតំណាលតៗគ្នាពីជំនាន់មួយទៅជំនាន់មួយរាប់រយឆ្នាំមកហើយ ។ ពួកគ្រឹងជឿថាព្រលឹងដូនតា និងអ្នកថែរក្សាតំបន់នោះ មើលថែទាំភូមិរបស់ពួកខ្លួន ។ បើសិនគេធ្វើការគោរពប្រតិបត្តិបានល្អ ព្រលឹងទាំងនេះនឹងជួយបញ្ចៀសជំងឺ ការខូតខាតផលដំណាំ និងបញ្ហាផ្សេងៗទៀត ។ បើសិនគេគោរពមិនបានល្អដល់ព្រលឹងទាំងនេះ នឹងកើតមានផលវិបាកយ៉ាងធ្ងន់ធ្ងរ ។ ការសិក្សាបានរកឃើញតំបន់ជាង២0 ដែលជាកន្លែងសក្តិសិទ្ធិបំផុតសំរាប់ជនជាតិគ្រឹង ហើយភាគច្រើនគឺជាព្រៃអ្នកតាដែលអាចប៉ះពាល់ដោយការកាប់ព្រៃសម្បទាន ។
- **ខេត្តតាកែវ - បីភូមិ** (Yoshida *et al.* 2001)៖ ទោះបីព្រៃឈើកំពុងចាប់ផ្តើមដុះឡើងវិញក៏ដោយ ក៏កង្វះអុសសំរាប់ចំអិនអាហារប្រចាំថ្ងៃ នៅតែជាបញ្ហានៅឡើយ ។ អ្នកភូមិប្រហែល ២0% ទៅ ៣0% ត្រូវទិញអុសដើម្បីបំពេញតំរូវការរបស់ខ្លួន ។ គ្រួសារខ្លះប្រើអង្កាម និងអាចម៍គោសំរាប់ចំអិនអាហារ ។

ករណីសិក្សាអំពីធនធានព្រៃឈើប្រើប្រាស់ដោយសហគមន៍ បានបង្ហាញនូវបញ្ហាជាទូទៅមួយចំនួនដូចជា ៖

- **បញ្ហាកំណើនការបំផ្លាញព្រៃឈើ និងការថយចុះគុណភាពព្រៃឈើ/លទ្ធភាពចូលព្រៃ៖** ថយចុះធនធានព្រៃឈើ

ដែលអាចរកបាននៅក្បែរៗភូមិ កំពុងបង្ខំឱ្យអ្នកភូមិធ្វើដំណើរទៅតំបន់ឆ្ងាយៗដើម្បីដោះស្រាយតំរូវការខ្លួន ។ មូលហេតុនៃការថយចុះធនធានព្រៃឈើ គឺមានការហាមឃាត់មិនឱ្យចូលព្រៃដោយសារការវាតយកព្រៃសម្បទាន (៤,២ពាន់លានហិកតា), ការកាប់ឈើខុសច្បាប់និងគ្មានចីរភាព, សម្ពាធនៃកំណើនប្រជាជនដែលនាំឱ្យមានការប្រើប្រាស់ធនធានព្រៃឈើគ្មានចីរភាពនៅក្នុងតំបន់ក្បែរៗភូមិ ។

- **ផលិតផលព្រៃឈើជាច្រើនគ្មានអ្វីអាចជំនួសបាន:** ចំពោះធនធានព្រៃឈើដែលមានសារៈសំខាន់ សំរាប់ជីវភាពជនបទ ដូចជាអុសជាដើម គឺមានរបស់តិចតួចណាស់ដែលអាចជំនួសវាបាននៅពេលវាកាន់តែខ្សត់ ។ នៅពេលចំណាយកើនខ្ពស់ឡើងដើម្បីទទួលបានធនធានព្រៃឈើ (ចំណាយពេលវេលា កំលាំងពលកម្ម ថវិកា និងហានិភ័យ) អ្នកភូមិត្រូវតែរ៉ាប់រងចំណាយទាំងនេះ ។ ដូច្នេះ ការថយចុះផលិតភាពព្រៃ និងការហាមឃាត់មិនឱ្យចូលព្រៃ គឺជាបន្ទុកមួយថ្មីចំពោះជីវភាពជនបទ ។
- **ការកើនឡើងភាពក្រីក្រនៅជនបទ ដោយសារប្រព័ន្ធព្រៃសម្បទាន:** ក្នុងវិធីសាស្ត្រនៃការគ្រប់គ្រងតាមបែបសម្បទានក្នុងពេលបច្ចុប្បន្ន សម្បទានិកកាន់កាប់សិទ្ធិផ្តាច់មុខលើធនធានព្រៃឈើ ។ សិទ្ធិរបស់សហគមន៍ជនបទទៅលើទ្រព្យសម្បត្តិរួម មិនត្រូវបានទទួលស្គាល់ឡើយ ។ ការបដិសេធមិនឱ្យទាញប្រយោជន៍ពីធនធានរួម បង្ខំឱ្យសហគមន៍ជនបទធ្វើសកម្មភាពទ្រទ្រង់ជីវភាព តែនៅលើទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួនប៉ុណ្ណោះ (ដីលំនៅដ្ឋាន និងដីកសិកម្ម) ។ ប៉ុន្តែដោយសារភាពពឹងពាក់ជាទូទៅរបស់សហគមន៍ជនបទទៅលើធនធានព្រៃឈើ ដូច្នេះការផាត់ចេញមិនឱ្យអ្នកភូមិប្រើប្រាស់ធនធានទាំងនេះ នឹងបណ្តាលឱ្យភាពក្រីក្រកើនឡើង ។
- **កំនើនភាពតានតឹងលើធនធានព្រៃឈើ:** ជាទូទៅទំនាស់កើតឡើង ដោយសារការហាមឃាត់មិនឱ្យចូលទៅរកធនធានព្រៃឈើ ការបាត់បង់ព្រៃឈើដោយសារការកាប់បំផ្លាញ និង/ឬ បរិយាកាសគំរាមកំហែងកើតចេញពីប្រតិបត្តិការរក្សាសន្តិសុខព្រៃសម្បទាន ។

## ៤.៤. ការពិនិត្យមើលប្រវត្តិនៃការគ្រប់គ្រងព្រៃឈើ

មុនរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៥ អាជីវកម្មព្រៃឈើស្របច្បាប់នៅកម្ពុជា ធ្វើឡើងនៅក្រោមប្រព័ន្ធ "លិខិតអនុញ្ញាតអាជីវកម្ម" ដែលបានបង្កើតឡើងតាំងពីក្នុងរបបអាណានិគមបារាំង ។ ក្រោមប្រព័ន្ធនេះ លិខិតអនុញ្ញាតត្រូវបានធ្វើឡើងសំរាប់ពេលកំណត់មួយ ហើយបរិមាណឈើកំណត់មួយ ដោយត្រូវបង់កំរៃថេរមួយ ។ ប្រព័ន្ធនេះមានលក្ខណៈទន់ភ្លន់ អាចបត់បែនបានច្រើនណាស់ ទាំងសំរាប់អ្នកធ្វើអាជីវកម្ម និងអាជ្ញាធរផ្តល់ការអនុញ្ញាត ព្រោះអ្នកធ្វើអាជីវកម្មដែលមានលិខិតអនុញ្ញាត មិនចាំបាច់មានកិច្ចសន្យាសម្បទាន ផែនការគ្រប់គ្រង ឬការកំណត់តំបន់ប្រមូលផលជាក់លាក់ឡើយ ។

មានការយល់ដឹងតិចតួចណាស់ អំពីការគ្រប់គ្រងព្រៃឈើក្រោមរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែចលាចលក្នុងប្រទេស និងភាពឯកោដាច់ពីអន្តរជាតិ ប្រហែលជានាំឱ្យមានការថយចុះពាណិជ្ជកម្មឈើ និងការបំផ្លាញព្រៃឈើ ។ ប៉ុន្តែផ្ទុយទៅវិញ របបដែលផ្តោតទៅលើការពង្រីកកសិកម្មនេះ បានធ្វើឱ្យព្រៃលិចទឹកមួយចំនួនត្រូវបាត់បង់ ។

ក្នុងទសវត្សរ៍១៩៨០ នាយកដ្ឋានរុក្ខាប្រមាញ់មានធ្វើអាជីវកម្មឈើដោយផ្ទាល់ គឺធ្វើការកាប់ព្រៃក្នុងខេត្តកំពង់ចាម ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងកំពង់ធំ ហើយធ្វើប្រតបត្តិការរោងអារឈើនៅភ្នំពេញ ព្រៃវែង កំពង់ចាម និងកំពង់ធំ ។ ការកាប់ឈើក៏មានធ្វើឡើងផងដែរដោយ "ក្រុមសាមគ្គី" ដែលលក់ឈើកាប់ទៅឱ្យ នាយកដ្ឋានរុក្ខាប្រមាញ់ក្នុងថ្លៃថេរមួយដែលទាបជាងថ្លៃទីផ្សារ ។ យ៉ាងហោចណាស់ មានសម្បទានកាប់ឈើមួយកន្លែងមានទំហំ ៧៥.០០០ហិកតា ក្នុងខេត្តក្រចេះត្រូវបានផ្តល់ទៅឱ្យសាធារណៈរដ្ឋសង្គមនិយមវៀតណាម សំរាប់រយៈពេលពីមួយឆ្នាំ និងបន្តម្តងមួយឆ្នាំ (Curtis 1989) ។

សន្ទុះនៃការធ្វើអាជីវកម្មព្រៃឈើចាប់កើនឡើងនៅចុងទសវត្សរ៍១៩៨០ នៅពេលដែលក្រុមបក្សនយោបាយ និងយោធាផ្សេងៗ, មន្ត្រីយោធាថៃ, និងអ្នកជំនួញ, បានធ្វើការសំរុកកាប់ និងលក់ឈើប្រភេទរឹងនិងថ្លៃៗ ។ នៅដើមទសវត្សរ៍១៩៩០ មានរបាយការណ៍ពីការកាប់ឈើទូទៅនៅកម្ពុជា ។ ដោយកត់សំគាល់នូវកំនើនប្រហែលបួនដងក្នុងសកម្មភាពកាប់ឈើ The Far Eastern Economic Review (1992) បានលើកឡើងថា "ការបំផ្លាញពីអតីតកាល វាតូចតាចទេ បើធៀបនឹងការវាយលុកពេញទំហឹងទៅលើព្រៃឈើ ដែលអតីតភាគីច្បាំងគ្នាទាំង៤ កំពុងលើកផែនការ... ។ ភាគីនិមួយៗត្រូវការថវិកាសំរាប់រៀបចំការបោះឆ្នោតជ្រើសតាំងរដ្ឋាភិបាលនៅខែឧសភាខាងមុខ ហើយព្រៃឈើគឺជាចំលើយមួយដ៏ងាយ" (In Talbott 1998) ។ ដោយសារភាពដាច់ស្រយាល និងស្ថានភាពមានគ្រោះថ្នាក់នៃជនបទកម្ពុជាភាគច្រើនក្នុងពេលនោះ ដូច្នេះគេមានឯកសារតិចតួចណាស់ស្តីពីសកម្មភាព និងច្បាប់ទំលាប់ក្នុងការកាប់ឈើ ។ ប៉ុន្តែគេឃើញច្បាស់ថាកំលាំងនយោបាយធំៗទាំងបីដែលប៉ុនប៉ងក្តោបក្តាប់កម្ពុជា គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងខ្មែរក្រហមបានចូលរួមយ៉ាងខ្លាំងក្នុងការកាប់ឈើនៅតំបន់ស្ថិតក្រោមការ ត្រួតត្រារបស់គេ (Talbott 1998) ។

ក្រោយពីការបោះឆ្នោត១៩៩៣ បញ្ហាកាប់ឈើដោយគ្មានការត្រួតពិនិត្យបានកើតមានជាបន្ត ។ ចំណុចគួរឱ្យកត់សំគាល់មួយគឺ រដ្ឋាភិបាលបានធ្វើសេចក្តីសំរេចចិត្តនៅខែមិថុនា ឆ្នាំ១៩៩៤ គឺបានផ្តល់សិទ្ធិត្រួតពិនិត្យការនាំចេញឈើទៅឱ្យក្រសួងការពារជាតិ ។ ការសំរេចចិត្តនេះដែលសំដៅប្រមូលចំណូលពីការលក់ឈើសំរាប់យុទ្ធនាការរបស់កងខេមរភូមិន្ទកម្ពុជា ប្រឆាំងនឹងពួកខ្មែរក្រហម បានពង្រឹងនូវតួនាទីរបស់យោធាក្នុងការកាប់ឈើ ។

ក្នុងទសវត្សរ៍១៩៩០ រដ្ឋាភិបាលបានបង្កើតឡើងវិញនូវប្រព័ន្ធលិខិតអនុញ្ញាតអាជីវកម្ម និងសម្បទានព្រៃឈើជាលក្ខណៈឧស្សាហកម្មឯកជន សំរាប់ប្រើជាឧបករណ៍ចំបងក្នុងការគ្រប់គ្រងព្រៃឈើបែបពាណិជ្ជកម្ម ។ ប្រព័ន្ធទាំងពីរត្រូវបានពិភាក្សាលំអិតនៅខាងក្រោម ។ លិខិតអនុញ្ញាតអាជីវកម្ម ត្រូវបានហាមឃាត់នៅឆ្នាំ១៩៩៩ ប៉ុន្តែព្រៃសម្បទាននៅតែជាវិធីចំបងបំផុតសំរាប់ការគ្រប់គ្រងព្រៃឈើនៅកម្ពុជារហូតមកដល់សព្វថ្ងៃ ។

## ៤.៥. ប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើ

ប្រព័ន្ធនេះដែលធ្លាប់មានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ១៩៧៥មកម្ល៉េះ ត្រូវបានប្រើប្រាស់ជាថ្មីធ្វើជាមូលដ្ឋាននៃការកាប់ឈើគ្រប់ទិសទីនៅកម្ពុជាពីឆ្នាំ១៩៩៤-១៩៩៨ ។ លិខិតទាំងនេះ ដែលមានការអនុញ្ញាតពី គណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម ក្រសួងការពារជាតិ អភិបាលខេត្ត ឬមន្ត្រីថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវបានផ្តល់ឱ្យសម្បទានិកព្រៃឈើ អង្គភាពយោធា ក្រុមហ៊ុនជំនួញឈើ និងបុគ្គលមួយចំនួន និងផ្តល់ឱ្យនូវសិទ្ធិប្រមូលឈើចាស់ ឈើខុសច្បាប់ ឬឈើអនាធិបតេយ្យ ក្នុងចំនួនកំណត់ណាមួយ នៅក្នុងតំបន់ព្រៃណាមួយ និងក្នុងកំលុងពេលជាក់លាក់ណាមួយ ។

ប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើ ត្រូវបានគេបញ្ជាក់ហេតុផលថាជាមធ្យោបាយសមស្របចៀសវាងការខាតបង់វត្ថុធាតុដើមដ៏មានតំលៃដែលត្រូវទុកឱ្យពុកចោល បើសិនមិនប្រមូលយក ។ ក្នុងការអនុវត្តន៍ជាក់ស្តែង គំរោងតាមដានឈើនិងគ្រប់គ្រងការកាប់ឈើ បានរកឃើញថា ឈើចាស់ៗជាទូទៅគឺជាលទ្ធផលនៃការកាប់ដោយៈ (ក) អ្នកម៉ៅការកាប់ឈើឱ្យសម្បទានិក ដែលធ្វើសកម្មភាពតាមសំណើរបស់សម្បទានិក, (ខ) ក្រុមកាប់ឈើឯករាជ្យដែលធ្វើសកម្មភាពដោយមានជំនឿថា ការផ្តល់លិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើអាចផ្តល់នូវទីផ្សារក្នុងពេលអនាគតសំរាប់ឈើរបស់ពួកគេ, (គ) ក្រុមអ្នកកាប់ឈើនៅមូលដ្ឋាន នៅក្រោមការត្រួតត្រារបស់មន្ត្រីរដ្ឋាភិបាល ដែលធ្វើការកាប់ឈើព្រោះបានដឹងថា មានការផ្តល់លិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើរួចហើយ (DAI 1998) ។ ចំពោះបរិមាណឈើនៅក្នុងលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើ ភាគច្រើនគឺត្រូវបានបំពេញដោយការកាប់ឈើខុសច្បាប់ មិនមែនដោយការប្រមូលឈើចាស់នោះទេ ។

ឈើលក់ចេញក្រោមប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើ មានប្រហែល ៦% នៃបរិមាណឈើកាប់ក្នុងឆ្នាំ១៩៩៧ ប៉ុន្តែនៅមានឈើក្នុងចំនួនមិនច្បាស់លាស់មួយភាគទៀតដែលត្រូវបានកាប់និងលក់ក្រោម ប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើ ដោយគ្មានការបង់សួយឬប្រាក់កំរៃអ្វីទាំងអស់ (តារាង៤.៣) ។ ទោះបីទិន្នន័យស្តីពីចំនួនឈើសរុបក្រោមរបបលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើដោយគ្មានបង់ពន្ធ និងបរិមាណឈើដែលបានអនុញ្ញាតឱ្យកាប់ពុំមានផ្តល់ទៅឱ្យ គំរោងតាមដានឈើនិងគ្រប់គ្រងការកាប់ឈើក៏ដោយ ក៏គេអះអាងថា ការអនុញ្ញាតទាំងនេះតំណាងឱ្យមួយភាគធំនៃផលឈើក្នុងឆ្នាំ១៩៩៧ (DAI, 1998) ។

កងកំលាំងប្រដាប់អាវុធក៏បានទទួលនូវលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើពិសេសដែរ សំរាប់បរិមាណឈើយ៉ាងច្រើន ប៉ុន្តែគេមិនអាចរកបានទេនូវឯកសារច្បាស់លាស់ដែលបញ្ជាក់ពីការអនុញ្ញាតនេះ ។ ក្រៅពីសកម្មភាពកាប់ឈើស្របច្បាប់ដោយយោធា នៅមានការកាប់ឈើជាច្រើនទៀតដោយក្រុមប្រដាប់អាវុធដែលគ្មានការអនុញ្ញាត ក្នុងនេះមួយចំនួនក្តោបក្តាប់ដោយមេបញ្ជាការយោធា និងមួយចំនួនក្តោបក្តាប់ដោយអ្នកខ្លាំងផ្សេងទៀតដូចជាមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្តជាដើម ។ ក្រុមប្រដាប់អាវុធដែលចូលរួមកាប់ឈើ ជាទូទៅបានលក់ឈើកាប់ទៅឱ្យ ម៉ាស៊ីនអារឈើនៅមូលដ្ឋាន អ្នកទិញមកពីប្រទេសជិតខាង អ្នកមានលិខិតអនុញ្ញាត, ពាណិជ្ជករ ឬ សម្បទានិក (DAI 1998) ។

សេចក្តីប្រកាសលេខ១ ក្នុងខែមករា ១៩៩៩ របស់នាយករដ្ឋមន្ត្រី បានកត់សំគាល់ពីបញ្ហាខាងលើ ហាមឃាត់ការផ្តល់លិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើថ្មីៗទៀត និងទុកជាមោឃៈលិខិតអនុញ្ញាតដែលមានស្រាប់ ។ បំរាមនេះហាក់ដូចជាមានប្រសិទ្ធិភាពខ្លាំងក្នុងការកាត់បន្ថយសិទ្ធិស្របច្បាប់នៃការកាប់ឈើតាមលិខិតអនុញ្ញាត ប៉ុន្តែអង្គភាពតាមដានឧក្រិដ្ឋកម្មព្រៃឈើ បានរាយការណ៍ថា មានការរំលោភលើបំរាមមួយចំនួន ។ ឧទាហរណ៍ ក្រុមហ៊ុន Super Wood IPEP Ltd ប្រហែលត្រូវបានផ្តល់សិទ្ធិឱ្យប្រមូល"ឈើចាស់"ក្នុងឆ្នាំ១៩៩៩-២000 ដែលទំនងជាបំរើគោលដៅរកថវិកា សំរាប់ទ្រទ្រង់ការវិនិយោគក្នុងប្រតិបត្តិការព្រៃសម្បទាន (Forest Crime Monitoring Unit, 2000) ។

## ៤.៦. ការគ្រប់គ្រងព្រៃសម្បទាន

ពីឆ្នាំ១៩៩៤-១៩៩៧ រដ្ឋាភិបាលបានបង្កើតសម្បទានព្រៃឈើជាថ្មី ដើម្បីជាឧបករណ៍ចំបងក្នុងការគ្រប់គ្រងព្រៃឈើ ។ មានការផ្តល់សម្បទានជាង ៣0កន្លែង ដែលមានផ្ទៃដីប្រហែល ៥.៩លានហិកតា គឺត្រូវជាជាង ១/៣នៃផ្ទៃប្រទេស និងជាងពាក់កណ្តាលនៃព្រៃឈើនៅកម្ពុជា ។ ប្រព័ន្ធសម្បទានថ្មី ត្រូវបានដាក់អនុវត្តត្រួតពីលើប្រព័ន្ធលិខិតអនុញ្ញាតប្រមូលផលនិងអនុផលព្រៃឈើដែលមានស្រាប់ ហើយបានបង្កឱ្យមានភាពមិនច្បាស់លាស់នៅក្នុងបរិបទផ្លូវច្បាប់ សំរាប់ការគ្រប់គ្រងព្រៃពាណិជ្ជកម្ម ។

តាមរយៈការបង្កើតប្រព័ន្ធសម្បទានព្រៃឈើឡើងវិញ រដ្ឋាភិបាលប្រឹងប្រែងផ្ទេរសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ ទៅឱ្យក្រុមហ៊ុនឯកជន ព្រមទាំងប្រមូលចំណូលដែលត្រូវការចាំបាច់សំរាប់ការអភិវឌ្ឍន៏ជាតិ ។ ប៉ុន្តែ សម្បទានត្រូវបានផ្តល់តាមរយៈការចរចាជាឯកជនរវាងមន្ត្រីថ្នាក់ខ្ពស់ និងសម្បទានិក ដែលបង្កឱ្យមានកិច្ចសន្យាមិនច្បាស់លាស់ លំអៀងខ្លាំងទៅខាងសម្បទានិក ។ យោងតាមអ្នកវិភាគច្បាប់ដែលទ្រទ្រង់ដោយគំរោងកែទំរង់គោលនយោបាយព្រៃឈើរបស់ធនាគារពិភពលោក "កិច្ចសន្យាសម្បទានលំអៀងខ្លាំងណាស់ទៅខាងសម្បទានិក ដែលគេអាចចោទសួរបានថា តើវាសមរម្យឬទេជាលក្ខណ:ពាណិជ្ជកម្ម" (White and Case 1998) ។ អ្នកវិភាគបានរកឃើញថា កិច្ចសន្យាមានភាពមិនច្បាស់លាស់ខ្លាំង និងចោទបញ្ហាស្មុគស្មាញ ដែលស្ទើរតែគ្មានប្រយោជន៏អ្វីទេ បើសិនជាយើងពិនិត្យមួយបន្ទាត់ម្តងៗ ។ ក្នុងចំណោម ៤២បញ្ហាចោទខុសៗគ្នា គេបានកត់សំគាល់ចំណុចមួយចំនួនដូចខាងក្រោម:

- កិច្ចសន្យាសម្បទានគ្មានចែងក៏រិតគោល/ស្តង់ដា សំរាប់វាយតំលៃពីការគ្រប់គ្រងដើម្បីឱ្យមានចីរភាពទិន្នផល ។

- កិច្ចសន្យាសម្បទាន មិនបានកំណត់ពីនីតិវិធីបង់សួយ មិនបានផ្តល់ចំណូល ឬអត្ថប្រយោជន៍ផ្សេងទៀតឱ្យបានច្រើនជាអតិបរមាដល់រដ្ឋាភិបាល និងគ្មានចែងពីទណ្ឌកម្មចំពោះការមិនបង់ថ្លៃទេ ។
- កិច្ចសន្យាសម្បទានខ្វះការពិពណ៌នាលំអិតអំពីព្រំប្រទល់ព្រៃសម្បទាន ។

ការផ្តល់សម្បទាន បានប្រព្រឹត្តទៅដោយគ្មានការវាយតំលៃធនធានព្រៃឈើ ឬការពិចារណាពីផលប៉ះពាល់ខាងបរិស្ថាន ឬសង្គមកិច្ចទេ (Fraser Thomas *et al.* 2000) ។ ព្រំប្រទល់ព្រៃសម្បទាន ត្រូវបានដៅនៅលើផែនទី ដោយមានការពិចារណាតិចតួចពីផលប៉ះពាល់ដែលអាចកើតមានចំពោះប្រជាជនមូលដ្ឋាន ទីកន្លែងវប្បធម៌ ដីជំរាលប្រមូលទឹកភ្លៀងសំខាន់ៗ និងតំបន់អេកូឡូស៊ីដែលងាយប៉ះពាល់ ។ ទាក់ទិននឹងបញ្ហាព្រំប្រទល់ព្រៃសម្បទាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរាយការណ៍ក្នុងពេលថ្មីៗនេះថា មានដី ៧៥១.៩៦៨ហិកតា (ឬ ១៧%) នៃតំបន់ព្រៃសម្បទានបច្ចុប្បន្ន ដែលស្ថិតនៅក្រោមផលិតកម្មកសិកម្ម (MAFF 2002) ។

### *៤.៦.១. ស្ថានភាពនៃព្រៃសម្បទានបច្ចុប្បន្ន*

យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាមាន ១៩ក្រុមហ៊ុន បានកាន់កាប់កិច្ចសន្យាព្រៃសម្បទានចំនួន ១៩កន្លែង មានផ្ទៃសរុប ៤,២លានហិកតា (តារាង៤.៤) ។ ព្រៃសម្បទានជាច្រើនត្រូវបានលុបចោលវិញ ក្នុង ៣-៤ឆ្នាំកន្លងមកនេះ ប៉ុន្តែ ក្នុងករណីជាច្រើន ការលុបចោលនេះមិនបានបន្សល់ទុកនូវព្រៃសំរាប់រក្សាទុកទេ ពីព្រោះព្រៃសម្បទានត្រូវបានកាប់ឈើអស់ ហើយមុននឹងត្រូវបានគេលុបចោល ។ នៅឆ្នាំ១៩៩៩ រដ្ឋាភិបាលបានលុបកិច្ចសន្យាព្រៃសម្បទានចំនួន ១២កន្លែងដែលពាក់ព័ន្ធ ដល់ ១០ក្រុមហ៊ុន និងមានផ្ទៃដីប្រហែល ២,៣លានហិកតា ។ កិច្ចសន្យាសម្បទានត្រូវបានលុបចោល ពីព្រោះមានការបំពានលើ មាត្រា១០.៤ នៃកិច្ចព្រមព្រៀងវិនិយោគ[៣៣] ។ ក្រុមហ៊ុនមួយបានស្ម័គ្រចិត្តបញ្ចប់កិច្ចសន្យាសម្បទានរបស់ខ្លួន ដោយសារតែគ្មានភាពចំណេញផ្នែកពាណិជ្ជកម្ម ។ ក្រុមហ៊ុនសម្បទានពីរទៀត (Hero Taiwan Company and Voot Tee Peanich Import Expor Co., Ltd) ត្រូវបានលុបចោលនៅខែឧសភា ឆ្នាំ២០០២[៣៤] ។ មានសេចក្តីរាយការណ៍ផងដែរថា ព្រៃសម្បទានរបស់ក្រុមហ៊ុន GAT International ត្រូវបានលុបចោលនៅចុងខែមិថុនា ឆ្នាំ២០០២ អាស្រ័យដោយសារតែមានការបំពានលើបំរាមកាប់ឈើ ក៏ប៉ុន្តែ ការលុបចោលនេះ មិនអាចបញ្ជាក់ជាផ្លូវការឡើយ នៅពេលបោះពុម្ពឯកសារនេះ ។

ក្រុមហ៊ុនឈើទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន គឺជាសមាជិកនៃសមាគមឧស្សាហកម្មឈើហ៊ុបនៅកម្ពុជា (CTIA) ។ ទោះជាមានសមាគមពាណិជ្ជកម្ម និងក្រុមហ៊ុនបរទេសជាច្រើនក៏ដោយ ក៏សក្តានុពលនៃការផ្ទេរជំនាញឯកទេសបរទេសមកឱ្យអ្នកគ្រប់គ្រងព្រៃឈើកម្ពុជា ហាក់ដូចជាមិនទាន់ឃើញកើតមាននៅឡើយ ។ តាមការធ្វើចំណាត់ថ្នាក់ដោយ The Cambodian Forest Coccession Review (2000) និងការវិភាគដោយឡែកដោយ Global Witness (1999a) គេឃើញថា មានក្រុមហ៊ុនពីរប៉ុណ្ណោះ គឺ GAT International និង Samling International ដែលមានសមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងព្រៃឈើទៅតាមបច្ចេកទេសវិជ្ជាជីវៈត្រឹមត្រូវ ប៉ុន្តែមានគេរាយការណ៍ថា ក្រុមហ៊ុនទាំងពីរបានធ្វើសកម្មភាពខុស

---

[៣៣] មាត្រា១០.៤: ក្នុងករណីដែលវិនិយោគិនមិនធ្វើតាមកិច្ចព្រមព្រៀងនេះ និងមិនបានចាប់ផ្តើមសកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់សម្បទានក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលកម្ពុជារក្សាសិទ្ធិក្នុងការបញ្ចប់កិច្ចព្រមព្រៀងដោយគ្មានលក្ខខ័ណ្ឌ និងដោយគ្មានការចេញសំណង ។ ការបញ្ចប់កិច្ចសន្យានេះ នឹងបណ្តាលឱ្យមានការរឹបអូសយកប្រាក់កក់របស់វិនិយោគិនដែលបានបង់ទៅឱ្យរាជរដ្ឋាភិបាល អនុលោមទៅតាមមាត្រា១៣នៃអាជ្ញាប័ណ្ណឈើព្រៃ ។

[៣៤] កិច្ចសន្យាសម្បទានទាំងនេះត្រូវបានលុបជាផ្លូវការ តាមសេចក្តីសំរេចលេខ ២៧ សសរ ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០២ (Global Witness 2002) ។

ច្បាប់[៣៥] ។ ក្រុមហ៊ុនឯទៀត១ គឺជាវិនិយោគិនដែលជួលកិច្ចសន្យាកាប់ឈើបន្តទៅឱ្យភាគីទីបី ។ យោងទៅតាមរបាយការណ៍របស់ Global Witness (1995-2001) អ្នកទទួលកិច្ចសន្យាបន្តទាំងនេះ ភាគច្រើនជាអង្គភាពយោធា ឬអ្នកជំនួញមានខ្សែរយៈមាំ១ (ខ្នង) និងអ្នកមានអំណាច ដែលកាប់ឈើដោយមិនរើសមុខ ទាំងនៅក្នុង និងនៅក្រៅតំបន់សម្បទាន ទាំងនៅក្នុងតំបន់ការពារទៀតផង ។

The Cambodia Forest Coceession Review (2000) បានរកឃើញថា នៅកម្ពុជាគ្មានព្រៃសម្បទានណាមួយដែលមានការគ្រប់គ្រងប្រកបដោយចីរភាព គឺការកាប់ឈើមានកំរិតខ្ពស់ជាងអត្រាដែលគេរំពឹងទុកសំរាប់រយៈពេល ២៥-៣០ឆ្នាំនៃអាជ្ញាប័ណ្ណព្រៃឈើ ។ មានតែឆ្នាំ១៩៩៩ ប៉ុណ្ណោះ ដែលអត្រាកាប់ឈើបានធ្លាក់ចុះ ហើយ The Concession Review បានគិតថាមកពីក្រុមហ៊ុនសម្បទាន "មិនអាចរកឈើកាប់បានគ្រប់គ្រាន់" ។ ដូចមានបង្ហាញក្នុងតារាង៤.៤ ក្រុមហ៊ុនសម្បទានចំនួន៧នៅសល់រយៈពេលប្រមូលផលមិនដល់ ៥ឆ្នាំទៀតទេ, ៧ក្រុមហ៊ុនទៀតនៅសល់រយៈពេល ៥-១០ឆ្នាំ និង ៧ក្រុមហ៊ុនផ្សេងទៀតនៅសល់ ១០-១៥ឆ្នាំ ។ ក្រៅពីក្រុមហ៊ុនសម្បទានដែលចុះក្នុងតារាង៤.៤, The Concession Review បានរកឃើញកិច្ចសន្យាសម្បទានចំនួន៣ ដែលគ្មានលក្ខណៈចំណេញសំរាប់ការគ្រប់គ្រងបែបពាណិជ្ជកម្ម ពីព្រោះមានការបំផ្លាញធនធានព្រៃឈើរួចទៅហើយ ។ យោងតាមអនុសាសន៍របស់ The Concession Review នេះ រដ្ឋាភិបាលបានបញ្ឈប់កិច្ចសន្យាទាំងបី នៅមុនពេលមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយម្ចាស់ជំនួយនៅខែឧសភា ឆ្នាំ២០០០[៣៦] ។

## *៤.៦.២. លទ្ធភាពចំណេញរបស់ក្រុមហ៊ុនសម្បទាន*

យោងតាមពង្រាងអត្ថបទសិក្សាមួយរៀបចំឡើងក្នុងឆ្នាំ២០០១ ដោយក្រុមហ៊ុន KPMG គឺប្រព័ន្ធសម្បទានពុំឃើញមានផលចំណេញសំរាប់ក្រុមហ៊ុនសម្បទានសោះ ។ ដោយបាន CTIA ជួយគាំទ្រ, KPMG បានប្រមូលទិន្នន័យបឋមពី៥សម្បទានិកជា តំណាង ដើម្បីវាយតំលៃពីភាពចំណេញជាមធ្យម លទ្ធភាពបង់សួយ និងពន្ធនាំចេញរបស់សម្បទានិក។ ៥ក្រុមហ៊ុនសម្បទាននេះ មាន ៤០% នៃផ្ទៃដីព្រៃសម្បទានសរុបនៅកម្ពុជា ។ KPMG បានសន្និដ្ឋានថា "ក្នុងរយៈពេល៣ឆ្នាំកន្លងទៅ (១៩៩៧-៩៩) អ្នក ប្រមូលផលឈើនៅកម្ពុជាជាមធ្យម គឺមិនអាចរកចំណូលវិជ្ជមានសុទ្ធបានច្រើនគ្រប់គ្រាន់ និងមិនអាចសំរេចបាននូវការរំពឹងទុក នៃផលចំណេញក្នុងកំរិតសមហេតុផលមួយឡើយ" ។ ចំណូលសុទ្ធជាមធ្យមក្នុងឈើមូលមួយម៉ែត្រគូប (មុនបង់សួយ និងពន្ធនាំ ចេញ) មានប្រហែល -១៧,៣៤ដុល្លារនៅឆ្នាំ១៩៩៧, -៤៩,៥៣ដុល្លារនៅឆ្នាំ១៩៩៨ និង ៧,៧៣ នៅឆ្នាំ១៩៩៩ ។ KPMG បានលើកយោបល់ថា លទ្ធផល "ដ៏អន់ខ្សោយ" របស់ក្រុមហ៊ុនសម្បទានបានបន្សល់ទុកនូវចំណូលតិចតួចឬគ្មានសោះ សំរាប់ការ បង់សួយ និងពន្ធនាំចេញឱ្យរដ្ឋាភិបាល" ។ មានតែនៅឆ្នាំ១៩៩៦ ប៉ុណ្ណោះ ដែលក្រុមហ៊ុនជាមធ្យមសំរេចបាននូវចំណូលសុទ្ធ វិជ្ជមានក្នុងកំរិតទាបក៏ប៉ុន្តែទាល់តែយកចេញសិននូវសួយ និងពន្ធនាំចេញរបស់រដ្ឋាភិបាល... ។ ការណ៍នេះមានន័យថា ក្រុមហ៊ុន គ្មាននៅសល់ចំណូល

[៣៥] ឧទាហរណ៍ នៅរដូវកាប់ឈើឆ្នាំ១៩៩៩-២០០០ GAT បានកាប់ឈើចំនួន ៧៧៧ដើមដោយខុសច្បាប់ (ប្រហែល ២.០០០ម[៣]) នៅភាគកណ្តាលនៃតំបន់ភ្នំក្រវាញ ។ ថ្មី១នេះ Global Witness (2002) បានរាយការណ៍ពីការកាប់ឈើខុសច្បាប់ប្រហែល ១.០០០ដើមដោយ GAT (មានតំលៃទីផ្សារប្រហែល ១លានដុល្លារ) នៅតំបន់ក្រៅព្រៃគុបស្របច្បាប់ ។ ការកាប់ឈើខុសច្បាប់នេះ ត្រូវបានអនុវត្តក្នុងកំលុងឆ្នាំ ២០០២ គឺនៅពេលសកម្មភាពកាប់ឈើទាំងអស់ត្រូវផ្អាកជាផ្លូវការ ក្រោមសេចក្តីប្រកាសស្តីពីការផ្អាកសកម្មភាពកាប់ឈើព្រៃសម្បទានដែលមានប្រសិទ្ធិភាពចាប់ពីខែមករា ឆ្នាំ២០០២ ។ Samling International គឺជាក្រុមហ៊ុនមួយក្នុង ចំនោមក្រុមហ៊ុនតែពីរប៉ុណ្ណោះដែលបានទទួលការស្តីបន្ទោសជាផ្លូវការពីសំណាក់រដ្ឋាភិបាលលើសកម្មភាពរបស់ខ្លួន (Global Witness 1999a) ។

[៣៦] កិច្ចសន្យាដែលគេបានលុបចោល គឺរបស់: ១. Lansong International Co. Ltd. ដែលមានតែ ៥ព្រៃគុបប៉ុណ្ណោះ ២. Long Day Machinery Industry Co. Ltd. ដែលមាន ១១ព្រៃគុប ក្នុងនោះ ៤ព្រៃគុបគ្មានកន្លែងដែលប្រតិបត្តិការបាន និង ៧ព្រៃគុបត្រូវបានកាប់ឈើយ៉ាងច្រើនដោយសកម្មភាពខុសច្បាប់ពីអតីតកាល និង ៣. Cambodia Timber Product Pty. Ltd. មាន ៣ព្រៃគុបដែលសុទ្ធតែត្រូវបានកាប់ឈើអស់ដោយសកម្មភាពខុសច្បាប់ (Fraser Thomas *et al.* 2000) ។

ឬប្រាក់ឈ្នួលអ្វីសំរាប់បង់សួយ និងពន្ធដារទេ នៅក្នុងឆ្នាំទាំងឡាយដែលគេបានធ្វើការសិក្សា ។

## តារាង ៤.៤ ពតិមានស្តីពីព្រៃសម្បទាន

| ឈ្មោះក្រុមហ៊ុន | ខេត្ត | ប្រទេសជាម្ចាស់ក្រុមហ៊ុន | ផ្ទៃដី (ha) | ចំនួនឆ្នាំនៅសល់ សំរាប់ប្រមូលផល[១] |
|---|---|---|---|---|
| 1. GAT International Co., Ltd[2,3] | កោះកុង ពោធិសាត់ | ម៉ាឡេស៊ី | 215,720 | >10 |
| 2. GAT International Co., Ltd[2] | កំពង់ធំ ក្រចេះ | ម៉ាឡេស៊ី | 149,780 | 5-6 |
| 3. Colexim Enterprise | កំពង់ធំ | កម្ពុជា / ជប៉ុន | 147,187 | 10-15 |
| 4. Casotim Co., Ltd | ក្រចេះ | កម្ពុជា / រុស្ស៊ី | 131,380 | 3-6 |
| 5. Samling International Ltd | ក្រចេះ កំពង់ចាម មណ្ឌលគីរី | ម៉ាឡេស៊ី | 467,484 | 3-5 |
| 6. Samling International Ltd[3] | កំពង់ស្ពឺ កោះកុង | ម៉ាឡេស៊ី | 298,598 | 5 |
| 7. Mieng Ly Heng Investment Co., Ltd | កំពង់ធំ ព្រះវិហារ កំពង់ចាម | កម្ពុជា | 198,500 | 6-7 |
| 8. Pheapimex Fuchan Cambodia Co., Ltd | កំពង់ធំ ក្រចេះ ស្ទឹងត្រែង ព្រះវិហារ | តៃវ៉ាន់ / កម្ពុជា | 358,725 | 5-10, >10 in Stung Treng |
| 9. Pheapimex Fuchan Cambodia Co., Ltd | ស្ទឹងត្រែង រតនគីរី | តៃវ៉ាន់ / កម្ពុជា | 350,000 | >10 |
| 10. King Wood Industry Pte, Ltd | ក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី | តៃវ៉ាន់ | 301,200 | 3 |
| 11. Cambodia Cherndar Plywood Mfg. Co., Ltd | ព្រះវិហារ | តៃវ៉ាន់ | 103,300 | 5-10 |
| 12. Sam Rong Wood Industry Pte., Ltd | សៀមរាប | កម្ពុជា | 200,050 | 5-10 |
| 13. Everbright CIG Wood Co., Ltd | ក្រចេះ ស្ទឹងត្រែង | ចិន | 136,376 | 10-15 |
| 14. Super Wood IPEP Ltd | ពោធិសាត់ កំពង់ស្ពឺ | ម៉ាឡេស៊ី | 94,419 | 10-15 |
| 15. Timas Resources Ltd | កំពង់ចាម ក្រចេះ ព្រះវិហារ | សឹង្ហបុរី | 161,450 | 10-12 |
| 16. Silverroad Wood Products Ltd[3] | កោះកុង ពោធិសាត់ | ចិន | 215,460 | <5 |
| 17. Silverroad Wood Products Ltd | កោះកុង | ចិន | 100,000 | <5 |
| 18. You Ryasco Company | ពោធិសាត់ បាត់ដំបង | កម្ពុជា | 214,000 | <10 |
| 19. TPP Cambodia Timber Product PTE, Ltd | សៀមរាប ព្រះវិហារ ពោធិសាត់ | ថៃ | 395,900 | 2-4 |
| **១៥ ក្រុមហ៊ុន, ១៩សម្បទាន** | **សម្បទានមាននៅក្នុង ១២ខេត្ត** | **ក្នុងចំណោម ១៩ព្រៃសម្បទាន ១៦មានក្រុមហ៊ុនបរទេសចូលរួម** | **4,239,529** (ស្មើនឹង ៤០% ផ្ទៃព្រៃសរុប) | **6 concessions with >10 years**<br>**6 concessions with 5-10 years**<br>**7 concessions with <5 years** |

[១] *ការប៉ាន់ស្មានផ្អែកលើការវាយតំលៃដែលធ្វើឡើងនៅក្នុងកំលុងរដូវកាប់ឈើ ឆ្នាំ១៩៩៩-២០០០ ។*

[២] *គេបានរាយការណ៍ថា ព្រៃសម្បទានរបស់ GAT Internation ត្រូវបានលុបចោលនៅចុងខែមិថុនា ដោយសារការរំលោភលើការផ្អាកកាប់ឈើបណ្តោះអាសន្ន ប៉ុន្តែការលុបចោលនេះមិនអាចបញ្ជាក់ជាផ្លូវការបានទេនៅពេលបោះពុម្ពនេះ ។*

[៣] *គេបានរាយការណ៍ថា ការការពារភាគកណ្តាលនៃតំបន់ភ្នំក្រវាញ នឹងត្រូវសំរេចនៅចុងខែមិថុនា ដែលជាការប្តូរផ្ទៃធំៗនៃសម្បទានទាំងនេះ ពីតំបន់ផលិតកម្ម ទៅជាព្រៃការពារវិញ ។*

*ប្រភព: Fraser Thomas et al. 2000, Appendix 8; Chan et al.2001*

## ៤.៧. ការគ្រប់គ្រងព្រៃសហគមន៍

ដោយធនធានរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ បានផ្ដោតលើការអភិវឌ្ឍន៍ និងការកែទំរង់ប្រព័ន្ធព្រៃសម្បទាន ដូច្នេះព្រៃសហគមន៍មិនសូវមានគេយកចិត្តទុកដាក់ទេនៅកម្ពុជា ។ ឧទាហរណ៍ របាយការណ៍ដ៏មានឥទ្ធិពលរបស់ធនាគារពិភពលោក គឺ *Cambodia: A Vision for Forestry Sector Development (1999)* បានអំពាវនាវឱ្យកសាងវិស័យព្រៃឈើមួយដែលក្នុងនោះ "ព្រៃដែលនៅមានស្តុកឈើច្រើន" គឺទុកសំរាប់ផលិតកម្មពាណិជ្ជកម្ម រីឯ "តំបន់ព្រៃតូចតាចដែលមានដើមឈើខ្វះៗ" គឺទុកសំរាប់ឱ្យសហគមន៍មូលដ្ឋានគ្រប់គ្រង ។ គេត្រូវទទួលស្គាល់ថា "សហគមន៍ព្រៃឈើ គឺជាមធ្យោបាយដើម្បីឱ្យសំរេចបាននូវការគ្រប់គ្រងធនធានព្រៃឈើមានចីរភាពមួយភាគធំដែលមិនសមស្របសំរាប់ការធ្វើអាជីវកម្មពាណិជ្ជកម្ម ហើយហួសពីសមត្ថភាពគ្រប់គ្រងផ្ទាល់របស់រដ្ឋាភិបាល" ។ ទស្សនៈវិស័យនេះមិនបញ្ជាក់ទេថាតើសហគមន៍នៅក្នុង ឬនៅជាប់នឹងព្រៃដែលមានតំលៃពាណិជ្ជកម្ម គួរមានសិទ្ធិជាអាទិភាពឬទេដើម្បីទទួលប្រយោជន៍ពីធនធានទាំងនោះ ឬថាតើទឹកចិត្តសហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើឱ្យមានចីរភាព នឹងត្រូវប៉ះពាល់ឬទេ បើពួកគេទទួលបានតែសិទ្ធិគ្រប់គ្រងតំបន់ដែលនៅសល់ឈើតិចតួច និងមានតំលៃទាបនោះ ។

នៅក្នុងពេលថ្មីៗ គេបានយកចិត្តទុកដាក់ច្រើនណាស់ទៅលើសហគមន៍ព្រៃឈើ ថាជាជំរើសដ៏ប្រសើរមួយ សំរាប់ជំនួស (ឬបំពេញបន្ថែម) ចំពោះការគ្រប់គ្រងបែបព្រៃសម្បទាន ។ សហគមន៍ព្រៃឈើ មានន័យជាគោល១ថា គឺជាការប្រឹងប្រែងជួយទ្រទ្រង់ និងផ្តល់អំណាចដល់សហគមន៍ដើម្បីឱ្យពួកគេបន្តការប្រើប្រាស់ធនធានព្រៃឈើជាប្រពៃណី និងជំរុញឱ្យមានរបៀបរបបអនុវត្តប្រកបដោយចីរភាព ។ សហគមន៍ព្រៃឈើក៏មានគោលដៅទាញយកមកប្រើប្រាស់នូវចំណេះដឹង និងទេពកោសល្យរបស់ប្រជាជននៅមូលដ្ឋានស្តីពីការគ្រប់គ្រងព្រៃឈើ និងធានាឱ្យសហគមន៍ មានសំលេងខ្លាំងជាងមុនក្នុងការសំរេចចិត្តផ្សេងៗពីរឿងព្រៃឈើ ។ សញ្ញាបង្ហាញអំពីកំណើននៃការគាំទ្រដល់សហគមន៍ព្រៃឈើ រួមមាន ការប្រឹងប្រែងជាក់ស្តែងយ៉ាងច្រើននៅតាមមូលដ្ឋាន ដើម្បីរៀបចំ និងអភិវឌ្ឍន៍ព្រៃសហគមន៍, ម្ចាស់ជំនួយបង្កើនការគាំទ្រដល់សហគមន៍ព្រៃឈើ, ការបង្កើតអង្គភាពសហគមន៍ព្រៃឈើថ្នាក់ជាតិនៅក្នុងនាយកដ្ឋានរុក្ខាប្រមាញ់ និងនៅក្នុងក្រសួងបរិស្ថាន, ការផ្តើមធ្វើសិក្ខាសាលាថ្នាក់ជាតិស្តីពីសហគមន៍ព្រៃឈើនៅក្នុងឆ្នាំ២០០១ និងការងារកំពុងបន្តទៅមុខ ដើម្បីតាក់តែងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ។

ដើម្បីបង្កើនការយល់ដឹងពីវិមាត្រ និងទំហំនៃសកម្មភាពសហគមន៍ព្រៃឈើបច្ចុប្បន្ននៅកម្ពុជា, វបសអ បានធ្វើសារពើភ័ណ្ឌគំរោងបច្ចុប្បន្ន ដោយផ្អែកលើឯកសារដែលមានស្រាប់ ពត៌មានពីបណ្តាញព្រៃឈើ និងការសំភាសន៍តាមទូរស័ព្ទ (ពីខែមករា ដល់ខែមីនា ឆ្នាំ២០០២) ប៉ុន្តែ មិនបានចុះដល់មូលដ្ឋាន ដើម្បីបញ្ជាក់លើពត៌មានទាំងនេះទេ ។ ព្រៃសហគមន៍មានការប្រែប្រួល ខុសគ្នាខ្លាំងទៅតាមប្រភេទព្រៃ ការចាត់ចែង, គោលដៅ និងវិធីសាស្ត្រនៃការគ្រប់គ្រង, បញ្ហាត្រូវដោះស្រាយ, ភាពជឿនលឿន នៅក្នុងការបង្កើតសហគមន៍ព្រៃឈើ និងកំរិតនៃការគាំទ្រ ។ ដើម្បីបំរើដល់គោលដៅនៃការធ្វើបញ្ជីសារពើភ័ណ្ឌនេះ "សកម្មភាព សហគមន៍ព្រៃឈើ" បានកំណត់ន័យយ៉ាងទូលំទូលាយមួយ ដើម្បីបញ្ចូលការប្រឹងប្រែងនៅមូលដ្ឋាន ដើម្បីកែលំអលទ្ធភាពប្រើ ប្រាស់ព្រៃឈើ ការថែរក្សាឱ្យព្រៃដុះឡើងវិញ, ការគ្រប់គ្រង, និងការប្រើប្រាស់មានចីរភាព ។ អត្ថបទនេះពុំមានគោលដៅ កំនត់និយមន័យពាក្យ "សហគមន៍ព្រៃឈើ" ឱ្យបានសុក្រឹត ឬវាយតំលៃអំពីភាពសក្តិសិទ្ធិនៃការប្រឹងប្រែងក្នុងពេលបច្ចុប្បន្នទេ ។

វបសអ បានរកឃើញថា មាន ២៣៧ព្រៃសហគមន៍នៅកម្ពុជា (តារាង៤.៥)[៣៧] ។ គំរោងទាំងនេះត្រូវបានបំបែកជា

---

[៣៧] ក្រសួងកសិកម្ម (២០០២) រាយការណ៍ថា មានការបង្កើត ១១០សហគមន៍ព្រៃឈើ នៅក្នុង ១៥ខេត្ត នៅកម្ពុជា ។ ការប៉ាន់ស្មាននេះផ្អែកលើការពិគ្រោះយោបល់គ្នារវាងនាយកដ្ឋានរុក្ខាប្រមាញ់ និងការិយាល័យរុក្ខាប្រមាញ់ខេត្ត ។ បច្ចុប្បន្ន គេមិនអាចរកពត៌មានបន្ថែមស្តីពីទីតាំង ទំហំ និងអ្នកពាក់ព័ន្ធបានទេ ។ល។ គេមិនច្បាស់ទេថាតើព្រៃសហគមន៍ដែល វបសអ រកឃើញ គឺជាន់គ្នាក្នុងកំរិតណាជាមួយនឹងព្រៃសហគមន៍ដែលកំណត់ដោយនាយកដ្ឋានរុក្ខាប្រមាញ់ ។

ពួកគំរោងដែលចាប់ផ្តើមមុនឆ្នាំ២០០០ និងគំរោងដែលចាប់ផ្តើមនៅក្នុងឬក្រោយឆ្នាំ២០០០ ដើម្បីញែកព្រៃសហគមន៍ដែលទំនងជាលូតលាស់ពេញលេញចេញពីព្រៃសហគមន៍ដែលទើបចាប់ផ្តើមក្នុងពេលថ្មីៗ (ដែលទំនងជាមានពាក់ព័ន្ធច្រើនជាងនៅក្នុងការងារធ្វើផែនការ និងការរៀបចំ) ។ គំរោងដែលបានចាប់ផ្តើមមុនឆ្នាំ២០០០ បង្កើតបាន ១២៧ព្រៃសហគមន៍ដែលពាក់ព័ន្ធនឹង ២៨៨ភូមិ (ឬប្រហែល ២៣០.០០០នាក់) និងគ្របដណ្តប់លើផ្ទៃដីប្រហែល ៨៧.០០០ហិកតា ។ វិធីសាស្ត្រខុសៗគ្នាក្នុងការបង្កើតព្រៃសហគមន៍ បានស្តែងចេញជាភាពខុសគ្នាក្នុងទំហំព្រៃសហគមន៍ និងចំនួនប្រជាជនជាប់ពាក់ព័ន្ធ ។ ព្រៃសហគមន៍មួយចំនួនមានផ្ទៃក្រឡាតូចៗ និងជារឿយៗស្ថិតនៅជិតវត្តដែលមានការយកចិត្តទុកដាក់ជាសំខាន់លើការបង្កើតព្រៃ ដើម្បីធ្វើជាកន្លែងគោរពបូជា កន្លែងកំសាន្ត និងកន្លែងផ្តល់សោភ័ណភាព មិនមែនការកែលំអធនធានព្រៃឈើដែលមានស្រាប់នោះទេ ។ ព្រៃទាំងនេះដើរតួនាទីសំខាន់នៅក្នុងសហគមន៍ និងមានផលប៉ះពាល់ដល់ប្រជាជនច្រើនៗក៏ពិតមែន ប៉ុន្តែជាទូទៅគេមិនអាចប្រមូលផលិតផលព្រៃឈើឱ្យបានជាដុំកំភួនពីព្រៃទាំងនេះឡើយ ។

ដើម្បីស្វែងរកការបញ្ជាក់ច្បោលៗអំពីសក្តានុពលនៃធនធានព្រៃសហគមន៍ក្នុងការទ្រទ្រង់ជីវភាពជនបទ គេបានស្នើឱ្យតំណាងគំរោងធ្វើការវាយតំលៃពីគុណភាព/ស្តុកនៃមូលដ្ឋានរបស់ធនធានផលព្រៃឈើ ដូចជា អុស ផលិតផលព្រៃក្រៅពីឈើ និងឈើ ។ សំរាប់ផលិតផលនីមួយៗ តំណាងគំរោងចង្អុលបង្ហាញថាតើធនធាននៅក្នុងព្រៃសហគមន៍: (១) មិនគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ (២) គ្រប់គ្រាន់សំរាប់តែការប្រើប្រាស់នៅក្នុងគ្រួសារ (៣) គ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ និងសំរាប់លក់ ។ ចំពោះគំរោងព្រៃសហគមន៍ដែលបានចាប់ផ្តើមមុនឆ្នាំ២០០០ មានតែព្រៃសហគមន៍នៅរតនគីរី មណ្ឌលគីរី និងព្រះវិហារប៉ុណ្ណោះ ដែលមានធនធានឈើគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។ អុស និងធនធានព្រៃក្រៅពីឈើសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ មានសំបូរជាងឈើ ។

កំណែទំរង់ព្រៃឈើ ការប្រឹងប្រែងធ្វើវិមជ្ឈការ និងការយកចិត្តទុកដាក់ជាងមុនទៅលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ សុទ្ធតែញ៉ាំងឱ្យមានកំណើនសកម្មភាពសហគមន៍ព្រៃឈើ នៅក្នុងរយៈពេលជាង ២ឆ្នាំកន្លងមក ។ គំរោងដែលចាប់ផ្តើមចាប់តាំងពីឆ្នាំ២០០០ កំពុងស្ថិតក្នុងដំណើរការបង្កើតព្រៃសហគមន៍ យ៉ាងតិចបាន ១១០ព្រៃសហគមន៍ ពាក់ព័ន្ធនឹង ១២៨ភូមិ (ឬ ១៨០.០០០នាក់) ។ សព្វថ្ងៃគេមិនទាន់ដឹងច្បាស់ទេពីទំហំនៃព្រៃទាំងនេះ ពីព្រោះគំរោងជាច្រើនកំពុងស្ថិតក្នុងដំណាក់កាល ធ្វើផែនការ និង/ឬ ស្ទង់ស្វែងបង្កើតព្រៃសហគមន៍នៅក្នុងតំបន់ព្រៃសម្បទាន ។ ជាទូទៅ មូលដ្ឋានធនធានផលព្រៃឈើនៃគំរោងព្រៃសហគមន៍ដែលទើបបង្កើតឡើងថ្មីៗទាំងនេះ ទំនងជាមានគុណភាពអន់ច្រើនជាងគំរោងមុនៗ ។

**សហគមន៍ព្រៃឈើយក្សពយ: *ករណីសិក្សាជាឧទាហរណ៍មួយ***

នៅខែមករា ឆ្នាំ២០០១ កិច្ចព្រមព្រៀងរវាងមន្ត្រីថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធ និងគណៈកម្មការសហគមន៍ ព្រៃឈើយក្សពយ ត្រូវបានចុះហត្ថលេខា ដោយកំណត់យកព្រៃចំនួន ៥.៣៩៩ហិកតា នៅក្នុងឃុំពយ ស្រុកអូជុំ ខេត្តរតនគីរីថា ជាព្រៃសហគមន៍យក្សពយ ។ កិច្ចព្រមព្រៀងនេះ គឺជាលទ្ធផលនៃការងាររយៈពេល ៥ឆ្នាំ នៅក្នុងភូមិជនជាតិគ្រឹង ៦ ដោយ មានការគាំទ្រពីគំរោងព្រៃឈើ ក្រៅពីឈើនៅរតនគីរី និង NGOs ផ្សេងទៀត ។ នៅឆ្នាំ១៩៩៧ ភូមិទាំង៦ បានបង្កើត សមាគមព្រៃសហគមន៍សំរាប់តំបន់ព្រៃយក្សពយ ដែលស្ថិតនៅក្នុងសម្បទានរបស់ក្រុមហ៊ុន Hero Taiwan Company Concession ។ សមាគមព្រៃសហគមន៍ បានបង្កើត និងឯកភាពលើបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ និងកិច្ចការពារព្រៃឈើ ព្រមទាំងតួនាទី និងភារកិច្ចរបស់សមាគម ។ នៅក្រោម "លក្ខន្តិកៈព្រៃសហគមន៍យក្សពយ" សមាជិកនៃសហគមន៍ព្រៃឈើ យក្សពយត្រូវបានគេអនុញ្ញាតឱ្យៈ

- ប្រមូលឫស្សី ផ្តៅ និងវល្លិ៍ សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។
- កាប់ឈើសំរាប់ការប្រើប្រាស់នៅក្នុងគ្រួសារ ដោយមានការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ ។
- ប្រមូលផលព្រៃ ក្រៅពីឈើផ្សេងៗទៀត សំរាប់គោលដៅពាណិជ្ជកម្មដោយគោរពតាមគោលការណ៍ក្នុងច្បាប់ និងដោយគ្មានការបំផ្លាញព្រៃឈើ ។
- ប្រមាញ់សត្វតូចៗ និងចាប់ត្រី ដោយប្រើប្រាស់ឧបករណ៍ប្រមាញ់ និងនេសាទជាប្រពៃណី ។

បទប្បញ្ញត្តិបានហាមឃាត់ ការធ្វើអាជីវកម្មឈើជាលក្ខណៈជំនួញគ្រប់ប្រភេទ ការដុត និងការរានដីសំរាប់ធ្វើកសិកម្ម បន្លាស់ទី និងធ្វើច្បារដំណាំតាមផ្ទះ ការធ្វើអាជីវកម្មរ៉ែ ការនេសាទ និងការប្រមាញ់ដែលប្រើប្រាស់បច្ចេកវិជ្ជាទំនើប និង/ឬ សំរាប់គោលដៅពាណិជ្ជកម្ម ហើយនិងហាមមិនឱ្យធ្វើប្រមាញ់ថនិកសត្វធំៗ ឬពូជសត្វប្រឈមគ្រោះថ្នាក់នៃការបាត់បង់ ។ រយៈពេលនៃកិច្ចព្រមព្រៀងពុំមានចែងជាក់លាក់ទេ ប៉ុន្តែការគ្រប់គ្រងព្រៃឈើត្រូវមានការតាមដាន និងវាយតំលៃប្រចាំឆ្នាំ ។ បញ្ហាចោទខាងការគ្រប់គ្រង និងការបំពានលើកិច្ចព្រមព្រៀងជាបន្តបន្ទាប់អាចនាំឱ្យមានការបញ្ចប់កិច្ចព្រមព្រៀង ។

*(Bottomley 2000, RatanaKiri Non-Timber Forest Products Project 2001)*

## តារាង ៤.៥. សកម្មភាពព្រៃសហគមន៍នៅកម្ពុជា[១]

| ខេត្ត | ចំនួនព្រៃសហគមន៍ | ចំនួនភូមិ ដែលចូលរួម | ចំនួនប៉ាន់ស្មាន ប្រជាជនត្រូវប៉ះពាល់[២] | ផ្ទៃប៉ាន់ស្មាន ព្រៃសហគមន៍ (ha) | ស្ថានភាពផលិតផលព្រៃឈើ[៣] | | | កាលបរិច្ឆេទ ចាប់ផ្តើមគំរោង | ស្ថាប័ន/NGO ដែលធ្វើការកសាងព្រៃសហគមន៍ |
|---|---|---|---|---|---|---|---|---|---|
| | | | | | អុស | ផលក្រៅពីឈើ | ឈើ | | |
| **រកម្មភាពព្រៃសហគមន៍ដែលបានចាប់ផ្តើមនៅមុនឆ្នាំ២000** | | | | | | | | | |
| បន្ទាយមានជ័យ | 5 | 22 | 17,045 | 15 | គ្មានផលិតផលធំដុំ | | | 1998 | BFD |
| | 6 | 6 | 3,815 | 523 | N/A | N/A | N/A | 1999 | LWS/Seila/Addess |
| បាត់ដំបង | 10 | 17 | 15,905 | 20 | គ្មានផលិតផលធំដុំ | | | 1996 | BFD |
| កំពង់ឆ្នាំង | 12 | 12 | 5,535 | 750 | 2 | 2 | 1 | 1991 | Concern |
| | N/A* | 7 | N/A | N/A | 2 | 2 | 1 | កក្កដា 1998 | AEC/SADP |
| កំពង់ស្ពឺ | 3 | 3 | 466 | 35 | N/A | N/A | N/A | 1999 | PRASAC |
| កំពង់ធំ | 1 | 8 | 7,046 | 3 | គ្មានផលិតផលធំដុំ | | | 1997 | WTPS |
| | 2 | 2 | 2,013 | 30 | គ្មានផលិតផលធំដុំ | | | 1997 | WKK |
| | 5 | 5 | N/A | 159 | N/A | N/A | N/A | 1999 | GTZ |
| | 3 | 6 | 2,661 | 2402 | 2 | 3 | 1 | វិច្ឆិកា 1999 | BFDK |
| មណ្ឌលគិរី | 2 | 5 | 1,146 | 326 | 3 | 3 | 3 | ធ្នូ 1998 | DFW/SMRP |
| ព្រះវិហារ | 6 | 14 | 15,538 | N/A | 3 | 2 | 2 | វិច្ឆិកា 1998 | BPS |
| ព្រៃវែង | N/A | 7 | 15,619 | 70 | គ្មានផលិតផលធំដុំ | | | 1994 | Padek |
| | 2 | N/A | 3,897 | 7 | គ្មានផលិតផលធំដុំ | | | 1998 | Chet Thor |
| ពោធិសាត់ | 11 | 11 | 5,953 | 631 | 2 | 3 | 1 | 1995 | Concern |
| | 3 | 3 | 190 | 327 | 2 | 3 | 1 | ធ្នូ 1999 | EPDO |
| | 6 | 6 | 5,883 | 299 | N/A | N/A | N/A | 1998 | Seila |
| រតនគិរី | 4 | 32 | 17,996 | 10000 | 3 | 2 | 3 | 1996 | NTFP/ICC |
| | 5 | N/A | 18,277 | 10000 | 3 | 2 | 3 | 1996 | Seila/IDRC |
| សៀមរាប | 5 | 5 | 547 | 131 | 2-3 | 3 | 1 | 1995 | Padek |
| | 30 | 90 | 68,951 | 20000 | 2 | 2-3 | 1 | 1997 | FAO |
| | 4 | 4 | 4965 | 100 | N/A | N/A | N/A | 1995 | APDO |
| ស្វាយរៀង | 1 | 5 | 3360 | 414 | N/A | N/A | N/A | 1994 | Santi Sena |
| តាកែវ | 1 | 18 | 12,513 | 500 | 1 | 2 | 1 | 1992 | MCC |
| *សរុបរងទី១* | *127* | *288* | *229,321* | *46,742* | *2.2* | *2.5* | *1.3* | | |
| **រកម្មភាពព្រៃសហគមន៍ដែលបានចាប់ផ្តើមនៅក្នុង ឬនៅក្រោយ ឆ្នាំ២000** | | | | | | | | | |
| បន្ទាយមានជ័យ | 11 | 11 | 12,655 | 3,000 | N/A | N/A | N/A | មករា 2000 | CHRD |
| បាត់ដំបង | 7 | 7 | 6,549 | N/A | 3 | 3 | 1-2 | មករា 2001 | Seila/MoE |
| | 10 | 10 | 8,213 | 2030 | N/A | N/A | N/A | 2000 | ADDESS |
| កំពត | 1 | 3 | 700 | 200 | 3 | 3 | 1 | កក្កដា 2000 | CFRP/CIDSE |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| កោះកុង | 2 | 3 | 635 | 300-400 | 3 | 3 | 2 | កក្កដា 2001 | CFRP/AFSC |
| កំពង់ឆ្នាំង | 2 | 2 | 1,516 | 60 | 2 | 1 | 1 | ធ្នូ 2001 | LWS |
| កំពង់ស្ពឺ | 1 | 2 | 621 | 120-140 | 1 | 2 | 1 | មិថុនា 2001 | LWS |
| | 1 | 3 | 232 | 400 | N/A | N/A | N/A | សីហា 2001 | Mlup Baitong |
| | 3 | 3 | 1224 | 100 | N/A | N/A | N/A | 2000 | GTZ/CGFP |
| កំពង់ធំ | 8 | 8 | 6,920 | N/A | N/A | N/A | N/A | ធ្នូ 2000 | KVOD |
| | 3 | 5 | 3,593 | N/A | 3 | 3 | 3 | មករា 2001 | RPFD |
| | 6 | 6 | 3,624 | 1200 | 3 | 3 | 2 | មករា 2001 | KCAD |
| | 1 | 3 | 6,039 | 800 | 2 | 3 | 2 | ធ្នូ 2001 | CFRP |
| ក្រចេះ | 9 | 9 | 5,762 | 2000-3000 | 3 | 2 | 2 | មករា 2001 | CED |
| | 4 | 15 | 11,605 | 1200 | 3 | 2 | 2 | កុម្ភះ 2001 | EDCO |
| | 6 | N/A | 28,811 | N/A | 3 | 3 | 1 | កុម្ភះ 2001 | SSP |
| | 2 | N/A | 4,528 | 2000 | 2 | 3 | 1 | សីហា 2001 | CFRP/KAFDOC |
| មណ្ឌលគិរី | 4 | N/A | 16,040 | N/A | 3 | 3 | 3 | កុម្ភះ 2001 | SSP |
| | 1 | 1 | 300 | N/A | 2-3 | 2-3 | 2-3 | កក្កដា 2001 | WCS |
| ប៉ៃលិន | 5 | 5 | 35,050 | N/A | 2 | 3 | 3 | មេសា 2000 | FLOW |
| ព្រះវិហារ | 1 | 1 | N/A | N/A | 2-3 | 2-3 | 2-3 | វិច្ឆិកា 2001 | WCS |
| ពោធិសាត់ | 1 | 1 | 792 | N/A | 3 | 1 | 1 | វិច្ឆិកា 2000 | CFDS |
| | 1 | 5 | N/A | N/A | 2 | 2 | 1 | កុម្ភះ 2001 | AEC/SADP |
| | 2 | 3 | 600 | 600 | 2 | 3 | 3 | ធ្នូ 2001 | BDASE |
| | 8 | 8 | 7218 | 952 | N/A | N/A | N/A | 2000 | ADDESS |
| រតនគិរី | 2 | 6 | 8,942 | 7000 | 3 | 2 | 3 | 2000 | CIDSE |
| សៀមរាប | 2 | 2 | 2,189 | 210 | 3 | 3 | 1 | កក្កដា 2000 | Concern |
| | 1 | 3 | 2,260 | 2200 | 2 | 2 | 1 | កក្កដា 2001 | CFRP |
| ស្ទឹងត្រែង | 4 | N/A | 4,528 | N/A | 3 | 3 | 3 | កុម្ភះ 2001 | SSP |
| ស្វាយរៀង | 1 | 3 | 973 | 50 | 2 | 1 | 1 | កក្កដា 2001 | CWS |
| សរុបរងទី២ | *110* | *128* | *182,119* | *22,982* | *2.8* | *2.6* | *2.0* | | |
| សរុបរួម | **237** | **416** | **411,440** | **71,724**** | **2.5** | **2.5** | **1.7** | | |

[១] *"សកម្មភាពព្រៃសហគមន៍" រួមមានការប្រឹងប្រែងកែលំអលទ្ធភាពប្រើប្រាស់ព្រៃឈើ ការទុកឱ្យព្រៃលូតលាស់វិញ ការគ្រប់គ្រងឈើ និងការប្រើប្រាស់មានចីរភាព ។*

[២] *ក្នុងករណីខ្លះ តួលេខប៉ាន់ស្មាន គឺបានមកពីចំនួនគ្រួសារគុណនឹងចំនួនសមាជិកគ្រួសារជាមធ្យមនៅក្នុងខេត្ត*

[៣] *ចំពោះផលិតផលព្រៃឈើនីមួយៗ មានការលើកសំនួរចំពោះគំរោងព្រៃសហគមន៍ តើព្រៃសហគមន៍ ផ្តល់ (1) មិនគ្រប់គ្រាន់សំរាប់ការប្រើប្រាស់តាមគ្រួសារ; (2) គ្រប់គ្រាន់តែសំរាប់ការប្រើប្រាស់តាមគ្រួសារ (3) គ្រប់គ្រាន់សំរាប់ការប្រើប្រាស់តាមគ្រួសារ និងសល់សំរាប់លក់ទៀតផង ។ ព្រៃសហគមន៍មួយចំនួន គឺជាគំរោងខ្នាតតូចសំរាប់ថែរក្សា ឬបង្កើតព្រៃឡើងវិញ (ច្រើនតែនៅក្បែរវត្ត) ដែលផ្តល់ផលិតផលព្រៃឈើតិចតួចណាស់សំរាប់ឱ្យគេប្រមូលយក ។*

** N/A មានន័យថាគ្មានពត៌មាន ** គ្មានពត៌មានជាហិកតាសំរាប់ព្រៃសហគមន៍ចំនួន ៤៧ ។*

*ប្រភព: Community Forestry Working Group, និងការសំភាសន៍តាមទូរស័ព្ទ (Jan-Mar 2002). គ្មានការចុះតាមមូលដ្ឋានផ្ទាល់ដើម្បីបញ្ជាក់បន្ថែមលើពត៌មានទេ ។*

## ៤.៨. ចំណូលរដ្ឋាភិបាល

គោលដៅមួយនៃការបង្កើតប្រព័ន្ធព្រៃសម្បទាននៅកម្ពុជា គឺដើម្បីប្រមូលចំណូលរដ្ឋាភិបាល ។ នៅឆ្នាំ១៩៩៦ ធនាគារពិភពលោក, UNDP, និង FAO បានប៉ាន់ស្មានថា ចំណូលរដ្ឋាភិបាលដែលបានមកពីព្រៃឈើនៅកម្ពុជា អាចមានចំនួន ១០០លានដុល្លារ/ឆ្នាំ ។ ក្រោយមកធនាគារពិភពលោកបានកែតំរូវការប៉ាន់ស្មានមកត្រឹម ៤០-៨០លានដុល្លារ/ឆ្នាំ ។ ចំណូលប៉ាន់ស្មានទាំងនេះមានលក្ខណៈសុទិដ្ឋិនិយមពេក បើគិតតាមស្ថានភាពជាក់ស្តែង ។ ចាប់តាំងពីការព្យាករណ៍ចំណូលព្រៃឈើដំបូងនៅឆ្នាំ១៩៩៦ មក ចំណូលព្រៃឈើផ្លូវការរបស់រដ្ឋាភិបាល មានពី ៦-១២លានដុល្លារ/ឆ្នាំ ។ ចំណូលកើនខ្ពស់នៅឆ្នាំ១៩៩៤ និង១៩៩៥ នៅខណៈដែលសម្បទានជាច្រើនត្រូវបានផ្តល់ជាលើកដំបូង (តារាង៤.៦) ។ បច្ចុប្បន្នម្ចាស់ជំនួយមួយចំនួនបានសារភាពជាឯកជនថា វិស័យព្រៃឈើប្រហែលជាមិនអាចរកចំណូលជាដុំកំភួនឱ្យរដ្ឋាភិបាលបានទេ ។ លើសពីនេះគេគួរកត់សំគាល់ថា ផលឈើក្នុងអនាគត ទំនងជាទាបជាងកំរិតក្នុងអតីតកាល ដោយសារមានកំណែទំរង់ព្រៃឈើដែលសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងមានចីរភាព និងដោយសារមានសល់ឈើអាចកាប់បានតិចជាងមុន ។ ដូច្នេះចំណូលសួយ និងពន្ធនាំចេញសំរាប់រដ្ឋាភិបាល នឹងថយចុះ[៣៨] ។

**តារាង ៤.៦. ចំណូលរដ្ឋាភិបាលបានពីព្រៃឈើ ១៩៩២ - ២០០១**

| ឆ្នាំ | 1992 | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|---|---|---|
| ចំណូលរដ្ឋាភិបាលបានពីព្រៃឈើ (លានUS$) | 0.8 | 1.4 | 33.5 | 21.5 | 10.4 | 12.5 | 6.0 | 9.5 | 10.6 | 7.4 |

*Source: Ministry of Economy and Finance (2002)*

នៅក្នុងស្ថិតិចំណូលផ្លូវការរបស់រដ្ឋាភិបាល វិស័យព្រៃឈើមើលទៅហាក់ដូចមិនសូវសំខាន់ចំពោះសេដ្ឋកិច្ចកម្ពុជាទេ ប៉ុន្តែតាមពិតតួលេខផ្លូវការទាំងនេះវាបិទបាំងពីសារៈសំខាន់នៃការរួមចំណែករបស់វិស័យព្រៃឈើក្នុងអតីតកាល និងបច្ចុប្បន្នកាល ។ ភាគច្រើនតាមរយៈបណ្តាញក្រៅផ្លូវការ ចំណូលព្រៃឈើបានជួយទ្រទ្រង់អាជ្ញាធរខេត្តនិងស្រុក យោធា រដ្ឋាភិបាលជាតិ បុរសខ្លាំងខាងនយោបាយ គណបក្សនយោបាយ និងមន្ត្រីស៊ីវិល (Global Witness 1995-2001) ។ ថវិកាទាំងនេះ គេរកបានតាមរយៈការប្រមូលពន្ធថ្នាក់ខេត្ត/ស្រុក កំរៃក្រៅផ្លូវការ និងការចូលរួមកាប់ឈើដោយផ្ទាល់ពីសំណាក់យោធា ។ គេរាយការណ៍ថាក្រុមហ៊ុនឈើត្រូវចំណាយពី ៤០-៨០ដុល្លារ/ម$^{៣}$ ជាការបង់កំរៃក្រៅផ្លូវការទៅឱ្យមន្ត្រីរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធ (Forest Crime Monitoring Unit 2000)[៣៩] ។ កំរៃក្រៅផ្លូវការដែលគេប្រមូលបាននៅឆ្នាំ១៩៩៧ អាចច្រើនជាង ១៥០លានដុល្លារ (DAI 1998) ប៉ុន្តែគេមិនដឹងថា តើចំណែកប៉ុណ្ណានៃប្រាក់នេះ គេយកទៅផ្តល់ថវិកាឱ្យសេវាសាធារណៈត្រឹមត្រូវ (តាមរយៈថវិកាស្រប គ្នានឹងថវិការដ្ឋ) ចំណែកប៉ុណ្ណាចូលក្នុងហោប៉ៅបុគ្គល និងប៉ុណ្ណាទៀតគឺជាសំណូកដើម្បីជៀសវាងការបង់ពន្ធផ្លូវការ ។

## ៤.៩. មូលដ្ឋានច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងព្រៃឈើ

ការពិនិត្យពីមូលដ្ឋានច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងព្រៃឈើ មិនអាចផ្តល់គំនិតច្បាស់លាស់ទេថា តើការអនុវត្តន៍ជាក់ស្តែងណាខ្លះស្ថិតនៅក្រោមច្បាប់ និង តើស្ថាប័នមានណាខ្លះដែលពាក់ព័ន្ធ ។ ការណ៍នេះគឺបណ្តាលមកពីភាពមិនច្បាស់លាស់នៃច្បាប់ និងបទប្បញ្ញត្តិព្រៃឈើកម្ពុជាក្នុងពេលបច្ចុប្បន្ន ដែលផ្តល់ឱ្យមន្ត្រីនានានូវសិទ្ធិសំរេចជាដុំកំភួនក្នុងការកំណត់ពីរបៀបរបបអនុវត្តន៍របស់រដ្ឋាភិបាល, និងកង្វះតម្លាភាពពីតួនាទីរបស់រដ្ឋាភិបាលនៅក្នុងវិស័យព្រៃឈើ (White and Case 1998, Fraser

[៣៨] បច្ចុប្បន្នអត្រាសួយគឺ ៥៤ដុល្លារ/ម$^{៣}$ សំរាប់ឈើប្រភេទលេខ២ ដែលជាប្រភេទសំបូរជាងគេនៅក្នុងព្រៃសម្បទាន (Fraser Thomas *et al.* 2000) ។ អត្រានេះត្រូវបានកំណត់ដូចគ្នាដោយមិនគិតពីទីតាំងនៃព្រៃសម្បទាន ចំណាយក្នុងការប្រមូលផល និងតំលៃទីផ្សារឡើយ ។

[៣៩] ចំណាយទាំងនេះពិបាករកឯកសារបញ្ជាក់ណាស់ ហើយគំរោងតាមដានឈើ និងត្រួតពិនិត្យការកាប់ឈើ បានប៉ាន់ស្មានថា គឺប្រហែល ៥០ដុល្លារ/ម$^{៣}$ នៅឆ្នាំ១៩៩៧ (DAI 1998) ។

Thomas *et al*. 2000) ។ ដូច្នេះ គេពិបាកកំណត់ថាតើក្រសួង និង/ឬ មន្ត្រីណាខ្លះ ដែលបានអនុញ្ញាត ឬទទួលចំណេញពីការបែងចែកដីព្រៃ សកម្មភាពកាប់ឈើ (ខុសច្បាប់) និងការវិនិយោគលើការកែច្នៃឈើ ។ ស្រដៀងគ្នានេះដែរ មានពត៌មានតិចតួចណាស់ពីអន្តរកម្ម និងចំណងទាក់ទងច្បាស់លាស់ក្នុងចំណោមក្រសួង មន្ត្រី យោធា សម្បទានិក អ្នកម៉ៅការបន្ត (ដូចជា កងទ័ព ក្រុមហ៊ុន)[៤០] ។

## ៤.៩.១. ច្បាប់ និងបទប្បញ្ញត្តិព្រៃឈើ

ច្បាប់ព្រៃឈើថ្មីត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ និងត្រូវបានប្រគល់ជូនរដ្ឋសភាជាតិនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ ។ សព្វថ្ងៃច្បាប់នេះកំពុងពិភាក្សានៅក្នុងគណៈកម្មាការបច្ចេកទេសនៃរដ្ឋសភា ។ ច្បាប់ថ្មីនេះសំដៅបញ្ជាក់ឱ្យបានច្បាស់ពីគោលដៅនៃព្រៃឈើជាតិ ប្រភេទនិងដែនសមត្ថកិច្ចព្រៃឈើ ការគ្រប់គ្រងនិងរដ្ឋបាល សិទ្ធិលើធនធាន និងការអនុវត្តន៍ច្បាប់ ។ មុនពេលអនុម័តចេញនូវច្បាប់ព្រៃឈើថ្មី, ច្បាប់សំខាន់ជាងគេសំរាប់គ្រប់គ្រងព្រៃឈើកម្ពុជា គឺក្រឹត្យលេខ ៣៥ករច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ។ យោងតាមអ្នកវិភាគច្បាប់ White and Case (1998) ភាពមិនច្បាស់លាស់នៃច្បាប់ថ្មីនឹងផ្តល់ឱ្យរដ្ឋាភិបាលនូវសិទ្ធិសំរេចយ៉ាងច្រើនក្នុងការធ្វើអាជីវកម្ម និងគ្រប់គ្រងព្រៃឈើ ។

ក្រៅពីក្រឹត្យលេខ ៣៥ករច ឆ្នាំ១៩៨៨ រដ្ឋាភិបាលបានចេញបទប្បញ្ញត្តិ (ប្រកាស) និងបទបញ្ជាផ្សេងៗជាច្រើនស្តីពីការគ្រប់គ្រងព្រៃឈើ ការនាំចេញ និងការអនុវត្តន៍ច្បាប់[៤១] តាំងពីឆ្នាំ១៩៨៦ មកដល់សព្វថ្ងៃ ។ បទប្បញ្ញត្តិទាំងនេះរួមមាន អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន (កុម្ភៈ ២000) ដែលតំរូវឱ្យមានការគ្រប់គ្រងព្រៃសម្បទានប្រកបដោយចីរភាព និងប្រកាសស្តីពីការផ្អាកសកម្មភាពកាប់ឈើក្នុងព្រៃសម្បទានចុះថ្ងៃទី១៣ ធ្នូ ២០០១ ។ ប្រកាសថ្មីៗទាំងនេះ ដែលហាមឃាត់សកម្មភាពកាប់ឈើសម្បទានទាំងអស់ និងផ្អាកការចេញលិខិតអនុញ្ញាតប្រមូលផលព្រៃឈើទាំងអស់ បានចូលជាធរមាននៅថ្ងៃទី១ មករា ២០០២ ។ ដើម្បីលើកការផ្អាកនេះចេញ សម្បទានិកត្រូវកសាងផែនការគ្រប់គ្រងសម្បទានថ្មី ដែលត្រូវស្របតាមបទប្បញ្ញត្តិនានាខាងច្បាប់ និងបច្ចេកទេស ហើយដែលបានទទួលបានការអនុមតិពីរដ្ឋាភិបាល ។

## ៤.៩.២. តួនាទីផ្នែកស្ថាប័នរបស់រដ្ឋាភិបាលនៅក្នុងវិស័យព្រៃឈើ

នាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្ម មានការទទួលខុសត្រូវចំបងក្នុងការគ្រប់គ្រងព្រៃឈើរបស់រដ្ឋ ប៉ុន្តែក៏មានក្រសួងនាយកដ្ឋាន និងអាជ្ញាធរជាច្រើនទៀត ដែលដើរតួនាទីសំខាន់ដែរ ។ តួនាទី និងការទទួលខុសត្រូវជាផ្លូវការរបស់រដ្ឋាភិបាលនៅក្នុងវិស័យព្រៃឈើមានដូចតទៅ:

- នាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្ម មានការទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ព្រៃឈើដែលនៅក្រៅតំបន់ការពារ និងតំបន់ព្រៃលិចទឹក ។
  - ទីចាត់ការនាយកដ្ឋានរុក្ខាប្រមាញ់នៅក្រុងភ្នំពេញ បែងចែកជា ៦ការិយាល័យ, វិទ្យាស្ថានស្រាវជ្រាវមួយ និង ៣ក្រុមហ៊ុន ។ ក្នុងនេះក្រុមហ៊ុនពីរ គឺ COLEXIM និង CASOTIM ធ្វើប្រតិបត្តិការភាគច្រើន ដោយឯករាជ្យ ហើយទាំងពីរនេះ គឺជាក្រុមហ៊ុនសម្បទាន ។
  - ការិយាល័យរុក្ខានៅទូទាំងប្រទេស ដែលស្ថិតនៅក្រោមមន្ទីរកសិកម្មខេត្ត ឬការិយាល័យស្រុក និងដែលត្រូវ

[៤០] របាយការណ៍ និងអង្កេតដោយ Global Witness (1995-2001) ផ្តល់ពត៌មានអំពីបណ្តាញទំនាក់ទំនងនិងសកម្មភាពទាំងនេះច្រើនជាងគេ ។

[៤១] ប្រកាសលេខ ០៤៩សសរ ចុះថ្ងៃទី១២ ខែកញ្ញា ១៩៨៦, ក្រឹត្យលេខ ៣៥ករច ចុះថ្ងៃទី២៥ មិថុនា ១៩៨៨, ប្រកាសលេខ ០៣៥សសរ ចុះថ្ងៃទី៣០ ឧសភា ១៩៨៨, សេចក្តីប្រកាសលេខ ០៥ ចុះថ្ងៃទី៧ មករា ១៩៩៥, សេចក្តីប្រកាសលេខ ០២ DAGC ចុះថ្ងៃទី២៦ ធ្នូ ១៩៩៦ (ដែលត្រូវបានកំណត់បន្ថែមដោយសេចក្តីប្រកាសរបស់ក្រសួងកសិកម្មលេខ ០៧៤ ចុះថ្ងៃទី២៦ កុម្ភៈ ឆ្នាំ១៩៩៧) សេចក្តីប្រកាសលេខ៥ នៅឆ្នាំ១៩៩៧, សេចក្តីប្រកាសលេខ១ នៅខែមករា ១៩៩៦, អនុក្រឹត្យស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើលេខ៥ អនក្រ.បក ចុះថ្ងៃទី០៧ កុម្ភៈ ២000, ប្រកាសលេខ ៥៧២១ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី១៣ ធ្នូ ២០០១ ។

របាយការណ៍ឡើងមកនាយកដ្ឋានរុក្ខាប្រមាញ់នៅភ្នំពេញ ។

- នាយកដ្ឋានអភិរក្ស និងការពារធម្មជាតិនៃក្រសួងបរិស្ថាន មានការទទួលខុសត្រូវលើការគ្រប់គ្រងតំបន់ការពារទាំង ២៣របស់កម្ពុជា (៣,៣លានហិកតា) ក្នុងនេះតំបន់ការពារតែមួយចំនួនតូចប៉ុណ្ណោះដែលមានបុគ្គលិកទទួលបៀវត្សរ៍ពេញម៉ោងសំរាប់គ្រប់គ្រង និងពង្រឹងការអនុវត្តន៍ច្បាប់ ។
- អង្គភាពតាមដាន និងរាយការណ៍អំពីឧក្រិដ្ឋកម្មព្រៃឈើ ត្រូវបានបង្កើតឡើងនៅក្នុងក្រសួងបរិស្ថាន និងនាយកដ្ឋានរុក្ខាប្រមាញ់ ។ Global Witness ដើរតួនាទីតាមដានដោយឯករាជ្យនៅខាងក្រៅអង្គភាពទាំងនេះ ដោយរាយការណ៍ អំពីកិច្ចការរបស់ពួកគេទៅឱ្យគណៈរដ្ឋមន្ត្រី និងម្ចាស់ជំនួយ ។
- នាយកដ្ឋានជលផលនៃក្រសួងកសិកម្ម ទទួលខុសត្រូវគ្រប់គ្រងតំបន់ព្រៃលិចទឹក និងព្រៃកោងកាងនៅឆ្នេរសមុទ្រ ។
- គណៈរដ្ឋមន្ត្រី ទទួលខុសត្រូវក្នុងការអនុម័តកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនសម្បទាន ។
- កំលាំងប្រដាប់អាវុធ និងផ្នែកខ្លះនៃប៉ូលីស អាចចូលរួមក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ព្រៃឈើ ។
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងពាណិជ្ជកម្ម, ក្រសួងផែនការ, សុទ្ធតែចូលរួមក្នុងការអនុម័ត និងគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ ដោយរួមទាំងកម្មវិធីពាក់ព័ន្ធនឹងព្រៃឈើ ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាតឱ្យបង្កើតរោងម៉ាស៊ីនអារឈើ និងការ តំឡើងឧបករណ៍កែច្នៃផលិតផលព្រៃឈើផ្សេងទៀត ។

## ៤.១០. ការប្រឹងប្រែងកែទំរង់វិស័យព្រៃឈើ

សហគមន៍ម្ចាស់ជំនួយអន្តរជាតិ បានចាប់ផ្តើមសំដែងនូវការបារម្ភធ្ងន់ធ្ងរជាដំបូងទៅលើវិស័យព្រៃឈើកម្ពុជា នៅដើមទសវត្សរ៍១៩៩០ ។ ក្រោយមក ការបារម្ភទាំងនេះលេចជារូបរាងធំដុំនៅក្នុងរបាយការណ៍របស់ Global Witness ដែលផ្តល់ពត៌មានពីការស៊ើបអង្កេតលំអិតស្តីពីឧក្រិដ្ឋកម្ម និងការល្មើសច្បាប់នៅក្នុងវិស័យព្រៃឈើ ។ នៅក្នុងការពន្យាកំចីចំនួន ២០លានដុល្លារនៅខែវិច្ឆិកា ឆ្នាំ១៩៩៥, IMF បានចង្អុលបង្ហាញអំពីអសមត្ថភាព ឬភាពគ្មានឆន្ទៈរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងសកម្មភាពកាប់ឈើ និងការបង្វែរចំណូលយ៉ាងច្រើនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅឱ្យក្រសួងការពារជាតិ ។ ភស្តុតាងបន្ថែមពីលើនេះទៀតស្តីពីការចូលរួមរបស់មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់នៅក្នុងអំពើពុករលួយដែលទាក់ទិននឹងការកាប់ឈើ បាននាំឱ្យមានការបង្អាក់កំចីនេះ នៅខែឧសភា ឆ្នាំ១៩៩៦ (Talbott 1998) ។ ម្ចាស់ជំនួយមួយចំនួនផ្សេងទៀត បានអំពាវនាវឱ្យមានបំរាមនាំឈើមូលចេញ និងឱ្យមានការពិនិត្យឡើងវិញលើសម្បទានទាំងអស់ នៅក្នុងអង្គប្រជុំម្ចាស់ជំនួយអន្តរជាតិ កាលពីខែកក្កដា ឆ្នាំ១៩៩៦ ។ នៅចំពោះមុខសំពាធនេះ រដ្ឋាភិបាល បានចេញក្រឹត្យហាមឃាត់ការនាំចេញឈើមូលទាំងអស់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦ ។ ប៉ុន្តែ ដោយមានភស្តុតាងបង្ហាញពីការកាប់ឈើខុសច្បាប់យ៉ាងច្រើនបំផុតនៅឆ្នាំ១៩៩៧ (ដូចបានរៀបរាប់ខាងលើ) ដូច្នេះបំរាមនេះគ្មានប្រសិទ្ធិភាពឡើយ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៩៦ មុនការប្រកាសអំពីបំរាមនាំឈើមូលចេញ បេសកកម្មរួមគ្នាមួយរបស់ WB, UNDP និង FAO បង្ហាញនូវគំរូមួយសំរាប់គ្រប់គ្រងធនធានព្រៃឈើនៅកម្ពុជា ដើម្បីជួយទ្រទ្រង់ឱ្យបានធំទូលាយជាងមុនដល់គោលដៅអភិវឌ្ឍន៍នានា ។ ក្រុមបេសកកម្មនេះ បានគាំទ្រការប្រើប្រាស់ប្រព័ន្ធព្រៃសម្បទានជាមធ្យោបាយដ៏សមស្រប សំរាប់ការអភិវឌ្ឍន៍ធនធានព្រៃឈើនៅកម្ពុជា ដោយពួកគេបានកត់សំគាល់ថា "ប្រទេសជាច្រើនដែលសំបូរព្រៃឈើបានប្រើប្រាស់ប្រព័ន្ធសម្បទាន ហើយវាអាចរួមចំណែកយ៉ាងច្រើនក្នុងការបំរើឱ្យគោលដៅអភិវឌ្ឍន៍តាមវិស័យផ្សេងទៀត ដូច្នេះ វាស្ថិតក្នុងចំណោមមធ្យោបាយដ៏មាន

ប្រយោជន៍បំផុតនៃគោលនយោបាយព្រៃឈើ" (World Bank *et al.* 1996) ។ ការគាំទ្រប្រព័ន្ធសម្បទាននេះរួមបញ្ចូលការអំពាវនាវឱ្យមានកំណែទំរង់សំដៅធានានូវចីរភាពនៃការប្រមូលផលឈើពីព្រៃសម្បទាន និងកំនើនចំនូលរដ្ឋាភិបាលបានមកពីព្រៃឈើផងដែរ ។ នៅពេលបំរាមនាំចេញឈើមូលទទួលបរាជ័យនៅឆ្នាំ១៩៩៧ សហគមន៍ម្ចាស់ជំនួយភាគច្រើនបានចាប់យកវិធីសាស្ត្រគ្រប់គ្រងសម្បទានព្រៃឈើដោយមានចីរភាព ដែលក្រុមបេសកកម្មរួមគ្នាដូចបញ្ជាក់នៅខាងលើ បានផ្តល់មតិជំរុញ[៤២] ។

### ៤.១០.១. គំរោង និងគំនិតផ្តួចផ្តើម កែទំរង់សម្បទានព្រៃឈើចំបង១

ដើម្បីសំរេចបានការគ្រប់គ្រងព្រៃឈើមានចីរភាព រដ្ឋាភិបាល និងម្ចាស់ជំនួយ បានវិនិយោគធនធានជាច្រើន ក្នុងប៉ុន្មានឆ្នាំកន្លងមក ដើម្បីកែទំរង់ប្រព័ន្ធសម្បទាន ។ គំរោង និងគំនិតផ្តួចផ្តើម ចំបង១មានជាអាទិ:

- **គំរោងកែទំរង់គោលនយោបាយព្រៃឈើ:** នៅឆ្នាំ១៩៩៧-៩៨ ធនាគារពិភពលោកបានផ្តល់មូលនិធិសំរាប់ការសិក្សាប្រើប្រាស់ជំនួយបច្ចេកទេស នៅក្នុងវិស័យព្រៃឈើ នៅក្នុងក្របខ័ណ្ឌនៃគំរោងកែទំរង់គោលនយោបាយព្រៃឈើ ។ ការសិក្សាមានជាអាទិ៍:
  - *Legal Counsel (ការផ្តល់យោបល់ផ្នែកច្បាប់)* ដោយ White and Case (April 1998) ដែលបានពិនិត្យមើលច្បាប់ព្រៃឈើ និងកិច្ចសន្យាសម្បទាន
  - *តាមដានឈើ និងត្រួតពិនិត្យការកាប់ឈើ* ដោយ Development Alternatives, Inc. (May 1998) ដែលវាយតំលៃពីសកម្មភាពកាប់ឈើខុសច្បាប់ និងផ្តល់មតិពីវិធីសាស្ត្រកាត់បន្ថយសកម្មភាពទាំងនេះ ។
  - *កំណែទំរង់គោលនយោបាយព្រៃឈើ* ដោយ Associate in Rural Development, Inc. (May 1998) ដែលពិនិត្យមើលឡើងវិញនូវគោលនយោបាយព្រៃឈើ ។
  - *ការគ្រប់គ្រងព្រៃសម្បទាន* ដោយ FOTECH (December 1998) ដែលរៀបចំនូវស្តង់ដា និងសេចក្តីណែនាំសំរាប់ការគ្រប់គ្រងព្រៃសម្បទាន ។

  របកគំហើញនៃគំរោងនេះ បង្ហាញពីបញ្ហាដ៏ធំសម្បើមនៃការកាប់ឈើខុសច្បាប់ និងគ្មានការគ្រប់គ្រងនៅក្នុង និងនៅជុំវិញតំបន់សម្បទាន, ការប្រមូលចំណូលបានតិចតួចចូលរដ្ឋាភិបាល, និងច្បាប់ព្រៃឈើ និងកិច្ចសន្យាសម្បទានគ្មានភាពច្បាស់លាស់ ។ ទោះបីមានបញ្ហាយ៉ាងនេះក៏ដោយ ក៏គំរោងបានសន្និដ្ឋានថា "ប្រព័ន្ធសម្បទានព្រៃឈើ វាសមស្របបំផុតសំរាប់ការអភិវឌ្ឍន៍ជាលក្ខណ:ពាណិជ្ជកម្មនូវធនធានព្រៃឈើកម្ពុជា ប៉ុន្តែត្រូវមានការកែច្នៃខ្លះ១ ដើម្បីឱ្យស៊ីគ្នានឹងលក្ខខណ្ឌកម្ពុជា" (Associate for Rural Development 1998) ។ ក្រោយមក ធនាគារពិភពលោកបានធ្វើសំយោគរបកគំហើញនេះ ហើយកសាងបាននូវ ចក្ខុវិស័យជាយុទ្ធសាស្ត្រមួយសំរាប់វិស័យព្រៃឈើ ដែលបញ្ជាក់សាជាថ្មីពីការគាំទ្រដល់ការគ្រប់គ្រងព្រៃសម្បទានមានចីរភាពនៅកម្ពុជា (World Bank 1999) ។
- **សេចក្តីប្រកាសលេខ១:** ដូចបានកត់សំគាល់ខាងលើ នៅខែមករា ឆ្នាំ១៩៩៩ រដ្ឋាភិបាលបានប្រឹងប្រែងជាថ្មីក្នុងការបង្ក្រាបការកាប់ឈើខុសច្បាប់ដោយមានសេចក្តីប្រកាសលេខ១ របស់នាយករដ្ឋមន្ត្រី ។ សេចក្តីបញ្ជា ១៧ចំណុចដែលកាត់បន្ថយគួរឱ្យកត់សំគាល់ការកាប់ឈើខុសច្បាប់នៅរដូវកាប់ឈើឆ្នាំ១៩៩៨-៩៩ (មករា-ឧសភា ១៩៩៩) បានអំពាវនាវឱ្យ:
  - បញ្ឈប់ការចេញលិខិតអនុញ្ញាតប្រមូលឈើថ្មី១ទៀត និងលុបចោលលិខិតអនុញ្ញាតដែលមានស្រាប់ ។

[៤២] និយមន័យន័យពាក្យ "ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព" អាចមានច្រើន ប៉ុន្តែជាទូទៅវាតំរូវឱ្យមាន: ការធានាឱ្យធនធានព្រៃឈើផ្តល់នូវទិន្នផលឈើមានកំរិតចីរភាពនៅខណ:ដែលរក្សាគុណភាពព្រៃឈើធម្មជាតិបាន ការអភិរក្សជីវ:ចំរុះ និងមុខងារប្រព័ន្ធអេកូឡូស៊ី ការពារសេវាព្រៃឈើផ្សេង១ទៀត ដូចជាតំលៃដី និងជំរាលដែលគ្របដណ្តប់ដោយរុក្ខជាតិ ការថែរក្សាសិទ្ធិនៃលទ្ធភាពទៅរកព្រៃឈើដោយសហគមន៍មូលដ្ឋាន និងការដែរក្សាតំលៃវប្បធម៌ ។

- បញ្ឈប់ជាបន្ទាន់នូវពាណិជ្ជកម្មឈើខុសច្បាប់ទាំងអស់ និងដាក់អនុវត្តជាថ្មីនូវបំរាមនាំចេញឈើមូល (បំរាមលើកមុននេះ បានចេញនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦) ។
- កងកំលាំងប្រដាប់អាវុធ និងប៉ូលីស ត្រូវជួយនាយកដ្ឋានរុក្ខាប្រមាញ់ ក្នុងការអនុវត្តន៍ច្បាប់ព្រៃឈើ ។
- តាក់តែង និងអនុម័តច្បាប់ព្រៃឈើថ្មី និងកែលំអការតាមដានការរីកចំរើននៅក្នុងកំណែទំរង់ព្រៃឈើ ។

- **គំរោងគ្រប់គ្រងព្រៃឈើមានចីរភាព:** ពីឆ្នាំ១៩៩៩-២000 គំរោងគ្រប់គ្រងព្រៃឈើមានចីរភាព ផ្តល់ថវិកាដោយ ADB បានពិនិត្យឡើងវិញនូវប្រព័ន្ធសម្បទានព្រៃឈើ និងបានសន្និដ្ឋានថា ការអនុវត្តន៍សម្បទានដែលអន់ថយខ្លាំងវាបញ្ជាក់នូវ "ការបរាជ័យទាំងស្រុងនៃប្រព័ន្ធ" ។ ការពិនិត្យនេះរកឃើញថា គ្មានព្រៃសម្បទានណាមួយដែលត្រូវបានគ្រប់គ្រងឱ្យមានចីរភាពទេ ដោយអត្រាប្រមូលផលមានកំរិតខ្ពស់ខ្លាំងជាងអត្រាសំរាប់អាជ្ញាប័ណ្ណឈើរយៈ ២៥ ឆ្នាំ ។ ទោះបីរកឃើញលទ្ធផលគួរឱ្យបារម្ភបែបនេះក៏ដោយ ក៏គំរោងបានផ្តល់យោបល់ថា គួរបន្តការគាំទ្រប្រព័ន្ធព្រៃសម្បទាននៅកម្ពុជា ប៉ុន្តែតាមបែបបទមួយដែលមានការកែទំរង់ និងការកែរចនាសម្ព័ន្ធ ។ ក្នុងចំណោមអនុសាសន៍នានាក្នុងគំរោង គឺមានការអំពាវនាវឱ្យសម្បទានិក រៀបចំផែនការគ្រប់គ្រងមានចីរភាពឱ្យបាន និងមិនយឺតជាងខែវិច្ឆិកា ឆ្នាំ២00១ គឺមុនពេលចាប់ផ្តើមរដូវកាប់ឈើ ឆ្នាំ២00១ ។ សម្បទានិក នាយកដ្ឋានរុក្ខាប្រមាញ់ និងម្ចាស់ជំនួយជាប់ទាក់ទិន បានឯកភាពគ្នានៅលើអនុសាសន៍នេះ កាលពីខែឧសភា ឆ្នាំ២000 ដោយបានកំណត់យកខែកញ្ញា ឆ្នាំ២00១ ជាកាលបរិច្ឆេទចុងក្រោយសំរាប់សម្បទានិកប្រគល់ផែនការគ្រប់គ្រង និងកំណត់យកខែវិច្ឆិកា ឆ្នាំ២00១ ជាកាលបរិច្ឆេទចុងក្រោយសំរាប់រដ្ឋាភិបាលធ្វើការអនុម័ត ។
- **ក្រុមការងាររួមគ្នាខាងគ្រប់គ្រងព្រៃសម្បទាន:** ដើម្បីគាំទ្រដំណើរការធ្វើផែនការគ្រប់គ្រង ក្រុមការងាររួមគ្នាខាងការគ្រប់គ្រងព្រៃសម្បទាន ត្រូវបានបង្កើតឡើង (ដោយមានការផ្តល់ថវិកាពី DFID) រវាង CTIA និងនាយកដ្ឋានរុក្ខាប្រមាញ់ ។ ទោះបីជាក្រុមការងាររួមបានបញ្ជាក់ជាថ្មីនៅក្នុងអង្គប្រជុំខែតុលា ឆ្នាំ២000 និងខែមីនា ឆ្នាំ២00១ ថា ខែកញ្ញា ឆ្នាំ២00១ គឺជាអវសានវាទសំរាប់ការប្រគល់ផែនការគ្រប់គ្រងសម្បទាន ប៉ុន្តែគ្មានផែនការគ្រប់គ្រងណាមួយត្រូវបានប្រគល់មុនកាលកំណត់នេះឡើយ ។
- **គំរោងតាមដានបទឧក្រិដ្ឋព្រៃឈើ** (FCMP)**:** នៅក្នុងខែមេសា ឆ្នាំ១៩៩៩ រដ្ឋាភិបាលបានស្នើជំនួយពី UNDP/ FAO សំរាប់បង្កើតអង្គភាព FCMP ឯករាជ្យនៅក្នុងក្រសួងកសិកម្ម និងក្រសួងបរិស្ថាន ។ ការទ្រទ្រង់ដ៏ចាំបាច់ត្រូវបានឱ្យហើយជំនួយបច្ចេកទេសបានចាប់ផ្តើមនៅខែមករា ឆ្នាំ២000 ។ Global Witness ដើរតួនាទីជាអ្នកតាមដានឯករាជ្យ និងផ្តល់របាយការណ៍ទៅគណៈរដ្ឋមន្ត្រីអំពីការប្រឹងប្រែងរបស់អង្គភាពរដ្ឋាភិបាលទាំងពីរ ។
- **អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន:** អនុក្រឹត្យនេះដែលអនុម័តចេញនៅខែកុម្ភៈ ឆ្នាំ២000 មានបទប្បញ្ញត្តិស្តីពីដំណើរការអនុវត្តនិងអនុម័តសម្បទាន ការធ្វើផែនការនិងការគ្រប់គ្រងសម្បទាន ការតាមដាននិងការដាក់អនុវត្តន៍ច្បាប់ ។ ប៉ុន្តែ មាត្រា៥.១ ហាក់ដូចជាបានផាត់ចេញអំពីបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនូវព្រៃសម្បទានបច្ចុប្បន្ន បើសិនគ្មានការចរចាធ្វើកិច្ចសន្យាជាថ្មី ។ មាត្រានេះចែងថា "ចំពោះព្រៃសម្បទានដែលមានស្រាប់ គឺត្រូវបានគ្រប់គ្រងផងដែរ ដោយកិច្ចព្រមព្រៀងសម្បទានថ្មីដែលមានការព្រមព្រៀងពីគូរភាគីទាំងពីរតាមរយៈការចរចា ឬនៅពេលកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ត្រូវអស់សុពលភាព" ។
- **គំរោងសាកល្បងគ្រប់គ្រង និងត្រួតពិនិត្យព្រៃសម្បទាន:** ធនាគារពិភពលោកបានបន្តការគាំទ្ររបស់ខ្លួនចំពោះប្រព័ន្ធសម្បទានព្រៃឈើ ដោយបានបង្កើតគំរោងសាកល្បងគ្រប់គ្រងនិងត្រួតពិនិត្យព្រៃសម្បទាន សំរាប់រយៈពេល ៣ឆ្នាំ (២00១-២00៣) ។ គំរោងនេះមានគោលដៅបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងព្រៃឈើ មាគិាប្រតិបត្តិ

និងនីតិវិធីត្រួតពិនិត្យនៅក្នុងតំបន់សម្បទាន និងកសាងសមត្ថភាពសំរាប់តាមដាន និងទប់ស្កាត់បទឧក្រិដ្ឋព្រៃឈើឱ្យបានសក្តិសិទ្ធិ (World Bank 2000) ។ ធនាគារពិភពលោកកំពុងផ្តល់ជំនួយបន្ថែមសំរាប់គំរោង FCMP តាមរយៈគំរោងសាកល្បងគ្រប់គ្រង និងត្រួតពិនិត្យព្រៃសម្បទាន ។

- **ប្រកាសស្តីពីការផ្អាកសកម្មភាពកាប់ឈើព្រៃសម្បទាន:** អនុម័តចេញនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១ និងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០០២ ប្រកាសនេះបានហាមឃាត់គ្រប់សកម្មភាពកាប់ឈើសម្បទាន និងបញ្ឈប់ការផ្តល់លិខិតអនុញ្ញាតកាប់ឈើ រហូតដល់ពេលសម្បទានបានកសាង និងបានទទួលការអនុម័តលើផែនការគ្រប់គ្រងព្រៃសម្បទានថ្មី ដែលត្រូវមានខ្លឹមសារស្របតាមច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេស ។

### *៤.១០.២. កំណែទំរង់ការគ្រប់គ្រងព្រៃឈើក្នុងពេលអនាគត*

កាពិភាក្សាដ៏សំខាន់មួយកំពុងកើតមាននៅកម្ពុជា ស្តីពីវិធីល្អបំផុតសំរាប់កែទំរង់ការគ្រប់គ្រងព្រៃឈើ ។ ក្នុងរយៈពេល ៧ឆ្នាំកន្លងមក រដ្ឋាភិបាល និងម្ចាស់ជំនួយ បានផ្តោតធនធានលើកំណែទំរង់ប្រព័ន្ធសម្បទាន ក្នុងគោលដៅឱ្យបាននូវការគ្រប់គ្រងព្រៃឈើមានចីរភាព ។ ប៉ុន្តែដោយសារប្រព័ន្ធសម្បទានមានបញ្ហាទាក់ទិនច្រើនដូចជា ការប្រមូលចំណូលផ្លូវការចូលរដ្ឋ ភាពមានចំណេញរបស់សម្បទាន ការការិចរិលនិងការបាត់បង់ព្រៃឈើ និងផលប៉ះពាល់ខាងសង្គមកិច្ចនិងបរិស្ថាន... ដូច្នេះក៏មានការចោទសួរភាពសមរម្យនៃយុទ្ធសាស្ត្រយកធនធានដ៏កំរសំរាប់គ្រប់គ្រងព្រៃឈើ ទៅប្រើប្រាស់ជាបន្តធ្វើកំណែទំរង់សម្បទាន ។

McKenney (2002) បានរកឃើញហេតុផលជាច្រើនខាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបញ្ជាក់ថា ហេតុអ្វីបានជាការគ្រប់គ្រងសម្បទានព្រៃឈើមានចីរភាពនៅកម្ពុជា ប្រហែលជាមិនអាចសំរេចបាន ។ ទីមួយ ការតំរូវឱ្យធ្វើការប្រមូលផលមានចីរភាព គឺពី ១-៣ ដើម/ហិកតា (១០ម៣/ហិកតា) គឺពិបាកនឹងសំរេចខ្លាំងណាស់ ពីព្រោះប្រតិបត្តិការសម្បទានប្រហែលពុំមានចំណេញខាងសេដ្ឋកិច្ចអាចរស់បានទេ ក្រោមអត្រាប្រមូលផលទាបបែបនេះ ។ ទីពីរ ទោះបីសម្បទានិកអាចរកចំណេញបានសមរម្យក្រោមរបបប្រមូលផលមានចីរភាពក៏ដោយ ក៏ពួកគេមានចំណេញខាងហិរញ្ញវត្ថុច្រើនខ្លាំងណាស់ក្នុងការបន្តកាប់ឈើក្នុងកំរិតខ្ពស់ ពីព្រោះការអនុវត្តន៍បែបនេះបង្កើនចំណូល និងកាត់បន្ថយហានិភ័យរបស់ពួកគេ ។ ផលចំណេញខាងហិរញ្ញវត្ថុសំខាន់ៗនៃការកាប់ឈើក្នុងកំរិតខ្ពស់មានជាអាទិ៍:

- **ការសំរុកកាប់ កាត់បន្ថយកំរិតប្រឈមនឹងហានិភ័យរបស់សម្បទានិក:** ការកាប់ឈើពីព្រៃសម្បទានក្នុងរយៈពេល ២៥-៣០ឆ្នាំ ក្រោមរបបទិន្នផលមានចីរភាព (ជាជាងការកាប់ក្នុងរយៈ ៥-១០ឆ្នាំ ដូចអនុវត្តក្នុងពេលបច្ចុប្បន្ន) វាកាត់បន្ថយកំរិតប្រឈមនឹងហានិភ័យរបស់សម្បទានិកយ៉ាងច្រើន ។ នៅកម្ពុជា ហានិភ័យមានជាអាទិ៍: ការកាប់ឈើខុសច្បាប់ដោយភាគីផ្សេងទៀត ច្បាប់និងបទប្បញ្ញត្តិព្រៃឈើតឹងរឹងជាងមុន ការបញ្ឈប់កិច្ចសន្យា ភាពមិនទៀងទាត់ខាងនយោបាយ គ្រោះធម្មជាតិដូចជា ជំងឺដើមឈើ ភ្លើងឆេះព្រៃ និងទឹកជំនន់...
- **អត្រាចំណូលប្រចាំឆ្នាំខ្ពស់ជាងច្រើនអាចសំរេចបានតាមការសំរុកកាប់ និងការប្រាក់ចំណេញទៅលើវិនិយោគនៅកន្លែងផ្សេង (ជាជាងការកាប់មានចីរភាព):** ចំពោះសម្បទានិក ផលចំណេញក្នុងការផ្លាស់ប្តូរពីការសំរុកកាប់មកអនុវត្ត ការកាប់ឈើមានចីរភាព គឺការទុកឱ្យព្រៃបែតងគ្រប់រដូវដែលមានលក្ខណៈល្អខាងពាណិជ្ជកម្ម វាលូតលាស់ធំធាត់ កើនបរិមាណ និងតំលៃ សំរាប់ការប្រមូលផលម្តងទៀតក្នុងរយៈ ២៥-៣០ឆ្នាំខាងមុខ ។ ប៉ុន្តែ ចំពោះព្រៃនៅកម្ពុជា ឈើធំធាត់យឺតៗ ហើយឈើប្រទេសក្តៅវាមានកំណើនថ្លៃពីកំរិតទាបនៅក្នុងទីផ្សារ ដូច្នេះសម្បទានិកអាចបានចំណេញក្នុងអត្រាប្រចាំឆ្នាំប្រហែល ២-៣% សំរាប់ការ "រង់ចាំកាប់នេះ" ។ ជាជាងការអនុវត្តន៍របបប្រមូលផលមានចីរភាពដែលមានអត្រាទាញចំណូលប្រចាំឆ្នាំទាប និងមានហានិភ័យខ្ពស់ សម្បទានិកមានការលើកទឹកចិត្តខ្លាំងខាងហិរញ្ញវត្ថុ ក្នុងការកាប់ឈើឱ្យបានឆាប់តាមអាចធ្វើបាន ។ ផលចំណេញពីការកាប់នេះ អាចយកទៅ

វិនិយោគភ្លាម ដើម្បីបានចំណេញខ្ពស់ច្រើនជាងទៀត (បើធៀបនឹងផលចំណេញក្នុងរបបគ្រប់គ្រងមានចីរភាព) ។

- វិនិយោគបច្ចុប្បន្នរបស់សម្បទានិកលើសមត្ថភាពកែច្នៃឈើអាចប្រើមិនអស់លទ្ធភាព បើសិនការគ្រប់គ្រងព្រៃឈើមានចីរភាព វាកាត់បន្ថយការប្រមូលផលឈើៈ សព្វថ្ងៃសមត្ថភាពកែច្នៃឈើនៅកម្ពុជាគឺប្រហែល ១,២-២លានម$^{៣}$/ឆ្នាំ គឺខ្ពស់ច្រើនជាង បរិមាណកាប់ឈើមានចីរភាព ០,៥-១លានម$^{៣}$/ឆ្នាំ ។ អត្រាទាញចំណូលពីទុនវិនិយោគជាប់លាប់នៅក្នុងសមត្ថភាពកែច្នៃឈើ វាកើនឡើងតាមការប្រើប្រាស់ខ្លាំងនូវសមត្ថភាពនេះ (គឺកំណើនបរិមាណឈើមូល) ។ ការអនុវត្តន៍របបគ្រប់គ្រងព្រៃសម្បទានមានចីរភាពនឹងកាត់បន្ថយផលឈើកាប់ នាំឱ្យមានការប្រើប្រាស់ក៏រិតទាបនូវសមត្ថភាពកែច្នៃ ហើយប្រាក់ចំណូលលើទុនវិនិយោគជាប់លាប់ក៏នឹងថយចុះដែរ ។

ដោយសារមានបញ្ហាប្រឈមនៃការបង្កើនការគ្រប់គ្រងព្រៃសម្បទានមានចីរភាព និងដោយសារធនធានព្រៃឈើមានសារៈសំខាន់ចំពោះជីវភាពជនបទ ជំរើសផ្សេងទៀត ដូចជា ការគ្រប់គ្រងព្រៃដោយសហគមន៍ជាដើម ក្នុងពេលថ្មីៗនេះក៏បានទទួលការយកចិត្តទុកដាក់ និងការគាំទ្រច្រើនជាងមុន (សូមអានចំណុច "៤.៧ ការគ្រប់គ្រងព្រៃសហគមន៍") ។ ប៉ុន្តែ សព្វថ្ងៃព្រៃសហគមន៍ជាច្រើនកំពុងនៅក្មេងខ្ចីនៅឡើយ ។ ការអនុវត្តន៍ព្រៃសហគមន៍ឱ្យបានជោគជ័យជាទូទៅ វាអាស្រ័យទៅលើការទ្រទ្រង់របស់រដ្ឋាភិបាល ចំពោះការធ្វើវិមជ្ឈការគ្រប់គ្រងព្រៃឈើ ការស្វែងរកគំរូគ្រប់គ្រងដែលអស់ចំណាយតិច និងការទាញមេរៀនពីបរាជ័យ និងជោគជ័យ ។ រឿងនេះបង្ហាញពីតំរូវការដ៏សំខាន់ក្នុងពេលអនាគតនៃការវាយតំលៃឯករាជ្យពីគុណភាព និងភាពសក្តិសិទ្ធិនៃការប្រឹងប្រែងគ្រប់គ្រងរបស់សហគមន៍ ។

ក្រៅពីការគ្រប់គ្រងរបស់សហគមន៍ គឺមានការប្រឹងប្រែងជាថ្មីក្នុងការកំណត់តំបន់ព្រៃសំរាប់ការពារទុក នៅតាមកន្លែងដែលមានសារៈសំខាន់ខ្លាំងខាងជីវៈចំរុះ ជំរាលទទួលទឹកភ្លៀង អភិរក្ស និងសក្តានុពលសំរាប់អេកូទេសចរណ៍ ។ រដ្ឋាភិបាលបានចាត់វិធានការណ៍សំខាន់ៗមួយចំនួនហើយ ក្នុងការបង្កើតព្រៃការពារនៅភាគកណ្តាលនៃតំបន់ជួរភ្នំក្រវាញ ទោះបីជា មួយភាគធំស្ថិតនៅក្រោមសម្បទានបីខុសៗគ្នាក៏ដោយ ។ សកម្មភាពខាងលើរបស់រាជរដ្ឋាភិបាល បានទទួលស្គាល់ដោយប្រយោលថា សម្បទានិកបច្ចុប្បន្ន គ្មានសមត្ថភាពក្នុងការអនុវត្តន៍ការគ្រប់គ្រងព្រៃមានចីរភាព ដើម្បីការពារផលប្រយោជន៍ខាងបរិស្ថាននៅក្នុងតំបន់នេះទេ ។

## ៤.១១. សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំរាប់ការស្រាវជ្រាវ

វិស័យព្រៃឈើកម្ពុជា ស្ថិតក្នុងស្ថានភាពមានវិបត្តិធ្ងន់ធ្ងរនៅទូទាំងទសវត្សរ៍១៩៩០ ដោយសារមានការកាប់ឈើអនាធិបតេយ្យ និងខុសច្បាប់ទូទាំងប្រទេស, អំពើពុករលួយគ្រប់ទីកន្លែង, ច្បាប់ព្រៃឈើនិងកិច្ចព្រមព្រៀងសម្បទានគ្មានភាពច្បាស់លាស់ និងការគ្រប់គ្រង/ការអនុវត្តន៍ច្បាប់ទន់ខ្សោយ ។ ទិន្នន័យគំរប (ផ្ទៃ) ព្រៃឈើបង្ហាញថា អត្រាកាប់ព្រៃឈើកើនឡើងយ៉ាងខ្ពស់ពីឆ្នាំ១៩៩៣-១៩៩៧ (ឆ្នាំចុងក្រោយបំផុតដែលមានទិន្នន័យបញ្ជាក់) ។ លើសពីនេះ ករណីសិក្សា និងភស្តុតាងអះអាងផ្សេងៗបង្ហាញថា គុណភាពព្រៃនៅសល់បានថយចុះគួរឱ្យកត់សំគាល់ ដែលអាចបង្កការខូចខាតដល់តួនាទី "សំណាញ់សុវត្ថិភាព" ជាប្រវត្តិសាស្ត្រនៃធនធានព្រៃឈើចំពោះជីវភាពជនបទ ។

ទោះបីមានបរិបទមិនសូវអំណោយផលបែបនេះក៏ដោយ ក៏ការប្រឹងប្រែងធ្វើកំណែទំរង់ក្នុងពេលថ្មីៗ បានផ្តល់នូវឱកាសល្អដើម្បីកាត់បន្ថយអត្រាកាប់ព្រៃឈើ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងដែលមានប្រយោជន៍ច្រើនសំរាប់ប្រជាជនក្រីក្រនៅជនបទ ។ ការប្រឹងប្រែងរួមមាន ការផ្អាកការកាប់ឈើសម្បទានក្នុងពេលថ្មីៗ ការតាក់តែងច្បាប់ព្រៃឈើថ្មី និងអនុក្រឹត្យស្តីពីព្រៃសហគមន៍ ការបង្កើត និងពង្រីករចនាសម្ព័ន្ធព្រៃសហគមន៍ ។ ក្នុងការបោះជំហានទៅមុខនេះ បញ្ហាដ៏សំខាន់មួយសំរាប់ការគ្រប់គ្រងព្រៃឈើ គឺថាតើគេគួរ ឬមិនគួររក្សាទុកប្រព័ន្ធសម្បទាន ។ ក្នុងបញ្ហាដ៏សំខាន់ៗនៃការប្រមូលចំណូលរដ្ឋ ភាពមានចំណេញនៃសម្បទាន ការបាត់បង់និងការរិចរិលព្រៃឈើ

និងផលប៉ះពាល់ខាងសង្គមកិច្ច/បរិស្ថាន គេអាចឃើញច្បាស់ថា ប្រព័ន្ធសម្បទានកន្លងមក សំរេចបានតិចតួចណាស់នូវគោលដៅខាងគ្រប់គ្រង និងអភិវឌ្ឍន៍ដែលគេចង់បាន ។ ក្នុងការពិភាក្សាពីបញ្ហានេះ គេត្រូវពិចារណាផងដែរពីជំរើសផ្សេងទៀតនៃការគ្រប់គ្រងព្រៃឈើដែលអាចជំនួសឱ្យប្រព័ន្ធសម្បទាន ។ ដោយឡែកគេត្រូវធ្វើការសិក្សាច្រើនថែមទៀតពីតួនាទីផ្សេងៗនៃការគ្រប់គ្រងព្រៃសហគមន៍ដែលកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស ។

ការធ្វើគោលនយោបាយដ៏មធ្យ័តសំរាប់វិស័យព្រៃឈើ ទាមទារនូវពត៌មានថ្មីៗអំពីគំរបព្រៃឈើ ស្តុក និងការកាប់ឈើ ។ ៥វដ្ដរាកាប់ឈើបានកន្លងទៅហើយ ក្រោយពីការធ្វើបច្ចុប្បន្នភាពទិន្នន័យគំរបព្រៃឈើលើកចុងក្រោយ ។ ការធ្វើបច្ចុប្បន្នភាពគួបផ្សំនឹងការសិក្សាដល់ទីកន្លែងមួយចំនួន នឹងផ្តល់ជាអាំងឌីកាទ័រដ៏សំខាន់ សំរាប់វាយតំលៃពីភាពរីកចំរើននៃការគ្រប់គ្រងព្រៃឈើចាប់តាំងពីឆ្នាំ១៩៩៧មក ។ ការសិក្សានឹងជួយកំណត់កន្លែងផ្សេងៗដែលមានការកាប់ឈើលឿនបំផុតនៅកម្ពុជាផងដែរ ហើយរយៈតាមនេះគេនឹងអាចពិនិត្យឱ្យបានសព្វជ្រុងជ្រោយពីមូលហេតុដើមនៃការកាប់ព្រៃឈើ ។

ក្រៅពីការលំអពត៌មានស្ដីពីមូលដ្ឋានធនធានព្រៃឈើ នៅមានតំរូវការធ្វើការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ចស្ដីពីចំណងទាក់ទងរវាងធនធានព្រៃឈើ នឹងជីវភាពជនបទ ។ ទោះបីគេទទួលស្គាល់ជាទូទៅថា ប្រជាជនជនបទជាច្រើនត្រូវពឹងផ្អែកលើព្រៃឈើដើម្បីចិញ្ចឹមជីវិត ប៉ុន្តែគេនៅជជែកវែកញែកជាបន្តថា តើធ្វើយ៉ាងណាអាចគ្រប់គ្រងធនធានព្រៃឈើបានល្អបំផុត ដើម្បីសំរេចបាននូវគោលដៅខាងអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ ។ ដើម្បីផ្តល់ពត៌មានដល់ការជជែកវែកញែកខាងក្រោមនេះគឺជាប្រធានបទសំខាន់ៗមួយចំនួនសំរាប់ការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ចក្នុងពេលអនាគត ។

## ១. តើប្រព័ន្ធសម្បទានព្រៃឈើមានប្រសិទ្ធិភាពដូចម្ដេចនៅក្នុងការសំរេចគោលបំណងអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

ទោះបីក្នុងពេលថ្មីៗព្រៃសម្បទានត្រូវបានកាត់បន្ថយទៅនេះ ក៏វានៅតែជាវិធីគ្រប់គ្រងដ៏ចំបងសំរាប់ ៤,២លានហិកតានៃព្រៃឈើដែលមានទិន្នផលខ្ពស់របស់កម្ពុជា ។ ការគ្រប់គ្រងព្រៃសម្បទាន មានគោលដៅជាច្រើនដូចជា:

- ការគ្រប់គ្រងព្រៃឈើមានចីរភាព ដើម្បីធានាឱ្យមនុស្សជំនាន់ក្រោយទទួលប្រយោជន៍ពីធនធានព្រៃឈើផងដែរ ។
- ការបង្កើនចំណូលរដ្ឋាភិបាលតាមរយៈការជួល និងកំរៃផ្សេងៗ ។ ជាការប្រសើរបំផុត ថវិកាទាំងនេះត្រូវគាំទ្រដល់ការអភិវឌ្ឍន៍ជនបទ និងគំរោងកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ដែលទទួលផលអវិជ្ជមានពីសម្បទានព្រៃឈើ ។
- ការបង្កើតការងារ និងការអភិវឌ្ឍន៍ជនបទសំរាប់ប្រជាជននៅមូលដ្ឋាន ឧទាហរណ៍ ការកាប់ឈើ ការកែច្នៃឈើ និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ដែលអាចផ្តល់ការងារដល់ប្រជាជនរស់នៅក្នុង ឬនៅក្បែរព្រៃសម្បទាន ។

ទោះបីជាមានការពិនិត្យសព្វជ្រុងជ្រោយឡើងវិញលើសម្បទានព្រៃឈើក្នុងឆ្នាំ២០០០ក៏ដោយ ក៏ការសិក្សានោះផ្តោតតែលើការវាយតំលៃលើរបៀបរបបគ្រប់គ្រងព្រៃឈើរបស់សម្បទានិក ដោយមិនបានវាយតំលៃពីប្រសិទ្ធិភាពនៃប្រព័ន្ធសម្បទានក្នុងការបំពេញគោលដៅខាងអភិវឌ្ឍន៍ជនបទឡើយ ។ សំនួរស្រាវជ្រាវដែលអាចលើកឡើងសំរាប់ធ្វើការស៊ើបអង្កេតរួមមាន:

- តើចំនូលរដ្ឋាភិបាល (ផ្លូវការ និងក្រៅផ្លូវការ) ប៉ុណ្ណាដែលប្រមូលបានពីការជួលសម្បទានព្រៃឈើ និងកំរៃផ្សេងៗ ហើយតើចំណូលនេះត្រូវបានប្រើប្រាស់យ៉ាងដូចម្ដេចសំរាប់ដោះស្រាយគោលដៅខាងអភិវឌ្ឍន៍ជនបទ?
- តើព្រៃសម្បទានមានផ្តល់ផលប្រយោជន៍អ្វីទៀតទេសំរាប់ការអភិវឌ្ឍន៍ជនបទ ដូចជា ការងារនៅក្នុងប្រតិបត្តិការ និង/ឬ ការជួយទ្រទ្រង់ដល់ការកែច្នៃ និងម៉ាឃីតទីង?
- យោងតាមគោលដៅរបស់រដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ តើគួរផ្អែកលើមូលដ្ឋាន/លក្ខណៈវិច្ឆ័យអ្វីខ្លះ ចំពោះការរក្សាទុក ឬលុបចោលព្រៃសម្បទាន ដើម្បីចាប់យកប្រភេទគ្រប់គ្រង

ផ្សេងទៀត?

- តើសម្បទានព្រៃឈើកន្លងមកបានប៉ះពាល់យ៉ាងដូចម្តេចដល់លទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ សកម្មភាពទ្រទ្រង់ជីវភាព សន្តិសុខស្បៀង និង "សំណាញ់សុវត្ថិភាព" នៃធនធានរួមរបស់ប្រជាជនជនបទ?

## ២. តើមានបន្ទុកចំណាយ និងចំណេញអ្វីខ្លះ ក្នុងការបង្កើត និងគ្រប់គ្រងព្រៃសហគមន៍?

NGOs ជាច្រើនកំពុងជួយបង្កើតព្រៃសហគមន៍នៅកម្ពុជា ។ ការិយាល័យព្រៃសហគមន៍នៃនាយកដ្ឋានរុក្ខាប្រមាញ់ និង អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើដែលនឹងអនុម័តក្នុងអនាគត គឺសុទ្ធតែដើម្បីជួយគាំទ្រដល់ការប្រឹងប្រែងទាំងនេះ ។ ដូចគ្នានឹងសហគមន៍នេសាទដែរ ការបង្កើតព្រៃសហគមន៍ អាចជាការងារដ៏ធំមួយត្រូវមានចំណាយច្រើនទាក់ទិននឹងសកម្មភាពរៀបចំសហគមន៍ ការចរចាក្នុងចំណោមអ្នកពាក់ព័ន្ធ ការបង្កើតផែនការគ្រប់គ្រងនិងច្បាប់ទំលាប់ ការតាមដាននិងការអនុវត្តន៍ច្បាប់ និង ការដោះស្រាយទំនាស់ ។ ការបង្កើតព្រៃសហគមន៍បានជោគជ័យនឹងអាស្រ័យលើការកាត់បន្ថយចំណាយនៅក្នុងការបង្កើត និង ការគ្រប់គ្រង និងការបង្កើនអត្ថប្រយោជន៍ធនធានព្រៃឈើ ។

ជាការច្បាស់ណាស់ អត្ថប្រយោជន៍ជាសក្តានុពលនៃព្រៃសហគមន៍ មានចំណងទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងផលិតភាពនៃមូលដ្ឋានធនធាន ។ ដោយសារតំបន់ព្រៃឈើមានតំលៃភាគច្រើន ត្រូវបានផ្តល់ជាសម្បទានទៅឱ្យក្រុមជំនួញ ដូច្នេះអាចថាសហគមន៍ព្រៃឈើជាច្រើនក្នុងពេលបច្ចុប្បន្ន ទំនងជាកំពុងគ្រប់គ្រងតំបន់ដែលរិចរិលរួចហើយ ។ បើសិនអ្នកពាក់ព័ន្ធយល់ថាផលចំណេញទទួលបានពីព្រៃសហគមន៍នឹងមានកាន់តែតិចតួច ដូច្នេះ ពួកគេគ្មានការលើកទឹកចិត្តនឹងធ្វើវិនិយោគពេលវេលា/ការប្រឹងប្រែងដ៏ចាំបាច់ផ្សេងៗ ដើម្បីរក្សាឱ្យមានការគ្រប់គ្រងយ៉ាងសក្តិសិទ្ធនោះទេ ។ សំនួរស្រាវជ្រាវសំខាន់ៗរួមមាន:

- តើតំបន់ព្រៃដែលបែងចែកសំរាប់គ្រប់គ្រងដោយសហគមន៍មានស្ថានភាពដូចម្តេច? តើមូលដ្ឋានធនធាននេះខុសគ្នាដូចម្តេចនឹងតំបន់នៅក្បែរៗ (ក្នុងព្រៃសម្បទាន)? តើគុណភាពនៃមូលដ្ឋានធនធានមានផលប៉ះពាល់ដូចម្តេចចំពោះការបង្កើត និងថែរក្សាការគ្រប់គ្រងព្រៃសហគមន៍? តើត្រូវធ្វើដូចម្តេចដើម្បីបង្កើតអត្ថប្រយោជន៍ព្រៃសហគមន៍?
- តើចំណាយពាក់ព័ន្ធនឹងការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍វាមានកំរិតប៉ុនណា?
- តើអាចស្រង់មេរៀនអ្វីខ្លះពីបទពិសោធន៍បង្កើតព្រៃសហគមន៍បច្ចុប្បន្ន ដែលគេអាចយកទៅអនុវត្តសំរាប់កិច្ចប្រឹងប្រែងក្នុងអនាគតទៀត?

## ៣. តើទំនាស់អំពីធនធានព្រៃឈើ ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន ហើយគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

គេឃើញមានទំនាស់ជាច្រើនពីរឿងធនធានព្រៃឈើ ។ ឧទាហរណ៍ ជារឿយៗទំនាស់ជាប់ទាក់ទងនឹងដើមឈើយកជ័រ ពីព្រោះវាមានប្រយោជន៍សំរាប់អ្នកប្រមូលជ័រផង និងសម្បទានិកផង ។ ប្រជាជនជនបទបានត្អូញត្អែរផងដែរពីរឿងលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើនៅក្នុងតំបន់សម្បទាន និងតំបន់ "ត្រួតត្រា" ផ្សេងទៀត ។ ក្នុងនេះហាក់មានតំរូវការខ្លាំងនូវ ដំណើរការ និងយន្តការសំរាប់ដោះស្រាយទំនាស់អំពីធនធានព្រៃឈើ ប៉ុន្តែគេមានពត៌មានតែតិចតួចស្តីពីរបៀបរបបដោះស្រាយទំនាស់បច្ចុប្បន្ន ។ ស្រដៀងគ្នានឹងការស្រាវជ្រាវដែលបានលើកឡើងសំរាប់ការដោះស្រាយទំនាស់ជលផលដែរ ការស្រាវជ្រាវដំបូងៗពីរឿងទំនាស់ធនធានព្រៃឈើអាចផ្តោតលើសំនួរដូចតទៅ :

- តើមានដំណើរផ្លូវការអ្វីសំរាប់ដោះស្រាយទំនាស់ធនធានព្រៃឈើ ដោយយោងតាម ច្បាប់ព្រៃឈើ ព្រមទាំង អនុក្រឹត្យ និង បទប្បញ្ញត្តិជាប់ទាក់ទិន? តើអ្នកណាខ្លះជាប់ពាក់ព័ន្ធ ហើយគេមានតួនាទីយ៉ាងដូចម្តេច?

- តើទំនាស់ធនធានព្រៃឈើ គេតែងដោះស្រាយយ៉ាងដូចម្តេចក្នុងការអនុវត្តន៍ជាក់ស្តែង?
- តើគេអាចដកស្រង់មេរៀន និងគំរូជាប់ទាក់ទិនអ្វីខ្លះពីប្រទេសដទៃ សំរាប់ការដោះស្រាយទំនាស់ធនធានព្រៃឈើ?
- តើដំណើរការដោះស្រាយទំនាស់អាចកែលំអយ៉ាងដូចម្តេចបាន? ឧទាហរណ៍ តើមានតួនាទីសមស្របឬទេសំរាប់ក្រុមប្រឹក្សាឃុំទើបជាប់ឆ្នោតថ្មីៗ នៅក្នុងការដោះស្រាយទំនាស់ ?

## ៤. តើការកែច្នៃ ពាណិជ្ជកម្ម និងការនាំចេញផលិតផលព្រៃក្រៅពីឈើ មានស្ថានភាពយ៉ាងណាបច្ចុប្បន្ននេះ? តើជីវភាពជនបទអាចកែលំអយ៉ាងណាបានតាមរយៈការកែប្រែវិធីចាត់ចែងសកម្មភាពនាំងនេះ?

ឧទាហរណ៍ ការស្រាវជ្រាវជំហានដំបូងដោយ NGO Forum និងស្ថាប័នផ្សេងៗទៀតបង្ហាញឱ្យឃើញថា ការលក់ជ័រគឺជាសមាសភាគចំបងមួយនៃចំណូលជីវភាពនៅក្នុងតំបន់ព្រៃឈើ ។ ប៉ុន្តែ សព្វថ្ងៃមានរបាំងជាច្រើនចំពោះពាណិជ្ជកម្មជ័រ ក្នុងនេះរបាំងធំជាងគេ គឺអាជ្ញាប័ណ្ណដឹកជញ្ជូនជ័រ ។ ដោយសារការដឹកជញ្ជូនគ្មានអាជ្ញាប័ណ្ណ គឺជាអំពើខុសច្បាប់ ឯការសុំអាជ្ញាប័ណ្ណវាពិបាក និងមានតំលៃខ្ពស់ ដូច្នេះអ្នកប្រមូលជ័រជាទូទៅមានជំរើសតែពីរទេ គឺលក់ជ័រទៅឱ្យឈ្មួញដែលមានអាជ្ញាប័ណ្ណក្នុងតំលៃទាបជាងទីផ្សារ ឬត្រូវស្វែងរកវិធីរត់ពន្ធជ័រទៅកាន់ទីផ្សារ (ដែលអស់សោហ៊ុយមួយចំនួន និងមានហានិភ័យ) ។ នៅក្នុងជំរើសទាំងពីរ អ្នកប្រមូលជ័រសុទ្ធតែត្រូវខាតចំណូល ។ ការលុបចោលប្រព័ន្ធអាជ្ញាប័ណ្ណបច្ចុប្បន្នគឺជាការចាំបាច់ ពីព្រោះវាបង្កើនការប្រជែងទិញជ័រក្នុងចំណោមឈ្មួញកណ្តាល និងអ្នកនាំចេញជ័រ ដែលនឹងធ្វើឱ្យកំលាំងតថ្លៃរបស់អ្នកប្រមូលជ័រកើនឡើង ។

ក្រៅពីការសិក្សាប្រព័ន្ធអាជ្ញាប័ណ្ណបច្ចុប្បន្នសំរាប់ការដឹកជញ្ជូនជ័រ គេគួរស្វែងរកជំរើសផ្សេងៗក្នុងការកែច្នៃផលិតផលជ័រដើម្បីបង្កើនតំលៃបន្ថែមនៅថ្នាក់មូលដ្ឋាន ។ ឧទាហរណ៍ ជាតិប្រេងសំខាន់ៗនៅក្នុងជ័រ ត្រូវបានគេប្រើប្រាស់ជាគ្រឿងផ្សំនៅក្នុងទំនិញមានតំលៃខ្ពស់ជាច្រើន ដូចជាទឹកអប់ជាដើម ។ ដូច្នេះអាចមានដំណាក់កាលកែច្នៃមួយចំនួនដែលអាចអនុវត្តនៅថ្នាក់មូលដ្ឋាន ដើម្បីបង្កើតតំលៃបន្ថែម និងបង្កើនថ្លៃលក់ ។ ការស្រាវជ្រាវបន្ថែមពីការបញ្ជោជួញដូរ និងកែច្នៃជ័រ អាចមានដូចជា:

- តើជ័រត្រូវបានគេជួញដូរ និងនាំចេញដូចម្តេច? តើអ្នកណាខ្លះចូលរួម ហើយទីផ្សារចំបងៗមាននៅកន្លែងណាខ្លះ? តើការបង់ថ្លៃផ្លូវការ និងក្រៅផ្លូវការ និងចំណាយផ្សេងៗពាក់ព័ន្ធនឹងការនាំចេញមានចំនួនប៉ុន្មាន? ក្នុងការអនុវត្តន៍ជាក់ស្តែង តើមានកំរិតចំណេញប៉ុន្មានសំរាប់អ្នកចូលរួមផ្សេងៗនៅក្នុងទីផ្សារនាំចេញជ័រ (អ្នកចៀរជ័រ ឬអ្នកប្រមូលជ័រ អ្នកទិញ ឈ្មួញកណ្តាល អ្នកដឹកជញ្ជូន និងអ្នកនាំចេញ)? តើកំរិតចំណេញសំរាប់អ្នកចូលរួមក្នុងទីផ្សារម្នាក់ៗវាយ៉ាងណាដែរ បើទៅនឹងផលិតផល ឬសេវាដែលគេបានផ្តល់?
- តើមានរបាំងផ្លូវការនិងក្រៅផ្លូវការអ្វីខ្លះ ចំពោះការចូលទៅធ្វើពាណិជ្ជកម្ម និងការនាំចេញជ័រ? តើពាណិជ្ជកម្មជ័រត្រូវបានគ្រប់គ្រង ជាលក្ខណៈផ្តាច់មុខ ឬក្រោមការស៊ុំគ្រលំគ្នា បែបណាខ្លះ?
- ហេតុអ្វីបានជាការដឹកជញ្ជូនជ័រតំរូវឱ្យមានអាជ្ញាប័ណ្ណ? ក្រៅពីការរកចំណូល តើមានគោលដៅអ្វីទៀតនៃការគ្រប់គ្រងព្រៃឈើដែលគេបានលើកមកសំអាង ដើម្បីតំរូវឡើងនូវអាជ្ញាប័ណ្ណនេះ?
- តើគេអាចចាត់វិធានការណ៍អ្វីខ្លះ ដើម្បីបង្កើនកំលាំងតថ្លៃរបស់អ្នកប្រមូលជ័រ នៅក្នុងការលក់ជ័ររបស់ពួកគេ?
- តើជ័រត្រូវបានកែច្នៃយ៉ាងដូចម្តេច (នៅវៀតណាម នៅថៃ)? តើមានឱកាសល្អអ្វីខ្លះសំរាប់ការកសាងអាជីវកម្មកែច្នៃជ័រនៅមូលដ្ឋាន ដែលនឹងបង្កើតតំលៃបន្ថែម និងផលចំណូលនៅមូលដ្ឋាន? តើមានឱកាសល្អអ្វីខ្លះសំរាប់ការនាំចេញជ័រដោយផ្ទាល់ទៅទីផ្សារក្រៅប្រទេសដែលឱ្យតំលៃខ្ពស់ជាង?

## ឯកសារយោង


Agrawal, A. and C. Gibson (1999), "Enchantment and Disenchantment: The Role of Community in Natural Resource Conservation", in *World Development*, Vol. 27, No. 4, pp. 629-649

Ashwell, D. (no date), *Information and Issues Pertaining to Community Based Management of Forest Resources in Cambodia: A Discussion Paper*, (Phnom Penh: Community Forestry Working Group)

Associates for Rural Development, Inc. (1998), "Proceeds of Meeting to Brief the International Community and Senior Officials of the Royal Government of Cambodia on Forest Policy Reform" (Phnom Penh: Fortech Presentation)

Baltzer, M.C., T.D. Nguyen, and R.G. Shore (eds.) (2001), *Towards a Vision for Biodiversity Conservation in the Forests of the Lower Mekong Ecoreion Complex*, (Hanoi/Washington D.C.: WWF Indochina/WWF US)

Bottomley, R. (2000), *Structural Analysis of Deforestation in Cambodia* (Ratanakiri and Japan: Non-Timber Forest Products Project; Mekong Watch and Institute for Global Environmental Studies)

Castren, Tuukka (2000), *Timber Trade and Wood Flow Study: Cambodia*, (Regional Environmental Technical Assistance 5771, Poverty Reduction & Environmental Management in Remote Greater Mekong Subregion (GMS) Watersheds Project (Phase I))

Chan, S. (forthcoming), "Case Study Report on Dang Kdar Village, Kampong Thom Province", (Phnom Penh: CDRI)

Chan S., S. Tep, and S. Acharya (2001), *Land Tenure in Cambodia: A Data Update* (Phnom Penh: CDRI Working Paper No. 19)

Chea, S.A., and ARD Inc. (1998), *The Study of Effects of Forests on Rural Livelihoods in Kampong Thom Province, Cambodia*, (Phnom Penh: Department of Forestry and Wildlife)

Curtis, G. (1989), *Cambodia: A Country Profile*, (Stockholm: Swedish International Development Authority)

Development Alternatives, Inc. (DAI) (1998), *Result of the National Assessment on Illegal Logging, Processing and Timber Exports in Cambodia*, (Phnom Penh: Log Monitoring and Logging Control Project, submitted to Royal Government of Cambodia, Ministry of Economy and Finance, Ministry of Agriculture, Forestry and Fisheries)

DAI (1998), *Findings and Recommendations of the Log Monitoring and Logging Control Project-Main Report: Final Edition*, (Phnom Penh: Log Monitoring and Logging Control Project, submitted to Royal Government of Cambodia, Ministry of Economy and Finance, and Ministry of Agriculture, Forestry and Fisheries)

Forest Crime Monitoring Unit (2000), *Forest Crime Monitoring and Reporting Project: Independent Monitoring and Verification, Final Report, June 2000*, (Phnom Penh: Forest Crime Monitoring Unit)

Fraser Thomas, GFA-AGRAR, and ANZDEC (2000), *Cambodia Forest Concessionaire Review Report* with *Appendix 1: Individual Assessment of Concessions,* (Phnom Penh: Sustainable Forest Management Project, Asian Development Bank)

Fraser Thomas, GFA-AGRAR, and ANZDEC (2000), *Community Forest Guidelines*, (Phnom Penh: Sustainable Forest Management Project, Asian Development Bank)

Fraser Thomas and Department of Forestry and Wildlife (2000), *Forest Concession Management Planning Manual*, (Phnom Penh: ADB and World Bank)

Global Witness (2002), *Deforestation without limits: How the Cambodian government failed to tackle the untouchables*, (Phnom Penh: Global Witness)

Global Witness (2001), *The Credibility Gap – and the Need to Bridge It: Increasing the pace of forestry reform*, (Phnom Penh: Global Witness)

Global Witness (2000a), *Chainsaws speak louder than words*, (Phnom Penh: Global Witness)

Global Witness (2000b), *ADB Concession Review – Still Falling Short*, (Phnom Penh: Global Witness)

Global Witness (2000c), *Illegal Activities of GAT International in the Cardamom Mountains*, (Phnom Penh: Global Witness)

Global Witness (1999a), *The Untouchables: Forest crimes and the concessionaires – can Cambodia*

*afford to keep them?*, (Phnom Penh: Global Witness)

Global Witness (1999b), *Situation Report – Update on Cambodian Forest Sector*, (Phnom Penh: Global Witness)

Global Witness (1999c), *Crackdown or Pause: A Chance for Forestry Reform in Cambodia?*, (Phnom Penh: Global Witness)

Global Witness (1997), *A Tug of War: The Struggle to Protect Cambodia's Forests*, (Phnom Penh: Global Witness)

Global Witness (1996), *Cambodia, Where Money Grows on Trees*, (Phnom Penh: Global Witness)

Global Witness (1995a), *Forests, Famine, and War: The Key to Cambodia's Future*, (Phnom Penh: Global Witness)

Global Witness (1995b), *Thai – Khmer Rouge Links & The Illegal Trade in Cambodia's Timber*, (Phnom Penh: Global Witness)

Hardcastle, P.D. (2001), *Evaluation of National Community Forestry Programme: CONCERN Cambodia* (Phnom Penh: Concern Worldwide)

Hong, N. (1997), "Country Paper on Some Aspects of Forestry in Cambodia", in *Asia-Pacific Forestry Sector Outlook Study Working Paper Series*, No. 18 (Bangkok: FAO)

Hou, K., R. Sy, C. Chay, and S. Meas (2001), *Forest Use and Product Flow in Chumkiri District*, Kampot Province, (Singapore: Economy and Environment Program for Southeast Asia)

Hou, K. and T. Carson (2000), *Scoping Report: Community Based Natural Resource Management (CBNRM) in Cambodia*, (Phnom Penh: WWF Conservation Program in Cambodia and IDRC)

Kim Phat, N., Y. Uozumi, S. Ouk, and T. Ueki (1999), *Forest Management Problems in Cambodia – A Case Study of Forest Management of F Company*, (Nagano, Japan: Shinshu University)

Kim Phat, N., Y. Uozimi, T. Ueki, and W. Drury (1998), *Analysis on the Demand for Cambodia's Forest Products*, (Nagano, Japan: Shinshu University)

Kollert W., T. Dillon, and A. McNaughton (2000), *Cambodian Forest Concession Review: Evaluation of the Draft Report and Recommendation for Follow up Action*, (Phnom Penh: Sustainable Forest Management Project, Asian Development Bank)

KPMG International Forestry and Environmental Advisory Services Group (2001), *(Draft) The Equitability of the Forest Taxation System in Cambodia*, (Phnom Penh: prepared for Cambodia Timber Industry Association)

Lim, S., D.V. Samrang, S. Kim, and K. Mom (2001), "Case Study on Wild Fruit Collection in Bosthom Community Forestry", in CBNRM Team, *CBNRM Lessons Shared: A Series of CBNRM Case Studies from the Tonle Sap, Siem Reap Province* (Phnom Penh: WWF Conservation Program in Cambodia)

Lun, K., K. Hou, M. Srey, S. Ken, R. Choir, S. Lao, K. Phan, and M. Im (1998), *Forest Resource Use by Local Communities in Cambodia*, (Phnom Penh: IDRC and RECOFTC)

McKenney, B. (2002), "Questioning Sustainable Concession Forestry in Cambodia", in *Cambodia Development Review*, Vol. 6, Issue 1, pp. 1-7

McKenney, B. (2001), *Baseline Assessment of Cambodia's Forestry Sector*, (Phnom Penh: WWF Conservation Program in Cambodia)

Ministry of Agriculture, Forestry and Fisheries (2002), *Progress Report on Natural Resource Management to the Follow Up Meeting Second Semester 2001 between the Royal Government of Cambodia and Donor Community, 16 January 2002*, (Phnom Penh: MAFF)

Ministry of Agriculture, Forestry and Fisheries (2001), *Prakas on Suspension of Forest Concession Logging Activities*, (Phnom Penh: MAFF)

Ministry of Economy and Finance (2002), "Forestry revenue data", (Phnom Penh: provided to CDRI)

National Institute of Statistics (2000), *Report on the Cambodia Socio-Economic Survey 1999*, (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *General Population Census of Cambodia 1998* (Phnom Penh: Ministry of Planning)

Ratanakiri Non-Timber Forest Products Project (2001), *Agreement: Yakpoy Forest Community, Poy*

*Commune, O Chum District, Ratanakiri Province*, (Ratanakiri: NTFP Project)

Ratanakiri Non-Timber Forest Products Project (2001), *Statute of Yakpoy Forest Community, Poy Commune, O Chum District, Ratanakiri Province,* (Ratanakiri: NTFP Project)

Rao, Sar (1999), *The Assessment of Logging Damage: A Case Study in the Forest Concession Area of Colexim at Kompong Thom Province, Cambodia*, (Göttingen, Germany: Thesis to obtain Master of Science degree in Tropical Forestry at Georg-August University of Göttingen)

Ratanakiri Provincial Rural Development Department *et al*. (2000), *Cultural Resource Study: Impacts of the Hero Taiwan Company Concession on Sites of Religious and Cultural Significance in O Chum District, Ratanakiri*, (Ratanakiri, Cambodia)

Royal Government of Cambodia (20 July 2001), *(Draft) Forestry Law*, (Phnom Penh: submitted to National Assembly)

Royal Government of Cambodia (2000), *Sub-Decree on the Forest Concession Management*, (Phnom Penh: RGC No. 05 ONKR-BK)

Royal Government of Cambodia (1999), *Declaration on Managerial Measures and Stopping of Forestry Anarchy*, (Phnom Penh: Declaration No. 1)

So, S.M., M. Cheam, B. Son, T. Em, D. V. Samrang (2001), *Economic Valuation of Livelihoods Activities in Pourapet Village of Mondulkiri Province,* (Phnom Penh: WWF Conservation Program in Cambodia)

Srey, M., S. Colm, and K. Hou (2000), *Cultural Resource Study: Impacts of the Hero Taiwan Company Concession on Sites of Religious and Cultural Significance in O Chum District, Ratanakiri,* (Ratanakiri: CARERE, CIDSE, and NTFP-Ratanakiri)

Talbott, K. (1998), "Logging in Cambodia: Politics and Plunder" in Brown, F.Z. and D.G. Timberman (eds.) *Cambodia and the International Community: The Quest for Peace, Development and Democracy*, (Singapore: ISEAS)

Ung, S. A. (1991), *Forestry Situation in Kampuchea*, (Bangkok: RECOFTC Paper 79)

White and Case (1998), *Analysis of Cambodian Law and Forest Concession Contracts*, (Phnom Penh: Forest Policy Reform Project, submitted to Royal Government of Cambodia, Ministry of Economy and Finance, Ministry of Agriculture, Forestry and Fisheries)

World Bank (2000), *Project Appraisal Document on a Proposed Learning and Innovation Credit in the Amount of US$4.82 Million Equivalent to the Kingdom of Cambodia for a Proposed Forest Concession Management and Control Pilot Project* (Rural Development and Natural Resources Sector, East Asia and Pacific Region)

World Bank (1999), *Cambodia: A Vision for Forestry Sector Development*, (World Bank Background Note: 1999 Cambodia Consultative Group meeting)

World Bank, United Nations Development Programme, and Food and Agriculture Organisation (1996), *Cambodia Forestry Policy Assessment,* (World Bank: Report No. 15777-KH)

World Bank, United Nations Development Programme, and Food and Agriculture Organisation (1997), *Cambodia-Recent Development in Forestry Policy-Overview and Recommendations*, (Phnom Penh: World Bank/UNDP/FAO)

World Rainforest Movement (2001), "Cambodia: Resin tapping incomes at odds with logging", in *WRM Bulletin,* No. 48 (http://www.wrm.org.uy/bulletin/48/Cambodia.html)

Yoshida, K., S. Chea, S. Khun, P. Lay, P. Sok, and K. Ouk (2001), *Forest Resource Utilization and Tree Planting Activities around Phnom Tamao Area, Bati District, Takeo Province, Cambodia*, (Phnom Penh: Department of Forestry and Wildlife and Japan International Cooperation Agency)

# ការសន្និដ្ឋាន និងសេចក្តីសង្ខេប
# ពីផ្នែកគួរធ្វើការស្រាវជ្រាវ

ដោយមានប្រជាជនជនបទជាង ៧លាននាក់ត្រូវពឹងពាក់លើកសិកម្ម ការនេសាទ និងព្រៃឈើ សំរាប់ការរស់រាន ចំណុចសំខាន់មួយនៃការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រនៅជនបទក្នុងពេលអនាគត គឺការគ្រប់គ្រងធនធានធម្មជាតិឱ្យបានសក្តិសិទ្ធិ ។ ក្នុងមួយទសវត្សរ៍កន្លងទៅ ការប្រមូលផលឈើ និងត្រី ខុសច្បាប់ និងគ្មានចីរភាព ដោយសហគ្រាសជំនួញ យោធា អាជ្ញាធរមូលដ្ឋាន ព្រមទាំងកំណើនប្រជាជនជនបទ បានបង្កការបាត់បង់ និងរិចរឹលព្រៃឈើក្នុងកំរិតខ្ពស់ និងការថយចុះទិន្នផលនៅតាមតំបន់នេសាទជាច្រើន ។ ទន្ទឹមនឹងនេះ កំណើនការប្រជែងគ្នាដណ្តើមដី បាននាំឱ្យមានកំណើនប្រជាជនគ្មានដីធ្លី ។ កំណើនប្រជាជនយ៉ាងលឿន និងសម្ពាធជាប្រចាំនៃតំរូវការដី ព្រៃឈើ និងជលផល បានបង្ហាញថា ការរក្សាបាននូវជីវភាពគ្រប់គ្រាន់ក្នុងជនបទអាចជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅទសវត្សរ៍ខាងមុខ ។

គោលនយោបាយសំដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពជនបទ ត្រូវពិចារណាយ៉ាងប្រុងប្រយ័ត្នពីចំណងទាក់ទងដ៏ជិតស្និទ្ធរវាងជីវភាពជនបទ និងធនធានធម្មជាតិ ជាពិសេសតួនាទីដ៏សំខាន់នៃធនធានព្រៃឈើ និងជលផល ។ ជាញឹកញាប់ធនធានទាំងនេះគឺជា "សំណាញ់សុវត្ថិភាព" សំរាប់ជីវភាពពួកអ្នកក្រីក្របំផុត ពោលគឺអ្នកមានទ្រព្យសម្បត្តិតិចតួច និងគ្មានដីធ្លី ។ គោលនយោបាយនានាដែលរួមចំណែកធ្វើឱ្យបាត់បង់ និងរិចរឹលធនធានធម្មជាតិ គឺអាចចាត់ទុកជាទូទៅថា នឹងបង្កើនបញ្ហាចោទនៃភាពក្រីក្រនៅក្នុងតំបន់ជនបទ ។ ដូចគ្នាដែរ យុទ្ធសាស្ត្រគ្រប់គ្រងលើសម្បទាន បានកាត់បន្ថយលទ្ធភាពរបស់ប្រជាជនក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលកាលពីមុន គឺជាធនធានរួម ហើយវានឹងធ្វើឱ្យភាពក្រីក្រនៅជនបទកាន់តែធ្ងន់ធ្ងរឡើង ព្រមទាំងអាចនាំទៅដល់ទំនាស់ ។ គោលនយោបាយកាត់បន្ថយភាពក្រីក្រប្រហែលជាសក្តិសិទ្ធិជាង បើសិនផ្តោតទៅលើវិធីសាស្ត្រអភិវឌ្ឍន៍ចំរុះដែលសំដៅកែលំអយុទ្ធសាស្ត្រទ្រទ្រង់ជីវភាពជនបទ និងសំរាលផលប៉ះពាល់ពីវិស័យផ្សេងទៀត (ដូចជាផលប៉ះពាល់នៃការអភិវឌ្ឍន៍កសិកម្មទៅលើជលផល) ។

ការធ្វើគោលនយោបាយបានត្រឹមត្រូវ គឺអាស្រ័យដោយមានពត៌មានទាន់ពេល អាំងឌីការទ័រឆ្លុះបញ្ចាំងពីបញ្ហាជាគន្លឹះ និងការវិភាគដ៏មានប្រយោជន៍ ។ ពត៌មានបច្ចុប្បន្នស្តីពីធនធានធម្មជាតិ និងជីវភាពជនបទ អាចកែលំអបានតាមវិធីដូចតទៅ:

- **ធ្វើបច្ចុប្បន្នភាព និងកែលំអទិន្នន័យស្តីពីគំរបព្រៃឈើ ផលត្រី និងប្រភេទត្រីចាប់បាន:** ទិន្នន័យអំពីគំរបព្រៃឈើមិនបានធ្វើបច្ចុប្បន្នភាពទេចាប់តាំងពីឆ្នាំ១៩៩៧មក ដែលបង្កការលំបាកដល់ការវាយតំលៃពីការរីកចំរើនក្នុងកំណែទំរង់ការគ្រប់គ្រងព្រៃឈើ ។ តួលេខផលនេសាទសរុបមិនបានធ្វើបច្ចុប្បន្នភាពទេ ចាប់តាំងពីការកសាងតួលេខប៉ាន់ស្មានសំរាប់ឆ្នាំ១៩៩៤-៩៧ មក ។ ការប៉ាន់ស្មានផ្ទាល់លើផលនេសាទប្រចាំឆ្នាំ អាចធ្វើមិនកើតទេដោយសារបញ្ហា

ប្រឈមនៃការប្រមូលទិន្នន័យ ប៉ុន្តែ អង្កេតប្រចាំឆ្នាំស្តីពីការបរិភោគត្រីដោយគ្រួសារតំណាងមួយចំនួន គួបផ្សំនឹងការប៉ាន់ស្មានល្អជាងមុននូវបរិមាណត្រីនាំចេញ អាចក្លាយជាមូលដ្ឋាន សំរាប់ជួយដល់ការប៉ាន់ស្មានពីផលនេសាទប្រចាំឆ្នាំ ។ លើសពីនេះ អង្កេតលើប្រភេទត្រីចាប់បាន នឹងផ្តល់នូវពត៌មានសំខាន់ពីការប្រែប្រួលនៃប្រភេទពូជត្រី និងតំលៃនៃផលនេសាទ ។

- **បញ្ចូលប្រភេទការងារទី២ និងទី៣ ទៅក្នុងជំរឿនជាតិ និងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចៈ** ការអនុវត្តន៍ប្រមូលទិន្នន័យតែអំពីការងារទី១ ច្រើនតែធ្វើឱ្យគេផ្តោតការយកចិត្តទុកដាក់ទៅលើកសិកម្ម ដោយកាត់បន្ថយសារៈសំខាន់នៃការប្រមូលផលនេសាទ និងព្រៃឈើ នៅក្នុងជីវភាពជនបទ។ ដូច្នេះការបញ្ចូលការងារទី២ និងទី៣ នឹងបង្កើនភាពសុក្រឹតនៃលទ្ធផលនៅក្នុងអង្កេតជាតិ ហើយវាអាចឆ្លុះបញ្ចាំងបានកាន់តែប្រសើរនូវស្ថានភាពពិតនៃជីវភាពជនបទ ។
- **កែតំរូវប្រព័ន្ធគណនេយ្យជាតិ ដើម្បីឱ្យអាំងឌីការទ័រម៉ាក្រូសេដ្ឋកិច្ចផ្តល់នូវមូលដ្ឋានត្រឹមត្រូវជាងមុន សំរាប់ធ្វើការវាយតំលៃពីការរីកចំរើននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចមានចីរភាពៈ** តួលេខ ផសស និងចំណូលជាតិបច្ចុប្បន្ន មិនបានរាប់បញ្ចូលទេនូវ ការបាត់បង់ទ្រព្យជាធនធានធម្មជាតិ ដូចជាព្រៃឈើ និងស្តុកត្រី ជាដើម ។ ការធ្វើអាជីវកម្មដូចខាងលើ ជះឥទ្ធិពលល្អទៅលើអាំងឌីកាទ័រសេដ្ឋកិច្ច (ដូចជា ផសស) ទោះបីអត្រាធ្វើអាជីវកម្មវាគ្មានចីរភាពក៏ដោយ ។ ការកែតំរូវគណនេយ្យធនធានធម្មជាតិ អាចជួយឱ្យ ប្រព័ន្ធគណនេយ្យជាតិឆ្លុះបញ្ចាំងបានត្រឹមត្រូវជាងមុនពី ការធ្វើអាជីវកម្មធនធានធម្មជាតិ និងការបាត់បង់ធនធាននេះ ហើយតាមនេះវាជួយកែលំអដល់អាំងឌីការទ័រសេដ្ឋកិច្ច និងពង្រឹងមូលដ្ឋានសំរាប់ការធ្វើគោលនយោបាយអភិវឌ្ឍន៍មានចីរភាព ។

គេត្រូវការយល់ដឹងច្រើនថែមទៀត អំពីចំណងទាក់ទងរវាង ជីវភាពជនបទ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍មានចីរភាព ។ ក្នុងការធ្វើការវាយតំលៃជាមូលដ្ឋាននេះ ផ្នែកជាសក្តានុពលមួយចំនួនសំរាប់ ការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ចស្តីពីធនធានធម្មជាតិនិងជីវភាពជនបទ ត្រូវបានកំណត់ឡើងដែលជាប់ទាក់ទងនឹង ការគ្រប់គ្រងដោយសម្បទាន ការគ្រប់គ្រងដោយសហគមន៍ បញ្ហាផលិតកម្ម និងពាណិជ្ជកម្ម និងការដោះស្រាយទំនាស់ ។ ផ្នែកដែលគួរស្រាវជ្រាវទាំងនេះមានពិភាក្សាលំអិតនៅចុងជំពូកទី២ ទី៣ និងទី៤ ចំណែកឯសំនួរស្រាវជ្រាវចំបង១មានជាសង្ខេបដូចតទៅៈ

## ការស្រាវជ្រាវដែលអាចធ្វើនៅក្នុងបញ្ហាកសិកម្ម

១. តើអ្វីទៅជាមូលហេតុចំបងដែលធ្វើឱ្យបន្លែ និងដំណាំផ្សេងទៀតរបស់កម្ពុជា មិនអាចប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូលពីប្រទេសជិតខាង?

២. តើអ្វីទៅជាសក្តានុពលរយៈពេលខ្លី និងរយៈពេលវែង សំរាប់កែលំអ សមត្ថភាពកែច្នៃបង្កើតតំលៃបន្ថែម និងកែលំអម៉ាឃីទីង? តើការកែលំអទាំងនេះ នឹងមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះជីវភាពជនបទ?

៣. តើអ្វីខ្លះជាតួនាទីសមស្របសំរាប់សម្បទាននៅក្នុងការអភិវឌ្ឍន៍កសិកម្មជារួមនៅកម្ពុជា? តើសម្បទានដីកសិកម្មមានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការលើកកំពស់ជីវភាពជនបទ?

៤. តើទំនាស់លើដីសម្បទានកសិកម្ម ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន? តើគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់? តើគេអាចចាត់វិធានការណ៍អ្វីខ្លះដើម្បីកាត់បន្ថយលទ្ធភាពមានទំនាស់?

## ការស្រាវជ្រាវគួរធ្វើឡើងនៅក្នុងបញ្ហាជលផល

១. តើប្រព័ន្ធគ្រប់គ្រងឡូត៍នេសាទ មានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

២. តើមានបន្ទុកចំណាយ និងអត្ថប្រយោជន៍អ្វីខ្លះ ក្នុងការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ?

៣. តើមានបំរែបំរួលអ្វីខ្លះនៅក្នុងតំបន់ជាអតីតឡូត៍នេសាទ និងតើវាមានផលប៉ះពាល់អ្វីខ្លះទៅលើជីវភាពជនបទ? តើសហគមន៍ឡូត៍នេសាទមានប្រសិទ្ធិភាពប៉ុណ្ណានៅក្នុងការគ្រប់គ្រងតំបន់ជាអតីតឡូត៍នេសាទ?

៤. តើការនេសាទតាមវាលស្រែមានសារៈសំខាន់ប៉ុណ្ណាចំពោះជីវភាពជនបទ ហើយតើវាមានផលប៉ះពាល់អ្វីខ្លះចំពោះការអភិវឌ្ឍន៍នូវកសិកម្ម និងនេសាទ?

៥. តើទំនាស់អំពីតំបន់នេសាទ ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន ហើយតើគេអាចធ្វើអ្វីខ្លះ ដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

៦. តើការកែច្នៃត្រី សកម្មភាពពាណិជ្ជកម្ម និងការនាំចេញត្រី មានស្ថានភាពយ៉ាងណានាបច្ចុប្បន្ន? តើគេអាចលើកកំពស់ជីវភាពជនបទយ៉ាងណាបានតាមរយៈការកែប្រែវិធីសាស្រ្តបច្ចុប្បន្នក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ?

## ការស្រាវជ្រាវគួរធ្វើឡើងនៅក្នុងបញ្ហាព្រៃឈើ

១. តើប្រព័ន្ធសម្បទានព្រៃឈើមានប្រសិទ្ធិភាពប៉ុណ្ណាក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ?

២. តើមានបន្ទុកចំណាយ និងអត្ថប្រយោជន៍អ្វីខ្លះ ក្នុងការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍?

៣. តើទំនាស់អំពីធនធានព្រៃឈើ ត្រូវបានដោះស្រាយយ៉ាងណាក្នុងពេលបច្ចុប្បន្ន ហើយតើគេអាចធ្វើអ្វីខ្លះដើម្បីកែលំអយន្តការដោះស្រាយទំនាស់?

៤. តើការកែច្នៃ ពាណិជ្ជកម្ម និងការនាំចេញផលិតផលព្រៃក្រៅពីឈើ (NTFP) មានស្ថានភាពយ៉ាងណានាបច្ចុប្បន្ន? តើគេអាចលើកកំពស់ជីវភាពជនបទយ៉ាងណាបានតាមរយៈការកែប្រែវិធីសាស្រ្តបច្ចុប្បន្នក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ?

# តារាងឧបសម្ព័ន្ធ ~ ក

តារាងលំអិតពីសកម្មភាពការងាររបស់ក្រុមហ៊ុនវិនិយោគដីសម្បទានៈ បកប្រែចេញមកពីឯកសារដែលរៀបចំឡើងដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| ល.រ | ឈ្មោះក្រុមហ៊ុន | ទីតាំង | ផ្ទៃដី Ha | ប្រភេទដំណាំ | ១. គាលការណ៍<br>២. ចុះកិច្ចសន្យា<br>៣. ប្រាក់កក់ | សកម្មភាពអនុវត្តរបស់ក្រុមហ៊ុន |
|---|---|---|---|---|---|---|
| ១ | Agrostar | កំពង់ចាម | 2.400 | ស្វាយចន្ទី | ១. ៥៦៥/៩៤គវិជចុះ ២០/១២/៩៤<br>២. ០៩-០១-៩៥<br>៣. ពុំទាន់បង់ | – កំពុងដំណើរការដាំដុះ ។<br>– បញ្ហា និងការលំបាកមានការតវ៉ាពីប្រជាជនចំពោះដីសម្បទាន |
| ២ | សូគីម៉ិចវិនិយោគដំណាំ កៅស៊ូ | កំពង់ចាម | 9.900 | កៅស៊ូ | ១. ២៦សជណចុះ ០៩ -០៥-៩៨<br>២. ២៧-០៥-៩៨<br>៣. ពុំទាន់បង់ | – បញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន ។<br>– ក្រុមហ៊ុនកំពុងពិចារណាលើគំរោងវិនិយោគថាតើត្រូវបន្ត រឺបោះបង់ ។<br>– បញ្ហា និងការលំបាកៈ ប្រជាជនទន្ទ្រានកាប់ដី និងដាំដុះដំណាំលើទីតាំងសម្បទានម្យ៉ាងទៀត តំបន់សម្បទានមានដីក្រហមប្រមាណ ៣០-៣៥% តែប៉ុណ្ណោះ (តាមការសិក្សារបស់ក្រុមហ៊ុន) ។ |
| ៣ | ក្រុមហ៊ុន ធី ធី វ៉ាយ (TTY) | កំពង់ចាម | 1.070 | កៅស៊ូ | ១. ២៨២១/៩៦ គវិកចុះ ៣១-១២-៩៦<br>២. ០២-០៥-០០<br>៣. ពុំទាន់បង់ | – ពុំទាន់ចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– ក្រុមហ៊ុនកំពុងពិចារណាលើគំរោងវិនិយោគថាតើត្រូវបន្ត រឺបោះបង់មូលហេតុប្រជាជនទន្ទ្រានកាន់កាប់ដី និងដាំដំណាំលើទីតាំងដីសម្បទានស្មើ ១០០% នៃផ្ទៃដីសម្បទានសរុប (តាមការសិក្សារបស់ក្រុមហ៊ុន) ។ |
| ៤ | CAMBODA EVERSKY | កំពង់ធំ | 10.000 | ដំណាំកសិកម្ម (កប្បាស់ ) | ១. ៥៤៥សជណ. កសចុះ១៦/៦/៩៧ | – បញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពង់ដាំសាកល្បងនូវប្រភេទដំណាំមួយចំនួនដូចជា ពោត ស្រូវ កប្បាសលើទីតាំងដី |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ២. ០៣-១១-៩៨<br>៣. បានបង់រួច | សម្បទាន ។<br>– បញ្ហា និងការលំបាកៈ តំបន់ដីសម្បទានមានប្រភេទដីជាដីខ្សាច់និងលិចទឹក ។ |
| ៥ | CamChi International Agriculture Development | កំពង់ធំ | 26.500 | ដំឡូងមី | ១. ២២សជណចុះ៦-១-២០០០<br>២. ០៣-០៣-០០<br>៣. ត្រៀមបង់ | – បញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពង់បំពេញបែបបទនៅក្រសួងដើម្បីចុះអនុវត្ត ។<br>– ប្រាក់កក់ធានាកិច្ចសន្យាៈ ក្រុមហ៊ុនសុំឱ្យក្រសួងចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មទើបបង់តាមក្រោយ ។ |
| ៦ | លាង ហួ ហុង អាហ័រណេ នីហ័រណេ និង អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ | បាត់ដំបង | 8.000 | អំពៅ ដំឡូង | ១. ១០៥៤សជណចុះ ៤-៨-៩៩<br>២. ០៧-០៦-០០<br>៣. បានបង់ | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងកំពង់ធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– បញ្ហា និងការលំបាកៈ តំបន់ដីសម្បទានមានប្រជាជនទន្ទ្រានកាន់កាប់ដី និងអាជ្ញាធរឃុំលក់បង្កាន់ដៃកាន់កាប់ដីធ្លីឱ្យប្រជាជន ។ |
| ៧ | RATANA VISAL DEVELOPMENT Co. Ltd | ពោធិសាត់ | 3.000 | ស្វាយចន្ទី-ល្ហុងប្រេង | ១. ២២៤៥/៩៧ក.អ.កចុះ៤-៨-៩៧<br>២. ១៥-១០-៩៩<br>៣. បានបង់ | – ពុំទាន់បានចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិដីពាក់ព័ន្ធ ។<br>– ដាំស្វាយចន្ទីបាន៣០០ហិកតា និងល្ហុងប្រេង៧០០ហិកតា ។<br>– បញ្ហានិងការលំបាកៈ ល្ហុងប្រេងពុំផ្តល់ផលនិងមានប្រជាជនទន្ទ្រាន ។<br>– កាន់កាប់ដីមានការលួចដុតដំណាំ និងប្រព័ន្ធគមនាគមន៍ខូចខាតខ្លាំង ។ |
| ៨ | PHEAPIMEX Co.LTD | ពោធិសាត់-កំពង់ឆ្នាំង | 315.028 | ដាំឈើរោងចក្រក្រដាស | ១. ៨៥២សជណចុះ២៣/៩/៩៧<br>២. ០៨-០១-០០<br>៣. ពុំទាន់បង់ | – បានចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធសំរាប់ឆ្នាំទី១លើផ្ទៃដី៦<br>– ៦.៨០០ហិកតានៅស្រុកក្រគរ ខេត្តពោធិសាត់ ។<br>– ចុះអនុវត្តមិនបានមូលហេតុមានប្រជាជនតវ៉ា ។<br>– ក្រសួងបានជួយអន្តរាគមន៍ដោះស្រាយបញ្ហានេះ ។<br>– បញ្ហា និងការលំបាកៈ មានការតវ៉ាខ្លាំងពីប្រជាជនចំពោះទីតាំងដីសម្បទាននេះ ។<br>– ពេលនេះក្រុមហ៊ុនកំពុងសិក្សាដីនៅខេត្តកំពង់ឆ្នាំង ព្រោះក្រុមហុនមានទិសដៅមកដំណើរការនៅខេត្តកំពង់ឆ្នាំងវិញ ។ |
| ៩ | CAMBO VICTOR & INVESTING DEVELOPING | កំពង់ស្ពឺ | 26.550 | ដំណាំកសិកម្ម | ១. ១៣៦១សជណចុះ៩-៨-២០០០<br>២. ១៣-០៨-២០០១<br>៣. ពុំទាន់បង់ | – ត្រៀមចុះកំណត់ចំនុចគោល និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធលើដីសម្បទាន |
| ១០ | MONG RETHTHY INVESTMENT CAMBODIA OIL PALM Co.LTD | ក្រុងព្រះសីហនុ | 11.000 | ដូងប្រេង | ១. ៥៧៦សជណចុះ១៥/៥/៩៥<br>២. ០៩-០១-៩៥<br>៣. ពុំទាន់បង់ | – ពុំទាន់បានចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំឡរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– ផ្ទៃដីអាចដាំបានតែ២/៣នៃផ្ទៃដីសរុប ( តាមការសិក្សារបស់ក្រុមហុន) កំពុងដាំដូងប្រេងបានចំនួន ៣១០០ហិកតា ។<br>– ទិសដៅក្រុមហ៊ុននឹងសាងសង់រោងចក្រកែច្នៃនាពេលឆាប់ៗខាងមុខនេះ ។<br>– បញ្ហា និងការលំបាកៈ មានជនល្មើសលួចកាប់ឈើពីឧទ្យានជាតិបូកគោ រួចដឹកឆ្លងកាត់ចំការធ្វើឱ្យខូចផ្លូវ ក្នុងករណីបង្រាបការកាប់ឈើ ជនល្មើសលួចដុតដូងប្រេង និងមានប្រជាជន |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ទន្ទ្រានកាន់កាប់ដី តែបញ្ហានេះក្រុមហ៊ុនបានដោះស្រាយផ្ទាល់ជាមួយប្រជាជន។ |
| ១១ | ម៉ុង រិទ្ធី វិនិយោគទុនដំណាំដំឡូងមីកម្ពុជា | ក្រុងព្រះសីហនុ | 1.800 | ដំឡូងមី | ១. ៤០៦សជណ ចុះ២២-៤-៩៨<br>២. ១៨-០៣-០០<br>៣. ពុំទាន់បង់ | – ពុំទាន់បានចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– ផ្ទៃដីអាចដាំបានតែ៧០០-៨០០ហិកតា នៃផ្ទៃដីសរុប( តាមការសិក្សារបស់ក្រុមហ៊ុន) កំពុងដាំដុះ និងចិញ្ចឹមគោបាន ១០០០ក្បាល ។<br>– ទិសដៅក្រុមហ៊ុននឹងសាងសង់រោងចក្រកែច្នៃនាពេលឆាប់ៗខាងមុខនេះ ។<br>– បញ្ហា និងការលំបាកៈ មានជនល្មើសលួចកាប់ឈើពីឧទ្យានជាតិបូកគោរួចដឹកឆ្លងកាត់ចំការធ្វើឱ្យខូចផ្លូវ ក្នុងករណីបង្ក្រាបការកាប់ឈើជនល្មើសលួចដុតដូងប្រេង និងប្រជាជនទន្ទ្រានកាន់កាប់ដី តែបញ្ហានេះ ក្រុមហ៊ុនបានដោះស្រាយផ្ទាល់ជាមួយប្រជាជន។ ផ្ទៃដីមិនគ្រប់គ្រាន់តាមគំរោងវិនិយោគរបស់ក្រុមហ៊ុន។ |
| ១២ | CHINA CAMBODLA STATE FARM INTERNATIONAL | កោះកុង | 7.500 | ដំណាំកសិកម្មចិញ្ចឹមសត្វ | ១. ១១៣៨សជណចុះ១៩-១២-៩៧<br>២. ០៦-១០-៩៨<br>៣. ត្រៀមបង់ | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ<br>– ត្រៀមដំនើរការលើគំរោងចិញ្ចឹមសត្វ តែត្រូវអាក់ខានវិញមូលហេតុប្រជាជនចាប់យកដីក្នុងតំបន់សម្បទាន ។<br>– បញ្ហា និងការលំបាកៈ តំបន់ដីសម្បទានមានប្រជាជនទន្ទ្រានកាន់កាប់ដី និងអាជ្ញាធរឃុំ-ស្រុក បង្កការលំបាកលើបញ្ហាដីធ្លី ។ |
| ១៣ | TALAM PLANTATION HOLDINGSDN.BHD | កោះកុង | 36.700 | កៅស៊ូ-ដូងប្រេង | ១. ៥៦៧សជណចុះ០៦-០៦-៩៨<br>២. ០៥-១០-៩៨<br>៣. បានបង់រួច | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពុងសុំការសំរេចពីថ្នាក់ដឹកនាំក្រសួងលើបញ្ហាផ្ទៃដីពាក់ព័ន្ធ ។<br>– បញ្ហា និងការលំបាកៈ ប្រជាជនទន្ទ្រានកាន់កាប់ដី<br>– ក្នុងតំបន់ដីសម្បទានមានចំនួនច្រើន និងទំហំធំៗជាហេតុធ្វើឱ្យក្រុមហ៊ុនមានផ្ទៃដីមិនគ្រប់តាមគំរោង វិនិយោគរបស់ខ្លួន ។ |
| ១៤ | The Green Rich Co.LTD | កោះកុង | 60.200 | ដូងប្រេង-អាកាស្យា | ១. ៩៨៤សជណចុះ០៨-០៩-៩៨<br>២. ២៥-១១-៩៨<br>៣. បានបង់រួច | – ពុំទាន់បានចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– សុំពន្យាពេលកិច្ចសន្យា ត្រឹមខែមករា ឆ្នាំ២០០១ ។<br>– បន្ទាប់ពីហួសសុពលភាពសុំពន្យាកិច្ចសន្យា ក្រុមហុនពុំបានជូនដំណឹងដល់ក្រសួងព្រមទាំងបានធ្វើសកម្មភាពដូចជាឈូសផ្លូវធ្វើស្រែបង្គារ ក្នុងតំបន់សម្បទានទៀតផង ។<br>– ក្រុមហ៊ុនធ្លាប់បាននាយកដ្ឋានរុក្ខាប្រមាញ់ និងមន្ទីរកសិកម្មខេត្តកោះកុងបញ្ចប់សកម្មភាព។ |
| ១៥ | HENAN (CAMBODIA) ECONOMIC&TRADE DEVERLOPMENT ZONE | កំពង់ស្ពឺ | 4.100 | ដំណាំកសិកម្ម-ចិញ្ចឹមសត្វ | ១. ១២៤៦សជណចុះ៣០-១២-៩៩<br>២. ២៩-០៧-៩៩<br>៣. ពុំទាន់បង់ | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– រងចាំសុំការឯកភាពពីអាជ្ញាធរដែនដីលើរបាយការណ៍ក្រុមការងារ ។<br>– បញ្ហានិងការលំបាកៈតំបន់ដីសម្បទានមានប្រជាជនទន្ទ្រានកាន់កាប់ដីច្រើន និងមានទំហំធំៗភូមិបាល ស្រុកបង្កការលំបាកក្នុងការធ្វើសំរង់ស្ថិតិ ។ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | Cambodia Haining Group Co.Ltd | កំពង់ស្ពឺ | 23.000 | ដំឡូងមី-ដូងប្រេង | ១. ៣៣២សជណកសចុះ៣០-៣-៩៨<br>២. ២៣-០៧-៩៩<br>៣. ពុំទាន់បង់ | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។ ប៉ុន្តែស្ថិតិនៅក្នុងស្រុក ភ្នំស្រួចមានបញ្ហា ។<br>– ក្រសួងបានអន្តរាគមន៍ទៅគណៈកម្មាការដោះស្រាយបាតុភាពដីធ្លីខេត្ត-ក្រុង បានដំណើរការដាំសាកល្បងនៅស្រុកឱរ៉ាល់ ។<br>– បញ្ហា និងការលំបាកៈ តំបន់ដីសម្បទានមានប្រជាជនទន្ទ្រានកាន់កាប់ដីបែបអនាធិប្បតេយ្យពិសេស ត្រង់ក្បាលដី ផ្លូវឡើងទៅឧទ្យានជាតិគីរីរម្យ ។<br>– ក្រសួងកំពុងជួយអន្តរាគមន៍ទៅគណៈកម្មការដោះស្រាយបាតុកភាពដីធ្លីខេត្ត-ក្រុងជាលើកទី២ ។ |
| ១៧ | សាជីវកម្ម ស៊ី.ជេ ខាំបូឌា ចំកាត់ | កំពង់ស្ពឺ | 3.000 | ដំឡូងមី | ១. ១៣៣៧សជណចុះ១០-៩-៩៩<br>២. ១៥-១១-៩៩<br>៣. ពុំទាន់បង់ | – ចំពោះផ្ទៃដីសម្បទាន៣០០០ហិកតា ស.ជ.ណ បានណែនាំឱ្យក្រសួងកសិកម្មជាអ្នកចុះហត្ថលេខាលើកិច្ចសន្យា តែទ័ពជាអ្នកអនុវត្ត ។<br>– បានបញ្ចប់ការដាំដុះដំឡូងមីលើផ្ទៃដីសម្បទាន ចំនួន ៣០០០ហិកតា ។ |
| | | កំពង់ស្ពឺ | 5.000 | ដំឡូងមី | ១. ៣២៣សជណចុះ១០-៩-៩៩<br>២. ២០-០៤-២០០១<br>៣. បានបង់រួច | – ចំពោះផ្ទៃដីសម្បទានចំនួន ៥ ០០០ហិកតា បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពុងសុំការសំរេចពីថ្នាក់ដឹកនាំក្រសួងដើម្បីឱ្យក្រុមហ៊ុនបានដំណើរការអាជីវកម្មផលិតកម្មលើផ្ទៃដីសម្បទានចំនួន ៥០០០ហិកតា ។ |
| ១៨ | ផលិតម្សៅដំឡូងមីចំកាត់ | ស្ទឹងត្រែង | 7.400 | ម៉ៃសាក់ ចន្ទី | ១. ១៣២៣សជណចុះ២៤-១២-៩៨<br>២. ១៣-១១-៩៩<br>៣. បានបង់រួច | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពុងដំណើរការតាមសេចក្តីជូនដំណឹង លេខ ១៦៣៣សជណចុះថ្ងៃទី០៦ ខែតុលាឆ្នាំ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។<br>– បញ្ហា និងការលំបាកៈ មានការប្តឹងតវ៉ាពីសំណាក់ប្រជាជន ។ |
| ១៩ | មិត្តភាពម៉ែនសារុន និងរាម៉ាខ្មែរ | រតនគិរី | 20.000 | ដូងប្រេង | ១. ១៤៥៣សជណចុះ២១-៩-៩៥<br>២. ២១-១២-៩៩<br>៣. ពុំទាន់បង់ | – ពុំទាន់បានចុះចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– កំពុងសិក្សា (FeasibilityStudy) លើដំណាំ ដូងប្រេង និងការហ្វេ ។ |
| ២០ | China National Corporation for Oversea Economic Cooperation Laod Star Development Co. Ltd. | កំពង់ស្ពឺ | 8.000 | ដំណាំកសិ-ឧស្សាហកម្ម | ១. ៤១៦សជណចុះ២៣-៤-៩៨<br>២. ២៦-០៩-០០<br>៣. ពុំទាន់បង់ | – ត្រៀមចុះកំណត់ចំនុចគោល និងធ្វើសំរង់ស្ថិតិលើផ្ទៃដីសម្បទាន |
| ២១ | KIMSVILLE CORP | កំពង់ស្ពឺ | 3.200 | ដំឡូងមី | ១. ៥៨២/០០គ.វិ.កចុះ២៥-២-០០<br>២. ២៤-១០-០០<br>៣. បានបង់រួច | – បានបញ្ចប់ការចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធក្នុងតំបន់ A ។<br>– បានចុះដំណើរការតែបរាជ័យមូលហេតិមកពីសមាជិកគណបក្សប្រឆាំងបំផុសឱ្យប្រជាជនធ្វើការតវ៉ា និងបំផ្លាញសំភារៈរបស់ក្រុមហ៊ុនទៀតផង ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | – ក្រសួងបានអន្តរាគមន៍ជួយដោះស្រាយ ។<br>– បញ្ហា និងការលំបាក: តំបន់ដីសម្បទានមានពាក់ព័ន្ធដីរបស់ប្រជាជនភាគច្រើន ។ |
| ២២ | ខេមលេន<br>អាហ័រណ នីហ័រណ | កំពត | 16.400 | ដូងប្រេង | ១. ១៣៣៥សជណចុះ ១៣-១១-៩៦<br>២. ២៦-១០-00<br>៣. ពន្យាពេលបង់ | – ពុំទាន់បានចុះកំណត់ចំនុចគោលដីសម្បទាននិងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធជាមួយក្រសួងកសិកម្ម ។<br>– ប៉ុន្តែក្រុមហុនបានសហការជាមួយអាជ្ញាធរដែនដី និងជំនាញមូលដ្ឋាន ចុះធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធជាមុនសិន ។<br>– បញ្ហា និងការលំបាក: តំបន់ដីសម្បទានមានប្រជាជនទន្ទ្រានកាន់កាប់ដី និងដាំដំណាំ និងផ្ទៃដីសម្បទាន មួយចំនួនទៀតជាន់លើឧទ្យានជាតិបូកគោ ដូច្នេះនាំឱ្យផ្ទៃដីសម្បទានមិនគ្រប់តាមចំនួនផ្ទៃដីនៃគំរោង វិនិយោគរបស់ក្រុមហ៊ុន ។ |
| ២៣ | អភិវឌ្ឍន៍ដំណាំ<br>ឧស្សាហកម្មអ៊ុកឃុន | កំពង់ស្ពឺ | 12.506 | ស្វាយចន្ទី | ១. ១៤៦៩សជណចុះ១-៩-២000<br>២. ២៥-0៥-២00១<br>៣. ពន្យាពេលបង់ | – ចុះកំណត់ចំនុចគោលដីសម្បទាន និងធ្វើសំរង់ស្ថិតិផ្ទៃដីពាក់ព័ន្ធ ។<br>– ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកសញ្ញាសំគាល់ក្រុមហ៊ុនតែមានជនខិលខូច មកបំផ្លាញផ្លាកសញ្ញានេះចោលវិញ។<br>– ក្រុមហ៊ុនបានស្នើសុំឱ្យក្រសួងជួយដោះស្រាយបញ្ហាលើកផ្លាកសញ្ញានេះ ។<br>– ក្រសួងបានជួយអន្តរាគមន៍ដោយបានធ្វើការប្រជុំពិភាក្សាជាមួយអាជ្ញាធរខេត្ត លទ្ធផលទទួលបាន គឺរង់ចាំអាជ្ញាធរខេត្តធ្វើការត្រួតពិនិត្យផ្នែករដ្ឋបាល និងអាវុធជាតិផ្ទុះតំបន់នេះសិនទើបដំណើរការ ដាក់ផ្លាកសញ្ញាតាមក្រោយ ។<br>– បង់ប្រាក់កក់ធានាកិច្ចសន្យា: មិនទាន់ហួសការកំណត់តាមកិច្ចសន្យា |
| ២៤ | GREENSEA INDUSTRY Co;Ltd | ស្ទឹងត្រែង | 100.852 | ដាំឈើម៉ៃសាក់ | ១. ១៧៦៧សជណចុះ២៦-១០-២00១<br>២. ២៣-១០-២00១<br>៣. មិនទាន់បង់ | – គ្មាន |
| ២៥ | សហគមន៍គ្រួសារ<br>ហេង សារ៉ាត់ | កំពង់ចាម | 500 | ស្វាយចន្ទី | ១. ១៩៦១សជណចុះ១៧/១១/៩២<br>២. ២៣-0១-៩២<br>៣. ពុំទាន់បង់ | – បាត់ទំនាក់ទំនង |
| ២៦ | SHING YUI COMMERCIAL | កំពត | 10.000 | កៅស៊ូ ដូងប្រេង | ១. ១៥-0៥-៩៦ ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ២៧ | CHINAEVERGRET CAMBODIA AGRICULTURE DEVERLOPMENT | កំពត | 4.000 | កៅស៊ូដូងប្រេង | ១. ១. ៤១៦សជណចុះ២៣-៥-៩៨<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ២៨ | បុប្ផាអង្គរីម៉ិច<br>ត្រង់កុង | កំពង់ចាម | 5.000 | កៅស៊ូ | ១. ១៨៥សជណចុះ១៧-២-៩៩<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ២៩ | FORDTHAI | មណ្ឌលគិរី | 200 | កសិកម្ម | ១. កសក | – បាត់ទំនាក់ទំនង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ២. ពុំទាន់ចុះកិច្ចសន្យា | |
| ៣០ | ហួរ ហុង វិនិយោគ | កំពង់ស្ពឺ | 2.040 | ដំណាំកសិកម្ម | ១. ១២៥៥សជណចុះ៨-១២-៩៨<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៣១ | UNBORINTRADE AGRICULTURE DEVELOPMENT | កំពង់ស្ពឺ | 16.600 | ដំឡូង | ១. ៧៤០សជណចុះ១១-៦-៩៨<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៣២ | តាយ សេង នីហរ័ណ អាហរ័ណ | រតនះគីរី | 2.000 | កៅស៊ូ | ១. ១៨៣៩សជណចុះ២៥-១២-៩៨<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៣៣ | មៀង លីហេង វិនិយោគ | កំពង់ចាម | 3.000 | កៅស៊ូ | ១. ១៧៧៣សជណចុះ៩-១២-៩៥<br>២. ពុំទាន់ចុះកិច្ចសន្យា | – បានប្រជុំត្រៀមចុះពិនិត្យទីតាំងសាជាថ្មី |
| ៣៤ | លឹម គ្រី អភិវឌ្ឍន៍កសិកម្ម | តាកែវ | 1.050 | ដាំស្រូវ | ១. ៦៨៦គ.វិ.កចុះ ៣-០៨-៩៥<br>២. ពុំទាន់ចុះកិច្ចសន្យា | – បានប្រជុំត្រៀមចុះពិនិត្យទីតាំងសាជាថ្មី |
| ៣៥ | SOURKEAR Co.; LTD | ពោធិសាត់ | 300 | ស្វាយចន្ទី | ១. ០០១/៩៥គ.វិ.កចុះ០៧-១-៩៨<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៣៦ | CAMBODIA TAPIOCA ENTEPRICE | កំពត | 5.100 | ដំឡូងមី | ១. ២៥០៤/៩៦គ.វិ .កចុះ ៦-១១-៩៦<br>២. ពុំទាន់ចុះកិច្ចសន្យា | – អន្តរាគមន៍ទៅគណៈកម្មការដោះស្រាយបាតុភាពដីធ្លីទូទាំងខេត្ត-ក្រុង ដើម្បីជួយដោះស្រាយបញ្ហា ទន្ទ្រានកាន់កាប់ដីធ្លីពីសំណាក់ប្រជាជន |
| ៣៧ | SINTHAIKAMPOT Co;LTD | កំពត | 5.700 | ចន្ទី-ធូរ៉េន | ១. ៨៦៤/៩៦ក.វិ.កចុះ ២៦-៦-៩៦<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៣៨ | CHUNG SHING CAMBODIA | កោះកុង | 16.000 | ដាំដូងប្រេង | ១. ០៤០/៩៦ គ.វិ.កចុះ ១១- ១-៩៦<br>២. ពុំទាន់ចុះកិច្ចសន្យា | – សុំរក្សាទុកផ្ទៃដីសម្បទាន |
| ៣៩ | CONSOLIDATED PLANTATION | កំពង់ស្ពឺ | 12.700 | សាន់តាន់ ដំឡូង ស្រូវ | ១. ២៦៣៨/៩៧ ក.អ.កចុះ០៤-៨ ៩៧<br>២. ពុំទាន់ចុះកិច្ចសន្យា | – សុំសិទ្ធប្រទានទៅទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤០ | NACORICE | បាត់ដំបង | 2.000 | ដាំស្រូវ | ១. ៦៨៥៧ក.ស.កផ.ផកចុះ ១១-១១-៩៦<br>២. ពុំទាន់ចុះកិច្ចសន្យា | – បាត់ទំនាក់ទំនង |
| ៤១ | អង្គរអភិវឌ្ឍន៍ដំណាំ ឧស្សាហកម្ម | កំពង់ស្ពឺ | 20.000 | អំពៅ សត្វ | ១. កសក<br>២. លុបកិច្ចសន្យា | – តាមប្រកាសលេខ ៤០៦ ប្រក.កសក.ផ.ផកចុះ១៥-៩-៩៨ |
| ៤២ | សរ អ៊ុត | កំពង់ស្ពឺ | 1.550 | កាហ្វេ តែ | ១. កសក<br>២. លុបកិច្ចសន្យា | |
| ៤៣ | លី សេង អាហរ័ណ នីហរ័ណ | តាកែវ | 500 | ស្វាយចន្ទី | ១. ២៨០៦/៩៦គ.វិ.កចុះ៣១-១២-៩៦<br>២. លុបគោលការណ៍ | – តាមលិខិតលេខ៨៤២ សជណ.កសចុះ ២០-៣-០០ |
| ៤៤ | Yean Jan Trading Co; Ltd Cambodia Tapioca Corporation | កំពត | 3.800 | ដំឡូងមី | ១. ២៥០៧/៩៦គ.វិ.កចុះ ៦-១១-៩៦<br>២. លុបគោលការណ៍ | – តាមលិខិតលេខ៨៤២សជណ .កសចុះ ២០-៣-០០ |

| | | | | | | |
|---|---|---|---|---|---|---|
| | Limited | | | | | |
| ៤៥ | CHEL JADANG<br>(C&J Cambodia) | កំពង់ស្ពឺ | 18.300 | ដំឡូងមី | ១. ២២៥៨/៩៧គ.វិ.កចុះ៤-៨-៩៧<br>២. លុបគោលការណ៍ | – តាមលិខិតលេខ៨៤២សជណ.កសចុះ២០-៣-០០ |
| ៤៦ | អេស ខេ<br>ចំរើនអភិវឌ្ឍន៍ | រតនគីរី | 4.000 | កៅស៊ូ | ១. ២៤៣សជណ ចុះ១១-០៣-៩៧<br>២. លុបគោលការណ៍ | – តាមលិខិតលេខ៨៤២សជណ.កសចុះ២០-៣-០០ |
| ៤៧ | យូនីកឯកភាពពាណិជ្ជ អន្តរជាតិ | មណ្ឌលគីរី | 20.000 | កៅស៊ូ-កាហ្វេ | ១. ១៦០៩សជណ.ជសចុះ២-១១-៩៥<br>២. លុបគោលការណ៍ | – តាមលិខិតលេខ៨៤២សជណ.កសចុះ២០-៣-០០ |
| ៤៨ | ASIAGOLDENDRAGON | កំពង់ចាម | 4.000 | កៅស៊ូ | ១. ៦២០៤កសកផ.ផកចុះ១១-១០-៩៥<br>២. លុបគោលការណ៍ | – ប្រកាសលេខ៣៣៣ ប្រក.កសក.ផ.ផកចុះ៣១-៥-០០ |
| ៤៩ | គ.ឈ ហេ្សស៊ិនសហគ្រាស | កំពង់ចាម | 6.250 | ដំឡូងមី | ១. ០២៩៩/៦៣៦កសក.ផ.ផកចុះ១១ -១០-៩៥<br>២. លុបគោលការណ៍ | – ប្រកាសលេខ៣៣៣ប្រក.កសក.ផ.ផកចុះ៣១-៥-០០ |
| ៥០ | CAMBODIAPALMOIL | កោះកុង | 15.200 | ដូងប្រេង | ១. ៧០៣៦/៦៧០កសក.ផ.ផកចុះ១៩ -១២-៩៦<br>២. លុបគោលការណ៍ | – ប្រកាសលេខ៣៣៣ប្រក.កសក.ផ.ផកចុះ៣១-៥-០០ |
| ៥១ | សហគមន៍អភិវឌ្ឍន៍កសិកម្ម | កំពង់ចាម | 500 | កៅស៊ូ | ១. កសក<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ .សរចុះថ្ងៃទី១៤-៨-០០ |
| ៥២ | វ៉ាត វ៉ាន់នី | កំពង់ធំ | 3.000 | ដាំស្រូវ | ១. ៥៤-០០កសកផ.ផកចុះថ្ងៃទី៥-៩-៩៥<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ.សរចុះថ្ងៃទី១៤-៨-០០ |
| ៥៣ | CAMBOCAN<br>co;LTD | កំពង់ធំ | 11.400 | ស្រូវឡើងទឹក | ១. ៩១៨សជណចុះ១៨-៨-៩៨<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ.សរចុះថ្ងៃទី១៤-៨-០០ |
| ៥៤ | MACA<br>PLANTATION | កំពង់ស្ពឺ | 10.800 | កៅស៊ូ | ១. ៦៤៤៣កសកផផកចុះ១៥-១១-៩៦<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ.សរចុះថ្ងៃទី១៤-៨-០០ |
| ៥៥ | CHUNGTHAI<br>INVESTMENT | កោះកុង | 550 | ដំឡូងមី<br>ឈើហូបផ្លែ | ១. ៧២៣៥កសក.ផ.ផកចុះ៣១-១២-៩៦<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ.សរចុះថ្ងៃទី១៤-៨-០០ |
| ៥៦ | CAMBODIA SHAN SHOEI | កោះកុង | 3.830 | ឈើហូបផ្លែ-ចិញ្ចឹមសត្វ | ១. កសក<br>២. លុបគោលការណ៍ | – តាមលិខិតលេខ១៣៨១សជណ.សរចុះថ្ងៃទី១៤-៨-០០ |

*បញ្ជាក់:*

- *ក្រុមហ៊ុនសរុប ៥៦ក្រុមហ៊ុនលើផ្ទៃដីសម្បទានសរុបទូទាំងប្រទេស មានចំនួន ៩៣៤.៩២៦ហិកតាស្ថិតនៅតាមបណ្តារខេត្តចំនួន ១៣ ។*
- *ចុះកិច្ចសន្យារួចជាមួយក្រសួងកសិកម្មមានចំនួន ២៥ក្រុមហ៊ុន លើផ្ទៃដីសម្បទានចំនួន៧២៣.៦០៦ហិកតា ។*
- *បានលុបគោលការណ៍ និងកិច្ចសន្យា មានចំនួន ១៦ក្រុមហ៊ុន លើផ្ទៃដីសម្បទានចំនួន ១២៣.៦៨០ហិកតា ។*

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និង ពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឺលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូឌី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាព ក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី រត្ន័មុនី Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) *ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារ ពិភាក្សាលេខ ២១) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

# ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតំលៃជាមូលដ្ឋាន

បច្ចុប្បន្ននេះប្រជាជនកម្ពុជាជាង ១០លាននាក់រស់នៅតាមតំបន់ជនបទ ហើយក្នុងចំណោមនោះជាង ៨,៥លាននាក់រស់នៅដោយពឹងផ្អែកទៅលើធនធានធម្មជាតិ ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន ។ ពួកគេភាគច្រើន គឺជាអ្នកមានជីវភាពខ្សត់ខ្សោយដោយពឹងផ្អែកទៅលើឯកវប្បកម្មដំណាំស្រូវក្នុងមួយឆ្នាំ ត្រី និងធនធានក្នុងទឹកព្រមទាំងផលិតផលបានមកពីព្រៃឈើ ។ នៅក្នុងបែបផែននេះ ធនធានធម្មជាតិ កម្ពុជាមិនត្រឹមតែបានផ្តល់សន្តិសុខស្បៀង ប្រាក់ចំណូល និងឱកាសការងារសំរាប់ប្រជាជនភាគច្រើននោះទេ ក៏ប៉ុន្តែវាបានរួមចំណែកយ៉ាងសំខាន់នៅក្នុង "*ប្រព័ន្ធសុវត្ថិភាព*" សំរាប់ប្រជាជនក្រីក្រនៅតាមជនបទ ។ ក៏ប៉ុន្តែកំណើនសំពាធកាន់តែខ្លាំងទៅលើដីធ្លី ជលផល និងព្រៃឈើនោះ ការទ្រទ្រង់ជីវភាពដើម្បីចិញ្ចឹមជីវិតនៅតាមជនបទ នឹងត្រូវប្រឈមមុខយ៉ាងខ្លាំងមួយនៅក្នុងទសវត្សរ៍ខាងមុខនេះ ។

ការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនូវធនធានធម្មជាតិ នឹងរួមចំណែកយ៉ាងសំខាន់នាពេលអនាគតក្នុងការខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រនៅនៅកម្ពុជា ។ នៅក្នុងគោលគំនិតនេះ វិទ្យាស្ថាន CDRI បានបង្កើតឡើងនូវកម្មវិធីធនធានធម្មជាតិ និងបរិស្ថានរបស់ខ្លួននាចុងឆ្នាំ២០០១ ។ កម្មវិធីនេះ មានគោលបំណងគាំទ្រដល់គោលនយោបាយដឹកនាំស្តីអំពីបញ្ហានានាទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ។ ឯកសារពិភាក្សាដំបូងនេះបានផ្តល់នូវការប៉ាន់ស្មានស្តីពីស្ថានភាពបច្ចុប្បន្នលើបញ្ហានានាជុំវិញធនធានធម្មជាតិ និងជីវភាពប្រជាជនតាមជនបទ ដោយផ្តោតសំខាន់លើវិស័យជាគន្លឹះបី គឺកសិកម្ម ជលផល និងព្រៃឈើ ។ វិស័យទាំងនេះរួមបញ្ចូលការវាយតំលៃផលិតកម្ម និងពតិមាននៃការប្រមូលផល ការប្រកួតប្រជែងនៅក្នុងការគ្រប់គ្រង និងឱកាស ផលប៉ះពាល់ទៅលើវិស័យទាំងអស់ ម៉ាឃីទីង និងបញ្ហាពាណិជ្ជកម្ម ។ ដោយផ្អែកលើមូលដ្ឋាននេះ ចន្លោះ និងសេចក្តីត្រូវការនៃស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គមនាពេលអនាគត ត្រូវបានកំណត់ឡើង ។

---

លោកព្រុំ តុលា គឺជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI និងលោក Bruce McKenney គឺជាប្រធានគ្រប់គ្រងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៅវិទ្យាស្ថាន CDRI ។

១០.០០០រៀល

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh